ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍ស្តីពី
# អង្កេតកម្លាំងពលកម្មកម្ពុជា
# ឆ្នាំ ២០១៩


វិទ្យាស្ថានជាតិស្ថិតិ

ក្រសួងផែនការ

# បុព្វកថា

ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមរបស់ប្រទេសមួយពឹងផ្អែកយ៉ាងខ្លាំងទៅលើប្រជាជនសកម្មសេដ្ឋកិច្ចដែលបានចូលរួមចំណែកក្នុងការផលិតទំនិញ និងការផ្តល់សេវាកម្ម។ ខ្ញុំមានសេចក្តីរីករាយសូមចែករំលែកនូវលទ្ធផលអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩ ដែលផ្តល់នូវទិន្នន័យពាក់ព័ន្ធនឹងប្រជាជនសកម្មសេដ្ឋកិច្ចរបស់ប្រទេស រួមមានទំហំ និងទម្រង់នៃអត្រាកម្លាំងពលកម្ម អត្រាមានការងារធ្វើ អត្រាគ្មានការងារធ្វើ និងសូចនាករការងារសមរម្យនៅកម្ពុជា។ ខ្ញុំសង្ឃឹមថាព័ត៌មានដែលបានផ្តល់ជូននៅក្នុងរបាយការណ៍នេះ នឹងបម្រើជាធាតុចូលដ៏មានប្រយោជន៍សម្រាប់ការរៀបចំគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា និងកម្មវិធីទាក់ទងនឹងការងារ ដើម្បីបង្កើតការងារ និងកែលម្អលក្ខខណ្ឌការងារនៅក្នុងប្រទេស។

ខ្ញុំសូមសម្តែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលសម្តេចបានផ្តល់ថវិកាសម្រាប់ការអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩ តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ខ្ញុំសូមថ្លែងអំណរគុណដល់អង្គការអន្តរជាតិខាងការងារ (ILO) និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដែលបានជួយគាំទ្រថវិកា និងបច្ចេកទេសដល់អង្កេតនេះ។

ខ្ញុំក៏សូមសរសើរដោយអស់ពីចិត្តដល់ឯកឧត្តម **វី ហៀង** រដ្ឋលេខាធិការក្រសួងផែនការ ឯកឧត្តម **ហ៊ាង កាណុល** អនុរដ្ឋលេខាធិការក្រសួងផែនការ និងជាទីប្រឹក្សាបច្ចេកទេសអង្កេត លោកជំទាវ **ហង់ លីណា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ ជានាយកគម្រោង និងឯកឧត្តម **លឹម ពេញ** ទីប្រឹក្សា និងជាប្រធាននាយកដ្ឋានស្តង់ដារស្ថិតិ និងវិភាគស្ថិតិ ជាអ្នកគ្រប់គ្រងប្រតិបត្តិការអង្កេត ក៏ដូចជាក្រុមការងារអង្កេតវិទ្យាស្ថានជាតិស្ថិតិ ចំពោះការខិតខំក្នុងការងារអង្កេត និងការចងក្រងរបាយការណ៍នេះ។

ខ្ញុំមានជំនឿយ៉ាងមុតមាំថាគ្រប់ក្រសួង ស្ថាប័នជាតិ ដៃគូអភិវឌ្ឍន៍ អង្គការជាតិ និងអន្តរជាតិ គ្រឹះស្ថានសិក្សាស្រាវជ្រាវ វិស័យឯកជន និងសាធារណជនទូទៅ នឹងទទួលបាននូវអត្ថប្រយោជន៍ពីរបាយការណ៍នេះ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងផែនការ**

**កិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន**

# អារម្ភកថា

របាយការណ៍ស្តីពីអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩ ត្រូវបានផលិតដោយវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ដោយមានការជួយគាំទ្រពីអង្គការអន្តរជាតិខាងការងារ (ILO) និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។ របាយការណ៍នេះបានបង្ហាញអំពីចរិតលក្ខណៈនៃកម្លាំងពលកម្មនៅកម្ពុជា រួមមានកម្រិតនៃភាពមានការងារធ្វើ និងគ្មានការងារធ្វើ និងសូចនាករការងារសមរម្យមួយចំនួន។ ទិន្នន័យដែលបានប្រមូលតាមរយៈអង្កេតនេះ បានផ្តល់នូវរូបភាពដ៏ទូលំទូលាយមួយនៃការបែងចែក និងទម្រង់នៃប្រជាជនសកម្មសេដ្ឋកិច្ចនៅកម្ពុជា។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ** និងឯកឧត្តម **ថី ហៀង** រដ្ឋលេខាធិការក្រសួងផែនការ ឯកឧត្តម **ហ៊ាង ភាណុល** អនុរដ្ឋលេខាធិការក្រសួងផែនការ និងជាទីប្រឹក្សាបច្ចេកទេសអង្កេត ដែលបានជួយដល់សកម្មភាពអង្កេត និងការរៀបចំរបាយការណ៍នេះ។

អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩ បានទទួលការគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស ពីអង្គការអន្តរជាតិខាងការងារ (ILO) និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក Tite Habiyakare អ្នកស្រី Makiko Matsumoto និងលោក Yves Perardel នៃអង្គការអន្តរជាតិខាងការងារ (ILO) លោក Arturo Martinez Jr អ្នកស្រី Christian Flora Mae Soco អ្នកស្រី Remedios Baes-Espineda លោក Joseph Bulan អ្នកស្រី Mildred Addawe និងអ្នកស្រី Marymell Martillan នៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដែលបានផ្តល់អនុសាសន៍ល្អៗ ដល់របាយការណ៍នេះ និងអ្នកស្រី Joanne Gerber ជាអ្នកកែសម្រួលរបាយការណ៍។

ខ្ញុំសូមវាយតម្លៃខ្ពស់ដល់មន្ត្រីទាំងអស់នៃវិទ្យាស្ថានជាតិស្ថិតិ និងមន្ត្រីដទៃទៀតដែលចូលរួមក្នុងដំណាក់កាលនីមួយៗនៃការអង្កេត ចំពោះការខិតខំប្រឹងប្រែង និងបំពេញការងារល្អ ធ្វើឲ្យការអង្កេតនេះទទួលបានជោគជ័យ។ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះអ្នកឆ្លើយទាំងអស់នៃការអង្កេត ចំពោះកិច្ចសហប្រតិបត្តិការដ៏មានតម្លៃរបស់គាត់។

ជាទីបញ្ចប់ ខ្ញុំសូមសរសើរដោយស្មោះដល់ក្រុមការងារបច្ចេកទេសស្នូលនៃវិទ្យាស្ថានជាតិស្ថិតិ ដែលបានទទួលខុសត្រូវខ្ពស់ក្នុងការប្រតិបត្តិ និងត្រួតពិនិត្យសកម្មភាពអង្កេត។ ជាពិសេស ឯកឧត្តម **លឹម ពេញ** ទីប្រឹក្សា និងជាប្រធាននាយកដ្ឋានស្តង់ដារស្ថិតិ និងវិភាគស្ថិតិ និងក្រុមការងាររួមមាន លោកជំទាវ **សូរ្យ សុវណ្ណចរិយា** ទីប្រឹក្សា និងជាអគ្គនាយករង លោក **សុខ បូរិទ្ធ** អនុប្រធាននាយកដ្ឋាន លោក **ខៀវ ខេមរិន្ទ** អនុប្រធាននាយកដ្ឋាន និងអ្នកស្រី **ចាយ ដាវ៉ឿន** អនុប្រធាននាយកដ្ឋាន ដែលបានបំពេញការងារដ៏មានតម្លៃក្នុងការជ្រើសរើសសំណាកគំរូ ការកែច្នៃទិន្នន័យ ការវិភាគទិន្នន័យ និងការរៀបចំរបាយការណ៍។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុក**
**អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ**

**ហាន់ លីណា**

# មាតិកា


ទំព័រ

បុព្វកថា ................................................................ i

អារម្ភកថា ................................................................ ii

សង្ខេបរួម ................................................................ ix

**ជំពូក ១. សេចក្តីផ្តើម** ................................................................ **១**

១.១ សាវតារ ................................................................ ១

១.២ គោលដៅនៃការអង្កេត ................................................................ ៣

១.៣ ការសម្ភាត់ ................................................................ ៣

១.៤ ទស្សនាទាន និងនិយមន័យ ................................................................ ៤

**ជំពូក ២. វិធីសាស្ត្រអង្កេត** ................................................................ **៩**

២.១ ទំហំ និងវិសាលភាព ................................................................ ៩

២.២ បញ្ជីសំណួរ ................................................................ ៩

២.៣ វិធីសាស្ត្រជ្រើសសំណាកគំរូ ................................................................ ១០

២.៤ ក្របខ័ណ្ឌជ្រើសសំណាកគំរូ ................................................................ ១០

២.៥ សមាមាត្រទម្ងន់សំណាកគំរូ ................................................................ ១០

២.៦ វិធីសាស្ត្រប៉ាន់ស្មាន ................................................................ ១៣

២.៧ ការបណ្តុះបណ្តាល និងការប្រមូលទិន្នន័យ ................................................................ ១៣

២.៨ ការកែច្នៃទិន្នន័យ ................................................................ ១៣

២.៩ អត្រាឆ្លើយ ................................................................ ១៤

**ជំពូក ៣. ចរិតលក្ខណៈប្រជាសាស្ត្រ** ................................................................ **១៦**

៣.១ សេចក្តីផ្តើម ................................................................ ១៦

៣.២ ទំហំប្រជាជន ................................................................ ១៦

៣.៣ ទំហំគ្រួសារ ................................................................ ១៧

៣.៤ មេគ្រួសារ ................................................................ ១៧

៣.៥ ប្រជាជនមានពិការភាព ................................................................ ១៨

៣.៦ អត្រានៅក្នុងបន្ទុក ................................................................ ១៩

៣.៧ ប្រភពសម្រាប់ចិញ្ចឹមជីវិតរបស់គ្រួសារ ................................................................ ១៩

៣.៨ ការចូលរួមរបស់គ្រួសារក្នុងកសិកម្ម និងនេសាទ ................................................................ ២០

**ជំពូក ៤. ប្រជាជនក្នុងអាយុធ្វើការ** ................................................................ **២១**

៤.១ សេចក្តីផ្តើម ................................................................ ២១

៤.២ ប្រជាជនក្នុងអាយុធ្វើការ ................................................................ ២១

៤.៣ ស្ថានភាពទីផ្សារការងារ ................................................................ ២២

៤.៤ ការចូលរួមក្នុងកម្លាំងពលកម្ម ................................................................ ២៤

៤.៥ ការងារផលិតកម្មសម្រាប់ចិញ្ចឹមជីវិត ................................................................ ២៦

**ជំពូក ៥. ភាពមានការងារធ្វើ** ...... **២៨**
៥.១ សេចក្ដីផ្ដើម ...... ២៨
៥.២ ប្រជាជនមានការងារធ្វើ ...... ២៨
៥.៣ ការងារតាមមុខរបរ ...... ២៩
៥.៤ ការងារតាមសកម្មភាពសេដ្ឋកិច្ច ...... ៣០
៥.៥ ការងារតាមការសិក្សា ...... ៣១
៥.៦ អត្រាអ្នកមានការងារធ្វើធៀបនឹងប្រជាជន ...... ៣២
៥.៧ ស្ថានភាពការងារ ...... ៣៣
**ជំពូក ៦. ការងារក្នុងវិស័យក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធ** ...... **៣៤**
៦.១ សេចក្ដីផ្ដើម ...... ៣៤
៦.២ វិស័យក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធ ...... ៣៤
៦.៣ ការងារក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធ ...... ៣៥
**ជំពូក ៧. ចំណូលពីការងារ** ...... **៣៨**
៧.១ សេចក្ដីផ្ដើម ...... ៣៨
៧.២ មូលដ្ឋានទូទាត់ប្រាក់ឈ្នួល ...... ៣៨
៧.៣ ចំណូលប្រចាំខែជាមធ្យម ...... ៣៨
**ជំពូក ៨. ម៉ោងធ្វើការ** ...... **៤៣**
៨.១ សេចក្ដីផ្ដើម ...... ៤៣
៨.២ ម៉ោងធ្វើការ ...... ៤៣
៨.៣ ម៉ោងធ្វើការជាមធ្យមតាមសកម្មភាពសេដ្ឋកិច្ច ...... ៤៥
៨.៤ ម៉ោងធ្វើការធម្មតាជាមធ្យមតាមវិស័យ ...... ៤៦
៨.៥ ម៉ោងធ្វើការធម្មតាជាមធ្យមតាមក្រុមអាយុ ...... ៤៦
៨.៦ ធ្វើការលើសម៉ោង ...... ៤៧
៨.៧ ភាពមានការងារធ្វើមិនគ្រប់គ្រាន់ទាក់ទងនឹងពេលវេលា ...... ៤៧
**ជំពូក ៩. ការងារយុវជន** ...... **៤៩**
៩.១ សេចក្ដីផ្ដើម ...... ៤៩
៩.២ យុវជនចូលរួមក្នុងកម្លាំងពលកម្ម ...... ៤៩
៩.៣ យុវជនមានការងារធ្វើ និងគ្មានការងារធ្វើ ...... ៥០
៩.៤ យុវជនមិនធ្វើការងារ មិនសិក្សា ឬបណ្ដុះបណ្ដាល ...... ៥២
**ជំពូក ១០. ភាពគ្មានការងារធ្វើ** ...... **៥៤**
១០.១ សេចក្ដីផ្ដើម ...... ៥៤
១០.២ អ្នកគ្មានការងារធ្វើ ...... ៥៤
១០.៣ រយៈពេលគ្មានការងារធ្វើ ...... ៥៥
១០.៤ វិធីសាស្ត្រស្វែងរកការងារ ...... ៥៦
១០.៥ អត្រាគ្មានការងារធ្វើ ...... ៥៦
១០.៦ ការប្រើមិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម ...... ៥៨

**ជំពូក ១១. ចំណាយជ្រើសរើសរបស់ពលករចំណាកស្រុកនិវត្តន៍** ........ **៦៣**
១១.១ សេចក្តីផ្តើម ........ ៦៣
១១.២ ធ្វើការក្រៅប្រទេស ........ ៦៤
១១.៣ វិធីសាស្ត្រស្វែងរកការងារដំបូង ........ ៦៥
១១.៤ ចំណាយជ្រើសរើស ........ ៦៧
១១.៥ ចំណូល ........ ៦៧
១១.៦ សូចនាករចំណាយជ្រើសរើស ........ ៦៨
១១.៧ ចំនួនខែត្រូវសងចំណាយជ្រើសរើស ........ ៦៩
**ជំពូក ១២. សូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និង ការងារសមរម្យជ្រើសរើស** ........ **៧១**
១២.១ សេចក្តីផ្តើម ........ ៧១
១២.២ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការងារសមរម្យ ........ ៧១

ឯកសារយោង ........ ៧៥
ឧបសម្ព័ន្ធ ១៖ មន្ត្រីអង្កេត ........ ៧៧
ឧបសម្ព័ន្ធ ២៖ តារាងស្ថិតិបន្ថែម ........ ៨៣
ឧបសម្ព័ន្ធ ៣៖ បញ្ជីសំណួរអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩ ........ ១៧៣

# តារាង


តារាង ២.១ ភូមិ និងគ្រួសារសំណាកគំរូសម្រាប់អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩.................................. ១២
តារាង ២.២ ការបែងចែកសំណាកគំរូតាមតំបន់ទីប្រជុំជន និងជនបទ ក្នុងរាជធានី និងខេត្ត សម្រាប់អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩.................................. ១២
តារាង ២.៣ អត្រាឆ្លើយរបស់គ្រួសារសំណាកគំរូ.................................. ១៥
តារាង ៣.១ ការបែងចែកគ្រួសារ តាមទំហំ និងតំបន់.................................. ១៧
តារាង ៣.២ ការបែងចែកគ្រួសារ តាមក្រុមអាយុ ភេទនៃមេគ្រួសារ និងតំបន់.................................. ១៨
តារាង ៣.៣ អត្រានៅក្នុងបន្ទុក តាមតំបន់.................................. ១៩
តារាង ៣.៤ ប្រភពសម្រាប់ចិញ្ចឹមជីវិតរបស់គ្រួសារ តាមតំបន់.................................. ២០
តារាង ៣.៥ ការចូលរួមរបស់គ្រួសារក្នុងការងារកសិកម្ម តាមសកម្មភាពចម្បង និងតំបន់.................................. ២០
តារាង ៤.១ ការបែងចែកប្រជាជនក្នុងអាយុធ្វើការ តាមក្រុមអាយុ ភេទ និងតំបន់.................................. ២១
តារាង ៤.២ ការបែងចែកប្រជាជនក្នុងអាយុធ្វើការ តាមស្ថានភាពទីផ្សារការងារ និងភេទ.................................. ២២
តារាង ៤.៣ ការបែងចែកប្រជាជនក្នុងអាយុធ្វើការ តាមស្ថានភាពទីផ្សារការងារ កម្រិតសិក្សា និងភេទ.................................. ២៤
តារាង ៤.៤ អត្រាចូលរួមក្នុងកម្លាំងពលកម្ម តាមក្រុមអាយុ ភេទ និងតំបន់.................................. ២៥
តារាង ៤.៥ ការចូលរួមក្នុងផលិតកម្មសម្រាប់ចិញ្ចឹមជីវិត តាមក្រុមអាយុ ស្ថានភាពទីផ្សារការងារ ភេទ និងតំបន់..... ២៧
តារាង ៥.១ ការបែងចែកប្រជាជនមានការងារធ្វើ តាមក្រុមអាយុ តំបន់ និងភេទ.................................. ២៨
តារាង ៥.២ ប្រជាជនមានការងារធ្វើ តាមសកម្មភាពសេដ្ឋកិច្ច និងភេទ.................................. ៣១
តារាង ៥.៣ ប្រជាជនមានការងារធ្វើ តាមកម្រិតសិក្សា តំបន់ និងភេទ.................................. ៣២
តារាង ៥.៤ ប្រជាជនមានការងារធ្វើ តាមស្ថានភាពការងារ.................................. ៣៣
តារាង ៦.១ ប្រជាជនមានការងារធ្វើ តាមវិស័យក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធ.................................. ៣៤
តារាង ៦.២ ប្រជាជនមានការងារធ្វើ តាមការងារក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធ.................................. ៣៥
តារាង ៦.៣ អ្នកធ្វើការងារក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធ តាមមុខរបរ.................................. ៣៦
តារាង ៦.៤ អ្នកធ្វើការងារក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធ តាមសកម្មភាពសេដ្ឋកិច្ច.................................. ៣៧
តារាង ៦.៥ អ្នកធ្វើការងារក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធ តាមវិស័យ.................................. ៣៧
តារាង ៧.១ និយោជិត តាមមូលដ្ឋានទូទាត់ប្រាក់ឈ្នួល.................................. ៣៨
តារាង ៧.២ ប្រាក់ឈ្នួលប្រចាំខែជាមធ្យម និងជាមេដ្យាន តាមមុខរបរ និងភេទ.................................. ៤០
តារាង ៧.៣ ប្រាក់ឈ្នួលប្រចាំខែជាមធ្យម និងជាមេដ្យាន តាមសកម្មភាពសេដ្ឋកិច្ច និងភេទ.................................. ៤១
តារាង ៧.៤ ប្រាក់ឈ្នួលប្រចាំខែជាមធ្យម និងជាមេដ្យាន តាមក្រុមអាយុ និងភេទ.................................. ៤២
តារាង ៧.៥ ប្រាក់ឈ្នួលប្រចាំខែជាមធ្យម និងជាមេដ្យាន តាមតំបន់ និងភេទ.................................. ៤២
តារាង ៨.១ ម៉ោងធ្វើការជាមធ្យមក្នុងមួយសប្តាហ៍ ក្នុងការងារចម្បង តាមសកម្មភាពសេដ្ឋកិច្ច និងភេទ.................................. ៤៥
តារាង ៨.២ អ្នកធ្វើការលើសម៉ោងធ្វើការធម្មតាក្នុងមួយសប្តាហ៍ ក្នុងការងារចម្បង តាមក្រុមអាយុ និងភេទ.......... ៤៧
តារាង ៨.៣ អ្នកមានការងារធ្វើមិនគ្រប់គ្រាន់ទាក់ទងនឹងពេលវេលា តាមក្រុមអាយុ និងភេទ.................................. ៤៨
តារាង ៨.៤ អត្រាអ្នកមានការងារធ្វើមិនគ្រប់គ្រាន់ តាមក្រុមអាយុ និងភេទ.................................. ៤៨
តារាង ៩.១ យុវជនចូលរួមក្នុងកម្លាំងពលកម្ម តាមក្រុមអាយុ តំបន់ និងភេទ.................................. ៥០
តារាង ៩.២ យុវជនមានការងារធ្វើ និងគ្មានការងារធ្វើ តាមតំបន់ និងភេទ.................................. ៥១
តារាង ៩.៣ យុវជនមានការងារធ្វើ តាមមុខរបរ និងភេទ.................................. ៥១
តារាង ៩.៤ យុវជនមានការងារធ្វើ តាមសកម្មភាពសេដ្ឋកិច្ច និងភេទ.................................. ៥២

តារាង ៩.៥ យុវជនមិនធ្វើការងារ មិនសិក្សា ឬបណ្តុះបណ្តាល តាមក្រុមអាយុ តំបន់ និងភេទ.......................... ៥៣
តារាង ១០.១ ប្រជាជនគ្មានការងារធ្វើ តាមក្រុមអាយុ និងភេទ.................................................................... ៥៤
តារាង ១០.២ ប្រជាជនគ្មានការងារធ្វើ តាមកម្រិតសិក្សា តំបន់ និងភេទ....................................................... ៥៥
តារាង ១០.៣ រយៈពេលគ្មានការងារធ្វើ តាមភេទ...................................................................................... ៥៥
តារាង ១០.៤ អត្រាគ្មានការងារធ្វើ តាមកម្រិតសិក្សា តំបន់ និងភេទ........................................................... ៥៧
តារាង ១០.៥ អត្រាគ្មានការងារធ្វើ តាមក្រុមអាយុ តំបន់ និងភេទ............................................................... ៥៧
តារាង ១០.៦ សូចនាករទីផ្សារការងារ...................................................................................................... ៦១
តារាង ១០.៧ ការបែងចែកប្រជាជនក្នុងអាយុធ្វើការ នៅក្រៅកម្លាំងពលកម្មបន្ថែម តាមសកម្មភាពចម្បងបច្ចុប្បន្ន.... ៦២
តារាង ១១.១ ប្រជាជនក្នុងអាយុធ្វើការដែលបានទៅបរទេសរស់នៅ និងធ្វើការយកបៀវត្សរ៍ តាមក្រុមអាយុ និងភេទ ៦៤
តារាង ១១.២ ប្រជាជនក្នុងអាយុធ្វើការបានធ្វើការនៅបរទេស តាមប្រទេសក្រៅចុងក្រោយ និងភេទ.................... ៦៥
តារាង ១១.៣ វិធីសាស្ត្រស្វែងរកការងាររបស់ពលករចំណាកស្រុកអន្តរជាតិ តាមភេទ........................................ ៦៥
តារាង ១១.៤ ប្រភពព័ត៌មានអំពីការងារដំបូងនៅបរទេសសម្រាប់ពលករចំណាកស្រុកនិវត្តន៍ តាមភេទ................ ៦៦
តារាង ១១.៥ វិធីប្រើដោយពលករចំណាកស្រុកនិវត្តន៍ចូលទៅប្រទេសក្រៅចុងក្រោយដើម្បីធ្វើការ តាមភេទ.......... ៦៦
តារាង ១១.៦ ចំណាយទទួលបានការងារដំបូងនៅបរទេសរបស់ពលករចំណាកស្រុកនិវត្តន៍ តាមភេទ................. ៦៧
តារាង ១១.៧ ចំណូលប្រចាំខែរបស់ពលករចំណាកស្រុកនិវត្តន៍ពីការងារដំបូងនៅបរទេស តាមភេទ..................... ៦៨
តារាង ១១.៨ សូចនាករចំណាយជ្រើសរើស តាមភេទ តំបន់ភូមិសាស្ត្រ ក្រុមអាយុ វិស័យសេដ្ឋកិច្ច
និងប្រទេសក្រៅចុងក្រោយរបស់ការងារ.................................................................................. ៦៩
តារាង ១១.៩ ចំនួនខែរបស់ពលករចំណាកស្រុកនិវត្តន៍ត្រូវទូទាត់សងចំណាយជ្រើសរើស តាមភេទ..................... ៧០
តារាង ១២.១ សូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការងារសមរម្យជ្រើសរើសនៅកម្ពុជា ឆ្នាំ២០១៩ ៧២
តារាង ១២.២ ចំណូលប្រចាំខែជាមេធ្យាររបស់និយោជិតស្រី និងប្រុស តាមមុខរបរ.......................................... ៧៤
តារាង ១២.៣ ភាគរយនៃយុវជនមិនធ្វើការងារ មិនសិក្សា ឬបណ្តុះបណ្តាល................................................... ៧៤

# រូប


| | | |
|---|---|---|
| រូប ៣.១ | ពីរ៉ាមីតប្រជាជន | ១៦ |
| រូប ៣.២ | សមាមាត្រនៃប្រជាជន (អាយុ ៥ ឆ្នាំឡើង) មានពិការភាព តាមភេទ និងតំបន់ | ១៨ |
| រូប ៤.១ | ការបែងចែកប្រជាជនក្នុងអាយុធ្វើការ តាមក្រុមអាយុ និងភេទ | ២២ |
| រូប ៤.២ | ការបែងចែកប្រជាជនក្នុងអាយុធ្វើការ តាមស្ថានភាពទីផ្សារការងារ និងក្រុមអាយុ | ២៣ |
| រូប ៤.៣ | អត្រាចូលរួមក្នុងកម្លាំងពលកម្ម តាមក្រុមអាយុ និងភេទ | ២៥ |
| រូប ៥.១ | ការបែងចែកប្រជាជនមានការងារធ្វើ តាមមុខរបរ | ២៩ |
| រូប ៥.២ | ការបែងចែកប្រជាជនមានការងារធ្វើ តាមប្រភេទមុខរបរ និងភេទ | ៣០ |
| រូប ៥.៣ | អត្រាអ្នកមានការងារធ្វើ ធៀបនឹងប្រជាជន តាមក្រុមអាយុ និងភេទ | ៣២ |
| រូប ៦.១ | អ្នកធ្វើការងារក្រៅប្រព័ន្ធ តាមក្រុមអាយុ | ៣៥ |
| រូប ៦.២ | អ្នកធ្វើការងារក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធ តាមតំបន់ | ៣៦ |
| រូប ៧.១ | ការបែងចែកប្រាក់ឈ្នួលប្រចាំខែ តាមភេទ | ៣៩ |
| រូប ៧.២ | ចំណែកប្រាក់ឈ្នួលប្រចាំខែ តាមភេទ | ៣៩ |
| រូប ៨.១ | ម៉ោងធ្វើការជាមធ្យមក្នុងមួយសប្តាហ៍ ក្នុងការងារចម្បង តាមតំបន់ និងភេទ | ៤៣ |
| រូប ៨.២ | ម៉ោងធ្វើការធម្មតាជាមធ្យមក្នុងមួយសប្តាហ៍ ក្នុងការងារចម្បង តាមមុខរបរ និងភេទ | ៤៤ |
| រូប ៨.៣ | ម៉ោងធ្វើការជាក់ស្តែងជាមធ្យមក្នុងមួយសប្តាហ៍ ក្នុងការងារចម្បង តាមមុខរបរ និងភេទ | ៤៤ |
| រូប ៨.៤ | ម៉ោងធ្វើការធម្មតាជាមធ្យមក្នុងមួយសប្តាហ៍ ក្នុងការងារចម្បង តាមវិស័យ និងភេទ | ៤៦ |
| រូប ៨.៥ | ម៉ោងធ្វើការធម្មតាជាមធ្យមក្នុងមួយសប្តាហ៍ ក្នុងការងារចម្បង តាមក្រុមអាយុ និងភេទ | ៤៦ |
| រូប ១០.១ | វិធីសាស្ត្រស្វែងរកការងារ | ៥៦ |
| រូប ១០.២ | សមាសធាតុនៃការប្រើមិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម | ៥៩ |

# សេចក្តីសង្ខេប

អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩ គឺជាការអង្កេតគ្រួសារដែលបានដំណើរការដោយវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ដោយមានការគាំទ្រពីអង្គការអន្តរជាតិខាងការងារ (ILO) និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។ នេះជាអង្កេតលើកទីបួន ដែលរាជរដ្ឋាភិបាលកម្ពុជាបានប្រមូលទិន្នន័យអំពីការងារ និងភាពមានការងារធ្វើ តាមរយៈអង្កេតកម្លាំងពលកម្មកម្ពុជា។ អង្កេតកម្លាំងពលកម្មកម្ពុជាមុនៗក៏ត្រូវបានដំណើរការ ដោយសហការជាមួយដៃគូអភិវឌ្ឍន៍នានាផងដែរ។ ជាពិសេស អង្កេតលើកទីមួយបានធ្វើនៅឆ្នាំ២០០០ ហើយបន្ទាប់មកអង្កេតលើកទីពីរនៅឆ្នាំ២០០១ ដោយមានជំនួយបច្ចេកទេសពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងនៅឆ្នាំ២០១២ (អង្កេតកម្លាំងពលកម្ម និងពលកម្មកុមារកម្ពុជា) តាមរយៈការគាំទ្រពីនាយកដ្ឋានស្ថិតិនៃអង្គការអន្តរជាតិខាងការងារ (ILO) កម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ (IPEC) នាយកដ្ឋានសមាហរណ៍កម្មគោលនយោបាយ ការិយាល័យតំបន់សម្រាប់អាស៊ី និងប៉ាស៊ីហ្វិក និងក្រុមការងារសមរម្យសម្រាប់អាស៊ីបូព៌ា និងអាស៊ីអាគ្នេយ៍ និងប៉ាស៊ីហ្វិក។

## ចរិតលក្ខណៈប្រជាសាស្ត្រ

អង្កេតត្រូវបានដំណើរការនៅឆ្នាំ២០១៩ កម្ពុជាមានប្រជាជនប៉ាន់ស្មានសរុបប្រមាណ ១៥,៧ លាននាក់ ក្នុងនោះប្រុសមាន ៤៨% និងស្រី ៥២%។ ប្រមាណ ៦៦,១% ឬ ១០,៤ លាននាក់នៃប្រជាជនទូទាំងប្រទេសរស់នៅតំបន់ជនបទ ខណៈដែល ៣៣,៩% ឬ ៥,៣ លាននាក់ រស់នៅតំបន់ទីប្រជុំជន។

អង្កេតក៏បានប៉ាន់ស្មានផងដែរ ប្រមាណ ២,៤ លានគ្រួសារនៅតំបន់ជនបទ និង ១,៣ លានគ្រួសារនៅតំបន់ទីប្រជុំជន ដែលនាំឲ្យមានចំនួនគ្រួសារសរុបប្រមាណ ៣,៧ លានគ្រួសារនៅក្នុងប្រទេស។ ទំហំគ្រួសារជាមធ្យមថ្នាក់ជាតិមាន ៤,២ នាក់ (៤,៣ នាក់ក្នុងមួយគ្រួសារនៅតំបន់ជនបទ និង ៤,១ នាក់ក្នុងមួយគ្រួសារនៅតំបន់ទីប្រជុំជន)។

ក្នុងចំណោមនោះ ៧៦,៤% (ឬ ២,៩ លានគ្រួសារ) មានមេគ្រួសារជាប្រុស ខណៈ ២៣,៦ % (ឬ ០,៩ លានគ្រួសារ) មានមេគ្រួសារជាស្រី។ ការបែងចែកតាមភេទនៃមេគ្រួសារមានលំនាំសឹងតែដូចគ្នាទាំងនៅតំបន់ទីប្រជុំជន និងនៅតំបន់ជនបទ។ នៅតំបន់ទីប្រជុំជន ប្រមាណ ៧៣,៩% (ជិត ១,០ លានគ្រួសារ) មានមេគ្រួសារជាប្រុស ខណៈប្រមាណ ២៦,១ % (ជាង ០,៣ លានគ្រួសារ) មានមេគ្រួសារជាស្រី។ នៅតំបន់ជនបទ ប្រមាណ ៧៧,៨ % (១,៩ លានគ្រួសារ) មានមេគ្រួសារជាប្រុស ខណៈប្រមាណ ២២,២% (០,៥ លានគ្រួសារ) មានមេគ្រួសារជាស្រី។

យោងតាមលទ្ធផលអង្កេត ប្រជាជនប៉ាន់ស្មានអាយុពី ៥ ឆ្នាំឡើង មានពិការភាពប្រមាណ ៩,៦% នៃប្រជាជនសរុបនៅកម្ពុជា ឆ្នាំ២០១៩ តាមកម្រិតលំបាកផ្សេងគ្នា ដោយចាត់ថ្នាក់ពីលំបាកខ្លះទៅមិនអាចបំពេញមុខងារខាងរាងកាយបាន។

អត្រានៅក្នុងបន្ទុកសរុបនៅកម្ពុជាមាន ៥០,៦% ក្នុងនោះ ៤៥,៨% នៅតំបន់ទីប្រជុំជន និង ៥៣,១% នៅតំបន់ជនបទ។

ប្រមាណ ៤០,៣% នៃគ្រួសារ មានប្រាក់ចំណូលពីការងារមានប្រាក់ឈ្នួលដែលជាប្រភពចម្បងសម្រាប់ចិញ្ចឹមជីវិត ៣២,០% បានមកពីការធ្វើកសិកម្ម ឬនេសាទគ្រួសារ ខណៈប្រមាណ ២១,៩% មានប្រាក់ចំណូលពីអាជីវកម្មប្រតិបត្តិការដោយគ្រួសារក្រៅពីកសិកម្ម ឬនេសាទ។

## ប្រជាជនក្នុងអាយុធ្វើការ

យោងតាមលទ្ធផលអង្កេត ប្រជាជនក្នុងអាយុធ្វើការ (អាយុ ១៥ ឆ្នាំឡើង) មានប្រមាណ ១១,៥ លាននាក់ (៧៣,២% នៃប្រជាជនសរុប) ក្នុងនោះស្រីមាន ៦,១ លាននាក់ (៥៣,១%) និងប្រុស ៥,៤ លាននាក់ (៤៦,៩%)។ រាល់ចំនួនប្រុសក្នុងអាយុធ្វើការ ១០០ នាក់ មានស្រីចំនួន ១១៣ នាក់ក្នុងអាយុធ្វើការ ដូច្នេះសមាមាត្រប្រុសធៀបនឹងស្រីក្នុងអាយុធ្វើការ មាន ១០០:១១៣។ នៅទីប្រជុំជនមានប្រមាណ ៧៥,៧% នៃប្រជាជនសរុបស្ថិតនៅក្នុងអាយុធ្វើការ ខណៈដែលនៅតំបន់ជនបទមាន ៧១,៩%។

ក្នុងចំណោមប្រជាជនក្នុងអាយុធ្វើការទាំងអស់ មានប្រមាណ ៦៨,៥% (ឬ ៧,៩ លាននាក់) មានការងារធ្វើ ០,៨% (ឬ ៩៧.៦៨៧ នាក់) គ្មានការងារធ្វើ និង ៣០,៧% (ឬ ៣,៥ លាននាក់) មិននៅក្នុងកម្លាំងពលកម្ម នៅពេលធ្វើអង្កេត។

## អត្រាចូលរួមក្នុងកម្លាំងពលកម្ម

អត្រាចូលរួមក្នុងកម្លាំងពលកម្មនៃប្រជាជនក្នុងអាយុធ្វើការ (អាយុ ១៥ ឆ្នាំឡើង) ប៉ាន់ស្មានប្រមាណ ៦៩,៣% ក្នុងនោះប្រុស ៧៧,២% និងស្រី ៦២,៤%។ អត្រាចូលរួមក្នុងកម្លាំងពលកម្មមាន ៦៧,៧% នៅតំបន់ទីប្រជុំជន និង ៧០,២% នៅតំបន់ជនបទ។

## អ្នកមានការងារធ្វើ

ក្នុងចំណោមប្រជាជនប៉ាន់ស្មាន ៧,៩ លាននាក់ ដែលមានការងារធ្វើនៅឆ្នាំ២០១៩ ប្រុសមាន ៥២,២% និងស្រីមាន ៤៧,៨%។ ភាគច្រើននៃប្រជាជនមានការងារធ្វើ (៦៥,៧%) ត្រូវបានរកឃើញនៅតំបន់ជនបទ ខណៈ ៣៤,៣% នៅតំបន់ទីប្រជុំជន។ តាមមុខរបរ អ្នកធ្វើការខាងជំនាញកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានភាគរយខ្ពស់ជាងគេនៃអ្នកមានការងារធ្វើប្រមាណ ២៨,៧% បន្ទាប់មក ២២,៩% ធ្វើការខាងសិប្បកម្ម និងអាជីវកម្មពាក់ព័ន្ធ និង ២១,៤% ជាអ្នកធ្វើការខាងសេវាកម្ម និងលក់។

តាមសកម្មភាពសេដ្ឋកិច្ច សមាមាត្រធំជាងគេនៃប្រជាជនមានការងារធ្វើ បានចូលរួមក្នុងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមាន ៣៣,១% បន្ទាប់មកការផលិត និងការលក់ដុំ និងរាយ ដែលសកម្មភាពនីមួយៗមាន ១៦,៧% និងសំណង់ ១០,០%។ តាមសកម្មភាពសេដ្ឋកិច្ចចម្បង ចំណែកច្រើនជាងគេនៃអ្នកមានការងារធ្វើត្រូវបានរកឃើញនៅក្នុងវិស័យសេវាកម្ម (៣៩,៨%) ខណៈវិស័យកសិកម្ម ៣៣,១% និងវិស័យឧស្សាហកម្ម ២៧,០%។

ប្រមាណ ១០,៨% នៃអ្នកមានការងារធ្វើមិនដែលបានរៀន។ ប្រមាណ ៣៨,១% នៃប្រជាជនមានការងារធ្វើទាំងអស់បានបញ្ចប់បឋមសិក្សា ខណៈ ២៥,១% បានបញ្ចប់មធ្យមសិក្សាបឋមភូមិ និង ១៥,៧% បញ្ចប់មធ្យមសិក្សាទុតិយភូមិ។ មានតែ ៦,៦% នៃពួកគេបានបញ្ចប់សាកលវិទ្យាល័យ និង ០,៤% មានវិញ្ញាបនបត្រវិជ្ជាជីវៈ។ តាមភេទ សមាមាត្រស្រីមានការងារធ្វើមិនដែលបានរៀនមានចំនួនច្រើនជាងប្រុស៖ ១៣,១% ប្រៀបធៀបនឹង ៨,៧%។ មិនមានភាពខុសគ្នាគួរឲ្យកត់សម្គាល់ឡើយ រវាងសមាមាត្រប្រុសមានការងារធ្វើ (៧,៤%) និងស្រីមានការងារធ្វើ (៥,៨%) មានសញ្ញាបត្រសាកលវិទ្យាល័យ។

ភាគច្រើននៃប្រជាជនមានការងារធ្វើគឺជានិយោជិត (៤៧,៨%) បន្ទាប់មកអ្នកធ្វើការដោយខ្លួនឯង (៣៦,៩%) អ្នកធ្វើការឲ្យគ្រួសារមិនយកប្រាក់ឈ្នួល (១១,៩%) និងនិយោជក (៣,៤%)។

## ការងារក្រៅប្រព័ន្ធ

អង្កេតបានរកឃើញប្រមាណ ៨៨,៣% នៃអ្នកមានការងារធ្វើទាំងអស់អាយុ ១៥ ឆ្នាំឡើង ធ្វើការងារក្រៅប្រព័ន្ធ ខណៈ ១១,៧% ធ្វើការងារក្នុងប្រព័ន្ធ។ អ្នកធ្វើការងារក្រៅប្រព័ន្ធមានចំនួនច្រើននៅតំបន់ជនបទ (៩០,០%) ជាងនៅតំបន់ទីប្រជុំជន (៨៥,០%)។

យោងតាមលទ្ធផលអង្កេត អ្នកធ្វើការងារក្រៅប្រព័ន្ធមានចំនួនច្រើនជាងគេ គឺជំនាញកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (៩៨,៦%) បន្ទាប់មកអ្នកមានមុខរបរងាយៗ (៩៤,៨%) អ្នកធ្វើការខាងសេវាកម្ម និងលក់ (៩២,៦%) និងការីម៉ាស៊ីន និងរោងចក្រ (៩២,១%)។ តាមសកម្មភាពសេដ្ឋកិច្ច អ្នកធ្វើការខាងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (៩៨,៦%) និងសំណង់ (៩៧,២%) ភាគច្រើនជាការងារក្រៅប្រព័ន្ធ។

## ប្រាក់ចំណូលពីការងារ

លទ្ធផលអង្កេតបានបង្ហាញថា ចំនួនប៉ាន់ស្មាន ៣,៨ លាននាក់ ជានិយោជិតមានប្រាក់ឈ្នួល ក្នុងនោះ ៩៨,៨% បានទទួលប្រាក់ឈ្នួលតាមអត្រាពេលវេលាជាមូលដ្ឋាន និងមានតែ ១,២% តាមអត្រាឯកតាជាមូលដ្ឋាន។ ក្នុងចំណោមនិយោជិតធ្វើការតាមអត្រាពេលវេលាជាមូលដ្ឋាន មាន ៦៦,៤% មានប្រាក់ឈ្នួលប្រចាំខែ បន្ទាប់មក ១៨,១% មានប្រាក់ឈ្នួលប្រចាំថ្ងៃ ១១,៦% មានប្រាក់ឈ្នួលប្រចាំពីរសប្តាហ៍ និង ២,៧% មានប្រាក់ឈ្នួលប្រចាំសប្តាហ៍។

យោងតាមលទ្ធផលអង្កេត ប្រាក់ឈ្នួលជាមធ្យមរបស់និយោជិតមានប្រាក់ឈ្នួល ក្នុងមុខរបរចម្បងមានប្រមាណ ១.០៧៨.៥៩៥ រៀល (២៦៩,៦០ ដុល្លារអាមេរិក) ក្នុងមួយខែ ខណៈប្រាក់ឈ្នួលប្រចាំខែជាមេដ្យានមាន ៩១០.០០០ រៀល (២២៧,៥០ ដុល្លារអាមេរិក)។ ប្រាក់ឈ្នួលប្រចាំខែជាមធ្យម និងជាមេដ្យានរបស់ប្រុស និងស្រី មិនមានខុសគ្នាគួរឲ្យកត់សម្គាល់ឡើយក្នុងគ្រប់ក្រុមមុខរបរ។ តាមសកម្មភាពសេដ្ឋកិច្ច ទោះជាយ៉ាងណាក៏ដោយ ប្រុសមានប្រាក់ឈ្នួលប្រចាំខែខ្ពស់ជាងស្រីនៅក្នុងគ្រប់ក្រុមសកម្មភាពសេដ្ឋកិច្ច លើកលែងតែក្រុមអចលនទ្រព្យ ក្រុមព័ត៌មាន និងទំនាក់ទំនង និងក្រុមសិល្បៈ កម្សាន្ត និងសប្បាយ។

## ម៉ោងធ្វើការ

ជាសរុប ចំនួនម៉ោងធម្មតាជាមធ្យមធ្វើការក្នុងមួយសប្តាហ៍ ប្រុសមាន ៤៦,៣ ម៉ោង និងស្រីមាន ៤៥,៦ ម៉ោង។ ប្រុសធ្វើការច្រើនម៉ោងជាងស្រីក្នុងគ្រប់មុខរបរទាំងអស់ លើកលែងតែមុខរបរជាអ្នកជំនួយការស្មៀន និងអ្នកផ្តល់សេវាកម្ម និងលក់ ដែលជាមធ្យមស្រីបានធ្វើការច្រើនម៉ោងជាងប្រុស។ អ្នកធ្វើការជំនាញកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរាយការណ៍ចំនួនម៉ោងធម្មតាជាមធ្យមធ្វើការក្នុងមួយសប្តាហ៍តិចជាងគេ៖ ប្រុសមាន ៣៤,៤ ម៉ោង និងស្រីមាន ២៩,៧ ម៉ោង។

លទ្ធផលក៏បង្ហាញអំពីចំនួនម៉ោងធ្វើការជាក់លាក់ តាមសកម្មភាពសេដ្ឋកិច្ចផងដែរ។ ការរុករករ៉ែ និងថ្មមានចំនួនម៉ោងធ្វើការយូរជាងគេ ៦១,៦ ម៉ោងក្នុងមួយសប្តាហ៍ បន្ទាប់មកលក់ដុំ និងរាយ (៥៧,៨ ម៉ោងក្នុងមួយសប្តាហ៍) ដឹកជញ្ជូន និងស្តុកទំនិញ (៥៤,៧ ម៉ោង) និងសកម្មភាពសេវាកម្មដទៃទៀត (៥៤,២ ម៉ោង)។ ទន្ទឹមនេះ សកម្មភាពខាងអចលនទ្រព្យមានម៉ោងធ្វើការធម្មតាតិចជាងគេ គឺ ២៩,៥ ម៉ោងក្នុងមួយសប្តាហ៍។

ជាសរុប ប្រមាណ ៣៦,០% នៃប្រជាជនមានការងារធ្វើបានធ្វើការលើស ៤៨ ម៉ោងក្នុងមួយសប្តាហ៍ (ប្រុស ៣៦,៨% និងស្រី ៣៥,១%) ខណៈប្រមាណ ១,១% ជាអ្នកមានការងារធ្វើមិនគ្រប់គ្រាន់ទាក់ទងនឹងពេលវេលា ឬបានធ្វើការតិចជាង ៤០ ម៉ោង។

## អ្នកគ្មានការងារធ្វើ

នៅឆ្នាំ២០១៩ មានប្រមាណ ៩៧.៦៨៧ នាក់ ជាអ្នកគ្មានការងារធ្វើមានអាយុ ១៥ ឆ្នាំឡើង ក្នុងនោះប្រុស ៥១.៤៥៨ នាក់ និងស្រី ៤៦.២២៩ នាក់ ជាអ្នកគ្មានការងារធ្វើ។ អត្រាគ្មានការងារធ្វើប៉ាន់ស្មានជារួម (គឺជាភាគរយអ្នកគ្មានការងារធ្វើនៃកម្លាំងពលកម្មសរុប) មាន ១,២% ដែលអត្រានេះដូចគ្នាសម្រាប់ទាំងពីរភេទ។ អត្រាគ្មានការងារធ្វើថយចុះនៅពេលក្រុមអាយុកើនឡើង ដូច្នេះអត្រាខ្ពស់ជាងគេមាននៅក្នុងក្រុមអាយុ ១៥-២៤ ឆ្នាំ (២,៥%)។ ប្រុសមានអត្រាគ្មានការងារធ្វើខ្ពស់ជាងគេក្នុងក្រុមអាយុយុវជន (១៥-២៤ ឆ្នាំ) ទាំងនៅតំបន់ទីប្រជុំជន និងតំបន់ជនបទ។

ប្រមាណ ៨៤,០% នៃអ្នកគ្មានការងារធ្វើបានរាយការណ៍គ្មានការងារធ្វើក្នុងរយៈពេលខ្លី (តិចជាង ១២ ខែ) ខណៈ ៦,៤% បានស្វែងរកការងារធ្វើក្នុងរយៈពេលច្រើនជាងមួយឆ្នាំ។ ស្រីគ្មានការងារធ្វើក្នុងរយៈពេលខ្លីជាងប្រុស។ ដូច្នេះ ភាពគ្មានការងារធ្វើរយៈពេលវែងរបស់ប្រុសមានច្រើនជាងស្រី។

ក្នុងចំណោមអ្នកគ្មានការងារធ្វើសកម្មស្វែងរកការងារធ្វើមាន ១៩,២% បានចុះឈ្មោះនៅមជ្ឈមណ្ឌល ឬភ្នាក់ងារការងារឯកជន បន្ទាប់មកបានស្វែងរកការងារតាមការជួយពីសាច់ញាតិ មិត្តភក្តិ និងអ្នកជទៃ (១៧,៥%) ហើយមួយចំនួនបានចុះឈ្មោះនៅសេវាកម្មការងារសាធារណៈ (១៦,១%) និងដាក់ពាក្យតាមនិយោជកអនាគត (១៤,៨%)។

## យុវជនមានការងារធ្វើ

នៅឆ្នាំ២០១៩ យុវជនប្រមាណ ១,៥ លាននាក់ អាយុ ១៥-២៤ ឆ្នាំ បានចូលរួមក្នុងកម្លាំងពលកម្ម ត្រូវនឹង ៥៧,២% នៃកម្លាំងពលកម្មទាំងអស់ក្នុងប្រទេស។ ក្នុងនោះ ៥៩,១% ជាប្រុស និង ៥៥,៦% ជាស្រី។

ប្រមាណ ៩៧,៥% នៃយុវជនក្នុងកម្លាំងពលកម្ម ជាអ្នកមានការងារធ្វើនៅឆ្នាំ២០១៩ (ពោលគឺអត្រាគ្មានការងារធ្វើមាន ២,៥%) ហើយខុសគ្នាបន្តិចរវាងប្រុស និងស្រី និងរវាងតំបន់ទីប្រជុំជន និងតំបន់ជនបទ។

តាមមុខរបរ យុវជនទាំងស្រី និងប្រុសបានធ្វើការច្រើនជាងគេខាងសិប្បកម្ម និងអាជីវកម្មពាក់ព័ន្ធ៖ ស្រីមាន ៣៨,១% និងប្រុសមាន ៣៣,៧%។ តាមសកម្មភាពសេដ្ឋកិច្ច ប្រុសមានភាគរយច្រើនជាងគេ (២៦,៣%) បានធ្វើការខាងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខណៈស្រីមានភាគរយខ្ពស់ជាងគេ (៣៩,៤%) ធ្វើការខាងការផលិត។

ជាសរុប យុវជន ៣៤១.២៧២ នាក់ ត្រូវនឹង ១២,៧% នៃយុវជនទាំងអស់ មិនធ្វើការងារ មិនសិក្សា ឬបណ្តុះបណ្តាល (NEET)។ យុវជនមិនបានធ្វើការងារ មិនសិក្សា ឬបណ្តុះបណ្តាល ស្រី (១៩៥.០៧៩ នាក់ ឬ ១៣,៨% នៃយុវជនស្រីទាំងអស់) មានច្រើនជាងប្រុស (១៤៦.១៩៤ នាក់ ឬ ១១,៤% នៃយុវជនប្រុសទាំងអស់)។ លើសពីនេះទៀត យុវជនមិនបានធ្វើការងារ មិនសិក្សា ឬបណ្តុះបណ្តាលមានច្រើននៅតំបន់ជនបទ (១២,៩%) ជាងនៅតំបន់ទីប្រជុំជន (១២,២%)។

## ចំណាយជ្រើសរើសរបស់ពលករចំណាកស្រុកនិវត្តន៍

ការជ្រើសសំណាកគំរូនៃអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩ មិនត្រូវបានកែតម្រូវជាចាំបាច់ ដើម្បីចាប់យកទិន្នន័យបានល្អប្រសើរនូវទេសន្តរប្រវេសន៍អន្តរជាតិនិវត្តន៍ឡើយ។ ដូច្នេះ លទ្ធផលក្នុងអង្កេតនេះទំនងជាប៉ាន់ស្មានខ្វះនូវចំនួនជាក់ស្តែងនៃជនចំណាកស្រុកវិលត្រឡប់មកផ្ទះវិញ។ ម៉្យាងទៀត អង្កេតបានគ្របដណ្តប់តែអ្នកដែលរកឃើញនៅក្នុងគ្រួសាររបស់គាត់ដែលមានលំនៅឋានប្រក្រតី នៅពេលអង្កេតតែប៉ុណ្ណោះ។ ដោយសារសំណាកគំរូនៃពលករ

ចំណាកស្រុកវិលត្រឡប់មកផ្ទះមានចំនួនតិច (ចំនួនសរុប ៤៦០ ករណី) ការសន្និដ្ឋានមួយចំនួននៅក្នុងរបាយការណ៍នេះ ដូចជាសូចនាករតាមការបែងចែកលម្អិត គួរតែប្រើដោយប្រុងប្រយ័ត្ន។

ក្នុងចំណោមអ្នកបានទៅធ្វើការនៅបរទេស លទ្ធផលអង្កេតបានបង្ហាញប្រមាណ ១៨២.៩៩៤ នាក់ បានវិលត្រឡប់មកផ្ទះវិញក្នុងរយៈពេល ៣ ឆ្នាំមុន ក្នុងនោះប្រុស ១០៧.២២៩ នាក់ និងស្រី ៧៥.៧៦៥ នាក់។ ភាគច្រើននៃពលករចំណាកស្រុកនិវត្តន៍គឺនៅតំបន់ជនបទ និងនៅក្នុងក្រុមអាយុវ័យក្មេង ពោលគឺក្នុងក្រុមអាយុ ២៥-៣៤ ឆ្នាំ។

ភាគច្រើននៃពលករចំណាកស្រុកទាំងនេះបានវិលត្រឡប់មកពីប្រទេសថៃ (៩៥,៣%) ខណៈពលករផ្សេងទៀតបានវិលត្រឡប់មកពីប្រទេសកូរ៉េខាងត្បូង (១,៧%) ម៉ាឡេស៊ី (១,៥%) វៀតណាម (១,២%) និងហ្វីលីពីន (០,២%)។

សម្រាប់អង្កេតនេះ ការចំណាយជ្រើសរើសត្រូវបានកំណត់ជាការទូទាត់ធ្វើឡើង ដើម្បីទទួលបានការងារធ្វើនៅក្នុងប្រទេសមួយផ្សេងទៀត រួមមានចំណាយទៅលើ៖ (i) ឯកសារដូចជា លិខិតឆ្លងដែន និងទិដ្ឋាការ (ii) ការពិនិត្យ និងធ្វើតេស្តសុខភាព (iii) ការបណ្តុះបណ្តាល និងការវាយតម្លៃជំនាញមុនពេលចាកចេញ (iv) ការធានារ៉ាប់រង ការធ្វើកិច្ចសន្យា និងការបញ្ជាក់សុវត្ថិភាពធ្វើដំណើរ និង (v) អ្នកជ្រើសរើស ឈ្មួញកណ្តាល ឬភ្នាក់ងារជ្រើសរើសកម្លាំងពលកម្ម។ ចំណាយនេះក៏រាប់បញ្ចូលចំណាយធ្វើដំណើរផងដែរ (ឧទាហរណ៍ ការដឹកជញ្ជូន និងការស្នាក់នៅ) ចំណាយផ្លូវការ ឬក្រៅផ្លូវការផ្សេងទៀត (ឧទាហរណ៍ ឲ្យមិត្តភក្តិ ឬសាច់ញាតិដែលជួយរកការងារឲ្យធ្វើ) និងការប្រាក់លើប្រាក់កម្ចី។

ប្រមាណ ៣៩,៩% នៃពលករចំណាកស្រុកនិវត្តន៍បានចំណាយតិចជាង ៤០០.០០០ រៀល (១០០ ដុល្លារអាមេរិក) សម្រាប់ចំណាយលើការជ្រើសរើស ខណៈ ២៩,៦% បានចំណាយប្រមាណពី ៤០០.០០០ រៀល ទៅ ១.៦០០.០០០ រៀល (៤០០ ដុល្លារអាមេរិក)។ ចំណាយសរុបជាមធ្យមលើការជ្រើសរើសមាន ១.៤១៧.៥៣៧ រៀល (៣៥៤ ដុល្លារអាមេរិក)។

ជាសរុប ចំណូលរបស់ពលករចំណាកស្រុកនិវត្តន៍នៅកម្ពុជា ជាមធ្យម ២,២ លានរៀល (៥៥០ ដុល្លារអាមេរិក) ក្នុងមួយខែ និង ៨០,៤% នៃពលករចំណាកស្រុកនិវត្តន៍មានចំណូលប្រមាណពី ៤០០.០០០ រៀល (១០០ ដុល្លារអាមេរិក) ទៅប្រមាណ ១,៦ លានរៀល (៤០០ ដុល្លារអាមេរិក)។ អ្នកមានចំណូលច្រើនជាងគេក្នុងមួយខែ មាន ៤,០ លានរៀល (១.០០០ ដុល្លារអាមេរិក) ឬច្រើនជាង មានតែ ៥,៩% នៃពលករចំណាកស្រុកនិវត្តន៍ទាំងអស់។

សូចនាករចំណាយជ្រើសរើស (១០.៧.១) នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព គឺជាអត្រានៃចំណាយលើការជ្រើសរើសជាមធ្យម ធៀបនឹងប្រាក់ឈ្នួលប្រចាំខែជាមធ្យម (សម្រាប់ខែដំបូងនៃការងារនៅក្រៅប្រទេស)។ ក្នុងករណីពលករចំណាកស្រុកកម្ពុជា មានប្រមាណ ០,៧ ខែនៃចំណូល។ តិចជាងមួយខែនៃប្រាក់ឈ្នួលអាចគ្រប់គ្រាន់ដើម្បីទូទាត់សងចំណាយ។ ទោះជាយ៉ាងណាក៏ដោយ លទ្ធផលដែលបានរាយការណ៍ផ្ទាល់បានឲ្យដឹងថាចំនួនខែជាមធ្យមដែលត្រូវទូទាត់សងចំណាយឲ្យការជ្រើសរើសមានជាក់ស្តែង ១,៤ ខែ ប្រមាណពីរដងសូចនាករដែលបានគណនា។

## គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងសូចនាករការងារសមរម្យជ្រើសរើស

សូចនាករការងារសមរម្យនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ត្រូវបានបង្ហាញនៅក្នុងជំពូកចុងក្រោយនៃរបាយការណ៍នេះ។ ផ្នែកនេះរួមមានសូចនាករទាក់ទងនឹងកិច្ចគាំពារសង្គម សមភាពយេនឌ័រ និងសូចនាករការងារសមរម្យផ្សេងទៀត។ សូចនាករស្ទើរតែទាំងអស់ត្រូវបានបែងចែកតាមភេទ ភាពខុសគ្នាជាក់ស្តែងរវាងប្រុស និងស្រី។

គោលដៅ ១ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព គឺបញ្ចប់ភាពក្រីក្រគ្រប់ទម្រង់ និងសូចនាករមួយក្នុងចំណោមសូចនាករដែលទាក់ទងនឹងគោលដៅនេះ គឺកិច្ចគាំពារសង្គម។ សូចនាករនេះអាចត្រូវបានបំពេញបន្ថែមដោយសមាមាត្រនៃនិយោជិតដែលបានទទួលប្រាក់ឈ្នួលពេលឈប់សម្រាកឈឺ។ ប្រមាណ ១៩,១% នៃនិយោជិត ដែលនិយោជករបស់ខ្លួនចូលរួមចំណែកដល់របបសន្តិសុខសង្គម និងប្រមាណ ២២,៤% បានទទួលប្រាក់ឈ្នួលនៅពេលឈប់សម្រាកឈឺ។

គោលដៅ ៥ មានគោលបំណងសម្រាប់សមភាពយេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រី និងក្មេងស្រីទាំងអស់។ សូចនាករមួយចំនួនទាក់ទងនឹងគោលដៅនេះរួមមានសមាមាត្រនៃស្ត្រីនៅក្នុងមុខងារជាអ្នកគ្រប់គ្រង និងប្រាក់ចំណូលជាមធ្យម តាមភេទ។ នៅឆ្នាំ២០១៩ ស្ត្រី ៣ នាក់ ក្នុងចំណោម ១០ នាក់ មានមុខងារជាអ្នកគ្រប់គ្រង ខណៈបុរសមាន ៧ នាក់ ក្នុងចំណោម ១០ នាក់ មានមុខងារជាអ្នកគ្រប់គ្រង។

គោលដៅ ៨ រួមមានសូចនាករការងារសមរម្យមួយចំនួន តាមភេទ និងតំបន់ភូមិសាស្ត្រ។ អត្រាយុវជនគ្មានការងារធ្វើ (២,៥%) ខ្ពស់ជាងអត្រាមធ្យមថ្នាក់ជាតិ (១,២%) ទោះបីមានប្រមាណ ១២,៧% នៃយុវជន មិនធ្វើការងារ មិនសិក្សា ឬបណ្តុះបណ្តាលក៏ដោយ។

# ផែនទីកម្ពុជា



ប្រភពៈ វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ។

# ជំពូក ១
# សេចក្តីផ្តើម

## ១.១ សាវតារ

អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩ ជាការអង្កេតគ្រួសារត្រូវបានដំណើរការដោយវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ និងមានការគាំទ្រដោយអង្គការអន្តរជាតិខាងការងារ (ILO) និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។ នេះជាអង្កេតទូទាំងប្រទេសលើកទីបួន ដែលកម្ពុជាបានប្រមូលទិន្នន័យអំពីការងារ និងភាពមានការងារធ្វើ តាមរយៈអង្កេតកម្លាំងពលកម្មកម្ពុជា។ អង្កេតកម្លាំងពលកម្មកម្ពុជាដែលបានដំណើរការកន្លងមក ក៏បានសហការជាមួយដៃគូអភិវឌ្ឍន៍មួយចំនួនផងដែរ។ ជាពិសេស អង្កេតលើកទីមួយនៅឆ្នាំ២០០០ និងបន្ទាប់មកអង្កេតលើកទីពីរនៅឆ្នាំ២០០១ ត្រូវបានដំណើរការដោយមានជំនួយបច្ចេកទេសពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងនៅឆ្នាំ២០១២ (អង្កេតកម្លាំងពលកម្ម និងពលកម្មកុមារកម្ពុជា) តាមរយៈការគាំទ្រដោយនាយកដ្ឋានស្ថិតិនៃអង្គការអន្តរជាតិខាងការងារ (ILO) កម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ (IPEC) នាយកដ្ឋានសមាហរណ៍កម្មគោលនយោបាយ ការិយាល័យតំបន់សម្រាប់អាស៊ី និងប៉ាស៊ីហ្វិក និងក្រុមការងារសមរម្យសម្រាប់អាស៊ីបូព៌ា និងអាស៊ីអាគ្នេយ៍ និងប៉ាស៊ីហ្វិក។

កម្លាំងពលកម្មនៅកម្ពុជា (អាយុ ១៥ ឆ្នាំឡើង) បានកើនឡើងពី ៧.៣៩៩.៧២០ នាក់ នៅឆ្នាំ ២០១២ ទៅ ៧.៩៨០.៧៩៣ នាក់ នៅឆ្នាំ២០១៩ និងមានអត្រាចូលរួមក្នុងកម្លាំងពលកម្ម ៦៨,៨% នៅឆ្នាំ២០១២ និង ៦៩,៣% នៅឆ្នាំ២០១៩។ យុវជនអាយុ ១៥ ទៅ ២៤ ឆ្នាំ នៅក្នុងកម្លាំងពលកម្មបានថយចុះពីឆ្នាំ២០១២ (២.១៥៣.១៥២ នាក់ ឬ ៦៣,១%) មកឆ្នាំ២០១៩ (១.៥៤១.៥៤៤ នាក់ ឬ ៥៧,២%) ដែលឆ្លុះបញ្ចាំងពីនិន្នាការវិជ្ជមាននៃយុវជនដែលស្ថិតនៅបានយូរក្នុងប្រព័ន្ធអប់រំ។ ភាគរយនៃយុវជនកំពុងសិក្សាបានកើនឡើងពី ៣៤,៩% នៅឆ្នាំ២០១២ ទៅ ៣៨,៧% នៅឆ្នាំ២០១៩។

នៅឆ្នាំ២០១៩ អត្រាយុវជនចូលរួមក្នុងកម្លាំងពលកម្មបានកើនឡើងខ្ពស់នៅតំបន់ជនបទ (៦១,០%) ជាងនៅតំបន់ទីប្រជុំជន (៤៩,៤%)។ យុវជននៅតំបន់ជនបទ ជាពិសេសអ្នកមានអាយុ ១៥ ទៅ ១៩ ឆ្នាំ មានទំនោរចាកចេញពីការអប់រំមុនពេលកំណត់ ដើម្បីចូលរួមក្នុងទីផ្សារការងារ។ ទោះជាយ៉ាងណាក៏ដោយ ករណីនេះអាចដាក់កម្រិតលើការងារ និងអនាគតអាជីពរបស់ពួកគេ នាពេលអនាគត។

នៅឆ្នាំ២០១៩ ប្រជាជនប្រមាណ ៧,៨ លាននាក់ អាយុ ១៥ ឆ្នាំឡើង មានការងារធ្វើ បានឆ្លុះបញ្ចាំងពីកំណើនកម្លាំងពលកម្មពីឆ្នាំ២០១២ (៧,២ លាននាក់)។ ភាគរយនៃប្រជាជនក្នុងអាយុធ្វើការមានការងារធ្វើបានកើនឡើងពី ៦៧,០% នៅឆ្នាំ២០១២ ទៅ ៦៨,៥% នៅឆ្នាំ២០១៩ ថ្វីបើភាគរយសម្រាប់យុវជនបានថយចុះពី ៦០,៧% មក ៥៥,៨% ក្នុងរយៈពេលដូចគ្នាក៏ដោយ។ ជារួម អត្រាគ្មានការងារធ្វើទាបនៅឆ្នាំ២០១៩ (១,២%) បើប្រៀបធៀបនឹងឆ្នាំ២០១២ (២,៧%)។ ប្រជាជននៅក្នុងការងារ "ងាយរងគ្រោះ" ដែលបានកំណត់ជាអ្នកធ្វើការឲ្យគ្រួសារមិនយកប្រាក់ឈ្នួល និងអ្នកធ្វើការដោយខ្លួនឯង នៅតែជាចំណែកមួយដ៏ធំនៃប្រជាជនមានការងារធ្វើ៖ ៤៨,៨% នៅឆ្នាំ២០១៩ ថយចុះបន្តិចពី ៥៣,៦% នៅឆ្នាំ២០១២។

អាទិភាពគោលនយោបាយ និងគោលដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា គឺការអភិវឌ្ឍទីផ្សារការងារ មានប្រាក់ចំណូលខ្ពស់ មានលក្ខខណ្ឌការងារល្អ និងការយកចិត្តទុកដាក់លើសុខុមាលភាពកម្មករ និងនិយោជិតទាំងសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងសេដ្ឋកិច្ចក្រៅប្រព័ន្ធ[១]។

ទន្ទឹមនេះ កម្ពុជានៅបន្តជួបបញ្ហាប្រឈមមួយចំនួនៈ គុណភាពកម្លាំងពលកម្មនៅមានកម្រិត និងផលិតភាពនៅទាប បើធៀបទៅនឹងបណ្តាប្រទេសក្នុងតំបន់ កម្លាំងពលកម្មភាគច្រើនធ្វើការក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ប្រព័ន្ធគ្រប់គ្រងទិន្នន័យការងារ និងអតីតភាពការងារមិនទាន់រឹងមាំ ប្រព័ន្ធគ្រប់គ្រងសុខភាព និងសុវត្ថិភាពការងារនៅតាមរោងចក្រ និងសហគ្រាសនៅមានកម្រិត ការដឹកជញ្ជូនកម្មករ និងនិយោជិតមិនសូវមានសុវត្ថិភាព ការគ្រប់គ្រងការបិទរោងចក្រ និងការទូទាត់ប្រាក់អតីតភាពការងារនៅមិនទាន់បានល្អ និងសេវាគាំពារពលករទេសន្តរប្រវេសន៍នៅមានកម្រិត។

ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងបន្តអនុវត្តសកម្មភាពសំខាន់ៗ រួមមានៈ

- ធ្វើទំនើបកម្មប្រព័ន្ធអប់រំវិជ្ជាជីវៈ ដោយពង្រឹងគុណភាពបណ្តុះបណ្តាលជំនាញបច្ចេកទេស ពង្រីកការបណ្តុះបណ្តាលជំនាញ និងពង្រឹងភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន ដើម្បីធានាថា "**យុវជនម្នាក់មានជំនាញមួយយ៉ាងតិចប្រចាំជីវិត**" ក្នុងគោលបំណងលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងធ្វើឲ្យប្រទេសទទួលបានឋានៈជាអ្នកមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០
- ពង្រីកមុខរបរ និងឱកាសការងារ ដោយបង្កើនការងារសមរម្យ និងផលិតភាពការងារ ធ្វើឲ្យប្រសើរឡើងនូវការគ្រប់គ្រងកម្លាំងពលកម្មនៅកម្ពុជា និងការពារពលករចំណាកស្រុកកម្ពុជា និង
- អភិវឌ្ឍរបបសន្តិសុខសង្គមដល់កម្មករនិយោជិត មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ដោយបន្តពង្រឹង និងពង្រីករបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និងហានិភ័យការងារ ជំរុញការរៀបចំរបបសោធននិវត្តន៍ និងពង្រឹងរបបសន្តិសុខសង្គមលើវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ។

នៅកម្ពុជា ស្ថិតិដែលអាចរកបានអំពីសូចនាករកម្លាំងពលកម្ម និងការងារសមរម្យ គឺនៅមានកម្រិត និងនៅខ្វះចន្លោះមួយចំនួនៈ

- ទិន្នន័យភាគច្រើនអាចរកបានសម្រាប់ការវិភាគជាស៊េរីពេលវេលា គឺមានតែពីជំរឿនទូទៅប្រជាជន ប៉ុន្តែមានតែបីសំណុំទិន្នន័យជំរឿនប៉ុណ្ណោះដែលអាចប្រើបាន គឺឆ្នាំ១៩៩៨ ២០០៨ និង ២០១៩។
- ទិន្នន័យអង្កេត ភាគច្រើនបានមកពីអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាដែលត្រូវបានដំណើរការជាប្រចាំ ប៉ុន្តែការអង្កេតតាមឆ្នាំផ្សេងៗ គឺភាគច្រើនមិនអាចប្រៀបធៀបបានឡើយ ដោយសារភាពខុសគ្នានៃការជ្រើសសំណាកគំរូ វិធីសាស្ត្រ និងបញ្ជីសំណួរដែលបានប្រើប្រាស់។
- ទិន្នន័យអំពីទិដ្ឋភាពផ្សេងៗនៃទីផ្សារការងារ ដូចជាការងារក្រៅប្រព័ន្ធ ភាពមានការងារធ្វើមិនគ្រប់គ្រាន់ ភាពទំនាក់ទំនងការងារ ម៉ោងធ្វើការ ការងារបានចំណូលតិច ប្រាក់ឈ្នួល និងចំណូល និងលក្ខខណ្ឌការងារផ្សេងទៀតមិនមានលក្ខណៈត្រូវគ្នាឡើយ។ ទិន្នន័យដែលអាចមានទាក់ទងនឹងទស្សនាទានទាំងនេះ មិនត្រូវបានកំណត់ច្បាស់លាស់ ឬមិនត្រូវគ្នា ដូច្នេះមិនត្រូវបានប្រើសម្រាប់របាយការណ៍នេះឡើយ។

---

[១] រាជរដ្ឋាភិបាលកម្ពុជា ក្រសួងផែនការ។ ឆ្នាំ២០១៩។ *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣*។ ភ្នំពេញ។

យោងតាមច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង រាជរដ្ឋាភិបាលកម្ពុជាបានតម្រូវឲ្យវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ប្រកាសផ្សាយជាសាធារណៈនូវស្ថិតិអង្កេតកម្លាំងពលកម្មប្រចាំឆ្នាំ។ គោលបំណងសំខាន់គឺឆ្លើយតបទៅនឹងតម្រូវការរបស់រាជរដ្ឋាភិបាលកម្ពុជា អង្គការជាតិ និងអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល អ្នកស្រាវជ្រាវ អ្នកធ្វើផែនការ និងអ្នកធ្វើគោលនយោបាយ និងដើម្បីបង្កើនប្រសិទ្ធភាពក្នុងការអភិវឌ្ឍគោលនយោបាយអភិវឌ្ឍន៍ជាតិ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងការខិតខំដើម្បីសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា។ អ្វីដែលពិសេសនោះ គឺការចង់បានទិន្នន័យឆ្លុះបញ្ចាំងដល់ការគាំទ្រដំណាក់កាលទី ៤ នៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី ៦ នៃរដ្ឋសភា និងបម្រើតម្រូវការសម្រាប់គោលនយោបាយទីផ្សារការងារ។ ក្រសួងផែនការ ជាពិសេសវិទ្យាស្ថានជាតិស្ថិតិជាអ្នកគ្រប់គ្រងការផ្តល់ទិន្នន័យស្ថិតិផ្លូវការ ហើយក៏នឹងផ្តល់អាទិភាពដល់កិច្ចខិតខំប្រឹងប្រែងដើម្បីធ្វើឲ្យប្រសើរឡើងនូវការសម្របសម្រួលរវាងអ្នកផលិត និងអ្នកប្រើប្រាស់ទិន្នន័យសូចនាករដើម្បីធានាថាតម្រូវការត្រូវបានឆ្លើយតប។

អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩ មិនដូចអង្កេតកម្លាំងពលកម្ម និងពលកម្មកុមារកម្ពុជា ឆ្នាំ២០១២ឡើយ គឺជាការអង្កេតតែម្នាក់ឯងដែលធ្វើតាមគំរូអង្កេតកម្លាំងពលកម្មរបស់អង្គការអន្តរជាតិខាងការងារ (ILO) ដែលរួមមានសំណួរលម្អិតអំពីចរិតលក្ខណៈប្រជាសាស្ត្រ និងសារពើភ័ណ្ឌ ផ្នែកកម្លាំងពលកម្ម និងផ្នែកចំណាយលើការជ្រើសរើសពលករចំណាកស្រុក។ អង្កេតបានប្រមូលព័ត៌មានជាច្រើនដែលអាចប្រើសម្រាប់ការរៀបចំ ការអនុវត្ត ការតាមដាន និងការវាយតម្លៃគោលនយោបាយ និងកម្មវិធីការងារ និងកម្លាំងពលកម្មនានានៅទូទាំងប្រទេស។

## ១.២ គោលដៅនៃការអង្កេត

គោលដៅសំខាន់នៃអង្កេតគឺដើម្បីប្រមូលទិន្នន័យទូលំទូលាយអំពីកម្លាំងពលកម្ម រួមទាំងនិន្នាការការងារ និងភាពគ្មានការងារក្នុងចំណោមប្រជាជនអាយុ ១៥ ឆ្នាំឡើង សម្រាប់ប្រើប្រាស់ដោយរាជរដ្ឋាភិបាល អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល អ្នកស្រាវជ្រាវ និងដទៃទៀត ដើម្បីជួយដល់កិច្ចអន្តរាគមន៍គោលដៅប្រកបដោយប្រសិទ្ធភាព។ អង្កេតក៏មានគោលបំណង ដើម្បីគាំទ្រដល់សេចក្តីសម្រេចជាអន្តរជាតិទាក់ទងនឹងស្ថិតិការងារ ភាពមានការងារធ្វើ និងការប្រើមិនគ្រប់គ្រាន់នូវកម្លាំងពលកម្មផងដែរ។

## ១.៣ ការសម្ងាត់

មាត្រា ៣០ នៃច្បាប់ស្តីពីស្ថិតិបានបង្ហាញការរក្សាការសម្ងាត់។ មាត្រានេះបានចែងយ៉ាងច្បាស់ថា មន្ត្រីរាជការបុគ្គលិកធ្វើការនៅវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងអង្គភាពស្ថិតិក្នុងក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ក៏ដូចជាមន្ត្រីស្ថិតិដែលបានចាត់តាំងដោយអង្គការទាំងនោះ ត្រូវធានារក្សាការសម្ងាត់នូវរាល់ព័ត៌មានផ្ទាល់ខ្លួនទាំងឡាយដែលបានមកពីអ្នកឆ្លើយ។ ព័ត៌មានដែលប្រមូលបានក្រោមច្បាប់នេះ ត្រូវយកមកប្រើប្រាស់តែក្នុងគោលដៅស្ថិតិប៉ុណ្ណោះ។

មាត្រានេះត្រូវបានដាក់បញ្ចូលក្នុងច្បាប់ ជាពិសេសដើម្បីធានារក្សាការសម្ងាត់ទិន្នន័យផ្ទាល់ខ្លួនដែលងាយរំភើប ឬឈឺចាប់ ហើយក៏ចាំបាច់ណាស់ក្នុងការទទួលបានការទុកចិត្តពីអ្នកផ្តល់ទិន្នន័យ។ បើអ្នកឆ្លើយមិនជឿថាព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេនឹងត្រូវបានរក្សាទុកជាការសម្ងាត់ និងមិនត្រូវបានចែករំលែកដល់ស្ថាប័នរាជរដ្ឋាភិបាលដទៃទៀត (ឧទាហរណ៍ នាយកដ្ឋានពន្ធដារ) ពួកគេនឹងមិនផ្តល់នូវព័ត៌មានពិត ឬពួកគេនឹងបដិសេធផ្តល់ព័ត៌មានណាមួយទាល់តែសោះ ហើយជាលទ្ធផលមានអត្រាឆ្លើយអង្កេតទាប។ ការជឿទុកចិត្តរបស់អ្នកឆ្លើយពិតជាមានសារៈសំខាន់ដើម្បីធានាបាននូវអត្រាឆ្លើយខ្ពស់ និងប្រមូលបានទិន្នន័យមានគុណភាពល្អ។ មិនដាក់បញ្ចូលមាត្រានេះនឹងមានន័យថា បន្ថអត្រាឆ្លើយទាប និងស្ថិតិមានគុណភាពទាប។

ម៉្យាងទៀត មាត្រា ៣៤ នៃច្បាប់ស្តីពីស្ថិតិចែងថា មន្ត្រីរាជការ និងមន្ត្រីស្ថិតិដែលបានចាត់តាំងដោយក្រសួងផែនការ និងដោយក្រសួង ស្ថាប័នរាជរដ្ឋាភិបាលដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ៣០ នៃច្បាប់នេះ នឹងត្រូវទទួលទណ្ឌកម្មរដ្ឋបាល។

មាត្រានេះមានសារៈសំខាន់ណាស់ដែលអាចធានាដល់អ្នកផ្តល់ទិន្នន័យថា ការដាក់ពិន័យជាក់លាក់នឹងអនុវត្តចំពោះមន្ត្រីរាជការ និងមន្ត្រីស្ថិតិដែលបានចាត់តាំងដែលបានរំលោភលើការសម្ងាត់ ឬប្រើព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេមិនត្រឹមត្រូវ។

ក្នុងអំឡុងពេលបណ្តុះបណ្តាលអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩ ច្បាប់ស្តីពីស្ថិតិ ជាពិសេសជំពូកសិទ្ធិនិងកាតព្វកិច្ច និងជំពូកទោសប្បញ្ញត្តិ ត្រូវបានបង្ហាញដល់មន្ត្រីទាំងអស់ដែលបានចូលរួមក្នុងដំណើរការអង្កេតនេះ។

## ១.៤ ទស្សនាទាន និងនិយមន័យ

អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩ បានអនុវត្តតាមស្តង់ដារអន្តរជាតិថ្មី ដែលបានអនុម័តដោយសន្និសីទអន្តរជាតិនៃអ្នកស្ថិតិកម្លាំងពលកម្មលើកទី១៩ នៅឆ្នាំ២០១៣។ សន្និសីទអន្តរជាតិនៃអ្នកស្ថិតិកម្លាំងពលកម្មលើកទី១៩ បានដាក់ចេញនូវក្របខ័ណ្ឌថ្មីមួយសម្រាប់ស្ថិតិទីផ្សារការងារ រួមមានស្ថិតិទាក់ទងនឹងការងារ ភាពមានការងារធ្វើ និងការប្រើមិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម។

និយមន័យ "ភាពមានការងារធ្វើ" ដែលបានប្រើនៅក្នុងអង្កេតកម្លាំងពលកម្ម និងពលកម្មកុមារកម្ពុជា ឆ្នាំ២០១២ បានគ្របដណ្តប់លើសកម្មភាពស្ទើរតែទាំងអស់នៅក្នុងព្រំដែនផលិតកម្មនៃប្រព័ន្ធគណនេយ្យជាតិ រួមមានការផលិតសម្រាប់ប្រាក់ឈ្នួល ប្រាក់ចំណេញ ឬចំណេញរបស់គ្រួសារ និងការផលិតសម្រាប់ការប្រើប្រាស់ចុងក្រោយខ្លួនឯង។ និយមន័យថ្មីនៃភាពមានការងារធ្វើ ទោះជាយ៉ាងណាក៏ដោយ រួមបញ្ចូលតែការងារដែលបានធ្វើសម្រាប់អ្នកផ្សេងដើម្បីប្រាក់ឈ្នួល ឬចំណេញប៉ុណ្ណោះ ចំណែកឯការផលិតសម្រាប់ការប្រើប្រាស់ចុងក្រោយខ្លួនឯងមិនត្រូវបានប្រើ និងចាត់ទុកថាភាពមានការងារធ្វើទៀតឡើយ។ ដូច្នេះ ទិន្នន័យមួយចំនួនរបស់អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩ នឹងមិនអាចប្រៀបធៀបនឹងទិន្នន័យរបស់អង្កេតកម្លាំងពលកម្ម និងពលកម្មកុមារកម្ពុជា ឆ្នាំ២០១២ ឡើយ។

ខាងក្រោមនេះជានិយមន័យនៃទស្សនាទានដែលបានផ្តល់ដោយសន្និសីទអន្តរជាតិនៃអ្នកស្ថិតិកម្លាំងពលកម្មលើកទី១៩៖

**ប្រជាជនក្នុងអាយុធ្វើការ** សំដៅលើមនុស្សទាំងអស់អាយុ ១៥ ឆ្នាំឡើង។ ប្រជាជនក្នុងអាយុធ្វើការរួមមានអ្នកនៅក្នុងកម្លាំងពលកម្ម (ជាអ្នកមានការងារធ្វើ ឬអ្នកគ្មានការងារធ្វើ) ក៏ដូចជាអ្នកនៅក្រៅកម្លាំងពលកម្ម។

**អ្នកមានការងារធ្វើ** សំដៅលើមនុស្សក្នុងអាយុធ្វើការទាំងអស់ ដែលក្នុងរយៈពេលយោងខ្លី (ពោលគឺមួយសប្តាហ៍) បានចូលរួមក្នុងសកម្មភាពណាមួយ ដើម្បីផលិតទំនិញ ឬផ្តល់សេវាកម្មប្តូរយកប្រាក់ឈ្នួល ឬដើម្បីរកចំណេញ។ ពួកគេរួមមានអ្នកធ្វើការ "នៅកន្លែងការងារ" (ពោលគឺអ្នកដែលបានធ្វើការយ៉ាងហោចណាស់មួយម៉ោង) និងអ្នកធ្វើការ "មិននៅកន្លែងការងារ" ដោយសារតែអវត្តមានជាបណ្តោះអាសន្នពីការងារ ឬដោយសារការរៀបចំពេលវេលាធ្វើការ (ដូចជាការងារប្តូរវេន ការបញ្ចប់ការងារតាមពេលវេលាខុសៗគ្នា និងការឈប់សម្រាកសងម៉ោងបន្ថែម)។

អ្នកមានការងារធ្វើ រួមមាន៖

(i) អ្នកធ្វើការដើម្បីប្រាក់ឈ្នួល ឬចំណេញ ដែលកំពុងចូលរួមក្នុងវគ្គបណ្តុះបណ្តាល ឬក្នុងសកម្មភាពបង្កើនជំនាញដែលទាមទារដោយការងារ ឬសម្រាប់ការងារផ្សេងទៀតនៅក្នុងអង្គភាពសេដ្ឋកិច្ចតែមួយ (អ្នកទាំងនេះត្រូវបានចាត់ទុកជាអ្នកធ្វើការ "នៅកន្លែងការងារ" ដោយអនុលោមតាមស្តង់ដារស្ថិតិអន្តរជាតិស្តីពីពេលវេលាធ្វើការ)

(ii) អ្នករៀនធ្វើការ អ្នកហាត់ការ ឬអ្នកហាត់រៀន ដែលធ្វើការដើម្បីប្រាក់ឈ្នួលជាសាច់ប្រាក់ ឬជារបស់
(iii) អ្នកធ្វើការដើម្បីប្រាក់ឈ្នួល ឬចំណេញ តាមរយៈកម្មវិធីលើកកម្ពស់ការងារ
(iv) អ្នកធ្វើការនៅក្នុងអង្គភាពសេដ្ឋកិច្ចខ្លួនឯង ដើម្បីផលិតទំនិញក្នុងគោលបំណងចម្បងសម្រាប់លក់ ឬដោះដូរ ទោះបីផ្នែកខ្លះនៃផលិតផលត្រូវបានប្រើប្រាស់ដោយក្រុមគ្រួសារ ឬគ្រួសារក៏ដោយ
(v) អ្នកមានការងារតាមរដូវក្នុងពេលបិទរដូវ បើពួកគេនៅបន្តបំពេញភារកិច្ច និងកិច្ចការមួយចំនួននៃការងារ ដោយមិនរាប់បញ្ចូលការបំពេញកាតព្វកិច្ចផ្លូវច្បាប់ ឬរដ្ឋបាល (ឧទាហរណ៍ បង់ពន្ធ) និងមិនគិតការទទួលបានអត្ថប្រយោជន៍
(vi) អ្នកធ្វើការដើម្បីប្រាក់ឈ្នួល ឬចំណេញ ដែលត្រូវបង់ឲ្យក្រុមគ្រួសារ ឬគ្រួសារ
(ក) នៅក្នុងទីផ្សារប្រតិបត្តិការដោយសមាជិកគ្រួសាររស់នៅក្នុងគ្រួសារតែមួយ ឬក្នុងគ្រួសារផ្សេងទៀត
(ខ) បំពេញភារកិច្ច ឬកិច្ចការជានិយោជិតរបស់សមាជិកគ្រួសារនៅក្នុងគ្រួសារតែមួយ ឬក្នុងគ្រួសារផ្សេងទៀត
(vii) ជាសមាជិកទៀងទាត់នៃកងកម្លាំងប្រដាប់អាវុធ និងអ្នកមានមុខងារជាយោធា ឬជាស៊ីវិលជំនួស ដែលបំពេញការងារនេះដើម្បីប្រាក់ឈ្នួលជាសាច់ប្រាក់ ឬជារបស់។

អង្កេតកម្លាំងពលកម្មកម្ពុជាបានចាត់ថ្នាក់អ្នកនៅកន្លែងការងារជាអ្នកមានការងារធ្វើ កាលណាគាត់បានធ្វើការយ៉ាងហោចណាស់មួយម៉ោងក្នុងសប្តាហ៍យោង។

**អ្នកគ្មានការងារធ្វើ** សំដៅលើមនុស្សក្នុងអាយុធ្វើការទាំងអស់ ដែលមិនបានធ្វើការងារក្នុងរយៈពេលសប្តាហ៍យោង ប៉ុន្តែបានអនុវត្តសកម្មភាពស្វែងរកការងារធ្វើក្នុងរយៈពេលថ្មីៗជាក់លាក់មួយ និងបច្ចុប្បន្នអាចទទួលយកការងារធ្វើបាននៅពេលផ្តល់ឱកាសការងារឲ្យ។

អ្នកគ្មានការងារធ្វើ រួមមាន៖
(i) "មិនធ្វើការងារ" ត្រូវបានវាយតម្លៃដោយយោងទៅលើរយៈពេលយោងខ្លី សម្រាប់ការវាស់វែងការងារ
(ii) "បានស្វែងរកការងារធ្វើ" សំដៅលើសកម្មភាពណាមួយដែលបានអនុវត្ត ក្នុងរយៈពេលថ្មីៗជាក់លាក់មួយ រួមមាន ៤ សប្តាហ៍ ឬមួយខែមុន សម្រាប់គោលបំណងរកការងារ ឬបង្កើតអាជីវកម្ម ឬធ្វើកសិកម្ម។ ផ្នែកនេះក៏រាប់បញ្ចូលផងដែរនូវការងារក្រៅម៉ោង ការងារក្រៅប្រព័ន្ធ ការងារបណ្តោះអាសន្ន និងការងារតាមរដូវ ឬម្តងម្កាល ក្នុងប្រទេស ឬក្រៅប្រទេស។ ឧទាហរណ៍នៃសកម្មភាពទាំងនេះគឺ៖
(ក) ការរៀបចំធនធានហិរញ្ញវត្ថុ ដាក់ពាក្យសុំការអនុញ្ញាត អាជ្ញាប័ណ្ណ
(ខ) ស្វែងរកដី ទីក្នុងបរិវេណ ម៉ាស៊ីន សម្ភារៈផ្គត់ផ្គង់ ឧបករណ៍កសិកម្ម
(គ) ស្វែងរកជំនួយពីមិត្តភក្តិ សាច់ញាតិ ឬប្រភេទអន្តរការីផ្សេងទៀត
(ឃ) ចុះឈ្មោះជាមួយ ឬទាក់ទងសេវាកម្មការងារសាធារណៈ ឬឯកជន
(ង) ដាក់ពាក្យសុំដោយផ្ទាល់ដល់និយោជក ឆែកពិនិត្យកន្លែងធ្វើការ កសិដ្ឋាន ច្រកទ្វាររោងចក្រ ទីផ្សារ ឬកន្លែងជួបប្រជុំផ្សេងទៀត
(ច) ដាក់ពាក្យ ឬឆ្លើយតាមសារព័ត៌មាន ឬការផ្សាយពាណិជ្ជកម្មការងារតាមអនឡាញ
(ឆ) ដាក់ពាក្យ ឬធ្វើបច្ចុប្បន្នកម្មប្រវត្តិអំពីវិជ្ជាជីវៈ ឬគេហទំព័របណ្តាញសង្គមតាមអនឡាន
(iii) ចំណុចដែលសហគ្រាសចាប់ផ្តើមមានគួរតែត្រូវបានប្រើ ដើម្បីដឹងនូវភាពផ្សេងគ្នារវាងសកម្មភាពស្វែងរកក្នុងគោលដៅបង្កើតអាជីវកម្ម និងសកម្មភាពការងាររបស់ខ្លួនឯងផ្ទាល់ ដែលបង្ហាញភស្តុតាងតាមការចុះឈ្មោះសហគ្រាសដើម្បីប្រតិបត្តិការ ឬតាមនៅពេលមានធនធានហិរញ្ញវត្ថុ មានហេដ្ឋារចនាសម្ព័ន្ធ ឬសម្ភារៈចាំបាច់នៅនឹងកន្លែង ឬបានទទួលអតិថិជន ឬការបញ្ជាទិញដំបូង អាស្រ័យលើស្ថានភាពជាក់ស្តែង

(iv) "បច្ចុប្បន្នអាចធ្វើការបាន" ចង់ដឹងពីការត្រៀមខ្លួនជាស្រេច ដើម្បីចាប់ផ្ដើមការងារក្នុងពេលបច្ចុប្បន្ន ដែលវាយតម្លៃដោយរយៈពេលយោងខ្លីមួយប្រើសម្រាប់វាស់វែងការងារ៖

(ក) អាស្រ័យលើកាលៈទេសៈប្រទេស រយៈពេលយោងអាចរាប់បញ្ចូលរយៈពេលបន្តបន្ទាប់ខ្លីមួយ មិនលើសពីរសប្ដាហ៍គិតជាសរុប ដើម្បីធានាវិសាលភាពគ្រប់គ្រាន់នៃស្ថានភាពគ្មានការងារធ្វើក្នុងចំណោមក្រុមប្រជាជនខុសគ្នា។

រាប់បញ្ចូលក្នុងភាពគ្មានការងារធ្វើ៖

(i) អ្នកចាប់ផ្ដើមនាពេលអនាគតបានកំណត់ជាមនុស្ស "មិនធ្វើការងារ" និង "បច្ចុប្បន្នអាចធ្វើការបាន" ដែលមិនបាន "ស្វែងរកការងារធ្វើ" ពីព្រោះពួកគេបានរៀបចំរួចហើយ ដើម្បីចាប់ផ្ដើមការងារក្នុងរយៈពេលបន្តបន្ទាប់ខ្លីមួយ ដោយកំណត់លើរយៈពេលរង់ចាំជាទូទៅសម្រាប់ការចាប់ផ្ដើមការងារថ្មីនៅក្នុងបរិបទប្រទេស ប៉ុន្តែជាទូទៅមិនច្រើនជាងបីខែ

(ii) អ្នកចូលរួមក្នុងការបណ្ដុះបណ្ដាលជំនាញ ឬគម្រោងបណ្ដុះបណ្ដាលឡើងវិញក្នុងកម្មវិធីលើកកម្ពស់ការងារ ដោយផ្អែកលើមូលដ្ឋាន "មិនធ្វើការងារ" និងមិន "បច្ចុប្បន្នអាចធ្វើការបាន" និងមិនបាន "ស្វែងរកការងារធ្វើ" ពីព្រោះពួកគេមានការងារដែលផ្ដល់ឲ្យដែលត្រូវចាប់ផ្ដើមក្នុងរយៈពេលបន្តបន្ទាប់ខ្លីមួយ ជាទូទៅមិនច្រើនជាងបីខែ

(iii) អ្នក "មិនធ្វើការងារ" ដែលបានអនុវត្តសកម្មភាពចំណាកស្រុកទៅបរទេស ដើម្បីធ្វើការយកប្រាក់ឈ្នួល ឬចំណេញ ប៉ុន្តែពួកគេនៅរង់ចាំឱកាសចាកចេញ។

**កម្លាំងពលកម្ម** សំដៅលើមនុស្សក្នុងអាយុធ្វើការទាំងអស់ ដែលចូលរួមចំណែក ឬអាចចូលរួមចំណែកក្នុងការផលិតទំនិញ និងសេវាកម្មនៅក្នុងប្រទេស ដើម្បីយកប្រាក់ឈ្នួល ឬទទួលបានចំណេញ។ ពួកគេអាចជាអ្នកមានការងារធ្វើ ឬគ្មានការងារធ្វើ ក្នុងរយៈពេលសប្ដាហ៍យោងមុនអង្កេត។

**អ្នកនៅក្រៅកម្លាំងពលកម្ម** សំដៅលើមនុស្សក្នុងអាយុធ្វើការទាំងអស់ ដែលអត់ធ្វើការ ឬមិនធ្វើការងារក្នុងរយៈពេលយោងជាក់លាក់ ដោយសារ៖

(i) ជាប់រៀននៅគ្រឹះស្ថានសិក្សាជាសិស្ស

(ii) ជាប់ភារកិច្ចគ្រួសារ ថែទាំសមាជិកគ្រួសារ ឬក្នុងសកម្មភាពផ្សេងៗជាមេផ្ទះ

(iii) ចូលនិវត្តន៍ ឬចាស់ជរា

(iv) មូលហេតុផ្សេងទៀត ដូចជាភាពទន់ខ្សោយ ឬពិការភាព ដែលអាចបញ្ជាក់បាន ឬ

(v) ជឿថាគ្មានការងារធ្វើ មិនចង់ធ្វើការ ឬមិនមានការចាប់ផ្ដើមការងារក្នុងរយៈពេលខ្លី។

**ស្ថានភាពការងារ** សំដៅលើប្រភេទកិច្ចសន្យាការងារជាក់ស្ដែង ឬមិនជាក់លាក់នៃការងាររវាងមនុស្ស និងមនុស្ស ឬអង្គការផ្សេងទៀត។ ស្ថានភាពរបស់បុគ្គលសកម្មសេដ្ឋកិច្ចត្រូវគោរពតាមការងាររបស់ខ្លួន (ពោលទោះបីគាត់ជានិយោជក អ្នកធ្វើការដោយទុនផ្ទាល់ខ្លួន និយោជិត ឬអ្នកធ្វើការឲ្យគ្រួសារមិនយកប្រាក់ឈ្នួល) ត្រូវបានកំណត់ដូចខាងក្រោម៖

**និយោជិត** គឺជាមនុស្សម្នាក់ ដែលធ្វើការឲ្យនិយោជកសាធារណៈ ឬឯកជន ហើយទទួលសំណងជាប្រាក់ឈ្នួល បៀវត្សរ៍ កម្រៃជើងសារ ប្រាក់ទឹកតែ ប្រាក់តាមអត្រាការងារ ឬឲ្យជារបស់។ និយោជិតត្រូវបានបែងចែកជា៖

- និយោជិតមានប្រាក់ឈ្នួលទៀងទាត់ ជាមួយប្រាក់ឈ្នួលថេរ
- និយោជិតមានប្រាក់ឈ្នួលមិនទៀងទាត់/បណ្ដោះអាសន្ន
- អ្នកធ្វើការមានប្រាក់ឈ្នួលតាមអត្រាការងារ ឬតាមការងារដែលបានបំពេញ និង
- អ្នករៀនធ្វើការមានប្រាក់ឈ្នួលមិនមែនគ្រួសារ។

**និយោជក** គឺជាមនុស្សម្នាក់ ដែលក្នុងរយៈពេលយោង បានធ្វើការដោយទុនផ្ទាល់ខ្លួនរបស់គាត់ ឬជាមួយដៃគូម្នាក់ ឬច្រើននាក់នៅក្នុង "ការងារធ្វើដោយខ្លួនឯង" ជាមួយនិយោជិតម្នាក់ ឬច្រើននាក់ចូលរួមការងារជាប្រចាំជាមូលដ្ឋាន។

**អ្នកធ្វើការដោយទុនផ្ទាល់ខ្លួន** គឺជាមនុស្សម្នាក់ ដែលក្នុងរយៈពេលយោង បានធ្វើការដោយទុនផ្ទាល់ខ្លួនរបស់ពួកគេជាមួយដៃគូម្នាក់ ឬច្រើននាក់នៅក្នុង "ការងារធ្វើដោយខ្លួនឯង" ដោយគ្មាននិយោជិតណាមួយចូលរួមការងារជាប្រចាំ ប៉ុន្តែក៏អាចជាមួយអ្នកធ្វើការឲ្យគ្រួសារមិនយកប្រាក់ឈ្នួលម្នាក់ ឬច្រើននាក់ចូលរួមការងារម្តងម្កាលជាមូលដ្ឋានផងដែរ។ អ្នកធ្វើការប្រភេទនេះ រួមមានម្ចាស់អ្នកដាំដុះ អ្នកដាំដំណាំចែកគ្នា និងអ្នកដាំដុះកិច្ចសន្យាធ្វើការដើម្បីចំណេញ។

**អ្នកធ្វើការឲ្យគ្រួសារមិនយកប្រាក់ឈ្នួល** គឺជាមនុស្សម្នាក់ដែលធ្វើការដោយគ្មានប្រាក់ឈ្នួលជាសាច់ប្រាក់ ឬជារបស់ ក្នុងសហគ្រាសមួយដែលប្រតិបត្តិការដោយសមាជិកក្រុមគ្រួសាររបស់គាត់ ឬដោយសមាជិកគ្រួសារមួយ។

**ផ្សេងទៀត** រួមមានសមាជិកនៃសហករណ៍អ្នកផលិត ។ល។

**វិស័យក្នុងប្រព័ន្ធ** រួមមានអ្នកធ្វើការទាំងអស់នៅក្នុងរដ្ឋាភិបាល ឬសហគ្រាសរដ្ឋ ឬអង្គការអន្តរជាតិ និងក្នុងស្ថានទូតបរទេស ក៏ដូចជាក្រុមហ៊ុនមានដែនកំណត់ ភាពជាដៃគូពាណិជ្ជកម្ម ភាពជាដៃគូមានដែនកំណត់ និងសហគ្រាសបានចុះបញ្ជីជាមួយអាជ្ញាធរពាក់ព័ន្ធ និង/ឬ មានបញ្ជីគណនេយ្យពេញលេញសម្រាប់រាយការណ៍ទៅរដ្ឋាភិបាល រួមមានតារាងតុល្យភាពត្រឹមត្រូវមួយនៃទ្រព្យសម្បត្តិ ចំណូល និងចំណាយ។

**វិស័យក្រៅប្រព័ន្ធ** រួមមានអ្នកធ្វើការទាំងអស់នៅក្នុងសហគ្រាសដែលមិនបានចុះបញ្ជីជាមួយអាជ្ញាធរពាក់ព័ន្ធ និងគ្មានបញ្ជីគណនេយ្យពេញលេញ។ វិស័យក្រៅប្រព័ន្ធមិនរាប់បញ្ចូលគ្រួសារដែលផលិតសម្រាប់តែការប្រើប្រាស់ចុងក្រោយខ្លួនឯង កសិកម្មសម្រាប់ចិញ្ចឹមជីវិត ការសាងសង់លំនៅដ្ឋានខ្លួនឯង ។ល។

**គ្រួសារ** រួមមានអ្នកធ្វើការទាំងអស់នៅក្នុងសហគ្រាសគ្រួសារដែលផលិតទំនិញ និងសេវាកម្មសម្រាប់តែការប្រើប្រាស់ចុងក្រោយខ្លួនឯង។ គ្រួសារ រួមមានអ្នកធ្វើកិច្ចការផ្ទះមានប្រាក់ឈ្នួលជួលដោយគ្រួសារ។ បុគ្គលដែលបានចាត់ចូលក្នុងផ្នែក៩៧ នៃចំណាត់ថ្នាក់សកម្មភាពសេដ្ឋកិច្ចតាមស្តង់ដារអន្តរជាតិ ជំនាន់៤ (ISIC) និងផ្នែក៦៣ នៃចំណាត់ថ្នាក់មុខរបរតាមស្តង់ដារអន្តរជាតិ ឆ្នាំ២០០៨ (ISCO-08) ត្រូវបានរាប់បញ្ចូលក្នុងវិស័យនេះ។

**ការងារក្នុងប្រព័ន្ធ** រួមមានអ្នកដែលធ្វើការនៅក្នុងអាជីវកម្មផ្ទាល់ខ្លួនរបស់ពួកគេក្នុងវិស័យក្នុងប្រព័ន្ធ ឬអ្នកធ្វើការជានិយោជិត អ្នករៀនធ្វើការ អ្នកហាត់ការរបស់និយោជកដែលចូលរួមវិភាគទានដល់របបសោធននិវត្តន៍ សុខភាព និង/ឬមូលនិធិធានារ៉ាប់រងភាពគ្មានការងារធ្វើ ឬផ្តល់ប្រាក់ឈ្នួលឈប់សម្រាកប្រចាំឆ្នាំ និងឈប់សម្រាកឈឺក្នុងករណីមានជំងឺ ឬរបួស។

**ការងារក្រៅប្រព័ន្ធ** រួមមាននិយោជក និងអ្នកធ្វើការដោយទុនផ្ទាល់ខ្លួនដែលធ្វើការក្នុងសហគ្រាសវិស័យក្រៅប្រព័ន្ធផ្ទាល់ខ្លួនរបស់ពួកគេ អ្នកធ្វើការឲ្យគ្រួសារមិនយកប្រាក់ឈ្នួល និងនិយោជិតនិងអ្នករៀនធ្វើការនិងអ្នកហាត់ការដែលគ្មានប្រាក់ឈ្នួលពេលឈប់សម្រាកប្រចាំឆ្នាំ ឬអត្ថប្រយោជន៍ឈប់សម្រាកឈឺ និងដែលនិយោជករបស់ពួកគេមិនបានចូលរួមវិភាគទានដល់របបសន្តិសុខសង្គមរបស់ពួកគេ។ ចំនួនមនុស្សក្នុងផ្នែកនេះ ជាផលសងរវាងចំនួនមនុស្សទាំងអស់ដែលបានធ្វើការ និងចំនួនមនុស្សក្នុងការងារក្នុងប្រព័ន្ធ។

**ភាពមានការងារធ្វើមិនគ្រប់គ្រាន់ទាក់ទងនឹងពេលវេលា** សំដៅលើមនុស្សទាំងអស់ក្នុងការងារ ដែលក្នុងរយៈពេលយោងខ្លី ចង់ធ្វើការម៉ោងបន្ថែម ដោយសារចំនួនម៉ោងធ្វើការក្នុងការងារទាំងអស់របស់គាត់តិចជាងកម្រិតម៉ោងដែលបានកំណត់ (៤០ ម៉ោង សម្រាប់កម្ពុជា) ហើយគាត់អាចធ្វើការម៉ោងបន្ថែមបានបើផ្តល់ឱកាសការងារមានប្រាក់ឈ្នួលបន្ថែមទៀត ដែល៖

(i) "ម៉ោងធ្វើការ" សំដៅលើចំនួនម៉ោងជាក់ស្តែងបានធ្វើការ ឬចំនួនម៉ោងធម្មតាបានធ្វើការ អាស្រ័យលើគោលដៅនៃការវាស់វែង (ស្ថានភាពរយៈពេលខ្លី ឬវែង) និងអនុលោមតាមស្តង់ដារស្ថិតិអន្តរជាតិស្តីពីប្រធានបទ

(ii) "ម៉ោងបន្ថែម" អាចជាម៉ោងលើសនៅក្នុងការងារតែមួយ នៅក្នុងមួយឬច្រើនការងារបន្ថែម ឬនៅក្នុងមួយឬច្រើនការងារជំនួស

(iii) "កម្រិតកំណត់ចំនួនម៉ោង" គឺផ្អែកលើព្រំដែនរវាងការងារម៉ោងពេញ និងម៉ោងក្រៅ លើតម្លៃមេដ្យាន ឬម៉ូតនៃចំនួនម៉ោងធ្វើការធម្មតារបស់អ្នកធ្វើការងារទាំងអស់ ឬលើបទដ្ឋានចំនួនម៉ោងធ្វើការដូចមានចែងក្នុងច្បាប់ពាក់ព័ន្ធ ឬការអនុវត្តថ្នាក់ជាតិ និងការកំណត់សម្រាប់ក្រុមអ្នកធ្វើការជាក់លាក់ និង

(iv) "អាចធ្វើការងារម៉ោងបន្ថែម" ត្រូវបានកំណត់ក្នុងរយៈពេលយោងខ្លីមួយ ដែលឆ្លុះបញ្ចាំងពីរយៈពេលតាមតម្រូវការនៅក្នុងបរិបទប្រទេសរវាងការចាកចេញពីការងារមួយ និងការចាប់ផ្តើមការងារផ្សេងទៀត។

**កម្លាំងពលកម្មសក្តានុពល (អ្នកចូលរួម)** សំដៅលើមនុស្សក្នុងអាយុធ្វើការទាំងអស់ ដែលក្នុងរយៈពេលយោងខ្លី មិនបានធ្វើការងារ ឬគ្មានការងារធ្វើ ហើយ៖

(i) ធ្វើសកម្មភាព "ស្វែងរកការងារធ្វើ" ហើយមិន "បច្ចុប្បន្នអាចធ្វើការបាន" ប៉ុន្តែនឹងអាចធ្វើបានក្នុងរយៈពេលបន្តបន្ទាប់ខ្លីមួយ ទៅតាមកាលៈទេសៈប្រទេស (ពោលគឺអ្នកស្វែងរកការងារតែមិនអាចធ្វើបាន) ឬ

(ii) មិនធ្វើសកម្មភាព "ស្វែងរកការងារធ្វើ" ប៉ុន្តែចង់ធ្វើការ និង "បច្ចុប្បន្នអាចធ្វើការបាន" (ពោលគឺអ្នកស្វែងរកការងារមានសក្តានុពលដែលអាចធ្វើបាន)។

# ជំពូក ២
# វិធីសាស្ត្រអង្កេត

ជំពូកនេះពិពណ៌នាអំពីវិធីសាស្ត្រប្រើប្រាស់ក្នុងអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។ ជំពូកនេះពន្យល់អំពីទំហំ និងវិសាលភាពនៃការអង្កេត ការជ្រើសសំណាកគំរូ ប្រតិបត្តិការប្រមូលទិន្នន័យ និងការកែច្នៃទិន្នន័យ។ អង្កេតត្រូវបានដំណើរការក្នុងរយៈពេល ៣៥ ថ្ងៃ ពីថ្ងៃទី ២១ ខែតុលា ដល់ថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ២០១៩។ អង្កេតកម្លាំងពលកម្មកម្ពុជាមិនទាន់ត្រូវបានអនុវត្តតាមមូលដ្ឋានទៀងទាត់ទាំងស្រុងនៅឡើយ។

## ២.១ ទំហំ និងវិសាលភាព

ការអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩ ត្រូវបានដំណើរការ ដើម្បីផ្តល់ការប៉ាន់ស្មានគួរឲ្យជឿបាននូវចំនួនកម្លាំងពលកម្មកម្ពុជានៅថ្នាក់ជាតិ ទីប្រជុំជន និងជនបទ។ អង្កេតផ្តោតលើប្រជាជនក្នុងអាយុធ្វើការ ដែលបានកំណត់អាយុ ១៥ ឆ្នាំឡើង កំពុងរស់នៅក្នុងគ្រួសារសំណាកគំរូ។ អង្កេតបានរៀបចំឡើង ដើម្បីទទួលបានការប៉ាន់ស្មានថ្នាក់ជាតិនៃអថេរជាច្រើន ជាពិសេសទាក់ទងនឹងសកម្មភាពសេដ្ឋកិច្ច និងមិនមែនសេដ្ឋកិច្ចរបស់ប្រជាជនកម្ពុជាអាយុ ១៥ ឆ្នាំឡើង ដែលនៅក្នុងកម្លាំងពលកម្ម។

អង្កេតបានជ្រើសយកសំណាកគំរូ ៩.៦០០ គ្រួសារ ពី ៦០០ ភូមិសំណាកគំរូ ដោយបែងចែកក្នុងចំណោម ២៤ ខេត្ត និងរាជធានីភ្នំពេញ។ ការអង្កេតគ្របដណ្តប់ទាំងតំបន់ទីប្រជុំជន និងតំបន់ជនបទ និងគ្រប់ប្រភេទទាំងអស់នៃគ្រួសារ រួមទាំងគ្រួសារមានសមាជិកតែម្នាក់ផងដែរ។

## ២.២ បញ្ជីសំណួរ

បញ្ជីសំណួរអង្កេតកម្លាំងពលកម្មកម្ពុជាបានបង្កើតឡើងដោយផ្អែកលើ "សេចក្តីសម្រេចពាក់ព័ន្ធនឹងស្ថិតិការងារ ភាពមានការងារធ្វើ និងការប្រើមិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម" ដែលបានអនុម័តដោយសន្និសីទអន្តរជាតិនៃអ្នកស្ថិតិកម្លាំងពលកម្មលើកទី១៩ នៅឆ្នាំ២០១៣។[២] បញ្ជីសំណួរអង្កេតរួមបញ្ចូលបីទម្រង់នៃគំរូអង្កេតកម្លាំងពលកម្មរបស់អង្គការអន្តរជាតិខាងការងារ (ILO) សម្រាប់ការសម្ភាសប្រើក្រដាស និងខ្មៅដៃ (PAPI) រួមមាន ១៥ ផ្នែក ដូចខាងក្រោម៖

- ផ្នែក A បញ្ជីគ្រួសារ និងប្រជាសាស្ត្រ
- ផ្នែក B ស្ថានភាពទេសន្តរប្រវេសន៍អន្តរជាតិ
- ផ្នែក C ស្ថានភាពពិការ
- ផ្នែក D ប្រភពសម្រាប់ចិញ្ចឹមជីវិតរបស់គ្រួសារ
- ផ្នែក E កសិកម្មគ្រួសារ
- ផ្នែក F ធ្វើការនៅកន្លែងការងារ
- ផ្នែក G អវត្តមានជាបណ្តោះអាសន្ន
- ផ្នែក H ការងារកសិកម្ម និងទីផ្សារ

[២] អង្គការអង្គរជាតិខាងការងារ (ILO)។ *របាយការណ៍សន្និសីទ៖ សន្និសីទអន្តរជាតិនៃអ្នកស្ថិតិកម្លាំងពលកម្មលើកទី១៩ ហ្សឺណែវ ថ្ងៃទី ២-១១ ខែតុលា ឆ្នាំ ២០១៣* ។ ហ្សឺណែវ។ ទំព័រ ៤៧។ https://www.ilo.org/wcmsp5/groups/public/---dgreports/---stat/documents/publication/wcms_234124.pdf.

- ផ្នែក I ចរិតលក្ខណៈនៃការងារចម្បង
- ផ្នែក J ចរិតលក្ខណៈនៃការងារទីពីរ
- ផ្នែក K ម៉ោងធ្វើការក្នុងការងារ
- ផ្នែក L ការផលិតគ្រឿងបរិភោគសម្រាប់ប្រើប្រាស់ខ្លួនឯងក្នុងចំណោមអ្នកធ្វើការ
- ផ្នែក M ការស្វែងរកការងារ និងភាពអាចរកបានការងារ
- ផ្នែក N ការផលិតទំនិញផ្សេងទៀតសម្រាប់ប្រើប្រាស់ខ្លួនឯង
- ផ្នែក O ចំណាយជ្រើសរើសរបស់ពលករចំណាកស្រុកនិវត្តន៍

បញ្ជីសំណួរអង្កេតមានជូនភ្ជាប់នៅឧបសម្ព័ន្ធ ៣ ។

## ២.៣ វិធីសាស្ត្រជ្រើសសំណាកគំរូ

ដើម្បីសម្រេចបានគោលដៅផ្តល់ការប៉ាន់ស្មានគួរឲ្យជឿបាននៅថ្នាក់ជាតិ ទីប្រជុំជន និងជនបទ អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩ បានប្រើវិធីសាស្ត្រជ្រើសសំណាកគំរូតាមបីដំណាក់កាលគឺ (i) ជ្រើសរើសភូមិ (ii) ជ្រើសរើសមណ្ឌលសម្ភាសន៍មួយសម្រាប់ភូមិសំណាកគំរូនីមួយៗ និង (iii) ជ្រើសរើសគ្រួសារសម្រាប់មណ្ឌលសម្ភាសន៍សំណាកគំរូនីមួយៗ។ តំបន់ទីប្រជុំជន និងតំបន់ជនបទត្រូវបានបម្រើជាអថេរតាមផ្នែក។

ឯកតាសំណាកគំរូបឋម (PSU) គឺជាភូមិ។ ភូមិត្រូវបានជ្រើសជាសំណាកគំរូ តាមប្រូបាប៊ីលីតេសមាមាត្រទៅនឹងចំនួនគ្រួសារដែលបានចុះបញ្ជីនៅក្នុងក្របខ័ណ្ឌ។

មណ្ឌលសម្ភាសន៍ (EA) គឺជាផ្នែកមួយនៃភូមិមួយ ហើយផ្នែកមួយនេះត្រូវបានជ្រើសរើសដោយចៃដន្យពីក្នុងភូមិនីមួយៗ ដែលជាសំណាកគំរូ។

ឯកតាជ្រើសសំណាកគំរូចុងក្រោយ គឺគ្រួសារ ជាសរុបចំនួន ១៦ គ្រួសារ ត្រូវបានជ្រើសរើសដោយចៃដន្យតាមវិធីសាស្ត្រជ្រើសសំណាកគំរូតាមប្រព័ន្ធ ពីក្នុងមណ្ឌលសម្ភាសន៍នីមួយៗ។

## ២.៤ ក្របខ័ណ្ឌជ្រើសសំណាកគំរូ

ក្របខ័ណ្ឌជ្រើសសំណាកគំរូប្រើសម្រាប់អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩ ត្រូវបានរៀបចំដោយវិទ្យាស្ថានជាតិស្ថិតិ ដោយប្រើព័ត៌មានដែលបានប្រមូលពីជំរឿនទូទៅប្រជាជននៅកម្ពុជា ឆ្នាំ២០១៩។ ក្របខ័ណ្ឌមានចំនួន ១៤.៥១៤ ភូមិ បានបែងចែកក្នុងចំណោម ៦០០ ឯកតាសំណាកគំរូបឋម និង ៦០០ មណ្ឌលសម្ភាសន៍ នៅទូទាំងប្រទេស។

មុនធ្វើជំរឿនទូទៅប្រជាជននៅកម្ពុជា ឆ្នាំ២០១៩ ផែនទីព្រាងត្រូវបានរៀបចំដើម្បីកំណត់ព្រំប្រទល់នៃមណ្ឌលសម្ភាសន៍នីមួយៗ។ ផែនទីនេះក៏ត្រូវបានប្រើប្រាស់សម្រាប់អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩ ផងដែរ។

## ២.៥ សមាមាត្រទម្ងន់សំណាកគំរូ

ជំហានដំបូង សមាមាត្រទម្ងន់ (weight) សម្រាប់ឯកតាសំណាកគំរូបឋមដែលបានជ្រើសរើស (i) ក្នុងតំបន់ h (ទីប្រជុំជន/ជនបទ) ត្រូវបានគណនាតាមរូបមន្តខាងក្រោម៖

$$W_{I.hi} = \frac{M_h}{n_h.M_{hi}}$$

ដែល $M_h$ = ចំនួនគ្រួសារក្នុងតំបន់ (h) យោងតាមការចុះបញ្ជីភូមិ
$M_{hi}$ = ចំនួនគ្រួសារក្នុងឯកតាសំណាកគំរូបឋម (i) ក្នុងតំបន់ (h) យោងតាមការចុះបញ្ជីភូមិ
$n_h$ = ចំនួនឯកតាសំណាកគំរូបឋមដែលបានជ្រើសរើស ក្នុងតំបន់ (h)

ជំហានទីពីរ សមាមាត្រទម្ងន់សម្រាប់គ្រួសារដែលបានជ្រើសរើស ក្នុងឯកតាសំណាកគំរូបឋមដែលបានជ្រើសរើស ត្រូវបានគណនាតាមរូបមន្តខាងក្រោម៖

$$W_{II.hi} = \frac{M^*_{hi}}{m_{hik}}$$

ដែល $M^*_{hi}$ = ចំនួនគ្រួសារក្នុងឯកតាសំណាកគំរូបឋម (i) នៃតំបន់ (h) នៅពេលអង្កេត
$m_{hik}$ = ចំនួន ១៦ គ្រួសារសំណាកគំរូ ក្នុងមួយឯកតាសំណាកគំរូបឋម (i) ក្នុងតំបន់ (h)

$M^*_{hi}$ ត្រូវបានកំណត់ជាពីរវិធីសាស្ត្រផ្សេងគ្នា អាស្រ័យលើស្ថានភាព។ បើឯកតាសំណាកគំរូបឋមដែលបានជ្រើសរើសមានតែមួយមណ្ឌលសម្ភាសន៍ នោះការចុះបញ្ជីគ្រួសារនៅក្នុងមណ្ឌលសម្ភាសន៍នឹងចុះគ្រប់គ្រួសារទាំងអស់ដែលមាននៅក្នុងឯកតាសំណាកគំរូបឋម។ បើឯកតាសំណាកគំរូបឋមមានមណ្ឌលសម្ភាសន៍ច្រើន នោះការចុះបញ្ជីគ្រួសារត្រូវចុះតែចំនួនគ្រួសារនៅក្នុងមណ្ឌលសម្ភាសន៍ដែលបានជ្រើសរើសប៉ុណ្ណោះ។ ក្នុងករណីនេះ ចំនួនគ្រួសារនៅក្នុងឯកតាសំណាកគំរូបឋមត្រូវបានទទួលពីប្រធានភូមិ។

$M^*_{hi}$ ច្រើនតែខុសពី $M_{hi}$ ដែលជាចំនួនគ្រួសារក្នុងឯកតាសំណាកគំរូបឋម (i) យោងតាមការចុះបញ្ជីភូមិ។ ក្នុងករណីភាគច្រើន ភាពខុសគ្នានេះមានតិចតួចប៉ុណ្ណោះ។

ជំហានទីបី សមាមាត្រទម្ងន់សំណាកគំរូសម្រាប់គ្រួសារត្រូវបានគណនាដោយការរួមបញ្ចូលសមាមាត្រទម្ងន់ពីជំហានជ្រើសសំណាកគំរូទាំងពីរដំបូង។ សមាមាត្រទម្ងន់សំណាកគំរូ (គណនា weight) សម្រាប់គ្រួសារ (k) ក្នុងឯកតាសំណាកគំរូបឋម (i) ត្រូវបានគណនាតាមរូបមន្តខាងក្រោម៖

$$d_{hik} = W_{I.hi} \times W_{II.hi}$$

ដែល $d_{hik}$ = គណនាសមាមាត្រទម្ងន់ ក្នុងតំបន់ (h) ឯកតាសំណាកគំរូបឋម (i) និងគ្រួសារ (k)

ជាទូទៅ ការកែតម្រូវសម្រាប់ការមិនឆ្លើយត្រូវបានបញ្ចូលក្នុងការគណនាសមាមាត្រទម្ងន់អង្កេត។ ជាពិសេសបើឯកតាសំណាកគំរូបឋមមានតិចជាង ១៦ គ្រួសារបានឆ្លើយ នោះសមាមាត្រទម្ងន់គួរត្រូវបានកែតម្រូវតាមកត្តា ១៦/r ដែល r ជាចំនួនគ្រួសារបានឆ្លើយនៅក្នុងឯកតាសំណាកគំរូបឋមដែលត្រូវពិចារណា។ ទោះជាយ៉ាងណាក៏ដោយ ដោយសារមានតែមួយករណី ដែលចំនួនគ្រួសារបានឆ្លើយមានតិចជាង ១៦ គ្រួសារ ដូច្នេះដំណើរការគណនាសមាមាត្រទម្ងន់ត្រូវបានរំលង។

ទីបញ្ចប់ សមាមាត្រទម្ងន់គ្រួសារចុងក្រោយគឺ៖

$$W_{hik} = d_{hik} \times f$$

ដែល $W_{hik}$ = សមាមាត្រទម្ងន់គ្រួសារចុងក្រោយ
f = កត្តាគ្រួសារក្រិតតាមខ្នាត

### តារាង ២.១. ភូមិ និងគ្រួសារសំណាកគំរូសម្រាប់អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩

| តំបន់ | ភូមិសំណាកគំរូ | គ្រួសារសំណាកគំរូ |
|---|---|---|
| ទីប្រជុំជន | ១៨០ | ២.៨៨០ |
| ជនបទ | ៤២០ | ៦.៧២០ |
| **សរុប** | **៦០០** | **៩.៦០០** |

ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

### តារាង ២.២. ការបែងចែកសំណាកគំរូតាមតំបន់ទីប្រជុំជន និងជនបទ ក្នុងរាជធានី និងខេត្ត សម្រាប់អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩

| លេខកូដ | រាជធានី/ខេត្ត | ភូមិសំណាកគំរូ | | |
|---|---|---|---|---|
| | | ទីប្រជុំជន | ជនបទ | សរុប |
| ០១ | បន្ទាយមានជ័យ | ១០ | ១៩ | ២៩ |
| ០២ | បាត់ដំបង | ១១ | ៣៣ | ៤៤ |
| ០៣ | កំពង់ចាម | ៨ | ៣៥ | ៤៣ |
| ០៤ | កំពង់ឆ្នាំង | ២ | ១៩ | ២១ |
| ០៥ | កំពង់ស្ពឺ | ៣ | ២៦ | ២៩ |
| ០៦ | កំពង់ធំ | ៣ | ២៤ | ២៧ |
| ០៧ | កំពត | ៣ | ២១ | ២៤ |
| ០៨ | កណ្តាល | ១៦ | ៣៣ | ៤៩ |
| ០៩ | កោះកុង | ២ | ២ | ៤ |
| ១០ | ក្រចេះ | ២ | ១៣ | ១៥ |
| ១១ | មណ្ឌលគីរី | ១ | ២ | ៣ |
| ១២ | ភ្នំពេញ | ៧៤ | ០ | ៧៤ |
| ១៣ | ព្រះវិហារ | ១ | ៨ | ៩ |
| ១៤ | ព្រៃវែង | ៣ | ៤២ | ៤៥ |
| ១៥ | ពោធិ៍សាត់ | ៣ | ១៥ | ១៨ |
| ១៦ | រតនគីរី | ២ | ៦ | ៨ |
| ១៧ | សៀមរាប | ១២ | ២៧ | ៣៩ |
| ១៨ | ព្រះសីហនុ | ៥ | ៣ | ៨ |
| ១៩ | ស្ទឹងត្រែង | ១ | ៥ | ៦ |
| ២០ | ស្វាយរៀង | ៥ | ១៩ | ២៤ |
| ២១ | តាកែវ | ២ | ៣៣ | ៣៥ |
| ២២ | ឧត្តរមានជ័យ | ៣ | ៧ | ១០ |
| ២៣ | កែប | ២ | ០ | ២ |
| ២៤ | ប៉ៃលិន | ១ | ១ | ២ |
| ២៥ | ត្បូងឃ្មុំ | ៥ | ២៧ | ៣២ |
| | **សរុប** | **១៨០** | **៤២០** | **៦០០** |

ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

## ២.៦ វិធីសាស្ត្រប៉ាន់ស្មាន

ការប៉ាន់ស្មានថ្នាក់ជាតិគ្របដណ្តប់លើប្រទេសកម្ពុជាទាំងមូល [ទីប្រជុំជន (h=1) ឬជនបទ (h=2)]។ ដើម្បីប៉ាន់ស្មានសរុបថ្នាក់ជាតិនៃចរិតលក្ខណៈប្រជាជនជាក់លាក់ $X_{hik}$ គឺជាអថេរដែលរាប់បញ្ចូលគ្រួសារ (k) ឯកតាសំណាកគំរូបឋម (i) និងតំបន់ (h)។

ក្នុងទូទាំងប្រទេស ($\hat{X}$)៖

$$\hat{X} = \sum_{h=1}^{2} \sum_{i=1}^{n_{hi}} \sum_{k=1}^{m_{hik}} (X_{hik} \cdot W_{hik})$$

ក្នុងតំបន់ (h) (ទីប្រជុំជន ជនបទ) ($\hat{X}_h$)៖

$$\hat{X}_h = \sum_{i=1}^{n_{hi}} \sum_{k=1}^{m_{hik}} (X_{hik} \cdot W_{hik})$$

## ២.៧ ការបណ្តុះបណ្តាល និងការប្រមូលទិន្នន័យ

ដើម្បីដំណើរការអង្កេតក្នុងទូទាំងប្រទេសឲ្យបានត្រឹមត្រូវ កម្មវិធីបណ្តុះបណ្តាលល្អិតល្អន់ត្រូវបានរៀបចំសម្រាប់មន្ត្រីត្រួតពិនិត្យ និងមន្ត្រីសម្ភាសន៍អង្កេត ក៏ដូចជាមន្ត្រីសម្របសម្រួលអង្កេត។ ជាសរុប ចំនួន ១០០ នាក់ ត្រូវបានជ្រើសរើស ក្នុងនោះប្រុស ៧១ នាក់ និងស្រី ២៩ នាក់ (អ្នកត្រួតពិនិត្យ ២០ នាក់ និងអ្នកសម្ភាសន៍ ៨០ នាក់) ហើយពួកគេទទួលការបណ្តុះបណ្តាល ៥ ថ្ងៃ អំពីការប្រមូលទិន្នន័យ នៅខែតុលា ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិស្ថិតិ។ ក្នុងចំណោមពួកគេ មន្ត្រី ៤៦ នាក់ ត្រូវបានជ្រើសរើសពី ២៥ មន្ទីរផែនការរាជធានី និងខេត្ត និងមន្ត្រី ៥៤ នាក់ ត្រូវបានជ្រើសរើសពីវិទ្យាស្ថានជាតិស្ថិតិ និងបណ្តានាយកដ្ឋាននៅក្រសួងផែនការ។ វគ្គបណ្តុះបណ្តាលមានរយៈពេល ៣ ថ្ងៃសម្រាប់បណ្តុះបណ្តាល ១ ថ្ងៃសម្រាប់សាកល្បងសម្ភាសន៍នៅមូលដ្ឋាន និង ១ ថ្ងៃសម្រាប់ពិនិត្យឡើងវិញ។

វគ្គបណ្តុះបណ្តាលនេះផ្តោតលើការណែនាំបច្ចេកទេសសម្ភាសន៍ទូទៅ និងនីតិវិធីចុះអង្កេត (រួមទាំងការជ្រើសសំណាកគំរូ) ក៏ដូចជាការពិភាក្សាលម្អិតលើសំណួរក្នុងបញ្ជីសំណួរ និងការអនុវត្តសម្ភាសន៍នៅមូលដ្ឋាន។

បន្ទាប់ពីការបណ្តុះបណ្តាល ការងារប្រមូលទិន្នន័យនៅមូលដ្ឋានត្រូវបានធ្វើឡើងក្នុងរយៈពេល ៣៥ ថ្ងៃ ចាប់ពីថ្ងៃទី២១ ខែតុលា ដល់ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៩។ ឧបករណ៍អង្កេតរួមមាន ផែនទីមណ្ឌលសម្ភាសន៍ពីជំរឿនទូទៅប្រជាជននៅកម្ពុជា ឆ្នាំ២០១៩ ទម្រង់ចុះបញ្ជីគ្រួសារ និងបញ្ជីសំណួរ។

ការប្រមូលទិន្នន័យសម្រាប់អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩ ធ្វើឡើងដោយ ២០ ក្រុម ដែលក្រុមនីមួយៗមានមន្ត្រីត្រួតពិនិត្យម្នាក់ និងមន្ត្រីសម្ភាសន៍បួននាក់ ហើយក្រុមនីមួយៗត្រូវចុះសម្ភាស ៣០ មណ្ឌលសម្ភាសន៍។ មន្ត្រីសម្របសម្រួលអង្កេតប្រាំនាក់ត្រូវចុះត្រួតពិនិត្យការងារអង្កេតតាមមូលដ្ឋាន ដោយមន្ត្រីសម្របសម្រួលអង្កេតម្នាក់ត្រូវទទួលខុសត្រូវមន្ត្រីត្រួតពិនិត្យបួននាក់។

## ២.៨ ការកែច្នៃទិន្នន័យ

បញ្ជីសំណួរដែលបានបំពេញហើយត្រូវប្រគល់ និងធ្វើការកែច្នៃទិន្នន័យនៅវិទ្យាស្ថានជាតិស្ថិតិ។ វគ្គបណ្តុះបណ្តាលមន្ត្រីកែច្នៃទិន្នន័យត្រូវបានចូលរួមដោយមន្ត្រីវិទ្យាស្ថានជាតិស្ថិតិ ២៤ នាក់៖ ១២ នាក់ ជាមន្ត្រីដាក់លេខកូដ និង ១២ នាក់ ជាមន្ត្រីវាយបញ្ចូលទិន្នន័យ។ មន្ត្រីដាក់លេខកូដត្រូវបានបណ្តុះបណ្តាលដើម្បីពិនិត្យមើលភាពត្រឹមត្រូវនៃកំណត់ត្រាក្នុងបញ្ជីសំណួរដែលបានបំពេញហើយ និងពិនិត្យមើលភាពត្រូវគ្នារវាងចម្លើយ កំណត់លេខកូដទៅនឹង

ចម្លើយ និងផ្ទៀងផ្ទាត់កំហុសកំណត់ត្រា និងលទ្ធផលពីកុំព្យូទ័រផ្សេងទៀត។ លេខកូដបួនខ្ទង់នៃចំណាត់ថ្នាក់មុខរបរតាមស្តង់ដារអន្តរជាតិ ឆ្នាំ២០០៨ (ISCO-08) និងលេខកូដបួនខ្ទង់នៃចំណាត់ថ្នាក់សកម្មភាពសេដ្ឋកិច្ចតាមស្តង់ដារអន្តរជាតិ ជំនាន់ ៤ (ISIC Rev4) ត្រូវបានប្រើប្រាស់។ មន្ត្រីវាយបញ្ចូលទិន្នន័យត្រូវបានបណ្តុះបណ្តាលដើម្បីវាយបញ្ចូលលេខកូដពីបញ្ជីសំណួរ ផ្ទៀងផ្ទាត់ទិន្នន័យដែលត្រូវវាយបញ្ចូល ពិនិត្យមើលភាពពេញលេញនៃកំណត់ត្រា និងកែតម្រូវកំហុសដែលមានក្នុងពេលវាយបញ្ចូលទិន្នន័យ ក៏ដូចជាកំហុសផ្សេងទៀតដែលមិនបានរកឃើញក្នុងពេលកែច្នៃដោយដៃ។

ការវាយបញ្ចូលទិន្នន័យត្រូវបានអនុវត្តដោយប្រើកម្មវិធីប្រព័ន្ធកែច្នៃជំរឿន និងអង្កេត (CSPro) ដែលជាកម្មវិធីកុំព្យូទ័រមួយបង្កើតដោយការិយាល័យជំរឿនសហរដ្ឋអាមេរិក។ កម្មវិធីកុំព្យូទ័រសម្រាប់វាយបញ្ចូលទិន្នន័យបានបង្កើតឡើងដោយមន្ត្រីវិទ្យាស្ថានជាតិស្ថិតិ។ ការផ្ទៀងផ្ទាត់ទិន្នន័យបានអនុវត្តតាមការបោះពុម្ពបញ្ជីទិន្នន័យដែលបានវាយបញ្ចូលលើកទីមួយ និងលើកទីពីរ (បញ្ជីប្រៀបធៀប) របស់មន្ត្រីវាយបញ្ចូលទិន្នន័យនីមួយៗដើម្បីផ្ទៀងផ្ទាត់ មន្ត្រីវាយបញ្ចូលទិន្នន័យក៏ត្រូវឆែកពិនិត្យតម្លៃត្រឹមត្រូវរបស់អថេរ ដោយពិនិត្យមើល ឬឆែកបញ្ជីសំណួរបំពេញហើយដាក់ស្តែង ហើយបន្ទាប់មកកែតម្រូវកំហុសវាក្នុងកុំព្យូទ័រ។

បន្ទាប់ពីការផ្ទៀងផ្ទាត់ទិន្នន័យរួចហើយ ការឆែកពិនិត្យភាពត្រូវគ្នានៃទិន្នន័យ ឬការពិនិត្យយោងឆ្លងបានធ្វើឡើងតាមការអនុវត្តកម្មវិធី CSPro ដែលបានរៀបចំសម្រាប់គោលបំណងនេះ។ បញ្ជីសំណួរដែលមានកំហុសត្រូវចុះបញ្ជីនៅក្នុងឯកសារបញ្ជីកំហុស ហើយបោះពុម្ពចេញសម្រាប់ការកែតម្រូវកំហុស រហូតដល់មានសារកំហុសសូន្យ។ បន្ទាប់ពីបានផ្ទៀងផ្ទាត់ និងសម្អាតទិន្នន័យរួចមក តារាងទិន្នន័យត្រូវបានផលិតដោយផ្អែកលើផែនការផលិតតារាងទិន្នន័យដែលបានរៀបចំជាមុន។ កម្មវិធីស្ថិតិសម្រាប់វិទ្យាសាស្ត្រសង្គម (SPSS) និងកម្មវិធីសម្រាប់វិទ្យាសាស្ត្រស្ថិតិ និងទិន្នន័យ (Stata) ត្រូវបានប្រើដើម្បីផលិតតារាងទិន្នន័យ។ បន្ទាប់មកកម្មវិធី Microsoft Excel ត្រូវបានប្រើដើម្បីរៀបចំតារាងទិន្នន័យ និងគណនាសូចនាករបន្ថែមដែលត្រូវការ។

## ២.៩ អត្រាឆ្លើយ

តារាង ២.៣ បង្ហាញអំពីអត្រាឆ្លើយសម្រាប់អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។ ជាសរុប ចំនួន ៩.៦០០ គ្រួសារត្រូវបានជ្រើសរើសជាសំណាកគំរូសម្រាប់ការអង្កេត ក្នុងនោះ ៩.៥៩៩ គ្រួសារត្រូវបានសម្ភាសដោយជោគជ័យ ផ្តល់អត្រាឆ្លើយបាន ៩៩.៩៩%។

ជំហានសំខាន់ៗដែលត្រូវអនុវត្ត ដើម្បីទទួលបានអត្រាឆ្លើយខ្ពស់ខ្លាំងមានដូចខាងក្រោម៖

១) លិខិតអនុញ្ញាតិជាផ្លូវការដើម្បីធ្វើអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩ ចុះហត្ថលេខាដោយឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវបានផ្ញើជាមុនទៅតាមឋានានុក្រមរដ្ឋបាលគ្រប់លំដាប់ថ្នាក់ (អភិបាលរាជធានី ឬ អភិបាលខេត្ត អភិបាលក្រុង-ស្រុក មេឃុំ ចៅសង្កាត់ និងមេភូមិ) មុនពេលប្រតិបត្តិការអង្កេត និង

២) មេភូមិនីមួយៗបានជូនដំណឹងដល់គ្រួសារទាំងអស់នៅក្នុងភូមិរបស់គាត់អំពីការអង្កេត។ អ្នកត្រួតពិនិត្យការប្រមូលទិន្នន័យនៅមូលដ្ឋានបានធ្វើការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរមូលដ្ឋាន ជាពិសេសមេភូមិ ក្នុងអំឡុងពេលប្រមូលទិន្នន័យនៅមូលដ្ឋាន។ ការចូលរួមរបស់មេភូមិអាចជំរុញកិច្ចសហប្រតិបត្តិការយ៉ាងសកម្មរបស់គ្រួសារ។

ម្យ៉ាងទៀត មាត្រា ៣៣ នៃច្បាប់ស្តីពីស្ថិតិចែងថា អ្នកឆ្លើយទាំងឡាយត្រូវផ្តល់ព័ត៌មានត្រឹមត្រូវ គ្រប់គ្រាន់ និងទាន់ពេលវេលាជូនមន្ត្រីស្ថិតិដែលត្រូវបានចាត់តាំងដោយក្រសួងផែនការ និងបណ្តាក្រសួង ស្ថាប័នរាជរដ្ឋាភិបាល។

មាត្រា ៣៥ នៃច្បាប់ស្តីពីស្ថិតិចែងថា បុគ្គល ឬមេគ្រួសារដែលប្រព្រឹត្តល្មើសមាត្រា ៣៣ នៃច្បាប់នេះ ត្រូវទទួលការព្រមានជាលាយលក្ខណ៍អក្សរដោយវិទ្យាស្ថានជាតិស្ថិតិ។ បន្ទាប់ពីទទួលបានលិខិតព្រមាន ហើយបុគ្គលនៅតែប្រព្រឹត្តល្មើសម្តងទៀតត្រូវពិន័យជាប្រាក់ពី ១០.០០០ រៀល ទៅ ៥០.០០០ រៀល។ និយោជិត ឬអ្នកទទួលខុសត្រូវក្នុងក្រុមហ៊ុន ឬសហគ្រាស ឬអង្គការផ្សេងទៀតដែលប្រព្រឹត្តល្មើសនឹងមាត្រា ៣៣ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ខែ ទៅ ៦ ខែ និងពិន័យជាប្រាក់ពី ៥.០០០.០០០ រៀល ទៅ ១០.០០០.០០០ រៀល។

លើសពីនេះ មាត្រា ៣៦ នៃច្បាប់ស្តីពីស្ថិតិចែងថា បុគ្គលរារាំងដោយចេតនានូវដំណើរការប្រមូលទិន្នន័យស្ថិតិដោយមន្ត្រីស្ថិតិដែលត្រូវបានចាត់តាំងដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ឬក្រសួង ស្ថាប័នរាជរដ្ឋាភិបាលតាមច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ ថ្ងៃ ទៅ ១ ខែ និងពិន័យជាប្រាក់ពី ១០.០០០ រៀល ទៅ ១០០.០០០ រៀល។

តារាង ២.៣. អត្រាឆ្លើយរបស់គ្រួសារសំណាកគំរូ

| តំបន់ | ភូមិសំណាកគំរូដែលបានជ្រើសរើស | គ្រួសារសំណាកគំរូដែលបានជ្រើសរើស | គ្រួសារសំណាកគំរូដែលបានសម្ភាស | អត្រាឆ្លើយ (%) |
|---|---|---|---|---|
| ទីប្រជុំជន | ១៨០ | ២.៨៨០ | ២.៨៧៩ | ៩៩,៩៧ |
| ជនបទ | ៤២០ | ៦.៧២០ | ៦.៧២០ | ១០០,០០ |
| **សរុប** | **៦០០** | **៩.៦០០** | **៩.៥៩៩** | **៩៩,៩៩** |

ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

# ជំពូក ៣
# ចរិតលក្ខណៈប្រជាសាស្ត្រ

## ៣.១ សេចក្តីផ្តើម

ជំពូកនេះផ្តល់ព័ត៌មានអំពីចរិតលក្ខណៈប្រជាសាស្ត្រនៃប្រជាជនដែលបានអង្កេត។ អថេរបានបង្ហាញរួមមាន ទំហំប្រជាជន ការបែងចែកប្រជាជន ទំហំគ្រួសារ មេគ្រួសារ ប្រជាជនមានពិការភាព អត្រានៅក្នុងបន្ទុក ប្រភពសម្រាប់ចិញ្ចឹមជីវិតរបស់គ្រួសារ និងចរិតលក្ខណៈគ្រួសារអាស្រ័យលើកសិកម្ម។

ព័ត៌មានប្រជាសាស្ត្រមានសារៈសំខាន់ណាស់នៅក្នុងរាល់ការអង្កេត ព្រោះវាផ្តល់នូវមូលដ្ឋានមួយសម្រាប់ការវិភាគចរិតលក្ខណៈប្រជាជន និងទំនាក់ទំនងពួកគេជាមួយកត្តាកំណត់ផ្សេងៗនៃការប្រែប្រួលប្រជាជន។ ឧទាហរណ៍ ព័ត៌មានប្រជាសាស្ត្រកំណត់បាននូវកម្រិតកំណត់សម្រាប់ឲ្យនិយមន័យប្រជាជនក្នុងអាយុធ្វើការ និងកម្លាំងពលកម្ម។

## ៣.២ ទំហំប្រជាជន

ប្រជាជន គឺជាចំនួនសរុបនៃមនុស្សទាំងអស់ទាំងពីរភេទ អាយុពី ០ ឆ្នាំឡើងទៅ នៅក្នុងទឹកដីមួយ ក្នុងពេលវេលាជាក់លាក់មួយ។ រូប ៣.១ បង្ហាញពីរ៉ាមីតប្រជាជន តាមក្រុមអាយុ និងភេទ។ នៅឆ្នាំ២០១៩ ចំនួនប្រជាជនត្រូវបានប៉ាន់ស្មានប្រមាណ ១៥,៧ លាននាក់ ក្នុងនោះ ៣៣,៩% រស់នៅតំបន់ទីប្រជុំជន និង ៦៦,១% រស់នៅតំបន់ជនបទ។ ចំនួនប្រជាជនលម្អិតនៅកម្ពុជា តាមក្រុមអាយុ ត្រូវបានបង្ហាញក្នុងឧបសម្ព័ន្ធ ២ ។

រូប ៣.១. ពីរ៉ាមីតប្រជាជន




ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

## ៣.៣ ទំហំគ្រួសារ

គ្រួសារ គឺជាមនុស្សម្នាក់ ឬមនុស្សមួយក្រុមដែលរស់នៅជាមួយគ្នាក្នុងផ្ទះ ឬបរិវេណតែមួយ ដែលបែងចែកកិច្ចការផ្ទះដូចគ្នា និងធ្វើម្ហូបអាហារពីចង្ក្រានតែមួយរួមគ្នា។ សមាជិករបស់គ្រួសារមួយមិនចាំបាច់ទាក់ទងនឹងគ្នា ដោយសាច់ញាតិ ឬរៀបការឡើយ។

នៅឆ្នាំ២០១៩ តាមការប៉ាន់ស្មានប្រមាណ ២,៤ លានគ្រួសារ នៅតំបន់ជនបទ និង ១,៣ លានគ្រួសារ នៅតំបន់ទីប្រជុំជន និងជាសរុបមាន ៣,៧ លានគ្រួសារ នៅក្នុងទូទាំងប្រទេស។ ទំហំគ្រួសារជាមធ្យមក្នុងទូទាំងប្រទេសមាន ៤,២ នាក់ (៤,៣ នាក់ក្នុងមួយគ្រួសារ នៅតំបន់ជនបទ និង ៤,១ នាក់ក្នុងមួយគ្រួសារ នៅតំបន់ទីប្រជុំជន)។

តារាង ៣.១. ការបែងចែកគ្រួសារ តាមទំហំ និងតំបន់

| ទំហំគ្រួសារ | ចំនួនគ្រួសារ | | | ភាគរយនៃគ្រួសារ | | |
|---|---|---|---|---|---|---|
| | កម្ពុជា | ទីប្រជុំជន | ជនបទ | កម្ពុជា | ទីប្រជុំជន | ជនបទ |
| ១ | ១០៣.១៧៧ | ៤៤.២៨៨ | ៥៨.៨៨៩ | ២,៨ | ៣,៤ | ២,៤ |
| ២ | ៤៤៧.៣៨៩ | ១៨១.០២២ | ២៦៦.៣៦៧ | ១២,០ | ១៣,៩ | ១០,៩ |
| ៣ | ៧២៨.២៨៧ | ២៦៤.៩៣៣ | ៤៦៣.៣៥៤ | ១៩,៥ | ២០,៣ | ១៩,០ |
| ៤ | ៩៩៦.៧០៥ | ៣៥៥.៨៩៣ | ៦៤០.៨១១ | ២៦,៧ | ២៧,៣ | ២៦,៣ |
| ៥ | ៧៦១.៦២៣ | ២៣៥.៩៨៤ | ៥២៥.៦៣៩ | ២០,៤ | ១៨,១ | ២១,៦ |
| ៦ | ៣៩៧.៤៦០ | ១២៤.៤១៣ | ២៧៣.០៤៦ | ១០,៦ | ៩,៥ | ១១,២ |
| ៧ | ១៦៧.៣៤៩ | ៥០.៨៤១ | ១១៦.៥០៨ | ៤,៥ | ៣,៩ | ៤,៨ |
| ៨ | ៧៧.៤៦៨ | ២៨.៨២៣ | ៤៨.៦៤៥ | ២,១ | ២,២ | ២,០ |
| ៩+ | ៥៩.៧៩៤ | ១៩.៥៤២ | ៤០.២៥២ | ១,៦ | ១,៥ | ១,៧ |
| **សរុប** | **៣.៧៣៩.២៥២** | **១.៣០៥.៧៤១** | **២.៤៣៣.៥១២** | **១០០,០** | **១០០,០** | **១០០,០** |
| ទំហំគ្រួសារជាមធ្យម | ៤,២ | ៤,១ | ៤,៣ | | | |

សម្គាល់៖ ១. សរុបអាចមិនស្មើផលបូក ដោយសារការបង្គត់លេខ។
២. ក្រឡាទទេបង្ហាញថាឈ្មោះក្នុងជួរដេកមិនអនុវត្ត។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

## ៣.៤ មេគ្រួសារ

ជាទូទៅ ប្រទេសកម្ពុជាត្រូវបានចាត់ទុកជាសង្គមបិតាធិបតេយ្យ។ នេះពិតជាបានឆ្លុះបញ្ចាំងតាមរយៈទិន្នន័យដែលមានប្រមាណជិត ២,៩ លានគ្រួសារ មានមេគ្រួសារជាប្រុស ប្រៀបធៀបនឹង ០,៩ លានគ្រួសារ ដែលមានមេគ្រួសារជាស្រី (មើលតារាង ៣.២)។ មានន័យថា ៧៦,៤% នៃគ្រួសារ មានមេគ្រួសារជាប្រុស។ នៅតំបន់ទីប្រជុំជន មានប្រមាណ ៧៣,៩% (ជិត ១,០ លានគ្រួសារ) មានមេគ្រួសារជាប្រុស ខណៈ ២៦,១% (០,៣ លានគ្រួសារ) មានមេគ្រួសារជាស្រី។ នៅតំបន់ជនបទ ប្រមាណ ៧៧,៨% (១,៩ លានគ្រួសារ) មានមេគ្រួសារជាប្រុស ខណៈ ២២,២% (០,៥ លានគ្រួសារ) មានមេគ្រួសារជាស្រី។

តារាង ៣.២. ការបែងចែកគ្រួសារ តាមក្រុមអាយុ ភេទនៃមេគ្រួសារ និងតំបន់

(%)

| ក្រុមអាយុ | កម្ពុជា | | | ទីប្រជុំជន | | | ជនបទ | | |
|---|---|---|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| ១៥–១៩ | ០,២ | ០,២ | ០,៤ | ០,៥ | ០,៤ | ០,៨ | ០,១ | ០,០ | ០,១ |
| ២០–២៤ | ១,៩ | ២,០ | ១,៤ | ២,៣ | ២,២ | ២,៦ | ១,៦ | ១,៩ | ០,៧ |
| ២៥–២៩ | ៥,៥ | ៦,០ | ៤,១ | ៦,០ | ៦,៤ | ៤,៨ | ៥,៣ | ៥,៧ | ៣,៧ |
| ៣០–៣៤ | ៩,៣ | ១០,៦ | ៥,២ | ៩,៩ | ១១,១ | ៦,៥ | ៩,០ | ១០,៤ | ៤,៤ |
| ៣៥–៣៩ | ១៣,៥ | ១៥,១ | ៨,៥ | ១២,២ | ១៣,៣ | ៨,៩ | ១៤,២ | ១៦,០ | ៨,៣ |
| ៤០–៤៤ | ១០,១ | ១០,៨ | ៧,៨ | ៩,៥ | ១០,៥ | ៦,៦ | ១០,៤ | ១០,៩ | ៨,៥ |
| ៤៥–៤៩ | ១១,២ | ១១,៨ | ៩,៤ | ១០,៤ | ១១,៣ | ៧,៩ | ១១,៦ | ១២,០ | ១០,៣ |
| ៥០–៥៤ | ១២,៥ | ១២,៥ | ១២,៤ | ១១,៧ | ១១,៦ | ១១,៩ | ១២,៩ | ១៣,០ | ១២,៨ |
| ៥៥–៥៩ | ១១,៤ | ១០,៧ | ១៣,៤ | ១០,៨ | ១០,៦ | ១១,៣ | ១១,៧ | ១០,៨ | ១៤,៨ |
| ៦០–៦៤ | ៨,៨ | ៧,៧ | ១២,២ | ៩,១ | ៨,២ | ១១,៩ | ៨,៦ | ៧,៥ | ១២,៤ |
| ៦៥ + | ១៥,៦ | ១២,៧ | ២៥,២ | ១៧,៧ | ១៤,៤ | ២៦,៨ | ១៤,៦ | ១១,៨ | ២៤,១ |
| **សរុប (%)** | **១០០,០** | **១០០,០** | **១០០,០** | **១០០,០** | **១០០,០** | **១០០,០** | **១០០,០** | **១០០,០** | **១០០,០** |
| **សរុប (ចំនួន)** | **៣.៧៣៩.២៥២** | **២.៨៥៧.៨៦៧** | **៨៨១.៣៨៥** | **១.៣០៥.៧៤១** | **៩៦៤.៦៧៦** | **៣៤១.០៦៤** | **២.៤៣៣.៥១២** | **១.៨៩៣.១៩០** | **៥៤០.៣២១** |

សម្គាល់៖ សរុបអាចមិនស្មើផលបូក ដោយសារការបង្គត់លេខ។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

## ៣.៥ ប្រជាជនមានពិការភាព

យោងតាមអនុសាសន៍ចុងក្រោយរបស់ក្រុមវ៉ាស៊ីនតោនស្តីពីស្ថិតិពិការភាព កម្រិតលំបាកដែលជនពិការអាចមានត្រូវបានកំណត់ក្នុងមុខងារស្នូលចំនួនប្រាំមួយ៖ ការមើល ការស្តាប់ ការដើរ ការចងចាំ ការថែទាំខ្លួនឯង និងការប្រាស្រ័យទាក់ទង។ អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩ បានបញ្ចូលសំណួរសំខាន់ៗប្រាំមួយ ដើម្បីទទួលបាននូវស្ថានភាពពិការភាពរបស់ប្រជាជនសំណាកគំរូ។

រូប ៣.២ បង្ហាញសមាមាត្រនៃជនពិការក្នុងចំណោមប្រជាជនកម្ពុជា អាយុ ៥ ឆ្នាំឡើង។ នៅឆ្នាំ២០១៩ ប្រមាណ ៩,៦% នៃប្រជាជនទាំងអស់ កំពុងរស់នៅជាមួយពិការភាពយ៉ាងហោចណាស់មួយប្រភេទពិការភាពតាមកម្រិតលំបាកផ្សេងគ្នា ចាប់ពីលំបាកខ្លះទៅលំបាកធ្ងន់ធ្ងរ (ពោលគឺមិនអាចធ្វើអ្វីបានទាល់តែសោះ) ក្នុងការធ្វើសកម្មភាពជាក់លាក់។ អត្រាទូទៅនៃពិការភាព ស្រីមានភាគរយខ្ពស់ ១០,៥% ជាងប្រុស ៨,៥%។

រូប ៣.២. សមាមាត្រនៃប្រជាជន (អាយុ ៥ ឆ្នាំឡើង) មានពិការភាព តាមភេទ និងតំបន់

(%)




ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

## ៣.៦ អត្រានៅក្នុងបន្ទុក

អង្កេតកម្លាំងពលកម្មកម្ពុជាបានឲ្យនិយមន័យ "អត្រានៅក្នុងបន្ទុកតាមអាយុ" ជាសមាមាត្រនៃប្រជាជនសរុបដែលមិននៅក្នុងអាយុធ្វើការ គឺអ្នកមានអាយុ ០-១៤ ឆ្នាំ និងអ្នកមានអាយុ ៦៥ ឆ្នាំឡើង ធៀបនឹងប្រជាជនក្នុងអាយុធ្វើការ (ពោលគឺអាយុ ១៥-៦៤ ឆ្នាំ)។ អត្រានៅក្នុងបន្ទុកតាមអាយុត្រូវបានចាត់ទុកជាសូចនាករសង្ខេបមួយនៃបន្ទុកដែលទទួលខុសត្រូវដោយប្រជាជនក្នុងអាយុធ្វើការ។

ដូចបានបង្ហាញក្នុងតារាង ៣.៣ អត្រានៅក្នុងបន្ទុកសរុបនៅកម្ពុជា នៅឆ្នាំ២០១៩ មាន ៥០,៦% ហើយ ៤៥,៨% នៅតំបន់ទីប្រជុំជន និង ៥៣,១% នៅតំបន់ជនបទ។ ភាគច្រើននៃអត្រានៅក្នុងបន្ទុកនេះ គឺដោយសារប្រជាជនវ័យក្មេងអាយុតិចជាង ១៥ ឆ្នាំ (៤០,៤%)។

តារាង ៣.៣. អត្រានៅក្នុងបន្ទុក តាមតំបន់

| ក្រុមអាយុ/ អត្រានៅក្នុងបន្ទុក | កម្ពុជា | | ទីប្រជុំជន | | ជនបទ | |
|---|---|---|---|---|---|---|
| | ចំនួន | % | ចំនួន | % | ចំនួន | % |
| ០–១៤ ឆ្នាំ | ៤.២១៧.០១៨ | ២៦,៨ | ១.២៩៧.០២៥ | ២៤,៣ | ២.៩១៩.៩៩៤ | ២៨,១ |
| ១៥–៦៤ ឆ្នាំ | ១០.៤៤៩.៤២១ | ៦៦,៤ | ៣.៦៥៣.០៩៣ | ៦៨,៦ | ៦.៧៩៦.៣២៨ | ៦៥,៣ |
| ៦៥ ឆ្នាំឡើង | ១.០៦៥.២៦១ | ៦,៨ | ៣៧៦.៧៧៣ | ៧,១ | ៦៨៨.៤៨៨ | ៦,៦ |
| **សរុប** | **១៥.៧៣១.៧០១** | **១០០,០** | **៥.៣២៦.៨៩១** | **១០០,០** | **១០.៤០៤.៨១០** | **១០០,០** |
| អត្រានៅក្នុងបន្ទុកវ័យក្មេង | | ៤០,៤ | | ៣៥,៥ | | ៤៣,០ |
| អត្រានៅក្នុងបន្ទុកវ័យចាស់ | | ១០,២ | | ១០,៣ | | ១០,១ |
| អត្រានៅក្នុងបន្ទុកទាំងពីរភេទ | | ៥០,៦ | | ៤៥,៨ | | ៥៣,១ |

សម្គាល់៖ ១. សរុបអាចមិនស្មើផលបូក ដោយសារការបង្គត់លេខ។
២. ក្រឡាទទេបង្ហាញថាឈ្មោះក្នុងបង្គោលមិនអនុវត្ត។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

## ៣.៧ ប្រភពសម្រាប់ចិញ្ចឹមជីវិតរបស់គ្រួសារ

អង្កេតក៏បញ្ចូលសំណួរអំពីប្រភពរបស់គ្រួសារសម្រាប់ចិញ្ចឹមជីវិត ក្នុងរយៈពេល ១២ ខែ មុនថ្ងៃសម្ភាសន៍។ លទ្ធផលខុសគ្នារវាងការងារទាក់ទងនឹងចំណូល និងប្រភពផ្សេងៗនៃចំណូលគ្រួសារ រួមមានប្រាក់បញ្ញើ ប្រាក់ផ្ទេរ និងគ្រឿងបរិភោគដែលផលិតដោយខ្លួនឯង។

តារាង ៣.៤ បង្ហាញថាប្រមាណ ៤០,៣% នៃគ្រួសារអាចរកចំណូលពីការងារមានប្រាក់ឈ្នួល ជាប្រភពចម្បងសម្រាប់ចិញ្ចឹមជីវិត ប្រមាណ ៣២,០% បានពីកសិកម្ម ឬនេសាទគ្រួសារ ខណៈ ២១,៩% ផ្អែកលើអាជីវកម្មប្រតិបត្តិការដោយគ្រួសារក្រៅពីកសិកម្ម ឬនេសាទ។

តារាង ៣.៤. ប្រភពសម្រាប់ចិញ្ចឹមជីវិតរបស់គ្រួសារ តាមតំបន់

| ប្រភពសម្រាប់ចិញ្ចឹមជីវិត | កម្ពុជា | ទីប្រជុំជន | ជនបទ | កម្ពុជា | ទីប្រជុំជន | ជនបទ |
|---|---|---|---|---|---|---|
| | ចំនួនគ្រួសារ | | | ភាគរយនៃគ្រួសារ | | |
| ចំណូលពីការធ្វើកសិកម្ម ឬនេសាទគ្រួសារ | ១.១៩៤.៨៤២ | ៣២៤.១៦០ | ៨៧០.៦៨២ | ៣២,០ | ២៤,៨ | ៣៥,៨ |
| ចំណូលពីអាជីវកម្មគ្រួសារ (ក្រៅពីកសិកម្ម ឬនេសាទ) | ៨១៩.៤៩៥ | ៣៣២.០៦៣ | ៤៨៧.៤៣២ | ២១,៩ | ២៥,៤ | ២០,០ |
| ចំណូលពីការងារមានប្រាក់ឈ្នួល | ១.៥០៦.២៦៣ | ៦៣៨.៣២៣ | ៨៦៧.៩៤០ | ៤០,៣ | ៤៨,៩ | ៣៥,៧ |
| គ្រឿងបរិភោគផលិតដោយគ្រួសារពីការធ្វើកសិកម្ម ចិញ្ចឹមសត្វ ឬនេសាទ | ៣៤.៣៣៧ | ១.៧២៤ | ៣២.៦១៣ | ០,៩ | ០,១ | ១,៣ |
| ប្រាក់ផ្ញើពីក្រៅប្រទេស | ៣៣.៧១១ | ៣.៩៣៧ | ២៩.៧៧៤ | ០,៩ | ០,៣ | ១,២ |
| ជួយពីគ្រួសារផ្សេងនៅក្នុងប្រទេស | ១២៨.៤០៩ | ៣.២១៦ | ១២៥.១៩៣ | ៣,៤ | ០,២ | ៥,១ |
| ចំណូលពីទ្រព្យសម្បត្តិ វិនិយោគ ឬការសន្សំ | ៨.០១៩ | ១.៤១១ | ៦.៦០៨ | ០,២ | ០,១ | ០,៣ |
| សោធននិវត្តន៍ឯកជន ឬរដ្ឋ ឬឧបត្ថម្ភផ្សេងទៀតពីរដ្ឋាភិបាល | ១៣.៤៦៧ | ៥១៧ | ១២.៩៤៩ | ០,៤ | ០,០ | ០,៥ |
| សប្បុរសទានពីអង្គការមិនមែនរដ្ឋាភិបាល ឬអង្គការសង្គ្រោះផ្សេងទៀត | ៧០៩ | ៣៨៩ | ៣២១ | ០,០ | ០,០ | ០,០ |
| **សរុប** | **៣.៧៣៩.២៥២** | **១.៣០៥.៧៤១** | **២.៤៣៣.៥១២** | **១០០,០** | **១០០,០** | **១០០,០** |

សម្គាល់៖ សរុបអាចមិនស្មើផលបូក ដោយសារការបង្គត់លេខ។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

## ៣.៨ ការចូលរួមរបស់គ្រួសារក្នុងកសិកម្ម និងនេសាទ

ផ្នែកនេះរួមមានព័ត៌មានមូលដ្ឋានស្តីពីការចូលរួមរបស់គ្រួសារក្នុងសកម្មភាពកសិកម្ម និងនេសាទ ដោយឈរលើមូលដ្ឋានឯករាជ្យ ដោយមិនគិតថាតើគ្រួសារមាន ឬគ្មានដី ឬឧបករណ៍ពាក់ព័ន្ធឡើយ។ ព័ត៌មានមូលដ្ឋាននៅទីនេះរួមមាន៖ ការចូលរួមរបស់គ្រួសារក្នុងសកម្មភាពកសិកម្ម (រួមទាំងការចិញ្ចឹមសត្វ) ឬនេសាទ លើមូលដ្ឋានឯករាជ្យជាចម្បងសម្រាប់គ្រួសារប្រើប្រាស់ អត្តសញ្ញាណសមាជិកគ្រួសារចូលរួមក្នុងសកម្មភាពកសិកម្ម ឬនេសាទគ្រួសារ និងវិសាលភាពនៃការចូលរួមរបស់សមាជិកគ្រួសារក្នុងការធ្វើសេចក្តីសម្រេច ចំពោះសកម្មភាពកសិកម្ម ឬនេសាទគ្រួសារ។

មេគ្រួសារ ឬអ្នកតំណាងគ្រួសារជាអ្នកឆ្លើយក្នុងផ្នែកអង្កេតនេះ។ អង្កេតត្រូវបានអនុវត្តនៅក្នុងអំឡុងពេលដែលគ្រួសារបានចូលរួមក្នុងសកម្មភាពធ្វើកសិកម្ម និង/ឬ សកម្មភាពនេសាទ។ ក្នុងករណីផ្សេងទៀត រយៈពេលយោងត្រូវបានកែតម្រូវយោង "រដូវកាលចុងក្រោយ" ឬរយៈពេលយោង ១២ ខែ មុនថ្ងៃសម្ភាសន៍។

នៅកម្ពុជា ប្រមាណ ៣២,៩% នៃគ្រួសារ (១,២ លានគ្រួសារ) បានចូលរួមក្នុងសកម្មភាពកសិកម្ម។ ប្រមាណពីរភាគបីនៃគ្រួសារបានរាយការណ៍ថាពួកគេបានធ្វើកសិកម្មដាំដំណាំ ផ្លែឈើ ឬផលិតផលដទៃទៀត។

តារាង ៣.៥. ការចូលរួមរបស់គ្រួសារក្នុងការងារកសិកម្ម តាមសកម្មភាពចម្បង និងតំបន់

| សកម្មភាពកសិកម្ម | កម្ពុជា | ទីប្រជុំជន | ជនបទ | កម្ពុជា | ទីប្រជុំជន | ជនបទ |
|---|---|---|---|---|---|---|
| | ចំនួនគ្រួសារ | | | ភាគរយនៃគ្រួសារ | | |
| គ្រួសារទាំងអស់ | ៣.៧៣៩.២៥២ | ១.៣០៥.៧៤១ | ២.៤៣៣.៥១២ | ១០០,០ | ១០០,០ | ១០០,០ |
| គ្រួសារបានចូលរួមក្នុងកសិកម្ម [a] | ១.២២៩.១៧៩ | ៣២៥.៨៨៤ | ៩០៣.២៩៥ | ៣២,៩ | ២៥,០ | ៣៧,១ |
| | ចំនួនឆ្លើយ | | | អត្រាឆ្លើយ (%) | | |
| ធ្វើកសិកម្មដាំដំណាំ ផ្លែឈើ ឬផលិតផលផ្សេង | ២.០០៨.៧៧៧ | ៦៤៧.៩០៨ | ១.៣៦០.៨៦៩ | ៦៦,៧ | ៦៤,៧ | ៦៧,៦ |
| ចិញ្ចឹមសត្វ ឬរក្សាសត្វសម្រាប់យកសាច់ ឬផលិតផលផ្សេង | ៨៣៣.៦៨៣ | ២៩០.៥៨៨ | ៥៤៣.០៩៦ | ២៧,៧ | ២៩,០ | ២៧,០ |
| ធ្វើនេសាទ នេសាទតាមបឹង ឬរកខ្យង ខ្ចៅ គ្រុំ លៀស | ១៧១.០៨៤ | ៦២.៨៧១ | ១០៨.២១៣ | ៥,៧ | ៦,៣ | ៥,៤ |
| **សរុប** | **៣.០១៣.៥៤៤** | **១.០០១.៣៦៨** | **២.០១២.១៧៨** | **១០០,០** | **១០០,០** | **១០០,០** |

[a] សំដៅលើសកម្មភាពរបស់គ្រួសារដែលចូលរួមក្នុងអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩ ក្នុងអំឡុងឆ្នាំ២០១៩ យោងតាមការអង្កេត។
សម្គាល់៖ សរុបអាចមិនស្មើផលបូក ដោយសារការបង្គត់លេខ។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

# ជំពូក ៤
# ប្រជាជនក្នុងអាយុធ្វើការ

## ៤.១ សេចក្តីផ្តើម

ជំពូកនេះរួមមានទិន្នន័យអំពីប្រជាជនក្នុងអាយុធ្វើការ ស្ថានភាពសកម្មភាពសេដ្ឋកិច្ចបច្ចុប្បន្ន និងការចូលរួមក្នុងកម្លាំងពលកម្ម។

## ៤.២ ប្រជាជនក្នុងអាយុធ្វើការ

ប្រជាជនក្នុងអាយុធ្វើការបានប៉ាន់ស្មានប្រមាណ ១១,៥ លាននាក់ ក្នុងនោះស្រីមាន ៦,១ លាននាក់ និងប្រុសមាន ៥,៤ លាននាក់។ ប្រមាណ ៧,៥ លាននាក់នៃប្រជាជនក្នុងអាយុធ្វើការរស់នៅក្នុងតំបន់ជនបទ ខណៈ ៤,០ លាននាក់ រស់នៅក្នុងតំបន់ទីប្រជុំជន (តារាង ៤.១)។

តារាង ៤.១. ការបែងចែកប្រជាជនក្នុងអាយុធ្វើការ តាមក្រុមអាយុ ភេទ និងតំបន់
(ចំនួន)

| ក្រុមអាយុ | កម្ពុជា | | | ទីប្រជុំជន | | | ជនបទ | | |
|---|---|---|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| ១៥-២៤ | ២.៦៩២.៧៤៦ | ១.២៧៧.៩២៧ | ១.៤១៤.៨១៩ | ៨៧០.៣០៤ | ៣៩៩.៩៤៩ | ៤៧០.៣៥៥ | ១.៨២២.៤៤២ | ៨៧៧.៩៧៨ | ៩៤៤.៤៦៤ |
| ២៥-៣៤ | ២.៦៤៨.២២៣ | ១.២៨៨.៦៣៧ | ១.៣៥៩.៥៨៦ | ១.០១៣.៨៧៩ | ៤៨៦.៨៣៥ | ៥២៧.០៤៤ | ១.៦៣៤.៣៤៤ | ៨០១.៨០២ | ៨៣២.៥៤៣ |
| ៣៥-៤៤ | ២.១១៣.៣១១ | ១.០១៩.៣៣៤ | ១.០៩៣.៩៧៧ | ៧៦៤.៥១៤ | ៣៥៨.៧៤៨ | ៤០៥.៧៦៦ | ១.៣៤៨.៧៩៨ | ៦៦០.៥៨៧ | ៦៨៨.២១១ |
| ៤៥-៥៤ | ១.៦៥៨.៧១៤ | ៧៩២.៦៦៣ | ៨៦៦.០៥២ | ៥៣៨.២៤៩ | ២៥៨.០៣៤ | ២៨០.២១៦ | ១.១២០.៤៦៥ | ៥៣៤.៦២៩ | ៥៨៥.៨៣៦ |
| ៥៥-៦៤ | ១.៣៣៦.៤២៧ | ៥៩១.២៧១ | ៧៤៥.១៥៦ | ៤៦៦.១៤៧ | ២០៥.១៩១ | ២៦០.៩៥៦ | ៨៧០.២៨០ | ៣៨៦.០៨០ | ៤៨៤.២០០ |
| ៦៥+ | ១.០៦៥.២៦១ | ៤៣៣.២៧១ | ៦៣១.៩៩០ | ៣៧៦.៧៧៣ | ១៦១.៧៤២ | ២១៥.០៣១ | ៦៨៨.៤៨៨ | ២៧១.៥២៩ | ៤១៦.៩៥៩ |
| **សរុប** | **១១.៥១៤.៦៨៣** | **៥.៤០៣.១០២** | **៦.១១១.៥៨០** | **៤.០២៩.៨៦៦** | **១.៨៧០.៤៩៨** | **២.១៥៩.៣៦៨** | **៧.៤៨៤.៨១៦** | **៣.៥៣២.៦០៤** | **៣.៩៥២.២១៣** |

សម្គាល់៖ សរុបអាចមិនស្មើផលបូក ដោយសារការបង្គត់លេខ។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

យោងតាមអង្គការសហប្រជាជាតិ (UN) "មនុស្សវ័យក្មេង" សំដៅលើមនុស្សអាយុ ១៥-២៤ ឆ្នាំ និង "មនុស្សពេញវ័យ" សំដៅលើមនុស្សអាយុ ២៥ ឆ្នាំឡើងទៅ។ នៅឆ្នាំ២០១៩ ចំនួនយុវជនធ្វើការបានប៉ាន់ស្មានប្រមាណ ២,៧ លាននាក់ ខណៈចំនួនមនុស្សពេញវ័យធ្វើការមានប្រមាណ ៨,៨ លាននាក់។

ប្រមាណជា ៤៦,៤% នៃប្រជាជនធ្វើការមានអាយុពី ១៥-៣៤ ឆ្នាំ បានឆ្លុះបញ្ចាំងពីភាពលេចធ្លោខាងប្រជាសាស្ត្ររបស់ប្រជាជនវ័យក្មេង។ ទន្ទឹមនេះ មានតែ ៩,៣% នៃប្រជាជនធ្វើការត្រូវបានសង្កេតឃើញថាមានអាយុយ៉ាងហោចណាស់ ៦៥ ឆ្នាំ (រូប ៤.១)។

រូប ៤.១. ការបែងចែកប្រជាជនក្នុងអាយុធ្វើការ តាមក្រុមអាយុ និងភេទ
(%)




សម្គាល់៖ ភាគរយអាចមិនស្មើសរុប ១០០% ដោយសារការបង្គត់លេខ។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

## ៤.៣ ស្ថានភាពទីផ្សារការងារ

តារាង ៤.២ បង្ហាញការបែងចែកប្រជាជនក្នុងអាយុធ្វើការ តាមស្ថានភាពទីផ្សារការងារ ទោះបីពួកគេមានការងារធ្វើ គ្មានការងារធ្វើ ឬនៅក្រៅកម្លាំងពលកម្ម (ពោលគឺអសកម្មសេដ្ឋកិច្ច)។ ក្នុងចំណោមប្រជាជនទាំងនេះ ប្រមាណ ៦៨,៥% (ឬ ៧,៩ លាននាក់) ត្រូវបានចាត់ថ្នាក់ជាអ្នកមានការងារធ្វើ ប្រមាណ ០,៨% (ឬ ៩៧.៦៨៧ នាក់) ជាអ្នកគ្មានការងារធ្វើ និង ៣០,៧% (ឬ ៣,៥ លាននាក់) ជាអ្នកនៅក្រៅកម្លាំងពលកម្ម នៅពេលធ្វើអង្កេត។

តារាង ៤.២. ការបែងចែកប្រជាជនក្នុងអាយុធ្វើការ តាមស្ថានភាពទីផ្សារការងារ និងភេទ
(ចំនួន)

| ស្ថានភាពទីផ្សារការងារ | ទាំងពីរភេទ | ប្រុស | ស្រី |
|---|---|---|---|
| មានការងារធ្វើ | ៧.៨៨៣.១០៦ | ៤.១១៧.៤៦៤ | ៣.៧៦៥.៦៤១ |
| គ្មានការងារធ្វើ | ៩៧.៦៨៧ | ៥១.៤៥៨ | ៤៦.២២៩ |
| **កម្លាំងពលកម្មសរុប** | **៧.៩៨០.៧៩៣** | **៤.១៦៨.៩២២** | **៣.៨១១.៨៧០** |
| នៅក្រៅកម្លាំងពលកម្ម (អសកម្មសេដ្ឋកិច្ច) | ៣.៥៣៣.៨៩០ | ១.២៣៤.១៧៩ | ២.២៩៩.៧១១ |
| **ប្រជាជនក្នុងអាយុធ្វើការ** | **១១.៥១៤.៦៨៣** | **៥.៤០៣.១០២** | **៦.១១១.៥៨០** |

សម្គាល់៖ សរុបអាចមិនស្មើផលបូក ដោយសារការបង្គត់លេខ។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

រូប ៤.២ បង្ហាញថាប្រជាជនវ័យក្មេងអាយុ ១៥-២៤ ឆ្នាំ មាន ២៣,៤ % នៃប្រជាជនក្នុងអាយុធ្វើការ នៅឆ្នាំ ២០១៩ ប៉ុន្តែមានតែ ១៩,៣% នៃកម្លាំងពលកម្មប៉ុណ្ណោះ។ ម្យ៉ាងទៀត អ្នកអាយុ ២៥-៣៤ ឆ្នាំ មាន ២៣,០% នៃប្រជាជនក្នុងអាយុធ្វើការ ប៉ុន្តែមាន ២៨,៦% នៃកម្លាំងពលកម្ម។ លំនាំដូចគ្នានេះក៏ត្រូវបានសង្កេតឃើញក្នុងចំណោមអ្នកមានអាយុ ៣៥-៤៤ ឆ្នាំ និង ៤៥-៥៤ ឆ្នាំ។ ចំពោះក្រុមអាយុចាស់ជាងគេ (អាយុ ៦៥ ឆ្នាំឡើង) មានចំណែកតិចជាងគេទាំងប្រជាជនក្នុងអាយុធ្វើការ (៩,៣%) និងកម្លាំងពលកម្ម (៣,៨%)។

ថ្វីបើក្រុមអាយុ ១៥-២៤ ឆ្នាំ មាន ១៩,៣% នៃកម្លាំងពលកម្ម ក៏មានតែ ១៩,១% នៃអ្នកមានការងារធ្វើ និង ៣៩,៨% នៃអ្នកគ្មានការងារធ្វើ។ ម្យ៉ាងទៀត អ្នកមានអាយុ ៤៥ ឆ្នាំឡើង មានចំណែកតិចនៃកម្លាំងពលកម្ម ប៉ុន្តែមានចំណែកខ្ពស់នៃអ្នកមានការងារធ្វើ និងចំណែកតូចជាងនៃអ្នកគ្មានការងារធ្វើ។

រូប ៤.២. ការបែងចែកប្រជាជនក្នុងអាយុធ្វើការ តាមស្ថានភាពទីផ្សារការងារ និងក្រុមអាយុ
(%)




សម្គាល់៖ ភាគរយអាចមិនស្មើសរុប ១០០% ដោយសារការបង្គត់លេខ។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

តារាង ៤.៣ បង្ហាញការបែងចែកប្រជាជនក្នុងអាយុធ្វើការ តាមស្ថានភាពទីផ្សារការងារ កម្រិតសិក្សា និងភេទ។ ក្នុងចំណោមប្រជាជនមានការងារធ្វើនៅឆ្នាំ២០១៩ ប្រមាណ ៣៨,១% នៃអ្នកមានការងារធ្វើ បានបញ្ចប់បឋមសិក្សា ២៥,១% បានបញ្ចប់មធ្យមសិក្សាបឋមភូមិ/អនុវិទ្យាល័យ និង ១៥,៧% បានបញ្ចប់មធ្យមសិក្សាទុតិយភូមិ/វិទ្យាល័យ។ មានតែ ៦,៦% បានបញ្ចប់សាកលវិទ្យាល័យ និង ០,៤% បានទទួលវិញ្ញាបនប័ត្រវិជ្ជាជីវៈ។ ទន្ទឹមនេះ ប្រមាណ ១០,៨% នៃប្រជាជនមានការងារធ្វើមិនដែលបានរៀន។ សមាមាត្រនៃអ្នកមានការងារធ្វើបានបញ្ចប់បឋមសិក្សាសម្រាប់ស្រីខ្ពស់ (៣៩,១%) ជាងប្រុស (៣៧,២%) ប៉ុន្តែលំនាំដូចគ្នានេះបានបញ្រ្ចាសគ្នាវិញសម្រាប់កម្រិតឧត្តមសិក្សា។

ក្នុងចំណោមអ្នកគ្មានការងារធ្វើ ប្រមាណ ២៦,៧% បានបញ្ចប់បឋមសិក្សា ប្រមាណ ៥៧,០% បានបញ្ចប់មធ្យមសិក្សា និង ៦,៧% បានបញ្ចប់មហាវិទ្យាល័យ។ សមាមាត្រនៃអ្នកគ្មានការងារធ្វើដែលបានបញ្ចប់បឋមសិក្សាសម្រាប់ស្រីខ្ពស់ (២៩,៤%) ជាងប្រុស (២៤,៣%) ហើយលំនាំដូចគ្នានេះបានបញ្រ្ចាសគ្នាវិញសម្រាប់កម្រិតឧត្តមសិក្សា។

តារាង ៤.៣. ការបែងចែកប្រជាជនក្នុងអាយុធ្វើការ តាមស្ថានភាពទីផ្សារការងារ កម្រិតសិក្សា និងភេទ

| កម្រិតសិក្សា | ប្រជាជនក្នុងអាយុធ្វើការ | មានការងារធ្វើ | គ្មានការងារធ្វើ | កម្លាំងពលកម្ម | នៅក្រៅកម្លាំងពលកម្ម |
|---|---|---|---|---|---|
| **ទាំងពីរភេទ** | | | | | |
| ប្រជាជន (ចំនួន) | ១១.៥១៤.៦៨៣ | ៧.៨៨៣.១០៦ | ៩៧.៦៨៧ | ៧.៩៨០.៧៩៣ | ៣.៥៣៣.៨៩០ |
| មិនដែលបានរៀន (%) | ១៣,៥ | ១០,៨ | ៧,០ | ១០,៨ | ១៩,៨ |
| មត្តេយ្យសិក្សា (%) | ៣,៣ | ៣,៣ | ២,៦ | ៣,៣ | ៣,២ |
| បឋមសិក្សា (%) | ៣៦,១ | ៣៨,១ | ២៦,៧ | ៣៨,០ | ៣១,៩ |
| មធ្យមសិក្សាបឋមភូមិ (%) | ២៤,១ | ២៥,១ | ២៤,៨ | ២៥,១ | ២១,៨ |
| មធ្យមសិក្សាទុតិយភូមិ (%) | ១៦,៤ | ១៥,៧ | ៣២,២ | ១៥,៩ | ១៧,៤ |
| បច្ចេកទេស/វិជ្ជាជីវៈ (%) | ០,៤ | ០,៤ | ០,០ | ០,៤ | ០,៣ |
| ឧត្តមសិក្សា (%) | ៦,៣ | ៦,៦ | ៦,៧ | ៦,៦ | ៥,៦ |
| **សរុប (%)** | **១០០,០** | **១០០,០** | **១០០,០** | **១០០,០** | **១០០,០** |
| **ប្រុស** | | | | | |
| ប្រជាជន (ចំនួន) | ៥.៤០៣.១០២ | ៤.១១៧.៤៦៤ | ៥១.៤៥៨ | ៤.១៦៨.៩២២ | ១.២៣៤.១៧៩ |
| មិនដែលបានរៀន (%) | ៩,៦ | ៨,៧ | ៧,៤ | ៨,៧ | ១២,៨ |
| មត្តេយ្យសិក្សា (%) | ២,៨ | ៣,០ | ១,៨ | ៣,០ | ២,៣ |
| បឋមសិក្សា (%) | ៣៥,៤ | ៣៧,២ | ២៤,៣ | ៣៧,០ | ៣០,២ |
| មធ្យមសិក្សាបឋមភូមិ (%) | ២៦,០ | ២៦,១ | ២២,៨ | ២៦,១ | ២៥,៩ |
| មធ្យមសិក្សាទុតិយភូមិ (%) | ១៨,៤ | ១៧,២ | ៣៦,៧ | ១៧,៥ | ២១,៦ |
| បច្ចេកទេស/វិជ្ជាជីវៈ (%) | ០,៤ | ០,៥ | ០,០ | ០,៤ | ០,២ |
| ឧត្តមសិក្សា (%) | ៧,៣ | ៧,៤ | ៧,០ | ៧,៤ | ៦,៩ |
| **សរុប (%)** | **១០០,០** | **១០០,០** | **១០០,០** | **១០០,០** | **១០០,០** |
| **ស្រី** | | | | | |
| ប្រជាជន (ចំនួន) | ៦.១១១.៥៨០ | ៣.៧៦៥.៦៤១ | ៤៦.២២៩ | ៣.៨១១.៨៧០ | ២.២៩៩.៧១១ |
| មិនដែលបានរៀន (%) | ១៧,០ | ១៣,១ | ៦,៥ | ១៣,១ | ២៣,៦ |
| មត្តេយ្យសិក្សា (%) | ៣,៧ | ៣,៧ | ៣,៥ | ៣,៧ | ៣,៧ |
| បឋមសិក្សា (%) | ៣៦,៧ | ៣៩,១ | ២៩,៤ | ៣៩,០ | ៣២,៨ |
| មធ្យមសិក្សាបឋមភូមិ (%) | ២២,៣ | ២៣,៩ | ២៧,១ | ២៤,០ | ១៩,៦ |
| មធ្យមសិក្សាទុតិយភូមិ (%) | ១៤,៦ | ១៤,១ | ២៧,២ | ១៤,២ | ១៥,១ |
| បច្ចេកទេស/វិជ្ជាជីវៈ (%) | ០,៣ | ០,៣ | ០,០ | ០,៣ | ០,៤ |
| ឧត្តមសិក្សា (%) | ៥,៥ | ៥,៨ | ៦,៤ | ៥,៨ | ៤,៩ |
| **សរុប (%)** | **១០០,០** | **១០០,០** | **១០០,០** | **១០០,០** | **១០០,០** |

សម្គាល់៖ សរុបអាចមិនស្មើផលបូក ដោយសារការបង្គត់លេខ។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

## ៤.៤ ការចូលរួមក្នុងកម្លាំងពលកម្ម

អត្រាចូលរួមក្នុងកម្លាំងពលកម្មវាស់វែងនូវសមាមាត្រនៃប្រជាជនសកម្មសេដ្ឋកិច្ច ធៀបនឹងប្រជាជនក្នុងអាយុធ្វើការទាំងអស់ ហើយបង្ហាញជាភាគរយ។ អត្រាចូលរួមក្នុងកម្លាំងពលកម្មទាបបង្ហាញថា សមាមាត្រតិចនៃប្រជាជនក្នុងអាយុធ្វើការចូលរួមជាក់ស្តែងក្នុងទីផ្សារការងារ។

តារាង ៤.៤ បង្ហាញអត្រាចូលរួមក្នុងកម្លាំងពលកម្ម តាមក្រុមអាយុ ភេទ និងតំបន់។ នៅឆ្នាំ២០១៩ អត្រាចូលរួមក្នុងកម្លាំងពលកម្មសរុប បានប៉ាន់ស្មានប្រមាណ ៦៩,៣% ហើយប្រុសមានអត្រានេះខ្ពស់ (៧៧,២%) ជាងស្រី (៦២,៤%)។ លំនាំដូចគ្នានេះត្រូវបានសង្កេតឃើញទាំងនៅតំបន់ជនបទ និងទីប្រជុំជន។ អត្រាចូលរួមក្នុងកម្លាំងពលកម្មនៅតំបន់ជនបទ (៧០,២%) ខ្ពស់ជាងនៅតំបន់ទីប្រជុំជន (៦៧,៧%)។ នៅតំបន់ទីប្រជុំជន អត្រាចូលរួមក្នុងកម្លាំងពលកម្មសម្រាប់ទាំងប្រុស និងស្រីបានកើនឡើងនៅអាយុ ៣០-៣៤ ឆ្នាំ ខណៈនៅតំបន់ជនបទ អត្រាចូលរួមក្នុងកម្លាំងពលកម្មបានកើនឡើងខ្ពស់នៅអាយុ ៣៥-៣៩ ឆ្នាំ សម្រាប់ប្រុស និងអាយុ ៣០-៣៤ ឆ្នាំ សម្រាប់ស្រី។

## តារាង ៤.៤. អត្រាចូលរួមក្នុងកម្លាំងពលកម្ម តាមក្រុមអាយុ ភេទ និងតំបន់

(%)

| ក្រុមអាយុ | កម្ពុជា | | | ទីប្រជុំជន | | | ជនបទ | | |
|---|---|---|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| ១៥–១៩ | ៤០,១ | ៤២,១ | ៣៨,៣ | ២៩,២ | ២៩,៥ | ២៨,៩ | ៤៤,៩ | ៤៧,៥ | ៤២,៥ |
| ២០–២៤ | ៧៦,៣ | ៧៨,៥ | ៧៤,៤ | ៦៩,៥ | ៦៩,៧ | ៦៩,៣ | ៧៩,៩ | ៨២,៨ | ៧៧,៣ |
| ២៥–២៩ | ៨៥,៣ | ៩២,០ | ៧៨,៩ | ៨៤,៩ | ៩០,៦ | ៧៩,៨ | ៨៥,៥ | ៩២,៨ | ៧៨,៣ |
| ៣០–៣៤ | ៨៦,៩ | ៩២,៩ | ៨១,២ | ៨៨,៣ | ៩៥,១ | ៨១,៩ | ៨៥,៩ | ៩១,៥ | ៨០,៧ |
| ៣៥–៣៩ | ៨៦,២ | ៩៣,៨ | ៧៨,៩ | ៨៥,៩ | ៩៥,០ | ៧៧,៩ | ៨៦,៤ | ៩៣,១ | ៧៩,៥ |
| ៤០–៤៤ | ៨៣,៦ | ៩១,៤ | ៧៦,៨ | ៨៣,៤ | ៩៣,៨ | ៧៤,០ | ៨៣,៧ | ៩០,២ | ៧៨,១ |
| ៤៥–៤៩ | ៧៨,៤ | ៨៩,៧ | ៦៨,៣ | ៧៨,៥ | ៩៥,៧ | ៦២,៧ | ៧៨,៤ | ៨៦,៨ | ៧០,៩ |
| ៥០–៥៤ | ៧៤,២ | ៨៥,២ | ៦៣,៩ | ៧៣,៦ | ៨៨,៥ | ៥៩,៩ | ៧៤,៤ | ៨៣,៦ | ៦៥,៨ |
| ៥៥–៥៩ | ៦៤,៥ | ៧៧,៧ | ៥៣,២ | ៦៣,៦ | ៨០,៧ | ៤៨,៩ | ៦៤,៩ | ៧៦,២ | ៥៥,៤ |
| ៦០–៦៤ | ៥២,៣ | ៦៣,៥ | ៤៤,២ | ៤៥,៩ | ៥៧,១ | ៣៨,០ | ៥៦,០ | ៦៧,០ | ៤៧,៩ |
| ៦៥+ | ២៨,៥ | ៣៦,៧ | ២២,៩ | ២៧,៣ | ៣៦,៧ | ២០,២ | ២៩,១ | ៣៦,៧ | ២៤,៣ |
| **សរុប** | **៦៩,៣** | **៧៧,២** | **៦២,៤** | **៦៧,៧** | **៧៦,៤** | **៦០,២** | **៧០,២** | **៧៧,៦** | **៦៣,៦** |

ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

នៅឆ្នាំ២០១៩ អត្រាចូលរួមក្នុងកម្លាំងពលកម្មថ្នាក់ជាតិ បានកើនឡើងនៅអាយុ ៣០-៣៤ ឆ្នាំ ហើយបានចាប់ផ្តើមធ្លាក់ចុះសម្រាប់ប្រជាជនវ័យចំណាស់។ លំនាំស្រដៀងគ្នានេះ បានសង្កេតឃើញសម្រាប់អត្រាចូលរួមក្នុងកម្លាំងពលកម្មរបស់ស្រីបានកើនឡើងខ្ពស់ខ្លាំងនៅអាយុ ៣០-៣៤ ឆ្នាំ មាន ៨១,២% ហើយបន្ទាប់មកបានធ្លាក់ចុះបន្តិចម្តងៗ រហូតដល់ ២២,៩% នៅអាយុ ៦៥ ឆ្នាំឡើង។ ម្យ៉ាងទៀត អត្រាចូលរួមក្នុងកម្លាំងពលកម្មរបស់ប្រុស បានកើនឡើងខ្ពស់នៅអាយុ ៣៥-៣៩ ឆ្នាំ មាន ៩៣,៨% និងធ្លាក់ចុះមក ៣៦,៧% នៅអាយុ ៦៥ ឆ្នាំឡើង (រូប ៤.៣)។

## រូប ៤.៣. អត្រាចូលរួមក្នុងកម្លាំងពលកម្ម តាមក្រុមអាយុ និងភេទ

(%)




ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

## ៤.៥ ការងារផលិតកម្មសម្រាប់ចិញ្ចឹមជីវិត

មួយនៃការរួមចំណែកដ៏សំខាន់បំផុតក្នុងសន្និសីទអន្តរជាតិនៃអ្នកស្ថិតិកម្លាំងពលកម្មលើកទី១៩ នៅឆ្នាំ២០១៣ បានបង្ហាញស្ថិតិស្តីពីអ្នកផលិតគ្រឿងបរិភោគសម្រាប់ចិញ្ចឹមជីវិត។ ផ្នែកនេះបង្ហាញទិន្នន័យអំពីអ្នកចូលរួមក្នុងការងារផលិតកម្មសម្រាប់ចិញ្ចឹមជីវិត និងអ្នកផលិតគ្រឿងបរិភោគសម្រាប់ចិញ្ចឹមជីវិត។

ផលិតកម្មសម្រាប់ចិញ្ចឹមជីវិតរួមមានសកម្មភាពណាមួយ ដើម្បីផលិតទំនិញ ឬផ្តល់សេវាកម្មសម្រាប់ការប្រើប្រាស់ចុងក្រោយខ្លួនឯង ដោយក្រុមគ្រួសារ ឬគ្រួសារ។ វារួមមាន៖

(i) ការផលិត និង/ឬ ដំណើរការសម្រាប់ការផ្ទុកផលិតផលកសិកម្ម នេសាទ ប្រមាញ់ និងប្រមូលផ្តុំ

(ii) ការប្រមូលអាហារពីព្រៃ ដូចជាផ្សិត ផ្លែឈើ និងតិណជាតិ

(iii) ការបរបាញ់សត្វព្រៃ ។ល។

(iv) ការធ្វើអាហារ ឬភេសជ្ជៈបម្រុងទុកសម្រាប់ផ្ទុក ដូចជាម្សៅ និងត្រីងៀត

(v) ការសាងសង់ ជួសជុលកែលម្អ ឬពង្រីកគេហដ្ឋាន អាគារកសិកម្មខ្លួនឯង ។ល។

(vi) ការច្នៃប្រឌិតទំនិញ ដូចជាកន្ទេល កន្ត្រក គ្រឿងសង្ហារឹម និងសម្លៀកបំពាក់

(vii) ការទៅយកទឹកពីប្រភពធម្មជាតិ ឬសាធារណៈ និង

(viii) ការប្រមូលឧស ឬផលិតផលធម្មជាតិដទៃទៀតសម្រាប់ប្រើជាឥន្ធនៈ។

អ្នកផលិតគ្រឿងអាហារសម្រាប់ចិញ្ចឹមជីវិតបង្កើតបានអនុក្រុមមនុស្សដ៏សំខាន់មួយនៅក្នុងការងារផលិតកម្មប្រើប្រាស់ខ្លួនឯង។ ពួកគេត្រូវបានកំណត់ជា៖

(i) មនុស្សទាំងឡាយដែលធ្វើសកម្មភាពណាមួយ ដូចជាផលិត និង/ឬ កែច្នៃសម្រាប់ស្តុក ផលិតផលពីកសិកម្ម នេសាទ ប្រមាញ់ និងប្រមូលផ្តុំ ជាគ្រឿងបរិភោគសម្រាប់ជីវភាពក្រុមគ្រួសារ ឬគ្រួសារ

(ii) ប៉ុន្តែមិនរាប់បញ្ចូលអ្នកដែលចូលរួមក្នុងការផលិតបែបនេះ សម្រាប់ជាការកម្សាន្ត ឬលំហែរឡើយ។

សូមកត់សម្គាល់ថា អ្នកផលិតទំនិញសម្រាប់ប្រើប្រាស់ខ្លួនឯងត្រូវបានដាក់បញ្ចូលក្នុងបញ្ជីសំណួរ និងមិនរាប់បញ្ចូលអ្នកនៅក្នុងការងារថែទាំគ្មានប្រាក់ឈ្នួលឡើយ។ ក្នុងអង្កេតនាពេលអនាគត សេវាកម្មដូចជាការថែទាំគ្រួសារគ្មានប្រាក់ឈ្នួលអាចត្រូវបានរាប់បញ្ចូលផងដែរ។

តារាង ៤.៥ បង្ហាញថាការប៉ាន់ស្មានប្រមាណ ៣.៩៨០.៤៦៦ នាក់ (៣៤,៦%) នៃមនុស្សអាយុ ១៥ ឆ្នាំឡើង បានចូលរួមក្នុងផលិតកម្មសម្រាប់ចិញ្ចឹមជីវិតក្នុងរយៈពេល ៧ ថ្ងៃ មុនសម្ភាសន៍។ ស្រីបានចូលរួមក្នុងផលិតកម្មសម្រាប់ចិញ្ចឹមជីវិតច្រើនជាងប្រុស (ស្រី ៣៦,៧% ទល់នឹងប្រុស ៣២,១%)។ អ្នកមានអាយុ ២៥-៦៤ ឆ្នាំ មានចំណែកខ្ពស់ខ្លាំង (៨០,០%) នៃប្រជាជនក្នុងអាយុធ្វើការបានចូលរួមក្នុងផលិតកម្មសម្រាប់ចិញ្ចឹមជីវិត យុវជនអាយុ ១៥-២៤ ឆ្នាំ មានចំណែកទាបជាង (១១,៦%) និងមានចំណែកទាបជាងគេ (៨,៤%) ចំពោះអ្នកមានអាយុ ៦៥ ឆ្នាំឡើង។

តាមស្ថានភាពទីផ្សារការងារ ចំណែកធំជាងគេនៃពួកគេបានចូលរួមក្នុងផលិតកម្មសម្រាប់ចិញ្ចឹមជីវិត គឺអ្នកមានការងារធ្វើ (៦៩,៩%) បន្ទាប់មកអ្នកនៅក្រៅកម្លាំងពលកម្ម (២៩,០%) និងអ្នកគ្មានការងារធ្វើ (១,១%)។ សូមកត់សម្គាល់ថា ក្នុងចំណោមអ្នកនៅក្រៅកម្លាំងពលកម្ម ស្រី (៣៥,៤%) មានច្រើនជាងប្រុស (២០,៧%) បានចូលរួមក្នុងផលិតកម្មសម្រាប់ចិញ្ចឹមជីវិត។ លំនាំដូចគ្នានេះត្រូវបានសង្កេតឃើញក្នុងចំណោមអ្នកផលិតគ្រឿងបរិភោគសម្រាប់ចិញ្ចឹមជីវិត។

## តារាង ៤.៥. ការចូលរួមក្នុងផលិតកម្មសម្រាប់ចិញ្ចឹមជីវិត តាមក្រុមអាយុ ស្ថានភាពទីផ្សារការងារ ភេទ និងតំបន់

| ប្រភេទ | កម្ពុជា | | | ទីប្រជុំជន | | | ជនបទ | | |
|---|---|---|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| **ផលិតកម្មសម្រាប់ចិញ្ចឹមជីវិតសរុប ដោយប្រជាជនក្នុងអាយុធ្វើការ** | | | | | | | | | |
| អ្នកផលិតសម្រាប់ចិញ្ចឹមជីវិត ដោយប្រជាជនក្នុងអាយុធ្វើការ (ចំនួន) | ៣.៩៨០.៤៦៦ | ១.៧៣៤.៦៩៥ | ២.២៤៥.៧៧១ | ៦១៧.០៨១ | ២៤៩.៩២២ | ៣៦៧.១៥៩ | ៣.៣៦៣.៣៨៤ | ១.៤៨៤.៧៧២ | ១.៨៧៨.៦១២ |
| សមាមាត្រនៃប្រជាជនក្នុងអាយុធ្វើការ ( %) | ៣៤,៦ | ៣២,១ | ៣៦,៧ | ១៥,៣ | ១៣,៤ | ១៧,០ | ៤៤,៩ | ៤២,០ | ៤៧,៥ |
| តាមក្រុមអាយុ (%) | | | | | | | | | |
| ១៥–២៤ | ១១,៦ | ១២,២ | ១១,២ | ៨,៣ | ៨,៥ | ៨,១ | ១២,២ | ១២,៨ | ១១,៨ |
| ២៥–៦៤ | ៨០,០ | ៧៩,៧ | ៨០,២ | ៨២,២ | ៨០,៧ | ៨៣,២ | ៧៩,៦ | ៧៩,៦ | ៧៩,៦ |
| ៦៥+ | ៨,៤ | ៨,១ | ៨,៦ | ៩,៥ | ១០,៧ | ៨,៧ | ៨,២ | ៧,៦ | ៨,៦ |
| តាមស្ថានភាពទីផ្សារការងារ (%) | | | | | | | | | |
| មានការងារធ្វើ | ៦៩,៩ | ៧៧,៧ | ៦៣,៨ | ៦៨,៧ | ៧៨,៥ | ៦២,១ | ៧០,១ | ៧៧,៦ | ៦៤,១ |
| គ្មានការងារធ្វើ | ១,១ | ១,៥ | ០,៨ | ០,៨ | ១,១ | ០,៥ | ១,២ | ១,៦ | ០,៩ |
| នៅក្រៅកម្លាំងពលកម្ម | ២៩,០ | ២០,៧ | ៣៥,៤ | ៣០,៥ | ២០,៤ | ៣៧,៤ | ២៨,៧ | ២០,៨ | ៣៥,០ |
| **ផលិតកម្មសម្រាប់ចិញ្ចឹមជីវិត ដោយប្រជាជនក្នុងអាយុធ្វើការ មិនធ្វើការងារ** | | | | | | | | | |
| អ្នកផលិតសម្រាប់ចិញ្ចឹមជីវិតដោយប្រជាជនក្នុងអាយុធ្វើការ មិនធ្វើការងារ (ចំនួន) | ១.១៩៩.០៩៧ | ៣៨៦.០៥១ | ៨១៣.០៤៦ | ១៩៣.០០៧ | ៥៣.៦៧៣ | ១៣៩.៣៣៤ | ១.០០៦.០៩០ | ៣៣២.៣៧៨ | ៦៧៣.៧១២ |
| សមាមាត្រនៃប្រជាជនក្នុងអាយុធ្វើការ (%) | ៣៣,០ | ៣០,០ | ៣៤,៧ | ១៤,៥ | ១១,៨ | ១៦,០ | ៤៣,៧ | ៤០,០ | ៤៥,៧ |
| តាមក្រុមអាយុ (%) | | | | | | | | | |
| ១៥–២៤ | ១៥,១ | ១៨,២ | ១៣,៦ | ១២,៨ | ១៧,៨ | ១០,៩ | ១៥,៥ | ១៨,២ | ១៤,២ |
| ២៥–៦៤ | ៧០,១ | ៦៥,១ | ៧២,៥ | ៧១,៧ | ៦១,៦ | ៧៥,៦ | ៦៩,៨ | ៦៥,៦ | ៧១,៩ |
| ៦៥+ | ១៤,៨ | ១៦,៨ | ១៣,៨ | ១៥,៤ | ២០,៥ | ១៣,៥ | ១៤,៧ | ១៦,២ | ១៣,៩ |
| **អ្នកផលិតគ្រឿងបរិភោគដោយប្រជាជនក្នុងអាយុធ្វើការ សម្រាប់ចិញ្ចឹមជីវិត** | | | | | | | | | |
| អ្នកផលិតគ្រឿងបរិភោគសម្រាប់ចិញ្ចឹមជីវិត(ចំនួន) | ៣.៥១៨.៧០៥ | ១.៤៣៨.៦១០ | ២.០៨០.០៩៥ | ៥៣៧.៣៨៤ | ២០៩.២២១ | ៣២៨.១៦៣ | ២.៩៨១.៣២១ | ១.២២៩.៣៨៨ | ១.៧៥១.៩៣៣ |
| សមាមាត្រនៃប្រជាជនក្នុងអាយុធ្វើការ (%) | ៣០,៦ | ២៦,៦ | ៣៤,០ | ១៣,៣ | ១១,២ | ១៥,២ | ៣៩,៨ | ៣៤,៨ | ៤៤,៣ |
| តាមក្រុមអាយុ (%) | | | | | | | | | |
| ១៥–២៤ | ១០,៤ | ១១,០ | ៩,៩ | ៧,៣ | ៨,២ | ៦,៨ | ១០,៩ | ១១,៥ | ១០,៥ |
| ២៥–៦៤ | ៨១,១ | ៨០,៨ | ៨១,៤ | ៨២,៥ | ៨០,០ | ៨៤,១ | ៨០,៩ | ៨០,៩ | ៨០,៩ |
| ៦៥+ | ៨,៥ | ៨,២ | ៨,៧ | ១០,១ | ១១,៨ | ៩,១ | ៨,២ | ៧,៦ | ៨,៦ |
| តាមស្ថានភាពទីផ្សារការងារ (%) | | | | | | | | | |
| មានការងារធ្វើ | ៦៩,៤ | ៧៧,១ | ៦៤,១ | ៦៧,៥ | ៧៦,៦ | ៦១,៧ | ៦៩,៨ | ៧៧,២ | ៦៤,៦ |
| គ្មានការងារធ្វើ | ១,០ | ១,២ | ០,៨ | ០,៧ | ១,១ | ០,៥ | ១,០ | ១,២ | ០,៨ |
| នៅក្រៅកម្លាំងពលកម្ម | ២៩,៦ | ២១,៧ | ៣៥,១ | ៣១,៧ | ២២,៣ | ៣៧,៨ | ២៩,២ | ២១,៦ | ៣៤,៦ |

សម្គាល់៖ សរុបអាចមិនស្មើផលបូក ដោយសារការបង្គត់លេខ។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

# ជំពូក ៥
# ភាពមានការងារធ្វើ

## ៥.១ សេចក្តីផ្តើម

ទិន្នន័យភាពមានការងារធ្វើផ្តល់នូវសូចនាករសេដ្ឋកិច្ចសង្គមដ៏សំខាន់ សម្រាប់ការយល់ដឹងអំពីសេដ្ឋកិច្ចរបស់កម្ពុជា។ លើសពីនេះទៀត ស្ថិតិភាពមានការងារធ្វើបានរកឃើញនូវចំនួនប្រជាជនដែលបានធ្វើការ ប្រភេទការងារដែលពួកគេបានធ្វើ គុណវុឌ្ឍិរបស់ពួកគេសម្រាប់ការងារ និងលំនាំធ្វើការរបស់ពួកគេ។

ជំពូកនេះបង្ហាញព័ត៌មានអំពីចរិតលក្ខណៈប្រជាជនមានការងារធ្វើ ដូចជាមុខរបរ និងសកម្មភាពសេដ្ឋកិច្ចដែលមនុស្សធ្វើ កម្រិតសិក្សារបស់ពួកគេ ស្ថានភាពការងាររបស់ពួកគេ និងអត្រាអ្នកមានការងារធ្វើធៀបនឹងប្រជាជនក្នុងអាយុធ្វើការទូទៅ។

## ៥.២ ប្រជាជនមានការងារធ្វើ

តារាង ៥.១ បង្ហាញការបែងចែកចំនួន និងភាគរយនៃប្រជាជនមានការងារធ្វើ តាមក្រុមអាយុ តំបន់ និងភេទ។ ប្រជាជនមានការងារធ្វើត្រូវបានប៉ាន់ស្មានប្រមាណ ៧.៨៨៣.១០៦ នាក់ ក្នុងនោះ ៥២,២% ជាប្រុស និង ៤៧,៨% ជាស្រី។ ភាគច្រើននៃប្រជាជនមានការងារធ្វើបានរកឃើញនៅតំបន់ជនបទ មានប្រមាណ ៦៥,៧% ខណៈ ៣៤,៣% នៃប្រជាជនមានការងារធ្វើបានរកឃើញនៅតំបន់ទីប្រជុំជន។ ជារួម ប្រុសមានចំនួនច្រើនជាងក្នុងប្រជាជនមានការងារធ្វើ ទាំងនៅតំបន់ទីប្រជុំជន (៥២,៤%) និងនៅតំបន់ជនបទ (៥២,២%)។ ម៉្យាងទៀត ភាគច្រើននៃប្រជាជនមានការងារធ្វើ ទាំងនៅតំបន់ទីប្រជុំជន និងតំបន់ជនបទ ក្នុងក្រុមអាយុ ១៥-២៤ ឆ្នាំ ជាស្រី។

ជាងពាក់កណ្តាលនៃប្រជាជនមានការងារធ្វើមានអាយុ ២០-៣៩ ឆ្នាំ។ ក្រុមអាយុក្មេង (១៥-១៩ ឆ្នាំ) មាន ៧,០% និងអ្នកមានអាយុ ៦០ ឆ្នាំឡើង មាន ៧,៧%។

តារាង ៥.១. ការបែងចែកប្រជាជនមានការងារធ្វើ តាមក្រុមអាយុ តំបន់ និងភេទ

(%)

| ក្រុមអាយុ | កម្ពុជា | | | ទីប្រជុំជន | | | ជនបទ | | |
|---|---|---|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| ១៥–១៩ | ៧,០ | ៦,៧ | ៧,៣ | ៤,៥ | ៤,០ | ៥,១ | ៨,៣ | ៨,១ | ៨,៥ |
| ២០–២៤ | ១២,១ | ១១,១ | ១៣,១ | ១០,៩ | ៩,៣ | ១២,៦ | ១២,៧ | ១២,១ | ១៣,៣ |
| ២៥–២៩ | ១៤,៥ | ១៤,៦ | ១៤,៤ | ១៥,៩ | ១៥,៣ | ១៦,៦ | ១៣,៨ | ១៤,៣ | ១៣,៣ |
| ៣០–៣៤ | ១៤,០ | ១៣,៩ | ១៤,១ | ១៦,៣ | ១៦,៤ | ១៦,២ | ១២,៨ | ១២,៦ | ១៣,១ |
| ៣៥–៣៩ | ១៤,០ | ១៤,៣ | ១៣,៧ | ១៥,៥ | ១៥,២ | ១៥,៧ | ១៣,២ | ១៣,៨ | ១២,៦ |
| ៤០–៤៤ | ៨,៦ | ៨,៥ | ៨,៨ | ៨,៥ | ៨,៧ | ៨,៣ | ៨,៧ | ៨,៤ | ៩,០ |
| ៤៥–៤៩ | ៨,២ | ៨,៥ | ៧,៩ | ៧,៨ | ៨,៦ | ៦,៨ | ៨,៤ | ៨,៤ | ៨,៤ |
| ៥០–៥៤ | ៧,៨ | ៨,៣ | ៧,២ | ៧,៤ | ៨,១ | ៦,៥ | ៨,០ | ៨,៣ | ៧,៦ |
| ៥៥–៥៩ | ៦,១ | ៦,៥ | ៥,៧ | ៦,០ | ៦,៧ | ៥,១ | ៦,២ | ៦,៤ | ៦,០ |
| ៦០–៦៤ | ៣,៩ | ៣,៨ | ៤,០ | ៣,៦ | ៣,៥ | ៣,៦ | ៤,០ | ៣,៩ | ៤,១ |
| ៦៥+ | ៣,៨ | ៣,៨ | ៣,៨ | ៣,៨ | ៤,២ | ៣,៤ | ៣,៩ | ៣,៧ | ៤,១ |
| **សរុប (%)** | **១០០,០** | **១០០,០** | **១០០,០** | **១០០,០** | **១០០,០** | **១០០,០** | **១០០,០** | **១០០,០** | **១០០,០** |
| **សរុប (ចំនួន)** | **៧.៨៨៣.១០៦** | **៤.១១៧.៤៦៤** | **៣.៧៦៥.៦៤១** | **២.៧០១.៩៦៣** | **១.៤១៥.០៧៦** | **១.២៨៦.៨៨៧** | **៥.១៨១.១៤៣** | **២.៧០២.៣៨៩** | **២.៤៧៨.៧៥៥** |

សម្គាល់៖ សរុបអាចមិនស្មើផលបូក ដោយសារការបង្គត់លេខ។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

## ៥.៣ ការងារតាមមុខរបរ

"មុខរបរ" គឺជាភារកិច្ច ឬការងារសំខាន់របស់មនុស្សម្នាក់នៅកន្លែងធ្វើការរបស់គាត់។ ចំណាត់ថ្នាក់មុខរបរតាមស្តង់ដារអន្តរជាតិ ឆ្នាំ២០០៨ (ISCO-08) ត្រូវបានប្រើក្នុងអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩ និងចាត់តាមប្រភេទអ្នកធ្វើការជា ១០ ក្រុមធំ។

រូប ៥.១ បង្ហាញការបែងចែកភាគរយនៃអ្នកមានការងារធ្វើ តាមមុខរបរ។ អ្នកធ្វើការខាងជំនាញកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានភាគរយខ្ពស់ជាងគេនៃអ្នកធ្វើការគឺ ២៨,៧% បន្ទាប់មក ២២,៩% ធ្វើការខាងសិប្បកម្ម និងអាជីវកម្មពាក់ព័ន្ធ និង ២១,៤% ខាងសេវាកម្ម និងលក់។ អ្នកគ្រប់គ្រង (១,៦%) អ្នកខាងជំនាញវិជ្ជាជីវៈ (១,៦%) និងកងកម្លាំងប្រដាប់អាវុធ (១,០%) មានចំណែកតិចជាងគេនៃអ្នកមានការងារធ្វើទាំងអស់។

រូប ៥.១. ការបែងចែកប្រជាជនមានការងារធ្វើ តាមមុខរបរ

(%)




ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩ បានប៉ាន់ស្មានច្រើនជាង ៥០% នៃអ្នកមានការងារធ្វើជាប្រុស។ រូប ៥.២ បង្ហាញថាប្រុសមានចំណែកច្រើនជាងគេនៃអ្នកមានការងារធ្វើក្នុងគ្រប់ក្រុមមុខរបរ លើកលែងតែអ្នកធ្វើការខាងជំនួយការស្មៀន និងខាងផ្តល់សេវាកម្ម និងលក់។ ចំណែកច្រើនជាងគេនៃការងាររបស់ប្រុស គឺក្នុងកងកម្លាំងប្រដាប់អាវុធ និងជាអ្នកបញ្ជាម៉ាស៊ីន និងផ្គុំតម្លើង ដែលមាន ៩ នាក់ ក្នុងចំណោមនិយោជិត ១០ នាក់ ជាប្រុស។

រូប ៥.២. ការបែងចែកប្រជាជនមានការងារធ្វើ តាមប្រភេទមុខរបរ និងភេទ

(%)




ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

## ៥.៤ ការងារតាមសកម្មភាពសេដ្ឋកិច្ច

ដូចបានបង្ហាញក្នុងតារាង ៥.២ សកម្មភាពសេដ្ឋកិច្ចដែលមានចំណែកខ្ពស់ជាងគេនៃប្រជាជនមានការងារធ្វើ គឺវិស័យសេវាកម្ម (៣៩,៨%)។ ចំណែករបស់វិស័យកសិកម្មមាន ៣៣,១% និងវិស័យឧស្សាហកម្មមាន ២៧,០%។

តារាងនេះបង្ហាញថា ម្នាក់ក្នុងចំណោមបីនាក់នៅកម្ពុជាបានធ្វើការខាងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដោយមិនគិតយេនឌ័រ។ ទោះជាយ៉ាងណាក៏ដោយ ភាពខុសគ្នាខាងយេនឌ័របានបញ្ជាក់ច្បាស់នៅក្នុងសកម្មភាពសេដ្ឋកិច្ចមិនមែនកសិកម្មដទៃទៀត។ ប្រុសភាគច្រើនធ្វើការខាងសំណង់ (១៥,៩%) ដឹកជញ្ជូន និងស្តុកទំនិញ (៨,៣%) និងរដ្ឋបាលសាធារណៈ និងការពារ សន្តិសុខសង្គមជាកាតព្វកិច្ច (៥,៦%)។ ម្យ៉ាងទៀត ស្រីភាគច្រើនធ្វើការខាងការផលិត (២២,៣%) និងពាណិជ្ជកម្មលក់ដុំ និងរាយ (២៣,៣%)។

តារាង ៥.២. ប្រជាជនមានការងារធ្វើ តាមសកម្មភាពសេដ្ឋកិច្ច និងភេទ

| សកម្មភាពសេដ្ឋកិច្ច [a] | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
|---|---|---|---|---|---|---|
| | ចំនួន | | | % | | |
| **កសិកម្ម** | **២.៦១២.៥៥១** | **១.៣៨៦.៣៧៩** | **១.២២៦.១៧២** | **៣៣,១** | **៣៣,៧** | **៣២,៦** |
| **ឧស្សាហកម្ម** | **២.១៣២.០៧៧** | **១.១៥៣.៧៥៩** | **៩៧៨.៣១៨** | **២៧,០** | **២៨,០** | **២៦,០** |
| រុករករ៉ែ និងថ្ម | ៦.៥៣៨ | ៤.៨៥២ | ១.៦៨៥ | ០,១ | ០,១ | ០,០ |
| ការផលិត | ១.៣១៤.៩៦៦ | ៤៧៥.៣៦៤ | ៨៣៩.៦០២ | ១៦,៧ | ១១,៥ | ២២,៣ |
| ផ្គត់ផ្គង់អគ្គិសនី ឧស្ម័ន ចំហាយ និងម៉ាស៊ីនត្រជាក់ | ៩.៦៧០ | ៧.៩៣០ | ១.៧៤០ | ០,១ | ០,២ | ០,០ |
| ផ្គត់ផ្គង់ទឹក គ្រប់គ្រងសំរាម លូទឹក និងសកម្មភាពកែលម្អ | ១៥.៦៩៣ | ៩.៦៦៣ | ៦.០៣០ | ០,២ | ០,២ | ០,២ |
| សំណង់ | ៧៨៥.២១០ | ៦៥៥.៩៥០ | ១២៩.២៦១ | ១០,០ | ១៥,៩ | ៣,៤ |
| **សេវាកម្ម** | **៣.១៣៨.៤៨០** | **១.៥៧៧.៣២៥** | **១.៥៦១.១៥៣** | **៣៩,៨** | **៣៨,៣** | **៤១,៥** |
| លក់ដុំ និងលក់រាយ ជួសជុលយានយន្ត | ១.៣១៩.០២៧ | ៤៤០.៦១២ | ៨៧៨.៤១៥ | ១៦,៧ | ១០,៧ | ២៣,៣ |
| ដឹកជញ្ជូន និងស្តុកទំនិញ | ៣៦៤.៨៦៣ | ៣៤២.៦៣២ | ២២.២៣១ | ៤,៦ | ៨,៣ | ០,៦ |
| សកម្មភាពសេវាកម្មស្នាក់នៅ និងអាហារ | ២៦៩.៥២៧ | ៩៥.៩៤៩ | ១៧៣.៥៧៨ | ៣,៤ | ២,៣ | ៤,៦ |
| ព័ត៌មាន និងទំនាក់ទំនង | ២៦.១៧៥ | ១៨.៥២៨ | ៧.៦៤៦ | ០,៣ | ០,៤ | ០,២ |
| សកម្មភាពហិរញ្ញវត្ថុ និងធានារ៉ាប់រង | ១១៤.២៣១ | ៧០.៥០៧ | ៤៣.៧២៤ | ១,៤ | ១,៧ | ១,២ |
| សកម្មភាពអចលនទ្រព្យ | ២៥.១២៣ | ១៥.៦៧៨ | ៩.៤៤៥ | ០,៣ | ០,៤ | ០,៣ |
| សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | ៦០.៥៧៩ | ៣០.៦៩៨ | ២៩.៨៨១ | ០,៨ | ០,៧ | ០,៨ |
| សកម្មភាពរដ្ឋបាល និងសេវាកម្មគាំទ្រ | ១៧៦.៨២១ | ៩៨.៣៨១ | ៧៨.៤៤១ | ២,២ | ២,៤ | ២,១ |
| រដ្ឋបាលសាធារណៈ និងការពារ សន្តិសុខសង្គមជាកាតព្វកិច្ច | ២៨៤.៨៩៤ | ២៣២.០១២ | ៥២.៨៨១ | ៣,៦ | ៥,៦ | ១,៤ |
| អប់រំ | ១៨២.៩៧២ | ៩៧.៦១៦ | ៨៥.៣៥៥ | ២,៣ | ២,៤ | ២,៣ |
| សកម្មភាពសុខភាពមនុស្ស និងកិច្ចការសង្គម | ៦៤.៧៣៣ | ៣៥.៣៨៧ | ២៩.៣៤៦ | ០,៨ | ០,៩ | ០,៨ |
| សិល្បៈ កម្សាន្ត និងសប្បាយ | ៧៦.៤០២ | ៣៥.១៤៨ | ៤១.២៥៤ | ១,០ | ០,៩ | ១,១ |
| សកម្មភាពសេវាកម្មដទៃទៀត | ១៣១.៦៦២ | ៤៧.២៥២ | ៨៤.៤១០ | ១,៧ | ១,១ | ២,២ |
| សកម្មភាពគ្រួសារជានិយោជក និងសកម្មភាពផលិតទំនិញ និងសេវាកម្មត្រូវគ្នារបស់គ្រួសារសម្រាប់ប្រើប្រាស់ខ្លួនឯង | ៣៣.៩៩៦ | ១២.៤៥០ | ២១.៥៤៦ | ០,៤ | ០,៣ | ០,៦ |
| សកម្មភាពអង្គការ និងអង្គភាពក្រៅប្រទេស | ៧.៤៧៥ | ៤.៤៧៥ | ៣.០០០ | ០,១ | ០,១ | ០,១ |
| **សរុប** | **៧.៨៨៣.១០៦** | **៤.១១៧.៤៦៤** | **៣.៧៦៥.៦៤១** | **១០០,០** | **១០០,០** | **១០០,០** |

[a] ប្រភេទសកម្មភាពសេដ្ឋកិច្ចមានក្នុងបង្គោលនេះ បានមកពីចំណាត់ថ្នាក់សកម្មភាពសេដ្ឋកិច្ចតាមស្តង់ដារអន្តរជាតិ ជំនាន់ ៤ (ISIC Rev4)។

សម្គាល់៖ សរុបអាចមិនស្មើផលបូក ដោយសារការបង្គត់លេខ។

ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

## ៥.៥ ការងារតាមការសិក្សា

តារាង ៥.៣ បង្ហាញការបែងចែកភាគរយនៃអ្នកមានការងារធ្វើ តាមកម្រិតសិក្សា។ ដូចបានរៀបរាប់ខាងលើ ប្រមាណ ១០,៨% នៃប្រជាជនមានការងារធ្វើ មិនដែលបានរៀន។ ប្រមាណ ៣៨,១% នៃប្រជាជនមានការងារធ្វើ បានបញ្ចប់បឋមសិក្សា ខណៈ ៤០,៨% បានបញ្ចប់មធ្យមសិក្សា (មធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ)។ មានតែ ៦,៦% នៃពួកគេ បានបញ្ចប់សាកលវិទ្យាល័យ និង ០,៤% មានវិញ្ញាបនបត្រវិជ្ជាជីវៈ។

ក្នុងចំណោមប្រុសមានការងារធ្វើ ប្រមាណ ៣៧,២% នៃពួកគេបានបញ្ចប់បឋមសិក្សា ២៦,១% បានបញ្ចប់មធ្យមសិក្សាបឋមភូមិ ១៧,២% បានបញ្ចប់មធ្យមសិក្សាទុតិយភូមិ ៧,៤% បានបញ្ចប់សាកលវិទ្យាល័យ និង ០,៥% មានវិញ្ញាបនបត្រវិជ្ជាជីវៈ។ បើប្រៀបធៀបជាមួយប្រុស ស្រីមានការងារធ្វើមានកម្រិតសិក្សានៅទាបជាង គឺ ១៣,១% មិនដែលបានរៀន (ប្រៀបធៀបនឹងប្រុសមាន ៨,៧% នៃអ្នកមានការងារធ្វើ)។ ខណៈស្រីមានការងារធ្វើ (៣៩,១%) ច្រើនជាងប្រុសបានបញ្ចប់បឋមសិក្សា ក៏មានស្រីតិចជាងប្រុសបានបញ្ចប់មធ្យមសិក្សា ឬសាកលវិទ្យាល័យផងដែរ។

សមាមាត្រធំជាងគេនៃប្រជាជនមានការងារធ្វើនៅទីប្រជុំជន បានបញ្ចប់មធ្យមសិក្សាបឋមភូមិ (២៨,៩%)។ ភាគច្រើននៃប្រជាជនមានការងារធ្វើនៅតំបន់ជនបទ បានបញ្ចប់បឋមសិក្សា (៤៣,១%)។ ដូច្នេះ អ្នកមានការងារធ្វើនៅតំបន់ជនបទមានកម្រិតសិក្សាទាប ខណៈអ្នកមានការងារធ្វើនៅតំបន់ទីប្រជុំជនមានកម្រិតសិក្សាខ្ពស់ជាង។

តារាង ៥.៣. ប្រជាជនមានការងារធ្វើ តាមកម្រិតសិក្សា តំបន់ និងភេទ

(%)

| កម្រិតសិក្សា | កម្ពុជា | | | ទីប្រជុំជន | | | ជនបទ | | |
|---|---|---|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| មិនដែលបានរៀន | ១០,៨ | ៨,៧ | ១៣,១ | ៥,៦ | ៤,៣ | ៧,០ | ១៣,៥ | ១០,៩ | ១៦,៣ |
| មត្តេយ្យសិក្សា | ៣,៣ | ៣,០ | ៣,៧ | ២,០ | ១,៦ | ២,៥ | ៤,០ | ៣,៧ | ៤,៣ |
| បឋមសិក្សា | ៣៨,១ | ៣៧,២ | ៣៩,១ | ២៨,៦ | ២៦,២ | ៣១,១ | ៤៣,១ | ៤២,៩ | ៤៣,៣ |
| មធ្យមសិក្សាបឋមភូមិ | ២៥,១ | ២៦,១ | ២៣,៩ | ២៨,៩ | ២៩,០ | ២៨,៨ | ២៣,១ | ២៤,៦ | ២១,៤ |
| មធ្យមសិក្សាទុតិយភូមិ | ១៥,៧ | ១៧,២ | ១៤,១ | ២០,៧ | ២២,៩ | ១៨,២ | ១៣,១ | ១៤,៣ | ១១,៩ |
| បច្ចេកទេស/វិជ្ជាជីវៈ | ០,៤ | ០,៥ | ០,៣ | ០,៥ | ០,៥ | ០,៤ | ០,៣ | ០,៤ | ០,២ |
| ឧត្តមសិក្សា | ៦,៦ | ៧,៤ | ៥,៨ | ១៣,៨ | ១៥,៥ | ១១,៩ | ២,៩ | ៣,២ | ២,៦ |
| **សរុប (ចំនួន)** | **៧.៨៨៣.១០៦** | **៤.១១៧.៤៦៤** | **៣.៧៦៥.៦៤១** | **២.៧០១.៩៦៣** | **១.៤១៥.០៧៦** | **១.២៨៦.៨៨៧** | **៥.១៨១.១៤៣** | **២.៧០២.៣៨៩** | **២.៤៧៨.៧៥៥** |

សម្គាល់៖ សរុបអាចមិនស្មើផលបូក ដោយសារការបង្គត់លេខ។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

## ៥.៦ អត្រាអ្នកមានការងារធ្វើធៀបនឹងប្រជាជន

អត្រាអ្នកមានការងារធ្វើធៀបនឹងប្រជាជន គឺជាសមាមាត្រនៃប្រជាជនមានការងារធ្វើ ធៀបទៅនឹងប្រជាជនក្នុងអាយុធ្វើការរបស់ប្រទេស ហើយបង្ហាញជាភាគរយ។ វាបង្ហាញពីសមត្ថភាពនៃសេដ្ឋកិច្ច ដើម្បីបង្កើតការងារ។ អត្រាខ្ពស់មានន័យថា សមាមាត្រដ៏ធំនៃប្រជាជនក្នុងអាយុធ្វើការរបស់ប្រទេសមួយត្រូវបានផ្តល់ការងារធ្វើ ហើយសមាមាត្រទាបមានន័យថា ចំណែកដ៏ធំនៃប្រជាជនក្នុងអាយុធ្វើការមិនត្រូវបានចូលរួមដោយផ្ទាល់ក្នុងសកម្មភាពទាក់ទងនឹងទីផ្សារដើម្បីប្រាក់ឈ្នួល ឬចំណេញ អាចដោយសារពួកគេគ្មានការងារធ្វើ ឬនៅក្រៅកម្លាំងពលកម្ម។

រូប ៥.៣ បង្ហាញអត្រាអ្នកមានការងារធ្វើធៀបនឹងប្រជាជន តាមក្រុមអាយុ និងភេទ។ នៅឆ្នាំ ២០១៩ អត្រាអ្នកមានការងារធ្វើធៀបនឹងប្រជាជនជាសរុបមាន ៦៨,៥% ហើយក្នុងចំណោមប្រុសមាន ៧៦,២% និងក្នុងចំណោមស្រីមាន ៦១,៦%។ អត្រារបស់ប្រុសមានខ្ពស់ជាងអត្រារបស់ស្រី ក្នុងក្រុមអាយុទាំងអស់។ ជាទូទៅ អត្រាអ្នកមានការងារធ្វើធៀបនឹងប្រជាជនបានកើនឡើងខ្ពស់នៅអាយុធ្វើការសំខាន់ជាងគេ (អាយុ ២៥-៤៤ ឆ្នាំ) ខណៈអត្រាបានថយចុះវិញ តាមការសង្កេតជាបន្តបន្ទាប់។

រូប ៥.៣. អត្រាអ្នកមានការងារធ្វើ ធៀបនឹងប្រជាជន តាមក្រុមអាយុ និងភេទ

(%)




ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

## ៥.៧ ស្ថានភាពការងារ

នៅពេលនិយាយអំពីស្ថានភាពការងារ ប្រជាជនមានការងារធ្វើមានពីរប្រភេទជាមូលដ្ឋានគឺៈ និយោជិតមានប្រាក់ឈ្នួល ឬបៀវត្សរ៍ និងអ្នកធ្វើការដោយខ្លួនឯង។ អ្នកធ្វើការដោយខ្លួនឯងអាចបែងចែកជាបីក្រុមទៀតគឺៈ និយោជក អ្នកធ្វើការដោយទុនផ្ទាល់ខ្លួន និងអ្នកធ្វើការឲ្យគ្រួសារមិនយកប្រាក់ឈ្នួល។ ទស្សនាទាននៃស្ថានភាពការងារគ្រប់ដណ្តប់លើឥរិយាបថការងារ លក្ខណៈការងារ និងលក្ខខណ្ឌការងារ។ សមាមាត្រខ្ពស់នៃអ្នកធ្វើការដោយខ្លួនឯងអាចបង្ហាញថាវិស័យកសិកម្មមានទំហំធំ ខណៈសមាមាត្រខ្ពស់នៃនិយោជិតអាចបង្ហាញពីភាពចម្រុះនៃឱកាសការងារដោយសារការអភិវឌ្ឍសេដ្ឋកិច្ច។

តារាង ៥.៤ បង្ហាញការបែងចែកអ្នកមានការងារធ្វើ តាមស្ថានភាពការងារ។ ចំណែកធំជាងគេនៃប្រជាជនមានការងារធ្វើ គឺនិយោជិត (៤៧,៨%) នៅឆ្នាំ២០១៩ បន្ទាប់មកគឺអ្នកធ្វើការដោយទុនផ្ទាល់ខ្លួន (៣៦,៩%) អ្នកធ្វើការឲ្យគ្រួសារមិនយកប្រាក់ឈ្នួល (១១,៩%) និងនិយោជក (៣,៤%)។

ជាទូទៅ ប្រុសមានសមាមាត្រខ្ពស់ជាងស្រីនៅក្នុងគ្រប់ប្រភេទនៃស្ថានភាពការងារ លើកលែងតែអ្នកធ្វើការឲ្យគ្រួសារមិនយកប្រាក់ឈ្នួល ដែលស្រីមានការងារធ្វើមានសមាមាត្រខ្ពស់ (១៧,៣%) ជាងប្រុស (៦,៩%)។

តារាង ៥.៤. ប្រជាជនមានការងារធ្វើ តាមស្ថានភាពការងារ

| ស្ថានភាពការងារ | ទាំងពីរភេទ | ប្រុស | ស្រី |
|---|---|---|---|
| **ចំនួនតាមប្រភេទនីមួយៗ** | | | |
| និយោជិត | ៣.៧៦៩.៥១៥ | ២.១៤៤.៩៣៣ | ១.៦២៤.៥៨២ |
| និយោជក | ២៦៩.៨២០ | ១៦៦.៥៦៨ | ១០៣.២៥២ |
| អ្នកធ្វើការដោយទុនផ្ទាល់ខ្លួន | ២.៩០៨.៤៤៧ | ១.៥២២.៥៦៥ | ១.៣៨៥.៨៨៣ |
| អ្នកធ្វើការឲ្យគ្រួសារមិនយកប្រាក់ឈ្នួល | ៩៣៥.៣២៤ | ២៨៣.៣៩៩ | ៦៥១.៩២៥ |
| **សរុប (ចំនួន)** | **៧.៨៨៣.១០៦** | **៤.១១៧.៤៦៤** | **៣.៧៦៥.៦៤១** |
| **ភាគរយតាមប្រភេទនីមួយៗ** | | | |
| និយោជិត | ៤៧,៨ | ៥២,១ | ៤៣,១ |
| និយោជក | ៣,៤ | ៤,១ | ២,៧ |
| អ្នកធ្វើការដោយទុនផ្ទាល់ខ្លួន | ៣៦,៩ | ៣៧,០ | ៣៦,៨ |
| អ្នកធ្វើការឲ្យគ្រួសារមិនយកប្រាក់ឈ្នួល | ១១,៩ | ៦,៩ | ១៧,៣ |
| **សរុប (%)** | **១០០,០** | **១០០,០** | **១០០,០** |

សម្គាល់៖ សរុបអាចមិនស្មើផលបូក ដោយសារការបង្គត់លេខ។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

# ជំពូក ៦
# ការងារក្នុងវិស័យក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធ

## ៦.១ សេចក្តីផ្តើម

ជំពូកនេះបង្ហាញទិន្នន័យអំពីការងារក្នុងវិស័យក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធនៅកម្ពុជា។ វិស័យក្រៅប្រព័ន្ធតំណាងឲ្យផ្នែកដ៏សំខាន់មួយនៃសេដ្ឋកិច្ច និងទីផ្សារការងារនៅក្នុងប្រទេសជាច្រើន ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ ដូច្នេះ វាចាំបាច់វាស់វែងការចូលរួមចំណែករបស់វិស័យក្រៅប្រព័ន្ធទៅក្នុងការងារ ក៏ដូចជាការចូលរួមចំណែកក្នុងផលិតផលក្នុងស្រុកសរុបផងដែរ។ មិនតែប៉ុណ្ណោះ វិស័យក្រៅប្រព័ន្ធដើរតួនាទីដ៏សំខាន់ក្នុងការបង្កើតការងារ ផលិតកម្ម និងការបង្កើតប្រាក់ចំណូល។ អត្រាការងារក្រៅប្រព័ន្ធត្រូវបានចាត់ទុកជាសូចនាករសំខាន់មួយនៃគុណភាពការងារនៅក្នុងសេដ្ឋកិច្ច ដែលមានទំនាក់ទំនងដូចគ្នានៅបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសឧស្សាហកម្ម។

## ៦.២ វិស័យក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធ

តារាង ៦.១ បង្ហាញការបែងចែកប្រជាជនមានការងារធ្វើបច្ចុប្បន្ន អាយុ ១៥ ឆ្នាំឡើង នៅក្នុងវិស័យក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធ តាមភេទ។ លទ្ធផលបង្ហាញថា ក្នុងចំណោមអ្នកមានការងារធ្វើ ៧,៩ លាននាក់ មានប្រមាណ ៧៧,៤% (ប្រុស ៧៧,៥% និងស្រី ៧៧,៤%) ធ្វើការក្នុងវិស័យក្រៅប្រព័ន្ធ ខណៈ ២១,៥% (ប្រុស ២១,៦% និងស្រី ២១,៤%) ធ្វើការក្នុងវិស័យក្នុងប្រព័ន្ធ និង ១,១% ផ្សេងទៀត (ប្រុស ០,៩% និងស្រី ១,២%) ធ្វើការក្នុងវិស័យគ្រួសារ។ ជាទូទៅមិនមានខុសគ្នាគួរឲ្យកត់សម្គាល់ឡើយ រវាងចំនួនអ្នកធ្វើការប្រុស និងស្រី ក្នុងវិស័យក្រៅប្រព័ន្ធ និងវិស័យក្នុងប្រព័ន្ធ ក្នុងសកម្មភាពកសិកម្ម និងមិនមែនកសិកម្ម។ ប្រុស និងស្រីភាគច្រើនបានធ្វើការក្នុងវិស័យមិនមែនកសិកម្មក្រៅប្រព័ន្ធ (៤៥,៥% និង ៤៦,២%) បន្ទាប់មកវិស័យកសិកម្មក្រៅប្រព័ន្ធ (៣២,០% និង ៣១,២%) និងវិស័យមិនមែនកសិកម្មក្នុងប្រព័ន្ធ (២០,៥% និង ២០,៧%)។ ភាគរយតិចជាងគេនៃអ្នកធ្វើការប្រុស និងស្រី បានធ្វើការក្នុងវិស័យកសិកម្មក្នុងប្រព័ន្ធ និងក្នុងវិស័យគ្រួសារ។ គួរកត់សម្គាល់ ស្រីមានចំនួនច្រើនជាងប្រុសបន្តិចបានធ្វើការនៅក្នុងវិស័យមិនមែនកសិកម្មក្រៅប្រព័ន្ធ វិស័យមិនមែនកសិកម្មក្នុងប្រព័ន្ធ និងវិស័យគ្រួសារ។

តារាង ៦.១. ប្រជាជនមានការងារធ្វើ តាមវិស័យក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធ

| វិស័យ | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
|---|---|---|---|---|---|---|
| | | (ចំនួន) | | | (%) | |
| **វិស័យក្រៅប្រព័ន្ធ** | | | | | | |
| កសិកម្ម | ២.៤៩២.២៤១ | ១.៣១៦.៦៤៩ | ១.១៧៥.៥៩២ | ៣១,៦ | ៣២,០ | ៣១,២ |
| មិនមែនកសិកម្ម | ៣.៦១២.៧៤០ | ១.៨៧៤.៣០៧ | ១.៧៣៨.៤៣៣ | ៤៥,៨ | ៤៥,៥ | ៤៦,២ |
| **សរុបរង (វិស័យក្រៅប្រព័ន្ធ)** | **៦.១០៤.៩៨១** | **៣.១៩០.៩៥៦** | **២.៩១៤.០២៥** | **៧៧,៤** | **៧៧,៥** | **៧៧,៤** |
| **វិស័យក្នុងប្រព័ន្ធ** | | | | | | |
| កសិកម្ម | ៧១.០៦៦ | ៤៤.៨៤០ | ២៦.២២៦ | ០,៩ | ១,១ | ០,៧ |
| មិនមែនកសិកម្ម | ១.៦២១.៣០៨ | ៨៤២.៨៩០ | ៧៧៨.៤១៨ | ២០,៦ | ២០,៥ | ២០,៧ |
| **សរុបរង (វិស័យក្នុងប្រព័ន្ធ)** | **១.៦៩២.៣៧៤** | **៨៨៧.៧៣០** | **៨០៤.៦៤៤** | **២១,៥** | **២១,៦** | **២១,៤** |
| **វិស័យគ្រួសារ** | | | | | | |
| **សរុបរង (វិស័យគ្រួសារ)** | **៨៥.៧៥១** | **៣៨.៧៧៩** | **៤៦.៩៧២** | **១,១** | **០,៩** | **១,២** |
| **សរុប** | **៧.៨៨៣.១០៦** | **៤.១១៧.៤៦៤** | **៣.៧៦៥.៦៤១** | **១០០,០** | **១០០,០** | **១០០,០** |

សម្គាល់៖ សរុបអាចមិនស្មើផលបូក ដោយសារការបង្គត់លេខ។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

## ៦.៣ ការងារក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធ

យោងតាមតារាង ៦.២ ចំនួនអ្នកមានការងារធ្វើច្រើនជាងគេ គឺក្នុងការងារក្រៅប្រព័ន្ធមានប្រមាណ ៨៨,៣% (ប្រុស ៨៩,០% និងស្រី ៨៧,៦%)។

តារាង ៦.២. ប្រជាជនមានការងារធ្វើ តាមការងារក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធ

| វិស័យ | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
|---|---|---|---|---|---|---|
| | (ចំនួន) | | | (%) | | |
| ការងារក្រៅប្រព័ន្ធ | ៦.៩៦០.០៦០ | ៣.៦៦៣.០៦៦ | ៣.២៩៦.៩៩៣ | ៨៨,៣ | ៨៩,០ | ៨៧,៦ |
| ការងារក្នុងប្រព័ន្ធ | ៩២៣.០៤៦ | ៤៥៤.៣៩៨ | ៤៦៨.៦៤៨ | ១១,៧ | ១១,០ | ១២,៤ |
| **សរុប** | **៧.៨៨៣.១០៦** | **៤.១១៧.៤៦៤** | **៣.៧៦៥.៦៤១** | **១០០,០** | **១០០,០** | **១០០,០** |

សម្គាល់៖ សរុបអាចមិនស្មើផលបូក ដោយសារការបង្គត់លេខ។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

ដូចបានបង្ហាញក្នុងរូប ៦.១ ភាគរយនៃអ្នកធ្វើការងារក្រៅប្រព័ន្ធបានចាប់ផ្តើមឡើងនៅក្រុមអាយុ ៣៥-៤៤ ឆ្នាំ មាន ៨៩,៩% ហើយបានបន្តឡើងខ្ពស់នៅក្រុមអាយុ ៦៥ ឡើង មាន ៩៤,៧%។ សមាមាត្រទាបក្នុងចំណោមយុវជនអាយុ ១៥-២៤ ឆ្នាំ មាន ៨៥,៨% និងក្នុងក្រុមអាយុ ២៥-៣៤ ឆ្នាំ មាន ៨៥,០%។

រូប ៦.១. អ្នកធ្វើការងារក្រៅប្រព័ន្ធ តាមក្រុមអាយុ

(%)




ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

ដូចបានឃើញក្នុងរូប ៦.២ អ្នកធ្វើការងារក្រៅប្រព័ន្ធខ្ពស់នៅតំបន់ជនបទ (៩០,០%) ជាងនៅទីប្រជុំជន (៨៥,០%)។ សមាមាត្រនៃអ្នកធ្វើការងារក្រៅប្រព័ន្ធនៅជនបទមាន ១,៧ ភាគរយលើសភាគរយមធ្យមថ្នាក់ជាតិ។

រូប ៦.២. អ្នកធ្វើការងារក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធ តាមតំបន់

(%)




ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

លទ្ធផលអំពីសមាមាត្រនៃក្រុមមុខរបរចម្បងដែលរាយការណ៍ដោយអ្នកធ្វើការងារក្រៅប្រព័ន្ធ (តារាង ៦.៣) បានឲ្យដឹងថា អ្នកធ្វើការងារក្រៅប្រព័ន្ធច្រើនជាងគេ គឺជំនាញកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (៩៨,៦%) មុខរបរងាយៗ (៩៤,៨ %) អ្នកផ្តល់សេវាកម្ម និងលក់ (៩២,៦%) និងការីម៉ាស៊ីន (៩២,១%)។

តារាង ៦.៣. អ្នកធ្វើការងារក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធ តាមមុខរបរ

| មុខរបរ [a] | ការងារក្រៅប្រព័ន្ធ | ការងារក្នុងប្រព័ន្ធ | សរុប | ការងារក្រៅប្រព័ន្ធ | ការងារក្នុងប្រព័ន្ធ | សរុប |
|---|---|---|---|---|---|---|
| | (ចំនួន) | | | (%) | | |
| អ្នកគ្រប់គ្រង | ៨១.០៣៨ | ៤៧.០៩០ | ១២៨.១២៨ | ៦៣,២ | ៣៦,៨ | ១០០,០ |
| អ្នកមានវិជ្ជាជីវៈ | ១៩៦.៩៦៨ | ១៣០.៣៩០ | ៣២៧.៣៥៨ | ៦០,២ | ៣៩,៨ | ១០០,០ |
| អ្នកបច្ចេកទេស និងវិជ្ជាជីវៈរង | ២០៤.៦៩០ | ៨៦.៦៥៧ | ២៩១.៣៤៧ | ៧០,៣ | ២៩,៧ | ១០០,០ |
| អ្នកជំនួយការស្មៀន | ៩១.៤៩៩ | ៣២.៥០៣ | ១២៤.០០២ | ៧៣,៨ | ២៦,២ | ១០០,០ |
| អ្នកផ្តល់សេវាកម្ម និងលក់ | ១.៥៦២.៦៥៨ | ១២៥.៦១១ | ១.៦៨៨.២៦៩ | ៩២,៦ | ៧,៤ | ១០០,០ |
| អ្នកជំនាញកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ២.២៣២.៤១២ | ៣០.៨៤៦ | ២.២៦៣.២៥៨ | ៩៨,៦ | ១,៤ | ១០០,០ |
| អ្នកធ្វើសិប្បកម្ម និងអាជីវកម្មពាក់ព័ន្ធ | ១.៤៤៨.០៧៧ | ៣៥៩.២៤៥ | ១.៨០៧.៣២១ | ៨០,១ | ១៩,៩ | ១០០,០ |
| ការីម៉ាស៊ីន និងរោងចក្រ និងអ្នកផ្គុំតម្លើង | ៣៦៤.២៧៩ | ៣១.២៣៩ | ៣៩៥.៥១៨ | ៩២,១ | ៧,៩ | ១០០,០ |
| អ្នកធ្វើមុខរបរងាយៗ | ៧៣៨.៣៥១ | ៤០.៤៧៩ | ៧៧៨.៨៣០ | ៩៤,៨ | ៥,២ | ១០០,០ |
| កងកម្លាំងប្រដាប់អាវុធ | ៤០.០៨៦ | ៣៨.៩៨៨ | ៧៩.០៧៤ | ៥០,៧ | ៤៩,៣ | ១០០,០ |
| **សរុប** | **៦.៩៦០.០៦០** | **៩២៣.០៤៦** | **៧.៨៨៣.១០៦** | **៨៨,៣** | **១១,៧** | **១០០,០** |

[a] ប្រភេទមុខរបរមានក្នុងបង្គោលនេះ បានមកពីចំណាត់ថ្នាក់មុខរបរតាមស្តង់ដារអន្តរជាតិ ឆ្នាំ២០០៨ (ISCO-08)។

សម្គាល់៖ សរុបអាចមិនស្មើផលបូក ដោយសារការបង្គត់លេខ។

ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

រូប ៦.៤ បង្ហាញការបែងចែកប្រជាជនមានការងារធ្វើរវាងការងារក្រៅប្រព័ន្ធ និងការងារក្នុងប្រព័ន្ធ តាមសកម្មភាពសេដ្ឋកិច្ច។ សកម្មភាពសេដ្ឋកិច្ចទាំងអស់ដែលមានក្នុងតារាង ៦.៤ ភាគច្រើននៃអ្នកធ្វើការងារក្រៅប្រព័ន្ធដែលមានសមាមាត្រធំជាងគេ គឺកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (៩៨,៦%) និងសំណង់ (៩៧,២%)។

## តារាង ៦.៤. អ្នកធ្វើការងារក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធ តាមសកម្មភាពសេដ្ឋកិច្ច

| សកម្មភាពសេដ្ឋកិច្ច [a] | ការងារក្រៅប្រព័ន្ធ | ការងារក្នុងប្រព័ន្ធ | សរុប | ការងារក្រៅប្រព័ន្ធ | ការងារក្នុងប្រព័ន្ធ | សរុប |
|---|---|---|---|---|---|---|
| កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ២.៥៧៥.២៧៦ | ៣៧.២៧៥ | ២.៦១២.៥៥១ | ៩៨,៦ | ១,៤ | ១០០,០ |
| រុករករ៉ែ និងថ្ម | ៦.២០៨ | ៣២៩ | ៦.៥៣៨ | ៩៥,០ | ៥,០ | ១០០,០ |
| ការផលិត | ៩២០.៨២៦ | ៣៩៤.១៤០ | ១.៣១៤.៩៦៦ | ៧០,០ | ៣០,០ | ១០០,០ |
| ផ្គត់ផ្គង់អគ្គិសនី ឧស្ម័ន ចំហាយ និងម៉ាស៊ីនត្រជាក់ | ៨.០៥២ | ១.៦១៨ | ៩.៦៧០ | ៨៣,៣ | ១៦,៧ | ១០០,០ |
| ផ្គត់ផ្គង់ទឹក គ្រប់គ្រងសំរាម លូទឹក និងសកម្មភាពកែលម្អ | ១៣.៣១៧ | ២.៣៧៦ | ១៥.៦៩៣ | ៨៤,៩ | ១៥,១ | ១០០,០ |
| សំណង់ | ៧៦៣.៤៩២ | ២១.៧១៨ | ៧៨៥.២១០ | ៩៧,២ | ២,៨ | ១០០,០ |
| លក់ដុំ និងលក់រាយ ជួសជុលយានយន្ត | ១.២៤២.៨៩២ | ៧៦.១៣៥ | ១.៣១៩.០២៧ | ៩៤,២ | ៥,៨ | ១០០,០ |
| ដឹកជញ្ជូន និងស្តុកទំនិញ | ៣៤៤.៩២៩ | ១៩.៩៣៤ | ៣៦៤.៨៦៣ | ៩៤,៥ | ៥,៥ | ១០០,០ |
| សកម្មភាពសេវាកម្មស្នាក់នៅ និងអាហារ | ២៥៦.៦៣៨ | ១២.៨៩០ | ២៦៩.៥២៧ | ៩៥,២ | ៤,៨ | ១០០,០ |
| ព័ត៌មាន និងទំនាក់ទំនង | ២១.៩១១ | ៤.២៦៤ | ២៦.១៧៥ | ៨៣,៧ | ១៦,៣ | ១០០,០ |
| សកម្មភាពហិរញ្ញវត្ថុ និងធានារ៉ាប់រង | ៧០.៣៧៣ | ៤៣.៨៥៨ | ១១៤.២៣១ | ៦១,៦ | ៣៨,៤ | ១០០,០ |
| សកម្មភាពអចលនទ្រព្យ | ២០.៤៥៩ | ៤.៦៦៤ | ២៥.១២៣ | ៨១,៤ | ១៨,៦ | ១០០,០ |
| សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | ៤៥.២៨១ | ១៥.២៩៧ | ៦០.៥៧៩ | ៧៤,៧ | ២៥,៣ | ១០០,០ |
| សកម្មភាពរដ្ឋបាល និងសេវាកម្មគាំទ្រ | ១៥១.០៨៤ | ២៥.៧៣៨ | ១៧៦.៨២១ | ៨៥,៤ | ១៤,៦ | ១០០,០ |
| រដ្ឋបាលសាធារណៈ និងការពារ សន្តិសុខសង្គមជាកាតព្វកិច្ច | ១៥៦.៥៥១ | ១២៨.៣៤៣ | ២៨៤.៨៩៤ | ៥៥,០ | ៤៥,០ | ១០០,០ |
| អប់រំ | ១០១.៣២៨ | ៨១.៦៤៤ | ១៨២.៩៧២ | ៥៥,៤ | ៤៤,៦ | ១០០,០ |
| សកម្មភាពសុខភាពមនុស្ស និងកិច្ចការសង្គម | ៣៣.២៦០ | ៣១.៤៧៣ | ៦៤.៧៣៣ | ៥១,៤ | ៤៨,៦ | ១០០,០ |
| សិល្បៈ កម្សាន្ត និងសប្បាយ | ៦៧.២៤៦ | ៩.១៥៦ | ៧៦.៤០២ | ៨៨,០ | ១២,០ | ១០០,០ |
| សកម្មភាពសេវាកម្មដទៃទៀត | ១២៣.៧៩៥ | ៧.៨៦៦ | ១៣១.៦៦២ | ៩៤,០ | ៦,០ | ១០០,០ |
| សកម្មភាពគ្រួសារជានិយោជក និងសកម្មភាពផលិតទំនិញ និងសេវាកម្មត្រូវគ្នារបស់គ្រួសារសម្រាប់ប្រើប្រាស់ខ្លួនឯង | ៣២.១៧៨ | ១.៨១៨ | ៣៣.៩៩៦ | ៩៤,៧ | ៥,៣ | ១០០,០ |
| សកម្មភាពអង្គការ និងអង្គភាពក្រៅប្រទេស | ៤.៩៦៤ | ២.៥១១ | ៧.៤៧៥ | ៦៦,៤ | ៣៣,៦ | ១០០,០ |
| **សរុប** | **៦.៩៦០.០៦០** | **៩២៣.០៤៦** | **៧.៨៨៣.១០៦** | **៨៨,៣** | **១១,៧** | **១០០,០** |

[a] ប្រភេទសកម្មភាពសេដ្ឋកិច្ចមានក្នុងបង្គោលនេះ បានមកពីចំណាត់ថ្នាក់សកម្មភាពសេដ្ឋកិច្ចតាមស្តង់ដារអន្តរជាតិ ជំនាន់ ៤ (ISIC Rev4)។
សម្គាល់៖ សរុបអាចមិនស្មើផលបូក ដោយសារការបង្គត់លេខ។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

តារាង ៦.៥ បង្ហាញថាក្នុងចំណោមអ្នកធ្វើការក្នុងវិស័យក្រៅប្រព័ន្ធ មានប្រមាណ ៩៨,២% ជាអ្នកធ្វើការងារក្រៅប្រព័ន្ធ។ ការងារក្រៅប្រព័ន្ធ គឺជាចំនួនសរុបនៃការងារក្រៅប្រព័ន្ធ ទោះបីអនុវត្តក្នុងសហគ្រាសវិស័យក្នុងប្រព័ន្ធ សហគ្រាសវិស័យក្រៅប្រព័ន្ធ ឬគ្រួសារ ក្នុងរយៈពេលយោងដែលផ្តល់ឲ្យ។ ការងារក្រៅប្រព័ន្ធរួមមាននិយោជក និងអ្នកធ្វើការដោយទុនផ្ទាល់ខ្លួនដែលធ្វើការក្នុងសហគ្រាសនៃវិស័យក្រៅប្រព័ន្ធផ្ទាល់ខ្លួនរបស់ពួកគេ អ្នកធ្វើការឲ្យគ្រួសារមិនយកប្រាក់ឈ្នួល និងនិយោជិតនិងអ្នករៀនធ្វើការ ឬអ្នកហាត់ការមានប្រាក់ឈ្នួល ដែលមិនបានទទួលប្រាក់ឈ្នួលពេលឈប់សម្រាកប្រចាំឆ្នាំ ឬអត្ថប្រយោជន៍ឈប់សម្រាកឈឺ និងដែលនិយោជករបស់ពួកគេមិនបានចូលរួមវិភាគទានដល់របបសន្តិសុខសង្គមរបស់ពួកគេ។

## តារាង ៦.៥. អ្នកធ្វើការងារក្រៅប្រព័ន្ធ និងក្នុងប្រព័ន្ធ តាមវិស័យ

| វិស័យ | ការងារក្រៅប្រព័ន្ធ | ការងារក្នុងប្រព័ន្ធ | សរុប | ការងារក្រៅប្រព័ន្ធ | ការងារក្នុងប្រព័ន្ធ | សរុប |
|---|---|---|---|---|---|---|
| | (ចំនួន) | | | (%) | | |
| វិស័យក្រៅប្រព័ន្ធ | ៥.៩៩២.៦៥៩ | ១១២.៣២២ | ៦.១០៤.៩៨១ | ៩៨,២ | ១,៨ | ១០០,០ |
| វិស័យក្នុងប្រព័ន្ធ | ៨៨៣.៤៦៨ | ៨០៨.៩០៦ | ១.៦៩២.៣៧៤ | ៥២,២ | ៤៧,៨ | ១០០,០ |
| វិស័យគ្រួសារ | ៨៣.៩៣៣ | ១.៨១៨ | ៨៥.៧៥១ | ៩៧,៩ | ២,១ | ១០០,០ |
| **វិស័យទាំងអស់** | **៦.៩៦០.០៦០** | **៩២៣.០៤៦** | **៧.៨៨៣.១០៦** | **៨៨,៣** | **១១,៧** | **១០០,០** |

សម្គាល់៖ សរុបអាចមិនស្មើផលបូក ដោយសារការបង្គត់លេខ។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

# ជំពូក ៧
# ចំណូលពីការងារ

## ៧.១ សេចក្តីផ្តើម

ជំពូកនេះផ្តោតលើនិយោជិត និងអ្នករៀនធ្វើការ និងអ្នកហាត់ការមានប្រាក់ឈ្នួល អាយុ ១៥ ឆ្នាំឡើង ដែលត្រូវបានបើកឲ្យជាសាច់ប្រាក់ ក្នុងគ្រាចុងក្រោយដែលពួកគេបានទទួលជាប្រាក់ឈ្នួលក្នុងការងារចម្បង។ ចំណូលរបស់ពួកគេសំដៅលើចំនួនទឹកប្រាក់ដែលពួកគេត្រូវបានបើកឲ្យដោយនិយោជករបស់ពួកគេ បូកកម្រៃបន្ថែមដែលពួកគេអាចរកបានពីប្រាក់ទឹកតែ កម្រៃជើងសារ ឬប្រាក់រង្វាន់។ ផលិតភាពការងារជាមួយចំណូលប្រកបដោយនិរន្តរភាព គឺជាមធ្យោបាយមួយធានាដល់សន្តិសុខចំណូលគ្រួសារ និងការកាត់បន្ថយភាពក្រីក្រ។ ការបែងចែកប្រាក់ឈ្នួល និងការងារមានប្រាក់ឈ្នួល គឺជាកត្តាសំខាន់ក្នុងការកំណត់កម្រិតវិសមភាពក្នុងចំណោមប្រជាជន។

## ៧.២ មូលដ្ឋានទូទាត់ប្រាក់ឈ្នួល

ដូចបានបង្ហាញក្នុងតារាង ៧.១ ប្រមាណ ៩៨,៨% នៃនិយោជិតទាំងអស់ត្រូវបានបើកឲ្យតាមមូលដ្ឋានអត្រាពេលវេលា និងនៅសល់ប្រមាណ ១,២% ត្រូវបានបើកឲ្យតាមមូលដ្ឋានអត្រាឯកតា។ ចំពោះមូលដ្ឋានទូទាត់ប្រាក់ឈ្នួលមានប្រមាណជាង ៨០% បានទទួលបៀវត្សរ៍របស់ពួកគេជាប្រចាំខែ (៦៦,៤%) ឬជាប្រចាំថ្ងៃ (១៨,១%) ជាមូលដ្ឋាន ខណៈនៅសល់ពីនោះត្រូវបានបើកឲ្យជាប្រចាំពីរសប្តាហ៍ (១១,៦%) ឬប្រចាំសប្តាហ៍ (២,៧%) ឬពួកគេបានទទួលប្រាក់ឈ្នួលតែមួយដង (១,២%)។ លំនាំដូចគ្នានេះត្រូវបានសង្កេតឃើញសម្រាប់និយោជិតប្រុស និងនិយោជិតស្រី ទោះជាយ៉ាងណាក៏ដោយ ចំនួនស្រីច្រើនជាងត្រូវបានបើកតាមមូលដ្ឋានប្រចាំខែ ប្រមាណ ៧,៣% លើសប្រុស ខណៈចំនួនប្រុសច្រើនជាងត្រូវបានបើកតាមមូលដ្ឋានប្រចាំថ្ងៃ លើសស្រីបន្តិច (ប្រមាណ ៧,៩%)។

តារាង ៧.១. និយោជិត តាមមូលដ្ឋានទូទាត់ប្រាក់ឈ្នួល

| មូលដ្ឋានទូទាត់ប្រាក់ឈ្នួល | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
|---|---|---|---|---|---|---|
| | | (ចំនួន) | | | (%) | |
| តាមអត្រាឯកតា ឬមួយពេល | ៤៥.៤៣៨ | ៣១.៤៨៦ | ១៣.៩៥២ | ១,២ | ១,៥ | ០,៩ |
| ប្រចាំថ្ងៃ | ៦៨២.៤៦៧ | ៤៦១.៤៩៨ | ២២០.៩៦៩ | ១៨,១ | ២១,៥ | ១៣,៦ |
| ប្រចាំសប្តាហ៍ | ១០១.៨៧៩ | ៧៦.៨១៥ | ២៥.០៦៤ | ២,៧ | ៣,៦ | ១,៥ |
| ប្រចាំពីរសប្តាហ៍ | ៤៣៦.៤៣៩ | ២១៨.៣៣២ | ២១៨.១០៧ | ១១,៦ | ១០,២ | ១៣,៤ |
| ប្រចាំខែ | ២.៥០៣.២៩៣ | ១.៣៥៦.៨០២ | ១.១៤៦.៤៩១ | ៦៦,៤ | ៦៣,៣ | ៧០,៦ |
| **សរុប** | **៣.៧៦៩.៥១៥** | **២.១៤៤.៩៣៣** | **១.៦២៤.៥៨២** | **១០០,០** | **១០០,០** | **១០០,០** |

សម្គាល់៖ សរុបអាចមិនស្មើផលបូក ដោយសារការបង្គត់លេខ។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

## ៧.៣ ចំណូលប្រចាំខែជាមធ្យម

រូប ៧.១ បង្ហាញការបែងចែកប្រាក់ឈ្នួលប្រចាំខែរបស់និយោជិតប្រុស និងស្រី ពីការងារចម្បងរបស់ពួកគេ។ រូបបង្ហាញថាប្រុស និងស្រីរកចំណូលបានពី ៣០០.០០០ រៀល (៧៥ ដុល្លារអាមេរិក) ដល់ ៣.០០០.០០០ រៀល

(៧៥០ ដុល្លារអាមេរិក)។ ម៉្យាងទៀត ប្រុសមានបៀវត្សរ៍ប្រចាំខែជាមធ្យមប្រមាណ ១.០០០.០០០ រៀល (២៥០ ដុល្លារអាមេរិក) នៅឆ្នាំ២០១៩ ខណៈស្រីមានបៀវត្សរ៍ ៨៦៦.៦៦៧ រៀល (២១៧ ដុល្លារអាមេរិក)។

រូប ៧.១. ការបែងចែកប្រាក់ឈ្នួលប្រចាំខែ តាមភេទ
(ជារៀល)




ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

រូប ៧.២ បង្ហាញថាស្រីច្រើនជាងប្រុសមានចំណូលតិចជាង ៤០០,០០០ រៀល (១០០ ដុល្លារអាមេរិក) ក្នុងមួយខែនៅឆ្នាំ២០១៩ (៥៥,១% ទល់នឹង ៤៤,៩%) ខណៈប្រុសច្រើនជាងមានចំណូល ៤០០,០០០ រៀល ឬច្រើនជាង។ លើកលែងក្រុមចំណូលខ្ពស់ជាងគេ ទិន្នន័យបង្ហាញពីភាពខុសគ្នាច្រើនបង្គួរខាងយេនឌ័រក្នុងការរកចំណូលពីការងារ។

រូប ៧.២. ចំណែកប្រាក់ឈ្នួលប្រចាំខែ តាមភេទ
(%)




ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

តារាង ៧.២ បង្ហាញប្រាក់ឈ្នួលប្រចាំខែជាមធ្យម និងជាមេដ្យាន រកដោយនិយោជិត អាយុ ១៥ ឆ្នាំឡើង តាមមុខរបរ និងភេទ។ ប្រាក់ឈ្នួលប្រចាំខែជាមធ្យមពីការងារចម្បងរបស់និយោជិត មានប្រមាណ ១.០៧៨.៥៩៥ រៀល (២៦៩,៦០ ដុល្លារអាមេរិក) ខណៈប្រាក់ឈ្នួលប្រចាំខែជាមេដ្យាន ៩១០.០០០ រៀល (២២៧,៥០ ដុល្លារអាមេរិក)។ ចំពោះគម្លាតរវាងប្រាក់ឈ្នួលប្រចាំខែជាមធ្យមរបស់ប្រុស និងស្រី បានបង្ហាញថាប្រាក់ឈ្នួលជាមធ្យមរបស់ប្រុសមាន ១៣៤.៣៦៦ រៀល (៣៣,៦ ដុល្លារអាមេរិក) លើសប្រាក់ឈ្នួលរបស់ស្រី។ វាក៏មានគម្លាតរវាងប្រាក់ឈ្នួលប្រចាំខែជាមេដ្យានរបស់ប្រុស និងស្រីផងដែរ ដោយប្រុសមានប្រាក់ឈ្នួលជាមេដ្យាន ១៣៣.៣៣៣ រៀល (៣៣,៣០ ដុល្លារអាមេរិក) លើសប្រាក់ឈ្នួលរបស់ស្រី។ តារាងបង្ហាញថា ប្រាក់ឈ្នួលប្រចាំខែជាមធ្យម និងជាមេដ្យានរបស់ប្រុសតែងតែខ្ពស់បន្តិចជាងស្រីស្ទើរតែគ្រប់មុខរបរ។ ករណីលើកលែងមួយត្រូវបានសង្កេតឃើញនៅក្នុងកងកម្លាំងប្រដាប់អាវុធ គឺស្រីមានប្រាក់ឈ្នួលជាមធ្យមច្រើនជាង។

តារាង ៧.២. ប្រាក់ឈ្នួលប្រចាំខែជាមធ្យម និងជាមេដ្យាន តាមមុខរបរ និងភេទ
(ជារៀល)

| មុខរបរ [a] | ប្រាក់ឈ្នួលប្រចាំខែជាមធ្យម | | | ប្រាក់ឈ្នួលប្រចាំខែជាមេដ្យាន | | |
|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| អ្នកគ្រប់គ្រង | ១.៣៧៣.៥៥៥ | ១.៤១៦.៩១៦ | ១.២៧៩.១៥៤ | ១.១៩១.៦៦៧ | ១.២០០.០០០ | ១.០០០.០០០ |
| អ្នកមានវិជ្ជាជីវៈ | ១.៥០០.៧៥២ | ១.៥១៦.៤២៧ | ១.៤៨៤.៣៤៧ | ១.២៩០.០០០ | ១.៣០០.០០០ | ១.២០០.០០០ |
| អ្នកបច្ចេកទេស និងវិជ្ជាជីវៈរង | ១.៣៨៣.៦៧៣ | ១.៤៤៧.៤៧៣ | ១.២៦៣.៤៨៧ | ១.២០០.០០០ | ១.២០០.០០០ | ១.២០០.០០០ |
| អ្នកជំនួយការស្មៀន | ១.៤៣៣.៨៣០ | ១.៥៩៥.៤០២ | ១.២៧៨.៥៣៣ | ១.២០០.០០០ | ១.២០០.០០០ | ១.២០០.០០០ |
| អ្នកផ្តល់សេវាកម្ម និងលក់ | ១.១៩២.២៤៨ | ១.៤៣០.២១០ | ៨៩៧.៦៦៧ | ៨០០.០០០ | ១.០០០.០០០ | ៦៨០.០០០ |
| អ្នកជំនាញកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៦៩២.០៧១ | ៧២០.៥៤៨ | ៦៤៩.៧៥៦ | ៦០៦.៦៦៧ | ៦៥០.០០០ | ៦០០.០០០ |
| អ្នកធ្វើសិប្បកម្ម និងអាជីវកម្មពាក់ព័ន្ធ | ១.០០៨.២៨១ | ១.០២៥.២០៩ | ៩៩០.០៦៤ | ៩១០.០០០ | ៩១០.០០០ | ៩១០.០០០ |
| ការីម៉ាស៊ីន និងរោងចក្រ និងអ្នកផ្គុំតម្លើង | ១.០៦៤.៥០៨ | ១.០៩៩.៧៨០ | ៩០០.៥៣៦ | ៩០០.០០០ | ១.០០០.០០០ | ៨០០.០០០ |
| អ្នកធ្វើមុខរបរងាយៗ | ៧៨០.៧៩១ | ៨១០.០៦៣ | ៧៤៣.៣២៤ | ៦៥០.០០០ | ៧៥៨.៣៣៣ | ៦៥០.០០០ |
| កងកម្លាំងប្រដាប់អាវុធ | ១.៣១២.៨៤៦ | ១.៣១១.៥០៩ | ១.៣២៨.៥៧៩ | ១.៣០០.០០០ | ១.៣០០.០០០ | ១.៤០០.០០០ |
| **សរុប** | **១.០៧៨.៥៩៥** | **១.១៣៦.៧០៧** | **១.០០២.៣៤១** | **៩១០.០០០** | **១.០០០.០០០** | **៨៦៦.៦៦៧** |

[a] ប្រភេទសមុខរបរមានក្នុងបង្គោលនេះ បានមកពីចំណាត់ថ្នាក់មុខរបរតាមស្តង់ដារអន្តរជាតិ ឆ្នាំ២០០៨ (ISCO-08)។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

តារាង ៧.៣ បង្ហាញថា អ្នកធ្វើការខាងអចលនទ្រព្យបានទទួលប្រាក់ឈ្នួលប្រចាំខែជាមធ្យមខ្ពស់ជាងគេ (២.១០៦.២៤៧ រៀល ឬ ៥២៦,៦០ ដុល្លារអាមេរិក) បន្ទាប់មកអ្នកធ្វើការក្នុងសកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា (១.៧៨៣.២២៣ រៀល ឬ ៤៤៥,៨០ ដុល្លារអាមេរិក) រដ្ឋបាលសាធារណៈ និងការពារ សន្តិសុខសង្គមជាកាតព្វកិច្ច (១.៦៤៨.៣៩៨ រៀល ឬ ៤១២,១០ ដុល្លារអាមេរិក) និងសកម្មភាពសុខភាពមនុស្ស និងកិច្ចការសង្គម (១.៥៨២.៨៣៧ រៀល ឬ ៣៩៥,៧០ ដុល្លារអាមេរិក)។ តារាងនេះក៏បង្ហាញផងដែរថា ស្រីមានប្រាក់ឈ្នួលប្រចាំខែជាមធ្យមខ្ពស់ជាងប្រុសនៅក្នុងវិស័យអចលនទ្រព្យ (២.៣០០.៦៣៩ រៀល ឬ ៥៧៥,២០ ដុល្លារអាមេរិក) ព័ត៌មាន និងទំនាក់ទំនង (១.៧៨៩.៥១០ រៀល ឬ ៤៤៧,៤០ ដុល្លារអាមេរិក) និងសិល្បៈ កម្សាន្ត និងសប្បាយ (១.៤២៦.១២៣ រៀល ឬ ៣៥៦,៥០ ដុល្លារអាមេរិក)។

### តារាង ៧.៣. ប្រាក់ឈ្នួលប្រចាំខែជាមធ្យម និងជាមេដ្យាន តាមសកម្មភាពសេដ្ឋកិច្ច និងភេទ
(ជារៀល)

| សកម្មភាពសេដ្ឋកិច្ច [a] | ប្រាក់ឈ្នួលប្រចាំខែជាមធ្យម | | | ប្រាក់ឈ្នួលប្រចាំខែជាមេដ្យាន | | |
|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| **កសិកម្ម** | **៧០២.០៦១** | **៧៥៤.៤៦៤** | **៦៤១.៨៧៣** | **៦០០.០០០** | **៦៥០.០០០** | **៥៤១.៦៦៧** |
| **ឧស្សាហកម្ម** | **១.០០៧.២០៦** | **១.០១៥.៩៥៧** | **៩៩៧.១៩៤** | **៩០០.០០០** | **៩០០.០០០** | **៩០០.០០០** |
| រុករករ៉ែ និងថ្ម | ៩៦៧.៥១៨ | ១.០៤៩.៣២៣ | ៦៤១.៦៧០ | ៩០០.០០០ | ៩០០.០០០ | ៨០០.០០០ |
| ការផលិត | ១.០៣២.១៥០ | ១.០៥៦.០០១ | ១.០២០.១៥៣ | ៩៥៣.៣៣៣ | ៩៩៦.៦៦៧ | ៩៥៣.៣៣៣ |
| ផ្គត់ផ្គង់អគ្គិសនី ឧស្ម័ន ចំហាយ និងម៉ាស៊ីនត្រជាក់ | ១.០៥២.០៤៣ | ១.១៥៧.៩៩៣ | ៦៨១.៥៥៧ | ៧៦០.០០០ | ៨០០.០០០ | ៧២០.០០០ |
| ផ្គត់ផ្គង់ទឹក គ្រប់គ្រងសំរាម លូទឹក និងសកម្មភាពកែលម្អ | ៦៩១.៧០៥ | ៧១០.១៩២ | ៦៣០.៩៦១ | ៨០០.០០០ | ៨០០.០០០ | ៦០០.០០០ |
| សំណង់ | ៩៧០.៨៦៦ | ៩៩១.៧៥៨ | ៨៦៧.២៦៣ | ៨៦៦.៦៦៧ | ៨៦៦.៦៦៧ | ៧៥៨.៣៣៣ |
| **សេវាកម្ម** | **១.២៦៤.៦៤៤** | **១.៣៥២.១៤៨** | **១.១២២.៧៣៥** | **១.១០០.០០០** | **១.២០០.០០០** | **១.០០០.០០០** |
| លក់ដុំ និងលក់រាយ ជួសជុលយានយន្ត | ១.០២៣.៨៧១ | ១.១៦៦.០៦៦ | ៨៥៨.៦៣៩ | ៨០០.០០០ | ១.០០០.០០០ | ៧៤០.០០០ |
| ដឹកជញ្ជូន និងស្តុកទំនិញ | ១.០៤៥.៩៩៩ | ១.០៥២.៦៧១ | ៩៧៧.៣០៣ | ៩០០.០០០ | ៩១០.០០០ | ៨៦៦.៦៦៧ |
| សកម្មភាពសេវាកម្មស្នាក់នៅ និងអាហារ | ៨៥៨.៦៨៦ | ១.០០១.៣៧០ | ៧៦៨.៩១៨ | ៧២០.០០០ | ៨៦៦.៦៦៧ | ៦០០.០០០ |
| ព័ត៌មាន និងទំនាក់ទំនង | ១.៣៩៣.១៧៩ | ១.២៤០.០២៨ | ១.៧៨៩.៥១០ | ១.២០០.០០០ | ១.២០០.០០០ | ១.០០០.០០០ |
| សកម្មភាពហិរញ្ញវត្ថុ និងធានារ៉ាប់រង | ១.៤៥២.២៥១ | ១.៤៨៧.១១៩ | ១.៣៩០.០៥៤ | ១.២០០.០០០ | ១.២០០.០០០ | ១.២០០.០០០ |
| សកម្មភាពអចលនទ្រព្យ | ២.១០៦.២៤៧ | ១.៩២៨.៨០១ | ២.៣០០.៦៣៩ | ១.៥១៦.៦៦៧ | ១.៥១៦.៦៦៧ | ១.២០០.០០០ |
| សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្រ្ត និងបច្ចេកវិទ្យា | ១.៧៨៣.២២៣ | ១.៩៩៨.៨៥៦ | ១.៥៩៩.១៩២ | ១.៣០០.០០០ | ១.៥០០.០០០ | ១.២០០.០០០ |
| សកម្មភាពរដ្ឋបាល និងសេវាកម្មគាំទ្រ | ១.០៣៨.៩២៩ | ១.០៦៩.៩០៨ | ៩៩៩.៨០៥ | ៨០០.០០០ | ៨០០.០០០ | ៧៦០.០០០ |
| រដ្ឋបាលសាធារណៈ និងការពារ សន្តិសុខសង្គមជាកាតព្វកិច្ច | ១.៦៤៨.៣៩៨ | ១.៦៩៦.៤០៣ | ១.៤៣៨.៥៨៤ | ១.៤០០.០០០ | ១.៤០០.០០០ | ១.៣០០.០០០ |
| អប់រំ | ១.៣៣០.៤០៧ | ១.៤០៣.០១៥ | ១.២៥០.០១៦ | ១.២៦០.០០០ | ១.៣០០.០០០ | ១.២០០.០០០ |
| សកម្មភាពសុខភាពមនុស្ស និងកិច្ចការសង្គម | ១.៥៨២.៨៣៧ | ១.៦២៧.១៣៦ | ១.៥៣៩.១៣៧ | ១.៣៨០.០០០ | ១.៤០០.០០០ | ១.៣០០.០០០ |
| សិល្បៈ កម្សាន្ត និងសប្បាយ | ១.៤១១.៩៨៥ | ១.៣៩៤.១៣០ | ១.៤២៦.១២៣ | ១.២០០.០០០ | ១.០៨០.០០០ | ១.៣០០.០០០ |
| សកម្មភាពសេវាកម្មដទៃទៀត | ៨៦៥.៤២៦ | ១.២៤៦.២៨៣ | ៥៤៥.១៨១ | ៦៥០.០០០ | ៨៦៦.៦៦៧ | ៤៨០.០០០ |
| សកម្មភាពគ្រួសារជានិយោជក និងសកម្មភាពផលិតទំនិញ និងសេវាកម្មត្រូវគ្នារបស់គ្រួសារសម្រាប់ប្រើប្រាស់ខ្លួនឯង | ៨៤៩.៤០៣ | ១.០៦៤.៤៥១ | ៦៨៣.៤៨៨ | ៦០០.០០០ | ៨៦៦.៦៦៧ | ៦០០.០០០ |
| សកម្មភាពអង្គការ និងអង្គភាពក្រៅប្រទេស | ១.២៩០.៧៥៩ | ១.៣១៨.០១៦ | ១.២៥៤.៩៤២ | ១.៣០០.០០០ | ១.៤០០.០០០ | ១.០០០.០០០ |
| **សរុប** | **១.០៧៨.៥៩៥** | **១.១៣៦.៧០៧** | **១.០០២.៣៤១** | **៩១០.០០០** | **១.០០០.០០០** | **៨៦៦.៦៦៧** |

[a] ប្រភេទសកម្មភាពសេដ្ឋកិច្ចមានក្នុងបង្គោលនេះ បានមកពីចំណាត់ថ្នាក់សកម្មភាពសេដ្ឋកិច្ចតាមស្តង់ដារអន្តរជាតិ ជំនាន់ ៤ (ISIC Rev4)។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

ដូចបានបង្ហាញក្នុងតារាង ៧.៤ ប្រាក់ឈ្នួលប្រចាំខែជាមធ្យម ជាទូទៅកើនឡើងទៅតាមអាយុ លើកលែងអ្នកធ្វើការអាយុ ៣៥-៤៤ និង ៦៥ ឆ្នាំឡើង។ យុវជនអាយុ ១៥-២៤ ឆ្នាំ គឺជានិយោជិតមានប្រាក់ឈ្នួលទាបជាងគេ ជាមួយប្រាក់ឈ្នួលប្រចាំខែជាមធ្យម ៩៤៦.៨៤៦ រៀល (២៣៦,៧០ ដុល្លារអាមេរិក) និងប្រាក់ឈ្នួលប្រចាំខែជាមេដ្យាន ៨៦៦.៦៦៧ រៀល (២១៦,៧០ ដុល្លារអាមេរិក)។ ដោយមិនគិតពីអាយុ ទាំងប្រាក់ឈ្នួលប្រចាំខែជាមធ្យម និងជាមេដ្យានរបស់និយោជិតស្រីមានទាបជាងនិយោជិតប្រុស។ ទោះជាយ៉ាងណាក៏ដោយ ស្រីអាយុ ១៥-២៤ ឆ្នាំ រកបានប្រាក់ឈ្នួលប្រចាំខែជាមធ្យមខ្ពស់បន្តិចជាងប្រុស។

តារាង ៧.៤ ក៏បង្ហាញផងដែរថា ប្រាក់ឈ្នួលប្រចាំខែជាមធ្យម និងជាមេដ្យានរបស់ស្រីបានធ្លាក់ចុះចាប់ពីអាយុ ៣៥ ឆ្នាំ។ នេះអាចបណ្តាលមកពីការពិតដែលថាស្ត្រីនៅប្រទេសកម្ពុជា ជាប្រពៃណីស្ត្រីបានចាកចេញពីទីផ្សារការងារ ដើម្បីទទួលយកការទទួលខុសត្រូវក្នុងគ្រួសារ ដូចជាការមើលថែទាំកូន ឬសមាជិកផ្សេងទៀតក្នុងគ្រួសារ។ ការអនុវត្តនេះអាចនាំឲ្យមិនត្រឹមតែការផ្លាស់ប្តូរម៉ោងធ្វើការធម្មតារបស់ពួកគេប៉ុណ្ណោះទេ ប៉ុន្តែក៏អាចរំខានដល់ការងារ ឬអាជីពរបស់ពួកគេផងដែរ។ នៅពេលដែលស្ត្រីទាំងនេះបានចូលទីផ្សារការងារឡើងវិញ ពួកគេច្រើនតែទទួលបានប្រាក់ឈ្នួល

ទាបជាងពេលដែលពួកគេរកបានពីមុន។ អង្កេតក៏បានរកឃើញថា ម៉ោងធ្វើការជាមធ្យមក្នុងមួយសប្តាហ៍របស់ស្ត្រីបានចាប់ផ្តើមធ្លាក់ចុះផងដែរ នៅពេលដែលពួកគេមានអាយុ ៣៥ ឆ្នាំ។

តារាង ៧.៤. ប្រាក់ឈ្នួលប្រចាំខែជាមធ្យម និងជាមេដ្យាន តាមក្រុមអាយុ និងភេទ

(ជារៀល)

| ក្រុមអាយុ | ប្រាក់ឈ្នួលប្រចាំខែជាមធ្យម | | | ប្រាក់ឈ្នួលប្រចាំខែជាមេដ្យាន | | |
|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| ១៥-២៤ | ៩៤៦.៨៤៦ | ៩៣៥.៦៧៤ | ៩៥៧.៥៥៥ | ៨៦៦.៦៦៧ | ៨៦៦.៦៦៧ | ៨៦៦.៦៦៧ |
| ២៥-៣៤ | ១.១២៥.៦២៩ | ១.១៤៩.១៤៦ | ១.០៩៦.២៤២ | ១.០០០.០០០ | ១.០០០.០០០ | ៩៩៦.៦៦៧ |
| ៣៥-៤៤ | ១.១០៥.០៤០ | ១.១៨៨.៥១៩ | ៩៨២.៣៩៥ | ៩៦០.០០០ | ១.០០០.០០០ | ៨៦៦.៦៦៧ |
| ៤៥-៥៤ | ១.២២០.២៩១ | ១.៣៥៦.៧០៧ | ៩១១.៧១៣ | ១.០០០.០០០ | ១.២០០.០០០ | ៧៥៨.៣៣៣ |
| ៥៥-៦៤ | ១.១១៤.៦១៤ | ១.២៧០.៥៤៧ | ៧២៤.៩៣៦ | ៨៦៦.៦៦៧ | ១.០០០.០០០ | ៥៥០.០០០ |
| ៦៥+ | ១.០១៩.៥០៦ | ១.០៧១.៥៣៦ | ៩០៦.១៥៧ | ៦៥០.០០០ | ៧៨០.០០០ | ៤៣៣.៣៣៣ |
| **សរុប** | **១.០៧៨.៥៩៥** | **១.១៣៦.៧០៧** | **១.០០២.៣៤១** | **៩១០.០០០** | **១.០០០.០០០** | **៨៦៦.៦៦៧** |

ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

តារាង ៧.៥ បង្ហាញថា ប្រាក់ឈ្នួលប្រចាំខែជាមធ្យម និងជាមេដ្យានរបស់និយោជិតនៅតំបន់ទីប្រជុំជនមានខ្ពស់ជាងនិយោជិតរស់នៅតំបន់ជនបទ។ លើសពីនេះទៀត និយោជិតស្រីនៅតំបន់ជនបទមានប្រាក់ឈ្នួលប្រចាំខែជាមធ្យម និងជាមេដ្យានទាបជាងគេ។

តារាង ៧.៥. ប្រាក់ឈ្នួលប្រចាំខែជាមធ្យម និងជាមេដ្យាន តាមតំបន់ និងភេទ

(ជារៀល)

| តំបន់ | ប្រាក់ឈ្នួលប្រចាំខែជាមធ្យម | | | ប្រាក់ឈ្នួលប្រចាំខែជាមេដ្យាន | | |
|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| ទីប្រជុំជន | ១.២៥២.០៩២ | ១.៣៥៣.២២៦ | ១.១១៤.៩២៥ | ១.០០០.០០០ | ១.២០០.០០០ | ១.០០០.០០០ |
| ជនបទ | ៩៧០.៥៤៩ | ៩៩៨.៧១៩ | ៩៣៤.៣៣៥ | ៨៦៦.៦៦៧ | ៨៦៦.៦៦៧ | ៨៤០.០០០ |
| **សរុប** | **១.០៧៨.៥៩៥** | **១.១៣៦.៧០៧** | **១.០០២.៣៤១** | **៩១០.០០០** | **១.០០០.០០០** | **៨៦៦.៦៦៧** |

ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

# ជំពូក ៨
# ម៉ោងធ្វើការ

## ៨.១ សេចក្តីផ្តើម

ជំពូកនេះបង្ហាញលទ្ធផលអំពីម៉ោងធ្វើការរបស់អ្នកធ្វើការ រួមទាំងម៉ោងធ្វើការលើសក្នុងមួយសប្តាហ៍ និងភាពមានការងារធ្វើមិនគ្រប់គ្រាន់ទាក់ទងនឹងពេលវេលា។ អង្កេតបានប្រមូលព័ត៌មានលម្អិតអំពីម៉ោងធ្វើការក្នុងចំណោមអ្នកមានការងារធ្វើ អាយុ ១៥ ឆ្នាំឡើង។ អ្នកឆ្លើយត្រូវបានសួរអំពីចំនួនម៉ោង និងថ្ងៃ ដែលពួកគេធ្វើការជាធម្មតាក្នុងមួយសប្តាហ៍ ក្នុងការងារចម្បង និងការងារទីពីររបស់ពួកគេ។ ដូចគ្នានេះ ពួកគេត្រូវបានសួរអំពីចំនួនម៉ោងដែលពួកគេបានធ្វើការជាក់ស្តែងតាមថ្ងៃនីមួយៗ ក្នុងរយៈពេល ៧ ថ្ងៃ មុនសម្ភាសន៍អង្កេត។

## ៨.២ ម៉ោងធ្វើការ

ពាក្យ "ម៉ោងធម្មតា" សំដៅលើចំនួនម៉ោងធម្មតាដែលអ្នកធ្វើការបានធ្វើការក្នុងរយៈពេលខ្លីយោង ដូចជាមួយសប្តាហ៍។ "ម៉ោងជាក់ស្តែង" នៃការងារក្នុងមួយសប្តាហ៍ សំដៅលើពេលវេលាដែលអ្នកធ្វើការបានចំណាយដោយផ្ទាល់ពិតប្រាកដ និងទាក់ទងទៅនឹងសកម្មភាពការងារ ពេលវេលាផ្អាកសកម្មភាព និងពេលវេលាសម្រាក ក្នុងរយៈពេលយោង។ ផ្នែកនេះផ្តោតលើម៉ោងធ្វើការជាមធ្យមប្រចាំសប្តាហ៍ (ធម្មតា និងជាក់ស្តែង) នៅក្នុងការងារចម្បង។ ម៉ោងធ្វើការជាមធ្យមប្រចាំសប្តាហ៍ត្រូវបានវិភាគ តាមភេទ មុខរបរ សកម្មភាពសេដ្ឋកិច្ច និងវិស័យ។

រូប ៨.១ បង្ហាញចំនួនម៉ោងធម្មតាជាមធ្យម និងម៉ោងជាក់ស្តែងជាមធ្យមក្នុងមួយសប្តាហ៍ ដោយអ្នកធ្វើការ អាយុ ១៥ ឆ្នាំឡើង។ យោងតាមលទ្ធផលដែលបានបង្ហាញ ចំនួនម៉ោងធម្មតាជាមធ្យម និងម៉ោងជាក់ស្តែងជាមធ្យមទាំងប្រុស និងស្រីមិនខុសគ្នាគួរឲ្យកត់សម្គាល់ឡើយ រវាងតំបន់ទីប្រជុំជន និងតំបន់ជនបទ។ ចំពោះភេទ បានសង្កេតឃើញថាប្រុសមានចំនួនម៉ោងធ្វើការធម្មតាជាមធ្យម និងម៉ោងធ្វើការជាក់ស្តែងជាមធ្យម ច្រើនជាងចំនួនម៉ោងធម្មតា និងម៉ោងជាក់ស្តែងរបស់ស្រី នៅតំបន់ជនបទ។ ផ្ទុយទៅវិញ ស្រីមានចំនួនម៉ោងធ្វើការធម្មតាជាមធ្យម និងម៉ោងធ្វើការជាក់ស្តែងជាមធ្យម ច្រើនជាងចំនួនម៉ោងធម្មតា និងម៉ោងជាក់ស្តែងរបស់ប្រុស នៅតំបន់ទីប្រជុំជន។

រូប ៨.១. ម៉ោងធ្វើការជាមធ្យមក្នុងមួយសប្តាហ៍ ក្នុងការងារចម្បង តាមតំបន់ និងភេទ




ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

ជាសរុប ចំនួនម៉ោងធ្វើការធម្មតាជាមធ្យមក្នុងមួយសប្តាហ៍ ប្រុសមាន ៤៦,៣ ម៉ោង និងស្រី ៤៥,៦ ម៉ោង។ ប្រុសមានចំនួនម៉ោងធ្វើការធម្មតាយូរជាងស្រីក្នុងគ្រប់មុខរបរទាំងអស់ លើកលែងតែមុខរបរជាអ្នកជំនួយការស្មៀន និងអ្នកផ្តល់សេវាកម្ម និងលក់។ អ្នកធ្វើការក្នុងជំនាញកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានចំនួម៉ោងធ្វើការតិចជាងគេក្នុងមួយសប្តាហ៍ទាំងពីរភេទ៖ ប្រុសជាមធ្យមមាន ៣៤,៤ ម៉ោង និងស្រីជាមធ្យម ២៩,៧ ម៉ោង ហើយក្នុងករណីទាំងពីរនេះ ប្រហែលដោយសារបញ្ហារដូវកាល (រូប ៨.២)។

រូប ៨.២. ម៉ោងធ្វើការធម្មតាជាមធ្យមក្នុងមួយសប្តាហ៍ ក្នុងការងារចម្បង តាមមុខរបរ និងភេទ




ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

ដូចបានបង្ហាញក្នុងរូប ៨.៣ ម៉ោងធ្វើការជាក់ស្តែងជាមធ្យមក្នុងការងារចម្បងក្នុងរយៈពេលយោង ប្រុសមានចំនួនម៉ោងខ្ពស់បន្តិច (៤៥,៦ ម៉ោង) ជាងចំនួនម៉ោងរបស់ស្រី (៤៥,២ ម៉ោង) ក្នុងមួយសប្តាហ៍។ លំនាំដូចគ្នានេះត្រូវបានសង្កេតឃើញក្នុងគ្រប់មុខរបរទាំងអស់ លើកលែងតែមុខរបរជាអ្នកជំនួយការស្មៀន និងអ្នកផ្តល់សេវាកម្ម និងលក់ កងកម្លាំងប្រដាប់អាវុធ និង (ខុសគ្នាបន្តិច) សិប្បករ និងអាជីវកម្មពាក់ព័ន្ធ ដែលស្រីបានធ្វើការយូរជាង។

រូប ៨.៣. ម៉ោងធ្វើការជាក់ស្តែងជាមធ្យមក្នុងមួយសប្តាហ៍ ក្នុងការងារចម្បង តាមមុខរបរ និងភេទ




ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

## ៨.៣ ម៉ោងធ្វើការជាមធ្យមតាមសកម្មភាពសេដ្ឋកិច្ច

តារាង ៨.១ បង្ហាញម៉ោងធ្វើការធម្មតាជាមធ្យមក្នុងមួយសប្តាហ៍ តាមសកម្មភាពសេដ្ឋកិច្ច និងភេទ ក៏ដូចជាម៉ោងធ្វើការជាក់ស្តែងជាមធ្យម ក្នុងរយៈពេលយោង។ ម៉ោងធ្វើការធម្មតាយូរជាងគេក្នុងមួយសប្តាហ៍ត្រូវបានសង្កេតឃើញនៅក្នុងការរុករករ៉ែ និងថ្ម (៦១,៦ ម៉ោង) លក់ដុំ និងរាយ (៥៧,៨ ម៉ោង) ដឹកជញ្ជូន និងស្តុកទំនិញ (៥៤,៧ ម៉ោង) សកម្មភាពសេវាកម្មដទៃទៀត (៥៤,២ ម៉ោង) សកម្មភាពរដ្ឋបាល និងសេវាកម្មគាំទ្រ (៥២,៦ ម៉ោង) សំណង់ (៥១,៧ ម៉ោង) សិល្បៈ កម្សាន្ត និងសប្បាយ (៥១,១ ម៉ោង) សេវាកម្មស្នាក់នៅ និងអាហារ (៥១,០ ម៉ោង) និងការផលិត (៥០,១ ម៉ោង)។ ម៉ោងធម្មតាជាមធ្យមធ្វើការខាងរុករករ៉ែនិងថ្ម ផ្គត់ផ្គង់ទឹកនិងលូ សំណង់ លក់ដុំនិងរាយ ព័ត៌មាននិងទំនាក់ទំនង ហិរញ្ញវត្ថុនិងធានារ៉ាប់រង សិល្បៈកម្សាន្តនិងសប្បាយ និងគ្រួសារឯកជនក្នុងចំណោមស្រីក៏មានច្រើនម៉ោងជាងប្រុសផងដែរ។ ផ្ទុយទៅវិញ ប្រុសធ្វើការច្រើនម៉ោងជាងស្រីខាងអចលនទ្រព្យ (៣៦,២ ម៉ោង ទល់នឹង ១៩,២ ម៉ោង)។ លំនាំដូចគ្នានេះត្រូវបានរកឃើញក្នុងម៉ោងធ្វើការជាក់ស្តែងជាមធ្យម នៅក្នុងគ្រប់ក្រុមសកម្មភាពសេដ្ឋកិច្ច។

តារាង ៨.១. ម៉ោងធ្វើការជាមធ្យមក្នុងមួយសប្តាហ៍ ក្នុងការងារចម្បង តាមសកម្មភាពសេដ្ឋកិច្ច និងភេទ

| សកម្មភាពសេដ្ឋកិច្ច [a] | ម៉ោងធ្វើការធម្មតាជាមធ្យម | | | ម៉ោងធ្វើការជាក់ស្តែងជាមធ្យម | | |
|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៣៤,៧ | ៣៦,៨ | ៣២,៣ | ៣៤,៤ | ៣៦,៦ | ៣២,០ |
| រុករករ៉ែ និងថ្ម | ៦១,៦ | ៦០,៧ | ៦៤,២ | ៥៨,៧ | ៥៦,៨ | ៦៤,២ |
| ការផលិត | ៥០,១ | ៥១,០ | ៤៩,៦ | ៥១,៥ | ៥១,៣ | ៥១,៦ |
| ផ្គត់ផ្គង់អគ្គិសនី ឧស្ម័ន ចំហាយ និងម៉ាស៊ីនត្រជាក់ | ៤៦,៩ | ៤៧,៥ | ៤៤,៤ | ៤៧,១ | ៤៧,៧ | ៤៤,៤ |
| ផ្គត់ផ្គង់ទឹក គ្រប់គ្រងសំរាម លូទឹក និងសកម្មភាពកែលម្អ | ៤៥,៦ | ៤៥,១ | ៤៦,៤ | ៤៥,៦ | ៤៥,១ | ៤៦,៤ |
| សំណង់ | ៥១,៧ | ៥១,៧ | ៥២,០ | ៥១,២ | ៥១,២ | ៥១,៤ |
| លក់ដុំ និងលក់រាយ ជួសជុលយានយន្ត | ៥៧,៨ | ៥៦,៩ | ៥៨,៣ | ៥៥,៧ | ៥៥,២ | ៥៦,០ |
| ដឹកជញ្ជូន និងស្តុកទំនិញ | ៥៤,៧ | ៥៤,៩ | ៥០,៣ | ៥៣,១ | ៥៣,៣ | ៥០,៥ |
| សកម្មភាពសេវាកម្មស្នាក់នៅ និងអាហារ | ៥១,០ | ៥២,៣ | ៥០,៣ | ៥០,៥ | ៥១,៥ | ៤៩,៩ |
| ព័ត៌មាន និងទំនាក់ទំនង | ៤៩,៥ | ៤៨,៩ | ៥១,១ | ៤៥,៩ | ៤៥,១ | ៤៨,០ |
| សកម្មភាពហិរញ្ញវត្ថុ និងធានារ៉ាប់រង | ៤៣,៧ | ៤៣,០ | ៤៤,៩ | ៤១,៩ | ៤១,០ | ៤៣,២ |
| សកម្មភាពអចលនទ្រព្យ | ២៩,៥ | ៣៦,២ | ១៩,២ | ២៦,២ | ៣១,១ | ១៨,២ |
| សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | ៤៧,៩ | ៤៨,១ | ៤៧,៧ | ៤៣,៨ | ៤៣,៤ | ៤៤,២ |
| សកម្មភាពរដ្ឋបាល និងសេវាកម្មគាំទ្រ | ៥២,៦ | ៥៤,៦ | ៥០,៣ | ៥១,១ | ៥២,៣ | ៤៩,៤ |
| រដ្ឋបាលសាធារណៈ និងការពារ សន្តិសុខសង្គមជាកាតព្វកិច្ច | ៤៥,៤ | ៤៦,០ | ៤២,៩ | ៤៣,២ | ៤៣,៦ | ៤១,២ |
| អប់រំ | ៣១,៩ | ៣២,៣ | ៣១,៤ | ៣១,៩ | ៣២,២ | ៣១,៥ |
| សកម្មភាពសុខភាពមនុស្ស និងកិច្ចការសង្គម | ៤៧,៥ | ៤៨,៦ | ៤៦,៣ | ៤៨,១ | ៤៩,០ | ៤៧,១ |
| សិល្បៈ កម្សាន្ត និងសប្បាយ | ៥១,១ | ៤៩,១ | ៥៣,០ | ៥០,១ | ៤៩,០ | ៥១,០ |
| សកម្មភាពសេវាកម្មដទៃទៀត | ៥៤,២ | ៤៨,៩ | ៥៧,២ | ៥១,១ | ៤៦,៩ | ៥៣,៥ |
| សកម្មភាពគ្រួសារជានិយោជក និងសកម្មភាពផលិតទំនិញ និងសេវាកម្មត្រូវគ្នារបស់គ្រួសារសម្រាប់ប្រើប្រាស់ខ្លួនឯង | ៤៥,៧ | ៤៤,១ | ៤៦,៧ | ៤៥,៥ | ៤៤,៤ | ៤៦,១ |
| សកម្មភាពអង្គការ និងអង្គភាពក្រៅប្រទេស | ៤៤,៧ | ៤៦,៤ | ៤២,១ | ៤៤,៧ | ៤៦,៤ | ៤២,១ |
| **សរុប** | **៤៥,៩** | **៤៦,៣** | **៤៥,៦** | **៤៥,៤** | **៤៥,៦** | **៤៥,២** |

[a] ប្រភេទសកម្មភាពសេដ្ឋកិច្ចមានក្នុងបង្គោលនេះ បានមកពីចំណាត់ថ្នាក់សកម្មភាពសេដ្ឋកិច្ចតាមស្តង់ដារអន្តរជាតិ ជំនាន់ ៤ (ISIC Rev4)។
សង្កេត៖ ទំហំសំណាកគំរូរបស់សកម្មភាពអចលនទ្រព្យ ប្រុសមាន ៣៧ និងស្រីមាន ១៨ (អាចផ្តល់ម៉ោងធ្វើការធម្មតាទាបខ្លាំងសម្រាប់ស្រី)។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

## ៨.៤ ម៉ោងធ្វើការធម្មតាជាមធ្យមតាមវិស័យ

រូប ៨.៤ បង្ហាញម៉ោងធ្វើការធម្មតាជាមធ្យមក្នុងមួយសប្តាហ៍ក្នុងការងារចម្បង តាមវិស័យ និងភេទ។ ម៉ោងធ្វើការធម្មតាជាមធ្យមរបស់ប្រុស និងស្រី មិនខុសគ្នាខ្លាំងគួរឲ្យកត់សម្គាល់ឡើយក្នុងវិស័យកសិកម្មក្នុងប្រព័ន្ធ មិនមែនកសិកម្មក្នុងប្រព័ន្ធ និងមិនមែនកសិកម្មក្រៅប្រព័ន្ធ។ ទោះជាយ៉ាងណាក៏ដោយ ប្រុសបានធ្វើការម៉ោងធម្មតាក្នុងមួយសប្តាហ៍ច្រើនជាងស្រីនៅក្នុងវិស័យកសិកម្មក្រៅប្រព័ន្ធ (៣៦,៦ ទល់នឹង ៣២,២ ម៉ោង)។

រូប ៨.៤. ម៉ោងធ្វើការធម្មតាជាមធ្យមក្នុងមួយសប្តាហ៍ ក្នុងការងារចម្បង តាមវិស័យ និងភេទ




ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

## ៨.៥ ម៉ោងធ្វើការធម្មតាជាមធ្យមតាមក្រុមអាយុ

រូប ៨.៥ បង្ហាញថាភាគច្រើននៃក្រុមអាយុ ប្រុសធ្វើការច្រើនម៉ោងជាងស្រី។ ចំនួនម៉ោងធ្វើការធម្មតាជាមធ្យមបានកើនឡើងក្នុងអាយុពី ១៥ ទៅ ៣៤ ឆ្នាំ ហើយបន្ទាប់មកចំនួនម៉ោងធ្វើការធម្មតាជាមធ្យមបានធ្លាក់ចុះវិញ។

រូប ៨.៥. ម៉ោងធ្វើការធម្មតាជាមធ្យមក្នុងមួយសប្តាហ៍ ក្នុងការងារចម្បង តាមក្រុមអាយុ និងភេទ




ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

## ៨.៦ ធ្វើការលើសម៉ោង

មាត្រា ១៣៧ នៃច្បាប់ស្តីពីការងារកម្ពុជា (ក្នុងផ្នែក ២ អំពីថិរវេលាធ្វើការ ថិរវេលាប្រចាំថ្ងៃ និងប្រចាំសប្តាហ៍) បានចែងថា ក្នុងគ្រឹះស្ថានប្រភេទណាក៏ដោយ ទោះបីគ្រឹះស្ថាននោះមានលក្ខណៈជាការសិក្សាវិជ្ជាជីវៈ ឬជាកិច្ចកុសល ព្រមទាំងនៅក្នុងវិជ្ជាជីវៈសេរីក៏ដោយ ថិរវេលាធ្វើការពេញលេញនៃកម្មករនិយោជិតទាំងពីរភេទមិនត្រូវឲ្យលើសពីប្រាំបីម៉ោង ក្នុងមួយថ្ងៃ ឬ ៤៨ ម៉ោងក្នុងមួយសប្តាហ៍ឡើយ។ សូចនាករធ្វើការលើសម៉ោងផ្តល់ព័ត៌មានអំពីសមាមាត្រនៃអ្នកធ្វើការដែលធ្វើការលើស ៤៨ ម៉ោងក្នុងមួយសប្តាហ៍។

លទ្ធផលអង្កេតបង្ហាញថាប្រមាណ ៣៦,០% នៃអ្នកធ្វើការទាំងអស់ បានធ្វើការម៉ោងធម្មតាច្រើនជាង ៤៨ ម៉ោងក្នុងមួយសប្តាហ៍ (ប្រុស ៣៦,៨% និងស្រី ៣៥,១%)។ ដូចបានបង្ហាញក្នុងតារាង ៨.២ ប្រមាណ ៤០% នៃអ្នកធ្វើការអាយុ ៣៥-៤៤ ឆ្នាំ បានធ្វើការម៉ោងធម្មតាច្រើនជាង ៤៨ ម៉ោង ក្នុងមួយសប្តាហ៍ បន្ទាប់មកអ្នកធ្វើការអាយុ ២៥-៣៤ ឆ្នាំ មាន ៣៧,១% និងអ្នកធ្វើការអាយុ ៤៥-៥៤ ឆ្នាំ មាន ៣៦,៦%។ ផ្ទុយទៅវិញ អ្នកធ្វើការអាយុ ៦៥ ឆ្នាំឡើង មានតែ ២៥,៥%។

តារាង ៨.២. អ្នកធ្វើការលើសម៉ោងធ្វើការធម្មតាក្នុងមួយសប្តាហ៍ ក្នុងការងារចម្បង តាមក្រុមអាយុ និងភេទ

| ក្រុមអាយុ | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
|---|---|---|---|---|---|---|
| | (ចំនួន) | | | (% នៃអ្នកមានការងារធ្វើទាំងអស់)[a] | | |
| ១៥-២៤ | ៥០៥.៤៧០ | ២៦៥.៧៥៦ | ២៣៩.៧១៤ | ៣៣,៦ | ៣៦,២ | ៣១,២ |
| ២៥-៣៤ | ៨៣៥.៣៩២ | ៤៥៤.៤៥៥ | ៣៨០.៩៣៧ | ៣៧,១ | ៣៨,៧ | ៣៥,៤ |
| ៣៥-៤៤ | ៧១២.៩៩៩ | ៣៧១.៧៨៤ | ៣៤១.២១៥ | ៤០,០ | ៣៩,៦ | ៤០,៤ |
| ៤៥-៥៤ | ៤៦១.០៩០ | ២៤៩.៤១៧ | ២១១.៦៧៤ | ៣៦,៦ | ៣៦,២ | ៣៧,២ |
| ៥៥-៦៤ | ២៤៧.៨២៦ | ១៣៣.៧៥៣ | ១១៤.០៧៣ | ៣១,៥ | ៣១,៦ | ៣១,៤ |
| ៦៥+ | ៧៧.០៧០ | ៤១.៥៩០ | ៣៥.៤៧៩ | ២៥,៥ | ២៦,៣ | ២៤,៦ |
| **សរុប** | **២.៨៣៩.៨៤៨** | **១.៥១៦.៧៥៥** | **១.៣២៣.០៩៣** | **៣៦,០** | **៣៦,៨** | **៣៥,១** |

[a] តម្លៃនៅក្នុងជួរឈរទាំងបីនេះតំណាងឲ្យភាគរយនៃអ្នកធ្វើការក្នុងចំណោមប្រុស ស្រី ឬទាំងពីរភេទ នៅក្នុងក្រុមអាយុនីមួយៗ ដែលបានធ្វើការលើសម៉ោង និងដូចគ្នាក្នុងចំណោមអ្នកមានការងារធ្វើសរុប អាយុ ១៥ ឆ្នាំឡើង។
សម្គាល់៖ សរុបអាចមិនស្មើផលបូក ដោយសារការបង្គត់លេខ។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

## ៨.៧ ភាពមានការងារធ្វើមិនគ្រប់គ្រាន់ទាក់ទងនឹងពេលវេលា

ទិន្នន័យអំពីភាពមានការងារធ្វើមិនគ្រប់គ្រាន់ទាក់ទងនឹងពេលវេលា ត្រូវបានប្រមូលសម្រាប់អ្នកធ្វើការ អាយុ ១៥ ឆ្នាំឡើង ដោយផ្អែកលើសំណួរ "តើអ្នកចង់ធ្វើការច្រើនម៉ោងក្នុងមួយសប្តាហ៍ច្រើនជាងការងារដែលអ្នកតែងតែធ្វើជាធម្មតា ដើម្បីផ្តល់ប្រាក់ឈ្នួលក្រៅម៉ោងថែមទៀតឬទេ?"។ អ្នកមានការងារធ្វើគ្រប់គ្នាត្រូវបានសួរ៖ "ក្នុងរយៈពេលបួនសប្តាហ៍ចុងក្រោយ ចាប់ពី [កាលបរិច្ឆេទជាក់លាក់] ដល់ [ថ្ងៃចុងក្រោយ ឬម្សិលមិញ] តើអ្នកបានស្វែងរកការងារបន្ថែម ឬការងារមានប្រាក់ឈ្នួលផ្សេងទៀតឬទេ?"។ សំណួរនេះត្រូវបានបន្តដោយសំណួរទីបី៖ "តើអ្នកអាចចាប់ផ្តើមធ្វើការច្រើនម៉ោងក្នុងរយៈពេលពីរសប្តាហ៍ខាងមុខឬទេ?"។ ព័ត៌មានអំពីអ្នកធ្វើការដែលជាធម្មតាបានធ្វើការតិចជាង ៤០ ម៉ោង ក្នុងមួយសប្តាហ៍មុនអង្កេត បន្ទាប់មកត្រូវបានប្រើដើម្បីប៉ាន់ស្មានអ្នកមានការងារធ្វើមិនគ្រប់គ្រាន់។

លទ្ធផលអង្កេតបង្ហាញថា មានតែ ១,១% នៃអ្នកធ្វើការទាំងអស់បានឆ្លើយថាបានធ្វើការតិចជាង ៤០ ម៉ោង ក្នុងមួយសប្តាហ៍មុនអង្កេត (ប្រុសមាន ១,៣% និងស្រីមាន ០,៩%)។ យោងតាមតារាង ៨.៣ ប្រមាណ ២១,៨% នៃ

អ្នកមានការងារធ្វើមិនគ្រប់គ្រាន់មានអាយុ ១៥-២៤ ឆ្នាំ។ សមាមាត្រខ្ពស់ជាងគេនៃអ្នកមានការងារធ្វើមិនគ្រប់គ្រាន់ (២៥,១%) ត្រូវបានរកឃើញនៅក្នុងអាយុ ២៥-៣៤ ឆ្នាំ បន្ទាប់មកអ្នកមានអាយុ ៣៥-៤៤ ឆ្នាំ (១៩,៧%) អាយុ ៤៥-៥៤ ឆ្នាំ (១៨,៧%) និងអាយុ ៥៥-៦៤ ឆ្នាំ (១២,៦%)។ សមាមាត្រខ្ពស់ជាងគេនៃប្រុសមានការងារធ្វើមិនគ្រប់គ្រាន់ត្រូវបានរកឃើញនៅក្នុងអាយុ ២៥-៣៤ ឆ្នាំ (២៧,១%) ខណៈស្រីមានការងារធ្វើមិនគ្រប់គ្រាន់មានសមាមាត្រខ្ពស់ជាងគេនៅក្នុងអាយុ ១៥-២៤ ឆ្នាំ (២៥,០%)។ សមាមាត្រទាបជាងគេនៃអ្នកមានការងារធ្វើមិនគ្រប់គ្រាន់ត្រូវបានរាយការណ៍នៅក្នុងអាយុ ៦៥ ឆ្នាំឡើង (២,២%)។

### តារាង ៨.៣. អ្នកមានការងារធ្វើមិនគ្រប់គ្រាន់ទាក់ទងនឹងពេលវេលា តាមក្រុមអាយុ និងភេទ

| ក្រុមអាយុ | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
|---|---|---|---|---|---|---|
| | | (ចំនួន) | | | (%)[a] | |
| ១៥-២៤ | ១៨.២៨៨ | ១០.១៩២ | ៨.០៩៦ | ២១,៨ | ១៩,៨ | ២៥,០ |
| ២៥-៣៤ | ២១.០៨៧ | ១៣.៩៧៦ | ៧.១១២ | ២៥,១ | ២៧,១ | ២១,៩ |
| ៣៥-៤៤ | ១៦.៥៧៨ | ៨.៨៥៩ | ៧.៧២០ | ១៩,៧ | ១៧,២ | ២៣,៨ |
| ៤៥-៥៤ | ១៥.៦៦៩ | ៩.៦៧០ | ៥.៩៩៨ | ១៨,៧ | ១៨,៧ | ១៨,៥ |
| ៥៥-៦៤ | ១០.៥៥៩ | ៨.៥៥៩ | ២.០០០ | ១២,៦ | ១៦,៦ | ៦,២ |
| ៦៥+ | ១.៨២៣ | ៣២៦ | ១.៤៩៦ | ២,២ | ០,៦ | ៤,៦ |
| **សរុប** | **៨៤.០០៤** | **៥១.៥៨២** | **៣២.៤២២** | **១០០,០** | **១០០,០** | **១០០,០** |

[a] តម្លៃនៅក្នុងជួរឈរទាំងបីក្នុងផ្នែក "%" របស់តារាងតំណាងឲ្យភាគរយនៃចំនួនប្រុស ស្រី ឬសរុប (ទាំងពីរភេទ) មានការងារធ្វើមិនគ្រប់គ្រាន់ នៅក្នុងក្រុមអាយុនីមួយៗ។
សម្គាល់៖ សរុបអាចមិនស្មើផលបូក ដោយសារការបង្គត់លេខ។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

អត្រាអ្នកមានការងារធ្វើមិនគ្រប់គ្រាន់ទាក់ទងនឹងពេលវេលា ត្រូវបានកំណត់ជាភាគរយនៃអ្នកធ្វើការដែលបានធ្វើការម៉ោងធម្មតាតិចជាង ៤០ ម៉ោង ក្នុងមួយសប្តាហ៍ ហើយចង់ និងអាចធ្វើការច្រើនម៉ោងជាងចំនួនម៉ោងធម្មតារបស់ពួកគេ។ យោងតាមលទ្ធផលអង្កេត (មើលតារាង ៨.៤) អត្រាអ្នកមានការងារធ្វើមិនគ្រប់គ្រាន់សរុបមានកម្រិតទាបខ្លាំងនៅឆ្នាំ២០១៩ (១,១%)។

### តារាង ៨.៤. អត្រាអ្នកមានការងារធ្វើមិនគ្រប់គ្រាន់ តាមក្រុមអាយុ និងភេទ

| ក្រុមអាយុ | កម្ពុជា | | | ទីប្រជុំជន | | | ជនបទ | | |
|---|---|---|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| ១៥-២៤ | ១,២ | ១,៤ | ១,១ | ០,៦ | ០,២ | ១,០ | ១,៤ | ១,៨ | ១,១ |
| ២៥-៣៤ | ០,៩ | ១,២ | ០,៧ | ១,១ | ១,៤ | ០,៧ | ០,៨ | ១,០ | ០,៦ |
| ៣៥-៤៤ | ០,៩ | ០,៩ | ០,៩ | ០,៣ | ០,២ | ០,៤ | ១,៣ | ១,៤ | ១,២ |
| ៤៥-៥៤ | ១,២ | ១,៤ | ១,១ | ០,៤ | ០,៦ | ០,០ | ១,៧ | ១,៨ | ១,៥ |
| ៥៥-៦៤ | ១,៣ | ២,០ | ០,៦ | ១,៤ | ២,០ | ០,៧ | ១,៣ | ២,១ | ០,៥ |
| ៦៥+ | ០,៦ | ០,២ | ១,០ | ០,០ | ០,០ | ០,០ | ០,៩ | ០,៣ | ១,៥ |
| **សរុប** | **១,១** | **១,៣** | **០,៩** | **០,៧** | **០,៨** | **០,៦** | **១,២** | **១,៥** | **១,០** |

សម្គាល់៖ ភាគរយនៅក្នុងតារាងនេះ តំណាងដោយសមាមាត្រនៃអ្នកមានការងារធ្វើទាំងអស់នៅក្នុងក្រុមអាយុនីមួយៗ ដែលមានប្រុស ស្រី ឬសរុប (ទាំងពីរភេទ) មានការងារធ្វើមិនគ្រប់គ្រាន់។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

# ជំពូក ៩
# ការងារយុវជន

## ៩.១ សេចក្តីផ្តើម

ជំពូកនេះពិពណ៌នាអំពីចរិតលក្ខណៈយុវជន ដែលរួមមានប្រធានបទដូចជា យុវជនចូលរួមក្នុងកម្លាំងពលកម្ម យុវជនមានការងារធ្វើ និងយុវជនគ្មានការងារធ្វើ និងយុវជនមិនធ្វើការងារ មិនសិក្សា ឬបណ្តុះបណ្តាល (NEET)។ ផ្អែកតាមនិយមន័យអន្តរជាតិ អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩ បានឲ្យនិយមន័យ "យុវជន" ជាមនុស្សដែលមានអាយុ ១៥-២៤ ឆ្នាំ។[៣] សម្រាប់របាយការណ៍នេះ យុវជនត្រូវបានបែងចែកជាក្រុមអាយុវេងចន្លោះ ៥ ឆ្នាំ ចំនួនពីរក្រុមអាយុវេង៖ ១៥-១៩ ឆ្នាំ (យុវជនវ័យក្មេង) និង ២០-២៤ ឆ្នាំ (យុវជនពេញវ័យ)។

## ៩.២ យុវជនចូលរួមក្នុងកម្លាំងពលកម្ម

ចំនួនយុវជនក្នុងកម្លាំងពលកម្មបង្ហាញវិសាលភាពដែលយុវជនមានការងារធ្វើ អាចធ្វើការបាន និងសកម្មស្វែងរកការងារធ្វើក្នុងសេដ្ឋកិច្ច។

ដូចបានបង្ហាញក្នុងតារាង ៩.១ យុវជនជាង ១,៥ លាននាក់ ជាផ្នែកនៃកម្លាំងពលកម្មនៅឆ្នាំ២០១៩ ក្នុងនោះប្រុសមាន ៧៥៤.៧០៦ នាក់ និងស្រី ៧៨៦.៨៣៨ នាក់ តំណាងឲ្យ ៥៧,២% នៃកម្លាំងពលកម្មសរុប។ អត្រាចូលរួមក្នុងកម្លាំងពលកម្មរបស់យុវជននៅតំបន់ជនបទ (៦១,០%) ខ្ពស់ជាងនៅតំបន់ទីប្រជុំជន (៤៩,៤%)។ យុវជននៅតំបន់ជនបទ ជាពិសេសយុវជនវ័យក្មេងអាយុ ១៥-១៩ ឆ្នាំ មានទំនោរបោះបង់ការសិក្សាមុនពេល ដើម្បីទៅចូលរួមក្នុងទីផ្សារការងារ ភាគច្រើនដោយសារពួកគេខ្វះលទ្ធភាពទទួលបានការសិក្សា និងការបណ្តុះបណ្តាលបន្តទៀត។ ទោះជាយ៉ាងណាក៏ដោយ ទំនៀមទម្លាប់នេះអាចដាក់កម្រិតលើការងារ និងការរំពឹងអាជីពរបស់ពួកគេ នាពេលអនាគត។

[៣] អង្គការអន្តរជាតិខាងការងារ (ILO)។ និន្នាការការងារសកលសម្រាប់យុវជនឆ្នាំ២០១៥៖ បង្កើនការវិនិយោគសម្រាប់ការងារសមរម្យសម្រាប់យុវជន។ ហ្សឺណែវ៖ ការិយាល័យការងារអន្តរជាតិ នាយកដ្ឋានគោលនយោបាយការងារ។ https://www.ilo.org/wcmsp5/groups/public/---dgreports/---dcomm/---publ/documents/publication/wcms_412015.pdf.

តារាង ៩.១. យុវជនចូលរួមក្នុងកម្លាំងពលកម្ម តាមក្រុមអាយុ តំបន់ និងភេទ

| ក្រុមអាយុ | កម្ពុជា | | | ទីប្រជុំជន | | | ជនបទ | | |
|---|---|---|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| **កម្លាំងពលកម្ម (ចំនួន)** | | | | | | | | | |
| កម្លាំងពលកម្មយុវជន (១៥-២៤ ឆ្នាំ) | ១.៥៤១.៥៤៤ | ៧៥៤.៧០៦ | ៧៨៦.៨៣៨ | ៤២៩.៥១៧ | ១៩៥.៧៨៦ | ២៣៣.៧៣២ | ១.១១២.០២៧ | ៥៥៨.៩២០ | ៥៥៣.១០៧ |
| ១៥-១៩ ឆ្នាំ | ៥៦៩.២០៧ | ២៨៧.០៤៧ | ២៨២.១៦០ | ១២៦.៦៩៩ | ៦០.៦៨១ | ៦៦.០១៧ | ៤៤២.៥០៨ | ២២៦.៣៦៦ | ២១៦.១៤៣ |
| ២០-២៤ ឆ្នាំ | ៩៧២.៣៣៧ | ៤៦៧.៦៥៩ | ៥០៤.៦៧៨ | ៣០២.៨១៧ | ១៣៥.១០៤ | ១៦៧.៧១៣ | ៦៦៩.៥១៩ | ៣៣២.៥៥៤ | ៣៣៦.៩៦៥ |
| **កម្លាំងពលកម្មសរុប (១៥ ឆ្នាំឡើង)** | **៧.៩៨០.៧៩៣** | **៤.១៦៨.៩២៣** | **៣.៨១១.៨៧០** | **២.៧២៨.២៥៣** | **១.៤២៨.៧៧៧** | **១.២៩៩.៤៧៦** | **៥.២៥២.៥៤០** | **២.៧៤០.១៤៦** | **២.៥១២.៣៩៤** |
| **អត្រាចូលរួមក្នុងកម្លាំងពលកម្ម (%)** | | | | | | | | | |
| កម្លាំងពលកម្មយុវជន (១៥-២៤ ឆ្នាំ) | ៥៧,២ | ៥៩,១ | ៥៥,៦ | ៤៩,៤ | ៤៩,០ | ៤៩,៧ | ៦១,០ | ៦៣,៧ | ៥៨,៦ |
| ១៥-១៩ ឆ្នាំ | ៤០,១ | ៤២,១ | ៣៨,៣ | ២៩,២ | ២៩,៥ | ២៨,៩ | ៤៤,៩ | ៤៧,៥ | ៤២,៥ |
| ២០-២៤ ឆ្នាំ | ៧៦,៣ | ៧៨,៥ | ៧៤,៤ | ៦៩,៥ | ៦៩,៧ | ៦៩,៣ | ៧៩,៩ | ៨២,៨ | ៧៧,៣ |
| **កម្លាំងពលកម្មសរុប (១៥ ឆ្នាំឡើង)** | **៦៩,៣** | **៧៧,២** | **៦២,៤** | **៦៧,៧** | **៧៦,៤** | **៦០,២** | **៧០,២** | **៧៧,៦** | **៦៣,៦** |

សម្គាល់៖ សរុបអាចមិនស្មើផលបូក ដោយសារការបង្គត់លេខ។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

## ៩.៣ យុវជនមានការងារធ្វើ និងគ្មានការងារធ្វើ

អត្រាយុវជនមានការងារធ្វើ គឺជាចំនួនអ្នកធ្វើការ អាយុ ១៥-២៤ ឆ្នាំ ខណៈអត្រាយុវជនគ្មានការងារធ្វើ គឺជាចំនួនអ្នកគ្មានការងារធ្វើ អាយុ ១៥-២៤ ឆ្នាំ បានបង្ហាញជាភាគរយនៃកម្លាំងពលកម្មយុវជនសរុប។

តារាង ៩.២ បង្ហាញការបែងចែកចំនួន និងភាគរយនៃយុវជនមានការងារធ្វើ និងគ្មានការងារធ្វើ តាមតំបន់ទីប្រជុំជន និងជនបទ និងភេទ។ យុវជនសរុប ១.៥០២.៦៦៥ នាក់ មានការងារធ្វើនៅឆ្នាំ២០១៩ ក្នុងនោះប្រុសមាន ៤៨,៩% និងស្រី ៥១,១%។ លំនាំដូចគ្នានេះ ស្រីមានការងារធ្វើមានចំនួនច្រើនជាងប្រុសមានការងារធ្វើ ត្រូវបានសង្កេតឃើញនៅតំបន់ទីប្រជុំជន ខណៈប្រុសមានការងារធ្វើមានចំនួនច្រើនជាងស្រីមានការងារធ្វើ នៅតំបន់ជនបទ។ ចំពោះយុវជនគ្មានការងារធ្វើ ចំនួនប្រុសមានច្រើនជាងស្រីទាំងនៅតំបន់ទីប្រជុំជន និងជនបទ។ សមាមាត្រយុវជនមានការងារធ្វើនៃប្រជាជនមានការងារធ្វើសរុប មានប្រមាណ ១៩,១% ខណៈសមាមាត្រយុវជនគ្មានការងារធ្វើនៃប្រជាជនគ្មានការងារធ្វើសរុបមាន ៣៩,៨%។

ដូចបានបង្ហាញក្នុងតារាង ៩.២ ការប៉ាន់ស្មានប្រមាណ ៩៧,៥% នៃកម្លាំងពលកម្មយុវជន ជាអ្នកមានការងារធ្វើ ហើយខុសគ្នាបន្តិចរវាងប្រុស (៩៧,៣%) និងស្រី (៩៧,៧ %)។ អត្រាយុវជនមានការងារធ្វើខ្ពស់នៅតំបន់ជនបទ (៩៧,៨%) ជាងនៅតំបន់ទីប្រជុំជន (៩៦,៧%)។

អត្រាយុវជនគ្មានការងារធ្វើសរុបបានប៉ាន់ស្មានប្រមាណ ២,៥% ដោយប្រុសមាន ២,៧% ខ្ពស់បន្តិចជាងស្រី ២,៣%។ ទន្ទឹមនេះ អត្រាយុវជនគ្មានការងារធ្វើមាន ៣,៣% នៅតំបន់ទីប្រជុំជន ខ្ពស់ជាងនៅតំបន់ជនបទ ២,២% ហើយប្រុសមានអត្រាខ្ពស់ជាងស្រីទាំងនៅតំបន់ទីប្រជុំជន និងតំបន់ជនបទ។

## តារាង ៩.២. យុវជនមានការងារធ្វើ និងគ្មានការងារធ្វើ តាមតំបន់ និងភេទ

| ការងារ | កម្ពុជា | | | ទីប្រជុំជន | | | ជនបទ | | |
|---|---|---|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| **ចំនួនកម្លាំងពលកម្ម [a]** | | | | | | | | | |
| យុវជនមានការងារធ្វើ [b] | ១.៥០២.៦៦៥ | ៧៣៤.១៣០ | ៧៦៨.៥៣៥ | ៤១៥.៥០៦ | ១៨៧.៨២០ | ២២៧.៦៨៦ | ១.០៨៧.១៥៩ | ៥៤៦.៣១០ | ៥៤០.៨៤៩ |
| យុវជនគ្មានការងារធ្វើ | ៣៨.៨៧៩ | ២០.៥៧៦ | ១៨.៣០៣ | ១៤.០១១ | ៧.៩៦៦ | ៦.០៤៦ | ២៤.៨៦៨ | ១២.៦១០ | ១២.២៥៨ |
| **សរុប** | **១.៥៤១.៥៤៤** | **៧៥៤.៧០៦** | **៧៨៦.៨៣៨** | **៤២៩.៥១៧** | **១៩៥.៧៨៦** | **២៣៣.៧៣២** | **១.១១២.០២៧** | **៥៥៨.៩២០** | **៥៥៣.១០៧** |
| ***ភាគរយនៃសរុប អាយុ ១៥+*** | | | | | | | | | |
| យុវជនមានការងារធ្វើ [c] | ១៩,១ | ១៧,៨ | ២០,៤ | ១៥,៤ | ១៣,៣ | ១៧,៧ | ២១,០ | ២០,២ | ២១,៨ |
| យុវជនគ្មានការងារធ្វើ [d] | ៣៩,៨ | ៤០,០ | ៣៩,៦ | ៥៣,៣ | ៥៨,១ | ៤៨,០ | ៣៤,៨ | ៣៣,៤ | ៣៦,៤ |
| កម្លាំងពលកម្មយុវជនសរុប [e] | ១៩,៣ | ១៨,១ | ២០,៦ | ១៥,៧ | ១៣,៧ | ១៨,០ | ២១,២ | ២០,៤ | ២២,០ |
| **អត្រាសម្រាប់យុវជន (%)** | | | | | | | | | |
| អត្រាមានការងារធ្វើ | ៩៧,៥ | ៩៧,៣ | ៩៧,៧ | ៩៦,៧ | ៩៥,៩ | ៩៧,៤ | ៩៧,៨ | ៩៧,៧ | ៩៧,៨ |
| អត្រាគ្មានការងារធ្វើ | ២,៥ | ២,៧ | ២,៣ | ៣,៣ | ៤,១ | ២,៦ | ២,២ | ២,៣ | ២,២ |
| **សរុប** | **១០០,០** | **១០០,០** | **១០០,០** | **១០០,០** | **១០០,០** | **១០០,០** | **១០០,០** | **១០០,០** | **១០០,០** |

[a] "កម្លាំងពលកម្ម" សំដៅលើអ្នកដែលបច្ចុប្បន្នមានការងារធ្វើ ឬគ្មានការងារធ្វើ ប៉ុន្តែកំពុងស្វែងរកការងារធ្វើ។

[b] "យុវជន" សំដៅលើអ្នកមានអាយុ ១៥ ទៅ ២៤ ឆ្នាំ។

[c] ជួរដេកនេះបង្ហាញជាភាគរយ ចំណែករបស់ប្រុស ស្រី និងសរុបអ្នកមានការងារធ្វើ ក្នុងក្រុមអាយុ ១៥-២៤ ឆ្នាំ នៃប្រជាជនមានការងារធ្វើសរុប (អាយុ ១៥ ឆ្នាំឡើង)។

[d] ជួរដេកនេះបង្ហាញជាភាគរយ ចំណែករបស់ប្រុស ស្រី និងសរុបអ្នកគ្មានការងារធ្វើ ក្នុងក្រុមអាយុ ១៥-២៤ ឆ្នាំ នៃប្រជាជនគ្មានការងារធ្វើសរុប (អាយុ ១៥ ឆ្នាំឡើង)។

[e] ជួរដេកនេះបង្ហាញជាភាគរយ ចំណែករបស់ប្រុស ស្រី និងសរុបកម្លាំងពលកម្មយុវជន (ពោលគឺទាំងអ្នកមានការងារធ្វើ និងអ្នកគ្មានការងារធ្វើ ក្នុងក្រុមអាយុ ១៥-២៤ ឆ្នាំ) នៃកម្លាំងពលកម្មសរុប (អាយុ ១៥ ឆ្នាំឡើង)។

សម្គាល់៖ សរុបអាចមិនស្មើផលបូក ដោយសារការបង្គត់លេខ។

ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

តារាង ៩.៣ បង្ហាញការបែងចែកយុវជនធ្វើការ តាមមុខរបរ និងភេទ។ ភាគរយខ្ពស់ជាងគេនៃយុវជនគឺអ្នកធ្វើការខាងសិប្បកម្ម និងអាជីវកម្មពាក់ព័ន្ធ (៣៥,៩%) បន្ទាប់មកធ្វើការខាងសេវាកម្ម និងលក់ (១៧,៧%) ជំនាញកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (១៧,០%) និងក្នុងមុខរបរផ្សេងៗ (១៤,៤%)។ យុវជនទាំងស្រី និងប្រុសភាគច្រើនធ្វើការខាងសិប្បកម្ម និងអាជីវកម្មពាក់ព័ន្ធ មាន ៣៨,១% និង ៣៣,៧% តាមលំដាប់រៀង។ ម្យ៉ាងទៀត ស្រីមានចំនួនច្រើនជាងប្រុស ធ្វើការនៅក្នុងមុខរបរសេវាកម្ម និងលក់ និងមុខរបរសិប្បកម្ម និងអាជីវកម្មពាក់ព័ន្ធ។

## តារាង ៩.៣. យុវជនមានការងារធ្វើ តាមមុខរបរ និងភេទ

| មុខរបរ [a] | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
|---|---|---|---|---|---|---|
| | (ចំនួន) | | | (%) | | |
| អ្នកគ្រប់គ្រង | ១៣.៨៥០ | ៧.១០៧ | ៦.៧៤៣ | ០,៩ | ១,០ | ០,៩ |
| អ្នកមានវិជ្ជាជីវៈ | ៦២.៨៨៥ | ២០.៩២៨ | ៤១.៩៥៧ | ៤,២ | ២,៩ | ៥,៥ |
| អ្នកបច្ចេកទេស និងវិជ្ជាជីវៈរង | ៤៨.៧៤៩ | ២៣.៧៨៧ | ២៤.៩៦២ | ៣,២ | ៣,២ | ៣,២ |
| អ្នកជំនួយការស្មៀន | ៣៤.៥២៣ | ១៤.១៥៩ | ២០.៣៦៤ | ២,៣ | ១,៩ | ២,៦ |
| អ្នកផ្តល់សេវាកម្ម និងលក់ | ២៦៥.៧៥៦ | ៩៤.២០៤ | ១៧១.៥៥២ | ១៧,៧ | ១២,៨ | ២២,៣ |
| អ្នកជំនាញកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ២៥៥.៧៨៣ | ១៣៩.២៣៦ | ១១៦.៥៤៦ | ១៧,០ | ១៩,០ | ១៥,២ |
| អ្នកធ្វើសិប្បកម្ម និងអាជីវកម្មពាក់ព័ន្ធ | ៥៤០.០៨១ | ២៤៧.១៤២ | ២៩២.៩៣៩ | ៣៥,៩ | ៣៣,៧ | ៣៨,១ |
| ការីម៉ាស៊ីន និងរោងចក្រ និងអ្នកផ្គុំតម្លើង | ៥៧.១៦៥ | ៤៨.០០៨ | ៩.១៥៧ | ៣,៨ | ៦,៥ | ១,២ |
| អ្នកធ្វើមុខរបរផ្សេងៗ | ២១៥.៦៩១ | ១៣១.៩៨៦ | ៨៣.៧០៥ | ១៤,៤ | ១៨,០ | ១០,៩ |
| កងកម្លាំងប្រដាប់អាវុធ | ៨.១៨១ | ៧.៥៧៣ | ៦០៩ | ០,៥ | ១,០ | ០,១ |
| **សរុប** | **១.៥០២.៦៦៥** | **៧៣៤.១៣០** | **៧៦៨.៥៣៥** | **១០០,០** | **១០០,០** | **១០០,០** |

[a] ប្រភេទសមុខរបរមានក្នុងបង្គោលនេះ បានមកពីចំណាត់ថ្នាក់មុខរបរតាមស្តង់ដារអន្តរជាតិ ឆ្នាំ២០០៨ (ISCO-08)។

សម្គាល់៖ សរុបអាចមិនស្មើផលបូក ដោយសារការបង្គត់លេខ។

ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

តារាង ៩.៤ បង្ហាញថាភាគរយខ្ពស់ជាងគេនៃយុវជនមានការងារធ្វើ គឺក្នុងការផលិត (៣០,៤%) បន្ទាប់មក កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (២៣,០%)។ ប្រុសភាគច្រើន (២៦,៣%) ធ្វើការនៅក្នុងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ខណៈស្រី (៣៩,៤%) ធ្វើការនៅក្នុងការផលិត។

តារាង ៩.៤. យុវជនមានការងារធ្វើ តាមសកម្មភាពសេដ្ឋកិច្ច និងភេទ

| សកម្មភាពសេដ្ឋកិច្ច [a] | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
|---|---|---|---|---|---|---|
| | (ចំនួន) | | | (%) | | |
| កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៣៤៥.៣០៨ | ១៩២.៧៤៩ | ១៥២.៥៥៩ | ២៣,០ | ២៦,៣ | ១៩,៩ |
| រុករករ៉ែ និងថ្ម | ៧៦២ | ៧៦២ | ០ | ០,១ | ០,១ | ០,០ |
| ការផលិត | ៤៥៧.១៨៨ | ១៥៤.៧២៦ | ៣០២.៤៦២ | ៣០,៤ | ២១,១ | ៣៩,៤ |
| ផ្គត់ផ្គង់អគ្គិសនី ឧស្ម័ន ចំហាយ និងម៉ាស៊ីនត្រជាក់ | ៣.៤៩០ | ២.៣៤៧ | ១.១៤៣ | ០,២ | ០,៣ | ០,១ |
| ផ្គត់ផ្គង់ទឹក គ្រប់គ្រងសំរាម លូទឹក និងសកម្មភាពកែលម្អ | ៦៣៣ | ៦៣៣ | ០ | ០,០ | ០,១ | ០,០ |
| សំណង់ | ១៦៩.៩២៤ | ១៣៧.១៨៥ | ៣២.៧៣៨ | ១១,៣ | ១៨,៧ | ៤,៣ |
| លក់ដុំ និងលក់រាយ ជួសជុលយានយន្ត | ១៨៧.៧៧៦ | ៧៥.៥៤៥ | ១១២.២៣០ | ១២,៥ | ១០,៣ | ១៤,៦ |
| ដឹកជញ្ជូន និងស្តុកទំនិញ | ៥៣.៣០១ | ៤៩.៥៤៩ | ៣.៧៥២ | ៣,៥ | ៦,៧ | ០,៥ |
| សកម្មភាពសេវាកម្មស្នាក់នៅ និងអាហារ | ៦៩.២៤២ | ២៥.៨៥៥ | ៤៣.៣៨៧ | ៤,៦ | ៣,៥ | ៥,៦ |
| ព័ត៌មាន និងទំនាក់ទំនង | ៤.៤៦១ | ១.៤៩៩ | ២.៩៦២ | ០,៣ | ០,២ | ០,៤ |
| សកម្មភាពហិរញ្ញវត្ថុ និងធានារ៉ាប់រង | ៣០.០៨៨ | ១៩.០២២ | ១១.០៦៦ | ២,០ | ២,៦ | ១,៤ |
| សកម្មភាពអចលនទ្រព្យ | ២.០៩២ | ០ | ២.០៩២ | ០,១ | ០,០ | ០,៣ |
| សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | ៨.៦៣៣ | ១.៨៦៨ | ៦.៧៦៥ | ០,៦ | ០,៣ | ០,៩ |
| សកម្មភាពរដ្ឋបាល និងសេវាកម្មគាំទ្រ | ៤៣.៧៩១ | ២១.៣០៩ | ២២.៤៨២ | ២,៩ | ២,៩ | ២,៩ |
| រដ្ឋបាលសាធារណៈ និងការពារ សន្តិសុខសង្គមជាកាតព្វកិច្ច | ១៩.០៤៨ | ១៤.៧៧៨ | ៤.២៧០ | ១,៣ | ២,០ | ០,៦ |
| អប់រំ | ៣៤.៤៩៧ | ១២.០៣០ | ២២.៤៦៧ | ២,៣ | ១,៦ | ២,៩ |
| សកម្មភាពសុខភាពមនុស្ស និងកិច្ចការសង្គម | ៦.៣៨៣ | ១.៧០៣ | ៤.៦៨០ | ០,៤ | ០,២ | ០,៦ |
| សិល្បៈ កម្សាន្ត និងសប្បាយ | ៣០.១១០ | ១០.៤២៧ | ១៩.៦៨៣ | ២,០ | ១,៤ | ២,៦ |
| សកម្មភាពសេវាកម្មដទៃទៀត | ២៨.២៦០ | ៨.៩៨៨ | ១៩.២៧២ | ១,៩ | ១,២ | ២,៥ |
| សកម្មភាពគ្រួសារជានិយោជក និងសកម្មភាពផលិតទំនិញ និងសេវាកម្មត្រូវគ្នារបស់គ្រួសារសម្រាប់ប្រើប្រាស់ខ្លួនឯង | ៧.៦៧៩ | ៣.១៥៤ | ៤.៥២៦ | ០,៥ | ០,៤ | ០,៦ |
| សកម្មភាពអង្គការ និងអង្គភាពក្រៅប្រទេស | ០ | ០ | ០ | ០,០ | ០,០ | ០,០ |
| **សរុប** | **១.៥០២.៦៦៥** | **៧៣៤.១៣០** | **៧៦៨.៥៣៥** | **១០០,០** | **១០០,០** | **១០០,០** |

[a] ប្រភេទសកម្មភាពសេដ្ឋកិច្ចមានក្នុងបង្គោលនេះ បានមកពីចំណាត់ថ្នាក់សកម្មភាពសេដ្ឋកិច្ចតាមស្តង់ដារអន្តរជាតិ ជំនាន់ ៤ (ISIC Rev4)។
សម្គាល់៖ សរុបអាចមិនស្មើផលបូក ដោយសារការបង្គត់លេខ។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

## ៩.៤ យុវជនមិនធ្វើការងារ មិនសិក្សា ឬបណ្តុះបណ្តាល

ផ្នែកនេះបង្ហាញព័ត៌មានអំពីយុវជនមិនធ្វើការងារ មិនសិក្សា ឬបណ្តុះបណ្តាល (NEET)។ យុវជនមិនធ្វើការងារ មិនសិក្សា ឬបណ្តុះបណ្តាល គឺជាសូចនាករមួយដែលត្រូវបានប្រើយ៉ាងទូលំទូលាយសម្រាប់បង្កើតគោលនយោបាយ ក្នុងគោលបំណងដើម្បីកំណត់ឱកាសបណ្តុះបណ្តាលសមស្របសម្រាប់យុវជន។ ម្យ៉ាងទៀត យុវជនមិនធ្វើការងារ មិន សិក្សា ឬបណ្តុះបណ្តាលត្រូវបានប្រើ ដើម្បីជួយយុវជនក្នុងការស្វែងរកការងារមាននិរន្តរភាព ជាមួយគោលនយោបាយ ពង្រីកឱកាសការងារសម្រាប់យុវជន ពង្រីកគម្រោងអ្នកហាត់រៀនធ្វើការ កែទម្រង់ការអប់រំបច្ចេកទេស និងធ្វើឲ្យប្រសើរ ឡើងនូវការផ្តល់ប្រឹក្សាអាជីព។ លើសពីនេះទៀត រាជរដ្ឋាភិបាលប្រើសម្រាប់អនុវត្តមូលនិធិយុទ្ធសាស្ត្រក្នុងកម្មវិធីនានា សំដៅលើកកម្ពស់លទ្ធផលអប់រំសម្រាប់យុវជនដែលជួបការលំបាក និងអ្នកដែលមានការលំបាកក្នុងការសិក្សា ឬពិការ

ភាព។ បើគ្មានសូចនាករនេះទេ វានឹងមានការលំបាកណាស់ក្នុងការធ្វើឲ្យយុវជនមិនធ្វើការងារ មិនសិក្សា ឬបណ្តុះបណ្តាល បានចូលរួម។

តារាង ៩.៥ បង្ហាញការបែងចែកចំនួន និងភាគរយរបស់យុវជនអាយុ ១៥ ទៅ ២៤ ឆ្នាំ ដែលមិនធ្វើការងារ មិនសិក្សា ឬបណ្តុះបណ្តាល តាមតំបន់ និងភេទ។ ជាសរុបយុវជនប្រមាណ ៣៤១.២៧២ នាក់ មិនធ្វើការងារ មិនសិក្សា ឬបណ្តុះបណ្តាល តំណាងឲ្យ ១២,៧% នៃយុវជនទាំងអស់។ យុវជនមិនធ្វើការងារ មិនសិក្សា ឬបណ្តុះបណ្តាលមានចំនួនច្រើនក្នុងចំណោមស្រី (១៣,៨%) ជាងប្រុស (១១,៤%)។ ម្យ៉ាងទៀត យុវជនមិនធ្វើការងារ មិនសិក្សា ឬបណ្តុះបណ្តាល នៅតំបន់ជនបទ (១២,៩%) មានច្រើនជាងនៅតំបន់ទីប្រជុំជន (១២,២%)។

តារាង ៩.៥. យុវជនមិនធ្វើការងារ មិនសិក្សា ឬបណ្តុះបណ្តាល តាមក្រុមអាយុ តំបន់ និងភេទ

| ក្រុមអាយុ | កម្ពុជា | | | ទីប្រជុំជន | | | ជនបទ | | |
|---|---|---|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| **ចំនួន** | | | | | | | | | |
| ១៥–១៩ | ១៧៧.៤១៥ | ៨៩.៧៦៦ | ៨៧.៦៥០ | ៤៦.៦៤៧ | ២៥.៧០៧ | ២០.៩៤១ | ១៣០.៧៦៨ | ៦៤.០៥៩ | ៦៦.៧០៩ |
| ២០–២៤ | ១៦៣.៨៥៧ | ៥៦.៤២៨ | ១០៧.៤២៩ | ៥៩.១៦៥ | ១៨.៨៧៩ | ៤០.២៨៦ | ១០៤.៦៩២ | ៣៧.៥៤៩ | ៦៧.១៤៣ |
| **សរុប** | **៣៤១.២៧២** | **១៤៦.១៩៤** | **១៩៥.០៧៩** | **១០៥.៨១២** | **៤៤.៥៨៦** | **៦១.២២៧** | **២៣៥.៤៦០** | **១០១.៦០៨** | **១៣៣.៨៥២** |
| **ចំណែកនៃយុវជនសរុប (%)** | | | | | | | | | |
| ១៥–១៩ | ១២,៥ | ១៣,២ | ១១,៩ | ១០,៧ | ១២,៥ | ៩,២ | ១៣,៣ | ១៣,៥ | ១៣,១ |
| ២០–២៤ | ១២,៩ | ៩,៥ | ១៥,៨ | ១៣,៦ | ៩,៧ | ១៦,៧ | ១២,៥ | ៩,៣ | ១៥,៤ |
| **សរុប (១៥-២៤ ឆ្នាំ)** | **១២,៧** | **១១,៤** | **១៣,៨** | **១២,២** | **១១,១** | **១៣,០** | **១២,៩** | **១១,៦** | **១៤,២** |

សម្គាល់៖ សរុបអាចមិនស្មើផលបូក ដោយសារការបង្គត់លេខ។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

# ជំពូក ១០
# ភាពគ្មានការងារធ្វើ

## ១០.១ សេចក្តីផ្តើម

ជំពូកនេះបង្ហាញអំពីចរិតលក្ខណៈប្រជាជនគ្មានការងារធ្វើ ពិពណ៌នាអ្នកគ្មានការងារធ្វើ តាមអាយុ ភេទ រយៈពេលគ្មានការងារធ្វើ និងវិធីសាស្ត្រស្វែងរកការងារ ក៏ដូចជាអត្រាគ្មានការងារធ្វើ និងអត្រាប្រើមិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម។ ប្រជាជនគ្មានការងារធ្វើ រួមមានមនុស្សទាំងអស់ដែលនៅក្នុងរយៈពេលយោងមិននៅក្នុងការងារ ប៉ុន្តែសកម្មស្វែងរកការងារធ្វើ និងអាចធ្វើការបាន។

## ១០.២ អ្នកគ្មានការងារធ្វើ

នៅឆ្នាំ២០១៩ មានប្រមាណ ៩៧.៦៨៧ នាក់ ជាអ្នកគ្មានការងារធ្វើ អាយុ ១៥ ឆ្នាំឡើង នៅកម្ពុជា (តារាង ១០.១)។ ក្នុងចំណោមពួកគេ ៣៨.៨៧៩ នាក់ មានអាយុ ១៥-២៤ ឆ្នាំ (៣៩,៨%) និង ៥៧.៧៦៥ នាក់ មានអាយុ ២៥-៦៤ ឆ្នាំ (៥៩,១%) និងចំនួននៅសល់តិចដែលជាមនុស្សវ័យចាស់ (១.០៤២ នាក់ ឬ ១,១%)។ ក្នុងក្រុមអាយុយុវជន (១៥-២៤ ឆ្នាំ) ចំនួនប្រុសគ្មានការងារធ្វើច្រើនជាងស្រី ខណៈផ្ទុយគ្នាត្រូវបានសង្កេតឃើញក្នុងក្រុមអាយុច្រើនជាង (៣៥-៦៤ ឆ្នាំ)។

តារាង ១០.១. ប្រជាជនគ្មានការងារធ្វើ តាមក្រុមអាយុ និងភេទ

| ក្រុមអាយុ | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
|---|---|---|---|---|---|---|
| | (ចំនួន) | | | (%) | | |
| ១៥-២៤ | ៣៨.៨៧៩ | ២០.៥៧៦ | ១៨.៣០៣ | ៣៩,៨ | ៤០,០ | ៣៩,៦ |
| ២៥-៣៤ | ២៧.៨១៧ | ១៦.៤៩៤ | ១១.៣២៣ | ២៨,៥ | ៣២,១ | ២៤,៥ |
| ៣៥-៤៤ | ១៨.០៦៥ | ៨.៦៧២ | ៩.៣៩៣ | ១៨,៥ | ១៦,៩ | ២០,៣ |
| ៤៥-៥៤ | ៦.៨៥២ | ៣.៣១១ | ៣.៥៤១ | ៧,០ | ៦,៤ | ៧,៧ |
| ៥៥-៦៤ | ៥.០៣១ | ១.៧៥៣ | ៣.២៧៨ | ៥,២ | ៣,៤ | ៧,១ |
| ៦៥+ | ១.០៤២ | ៦៥៣ | ៣៨៩ | ១,១ | ១,៣ | ០,៨ |
| **សរុប** | **៩៧.៦៨៧** | **៥១.៤៥៨** | **៤៦.២២៩** | **១០០,០** | **១០០,០** | **១០០,០** |

សម្គាល់៖ សរុបអាចមិនស្មើផលបូក ដោយសារការបង្គត់លេខ។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

តារាង ១០.២ បង្ហាញការបែងចែកអ្នកគ្មានការងារធ្វើ តាមកម្រិតសិក្សារបស់ពួកគេ។ ក្នុងចំណោមអ្នកគ្មានការងារធ្វើនៅឆ្នាំ២០១៩ ស្ទើរតែមួយភាគបី (៣២,២%) មានកម្រិតមធ្យមសិក្សាទុតិយភូមិ ប្រមាណច្រើនជាងមួយភាគបួន (២៦,៧%) មានកម្រិតបឋមសិក្សា ប្រហែលមួយភាគបួន (២៤,៨%) បានបញ្ចប់មធ្យមសិក្សាបឋមភូមិ និងតិចជាងមួយភាគដប់ (៦,៧%) បានបញ្ចប់សាកលវិទ្យាល័យ។

ក្នុងចំណោមអ្នកមានកម្រិតបឋមសិក្សា ចំនួនស្រីគ្មានការងារធ្វើមានច្រើនជាងប្រុស។ ផ្ទុយទៅវិញ ប្រុសគ្មានការងារធ្វើនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ឬកម្រិតសាកលវិទ្យាល័យមានចំនួនច្រើនជាងស្រី។ នៅតំបន់ទីប្រជុំជនភាគច្រើន (៣៧,១%) នៃអ្នកគ្មានការងារធ្វើបានបញ្ចប់មធ្យមសិក្សាទុតិយភូមិ ខណៈនៅតំបន់ជនបទ ចំនួនដូចគ្នាមានកម្រិតបឋមសិក្សា ឬមធ្យមសិក្សាទុតិយភូមិ (៣០,៤% នីមួយៗ)។

តារាង ១០.២. ប្រជាជនគ្មានការងារធ្វើ តាមកម្រិតសិក្សា តំបន់ និងភេទ

(%)

| កម្រិតសិក្សា | កម្ពុជា | | | ទីប្រជុំជន | | | ជនបទ | | |
|---|---|---|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| មិនដែលបានរៀន | ៧,០ | ៧,៤ | ៦,៥ | ៨,៨ | ៨,៣ | ៩,៣ | ៦,៣ | ៧,០ | ៥,៥ |
| មត្តេយ្យសិក្សា | ២,៦ | ១,៨ | ៣,៥ | ០,០ | ០,០ | ០,០ | ៣,៥ | ២,៤ | ៤,៧ |
| បឋមសិក្សា | ២៦,៧ | ២៤,៣ | ២៩,៤ | ១៦,៩ | ១៣,៥ | ២០,៥ | ៣០,៤ | ២៨,២ | ៣២,៧ |
| មធ្យមសិក្សាបឋមភូមិ | ២៤,៨ | ២២,៨ | ២៧,១ | ២២,៣ | ២៤,០ | ២០,៤ | ២៥,៨ | ២២,៤ | ២៩,៦ |
| មធ្យមសិក្សាទុតិយភូមិ | ៣២,២ | ៣៦,៧ | ២៧,២ | ៣៧,១ | ៣៨,៣ | ៣៥,៩ | ៣០,៤ | ៣៦,២ | ២៤,០ |
| បច្ចេកទេស/វិជ្ជាជីវៈ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ |
| ឧត្តមសិក្សា | ៦,៧ | ៧,០ | ៦,៤ | ១៤,៩ | ១៥,៨ | ១៣,៩ | ៣,៧ | ៣,៨ | ៣,៥ |
| **សរុប (%)** | **១០០,០** | **១០០,០** | **១០០,០** | **១០០,០** | **១០០,០** | **១០០,០** | **១០០,០** | **១០០,០** | **១០០,០** |
| **សរុប (ចំនួន)** | **៩៧.៦៨៧** | **៥១.៤៥៨** | **៤៦.២២៩** | **២៦.២៩០** | **១៣.៧០១** | **១២.៥៨៩** | **៧១.៣៩៧** | **៣៧.៧៥៧** | **៣៣.៦៣៩** |

សម្គាល់៖ សរុបអាចមិនស្មើផលបូក ដោយសារការបង្គត់លេខ។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

## ១០.៣ រយៈពេលគ្មានការងារធ្វើ

រយៈពេលគ្មានការងារធ្វើ គឺជារយៈពេលដែលអ្នកគ្មានការងារធ្វើ មិនមានការងារ និងព្យាយាមស្វែងរកការងារមានប្រាក់ឈ្នួល ឬចាប់ផ្តើមអាជីវកម្ម។

តារាង ១០.៣ បង្ហាញថាប្រមាណ ៨៤,០% នៃអ្នកគ្មានការងារធ្វើបានរាយការណ៍គ្មានការងារធ្វើរយៈពេលខ្លី (តិចជាង ១២ ខែ) នៅឆ្នាំ២០១៩ ខណៈ ៦,៤% បានស្វែងរកការងារធ្វើអស់រយៈពេលជាង ១ ឆ្នាំ។ ភាគច្រើននៃអ្នកគ្មានការងារធ្វើរយៈពេលខ្លីបានស្វែងរកការងារអស់រយៈពេលតិចជាង ១ ខែ (៣៦,៦%) ឬតិចជាង ៣ ខែ (៣១,៥%)។ ច្រើនជាងមួយភាគដប់ (១១,៣%) បានស្វែងរកការងារអស់រយៈពេលប្រមាណ ៣ ទៅ ៦ ខែ និង ៤,៦% អស់រយៈពេល ៦ ខែ ទៅតិចជាងមួយឆ្នាំ។

ស្រីគ្មានការងារធ្វើរយៈពេលខ្លីមានចំនួនច្រើនជាងប្រុស។ ផ្ទុយមកវិញ អ្នកគ្មានការងារធ្វើរយៈពេលវែង ប្រុសមានចំនួនច្រើនជាងស្រី។

តារាង ១០.៣. រយៈពេលគ្មានការងារធ្វើ តាមភេទ

| រយៈពេល | | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
|---|---|---|---|---|---|---|---|
| | | (ចំនួន) | | | (%) | | |
| គ្មានការងារធ្វើរយៈពេលខ្លី | តិចជាង ១ ខែ | ៣៥.៧៤១ | ២០.៤៥៧ | ១៥.២៨៥ | ៣៦,៦ | ៣៩,៨ | ៣៣,១ |
| | ១ ទៅតិចជាង ៣ ខែ | ៣០.៧៣១ | ១៥.៥៥២ | ១៥.១៧៩ | ៣១,៥ | ៣០,២ | ៣២,៨ |
| | ៣ ទៅតិចជាង ៦ ខែ | ១១.០៨៥ | ៥.០៦១ | ៦.០២៤ | ១១,៣ | ៩,៨ | ១៣,០ |
| | ៦ ទៅតិចជាង ១២ ខែ | ៤.៤៦៦ | ១.៦២២ | ២.៨៤៥ | ៤,៦ | ៣,២ | ៦,២ |
| | **សរុបរងរយៈពេលខ្លី** | **៨២.០២៣** | **៤២.៦៩២** | **៣៩.៣៣៣** | **៨៤,០** | **៨៣,០** | **៨៥,១** |
| គ្មានការងារធ្វើរយៈពេលវែង | ១២ ខែ ទៅតិចជាង ២ ឆ្នាំ | ៥.៧២៤ | ២.៩៦៨ | ២.៧៥៦ | ៥,៩ | ៥,៨ | ៦,០ |
| | ២ ឆ្នាំឡើង | ៥៤០ | ៥៤០ | 0.0 | ០,៦ | ១,០ | ០,០ |
| | **សរុបរងរយៈពេលវែង** | **៦.២៦៤** | **៣.៥០៨** | **២.៧៥៦** | **៦,៤** | **៦,៨** | **៦,០** |
| ចាប់ផ្តើមការងារនៅអនាគត [a] | | **៩.៣៩៩** | **៥.២៥៩** | **៤.១៤០** | **៩,៦** | **១០,២** | **៩,០** |
| **អ្នកគ្មានការងារធ្វើសរុប** | | **៩៧.៦៨៧** | **៥១.៤៥៨** | **៤៦.២២៩** | **១០០,០** | **១០០,០** | **១០០,០** |

[a] អ្នកគ្មានការងារធ្វើក៏រាប់បញ្ចូលអ្នកដែលមិនស្វែងរកការងារធ្វើ ឬចាប់ផ្តើមអាជីវកម្មក្នុងរយៈពេលយោង ព្រោះ (i) ពួកគេរំពឹងថានឹងចាប់ផ្តើមការងារថ្មីក្នុងពេលឆាប់ៗនេះ (ii) ពួកគេកំពុងចូលរួមក្នុងគម្រោងបណ្តុះបណ្តាល ឬ (iii) ពួកគេបានគ្រោងនឹងធ្វើចំណាកស្រុកទៅបរទេសដើម្បីស្វែងរកការងារធ្វើ។
សម្គាល់៖ សរុបអាចមិនស្មើផលបូក ដោយសារការបង្គត់លេខ។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

## ១០.៤ វិធីសាស្ត្រស្វែងរកការងារ

អ្នកចូលរួមក្នុងអង្កេតអំពីភាពគ្មានការងារធ្វើ ត្រូវបានសួរថាតើពួកគេបានស្វែងរកការងារមានប្រាក់ឈ្នួល ឬចាប់ផ្តើមអាជីវកម្ម ក្នុងរយៈពេល ៤ សប្តាហ៍មុនអង្កេតឬទេ។ ប្រមាណ ២ នាក់ ក្នុងចំណោម ១០ នាក់ ដែលគ្មានការងារធ្វើបានចុះឈ្មោះនៅទីភ្នាក់ងារការងារឯកជន បានស្វែងរកការជួយពីសាច់ញាតិ មិត្តភក្តិ និងអ្នកដទៃ បានចុះឈ្មោះនៅសេវាកម្មការងារសាធារណៈ ឬដាក់ពាក្យតាមនិយោជកអនាគត។ មួយភាគបីបានសាកសួរតាមរោងចក្រ បានធ្វើតេស្ត ឬសម្ភាសន៍ បានអាន ឬឆ្លើយការផ្សាយពាណិជ្ជកម្មការងារ បានរង់ចាំតាមផ្លូវដើម្បីគេជ្រើសយកទៅធ្វើការ ដាក់ប្រវត្តិរូបលើគេហទំព័របណ្តាញវិជ្ជាជីវៈ បានស្វែងការជួយហិរញ្ញវត្ថុ ឬរកដីធ្លី និងសម្ភារៈ ឬដាក់ពាក្យសុំការអនុញ្ញាតដើម្បីចាប់ផ្តើមអាជីវកម្ម (រូបភាព ១០.១)។

រូប ១០.១. វិធីសាស្ត្រស្វែងរកការងារ

(%)




ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

## ១០.៥ អត្រាគ្មានការងារធ្វើ

អត្រាគ្មានការងារធ្វើសំដៅលើប្រជាជនគ្មានការងារធ្វើជាភាគរយ នៃកម្លាំងពលកម្មសរុបដែលតាមនិយមន័យរួមមានអ្នកមានការងារធ្វើ និងអ្នកគ្មានការងារធ្វើ ប៉ុន្តែពួកគេកំពុងស្វែងរកការងារធ្វើ និងអាចចាប់ផ្តើមធ្វើការ។ អត្រាគ្មានការងារធ្វើជាសូចនាករទីផ្សារការងារដ៏សំខាន់មួយ ដែលបានប្រើយ៉ាងទូលំទូលាយសម្រាប់ទំនាក់ទំនងនឹងដំណើរការទីផ្សារការងារ និងសមត្ថភាពសេដ្ឋកិច្ចក្នុងការបង្កើតការងារបានគ្រប់គ្រាន់។ វាត្រូវបានប្រើដោយអ្នកធ្វើគោលនយោបាយ ដៃគូអភិវឌ្ឍន៍ អ្នកស្រាវជ្រាវ អ្នកសិក្សា និងសាធារណជនទូទៅ ដើម្បីវាយតម្លៃស្ថានភាពទីផ្សារការងារ។ វាអាចជួយដល់ការស្រាវជ្រាវ និងការវិភាគទីផ្សារការងារ ក៏ដូចជាការបង្កើត និងវាយតម្លៃគោលនយោបាយទីផ្សារការងារផងដែរ។ អត្រាគ្មានការងារធ្វើក៏ជារង្វាស់ដ៏ច្បាស់លាស់មួយអំពីភាពមិនស៊ីគ្នារវាងការផ្គត់ផ្គង់ និងសេចក្តីត្រូវការកម្លាំងពលកម្ម ដែលឆ្លុះបញ្ចាំងវិសាលភាពមួយចំនួននៃវដ្តអាជីវកម្ម និងស្ថានភាពសេដ្ឋកិច្ច សង្គមរបស់បុគ្គល។ អត្រាគ្មានការងារធ្វើទាបអាចឆ្លុះបញ្ចាំងពីដំណើរការសេដ្ឋកិច្ចល្អរបស់ប្រទេស។ ទោះជាយ៉ាងណាក៏ដោយ បើអត្រាគ្មានការងារធ្វើទាប

ពេកអាចឆ្លុះបញ្ចាំងពីកង្វះជម្រើសសម្រាប់ការងារ ពេលគឺអវត្តមាននៃឱកាសអប់រំ ការការពារសង្គម និងសំណាញ់សុវត្ថិភាពផ្សេងៗ ដែលតម្រូវឲ្យប្រជាជនធ្វើការដើម្បីរស់។

អត្រាគ្មានការងារធ្វើទូទៅនៅកម្ពុជា ឆ្នាំ២០១៩ មាន ១,២% ហើយមានតម្លៃស្មើគ្នាសម្រាប់ប្រុស និងស្រី។ យោងតាមតារាង ១០.៤ អត្រាគ្មានការងារធ្វើសម្រាប់អ្នកដែលបានសិក្សាមានអត្រាខ្ពស់ជាងអ្នកមិនដែលបានសិក្សា។ អត្រាខ្ពស់ជាងគេគឺអ្នកដែលបានបញ្ចប់មធ្យមសិក្សាទុតិយភូមិ (២,៥%) បន្ទាប់មកអ្នកមានមធ្យមសិក្សាបឋមភូមិ (១,២%) និងអ្នកបញ្ចប់ឧត្តមសិក្សា (១,២%)។ អត្រានេះទាបសម្រាប់អ្នកបានបញ្ចប់បឋមសិក្សា (០,៩%) ហើយអត្រាទាបជាងគេគឺអ្នកមិនដែលបានរៀន (០,៨%)។ ជាទូទៅ ស្រីមានអត្រាគ្មានការងារធ្វើខ្ពស់នៅគ្រប់កម្រិតសិក្សា លើកលែងមធ្យមសិក្សាទុតិយភូមិ។ នេះអាចបញ្ជាក់ពីទស្សនៈថា ពួកគេប្រហែលជាគ្មានជម្រើសណាផ្សេងក្រៅពីទទួលយកការងារណាក៏ដោយដើម្បីរស់។

តារាង ១០.៤. អត្រាគ្មានការងារធ្វើ តាមកម្រិតសិក្សា តំបន់ និងភេទ

(%)

| កម្រិតសិក្សា | កម្ពុជា | | | ទីប្រជុំជន | | | ជនបទ | | |
|---|---|---|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| មិនដែលបានរៀន | ០,៨ | ១,០ | ០,៦ | ១,៥ | ១,៨ | ១,៣ | ០,៦ | ០,៩ | ០,៥ |
| មត្តេយ្យសិក្សា | ១,០ | ០,៧ | ១,១ | ០,០ | ០,០ | ០,០ | ១,២ | ០,៩ | ១,៥ |
| បឋមសិក្សា | ០,៩ | ០,៨ | ០,៩ | ០,៦ | ០,៥ | ០,៦ | ១,០ | ០,៩ | ១,០ |
| មធ្យមសិក្សាបឋមភូមិ | ១,២ | ១,១ | ១,៤ | ០,៧ | ០,៨ | ០,៧ | ១,៥ | ១,៣ | ១,៨ |
| មធ្យមសិក្សាទុតិយភូមិ | ២,៥ | ២,៦ | ២,៣ | ១,៧ | ១,៦ | ១,៩ | ៣,១ | ៣,៤ | ២,៧ |
| បច្ចេកទេស/វិជ្ជាជីវៈ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ | ០,០ |
| ឧត្តមសិក្សា | ១,២ | ១,២ | ១,៣ | ១,០ | ១,០ | ១,១ | ១,៧ | ១,៦ | ១,៨ |
| **សរុប** | **១,២** | **១,២** | **១,២** | **១,០** | **១,០** | **១,០** | **១,៤** | **១,៤** | **១,៣** |

ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

តារាង ១០.៥ បង្ហាញអត្រាគ្មានការងារធ្វើ តាមក្រុមអាយុ តំបន់ និងភេទ។ តារាងបង្ហាញថា អត្រាគ្មានការងារធ្វើសរុប នៅឆ្នាំ២០១៩ មាន ១,២% ប៉ុន្តែជាទូទៅបានថយចុះនៅពេលអាយុកើនឡើង។ ដូច្នេះ អត្រាខ្ពស់ជាងគេគឺអ្នកមានអាយុ ១៥-២៤ ឆ្នាំ (២,៥%) និងអត្រាទាបជាងគេគឺអ្នកមានអាយុ ៦៥ ឆ្នាំឡើង (០,៣%)។ អត្រាគ្មានការងារធ្វើខ្ពស់ជាងគេគឺជាយុវជនប្រុស (១៥-២៤ ឆ្នាំ) នៅតំបន់ទីប្រជុំជន។

តារាង ១០.៥. អត្រាគ្មានការងារធ្វើ តាមក្រុមអាយុ តំបន់ និងភេទ

(%)

| ក្រុមអាយុ | កម្ពុជា | | | ទីប្រជុំជន | | | ជនបទ | | |
|---|---|---|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| ១៥-២៤ | ២,៥ | ២,៧ | ២,៣ | ៣,៣ | ៤,១ | ២,៦ | ២,២ | ២,៣ | ២,២ |
| ២៥-៣៤ | ១,២ | ១,៤ | ១,០ | ០,៩ | ០,៨ | ០,៩ | ១,៤ | ១,៧ | ១,១ |
| ៣៥-៤៤ | ១,០ | ០,៩ | ១,១ | ០,៤ | ០,៣ | ០,៥ | ១,៣ | ១,៣ | ១,៤ |
| ៤៥-៥៤ | ០,៥ | ០,៥ | ០,៦ | ០,២ | ០,២ | ០,២ | ០,៧ | ០,៦ | ០,៨ |
| ៥៥-៦៤ | ០,៦ | ០,៤ | ០,៩ | ០,៥ | ០,៤ | ០,៧ | ០,៧ | ០,៤ | ១,០ |
| ៦៥+ | ០,៣ | ០,៤ | ០,៣ | ០,០ | ០,០ | ០,០ | ០,៥ | ០,៧ | ០,៤ |
| **សរុប** | **១,២** | **១,២** | **១,២** | **១,០** | **១,០** | **១,០** | **១,៤** | **១,៤** | **១,៣** |

ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

អត្រាគ្មានការងារធ្វើទាបនៅក្នុងប្រទេសមួយ ទោះជាយ៉ាងណាក៏ដោយ មិនមានន័យថាទីផ្សារការងារមានប្រសិទ្ធភាពនោះទេ។ បន្ថែមពីលើការបង្ហាញនូវកង្វះជម្រើសសម្រាប់ការងារដូចបានកត់សម្គាល់ខាងលើ អត្រាទាបអាចបង្ហាញពីការពិតនូវចំនួនកម្មករដ៏ច្រើនបានធ្វើការច្រើនម៉ោង និងទទួលបានប្រាក់ចំណូលទាប ឬជាការពិតដែលភាគច្រើននៃអ្នកធ្វើការបានធ្វើការងារក្រៅប្រព័ន្ធ ដែលផ្តល់ការការពារតិចតួចទល់នឹងប្រាក់ចំណូល ឬវិបត្តិការងារ។

តាមពិត ហេតុផលដែលនាំឲ្យចំនួនអ្នកគ្មានការងារធ្វើទាប យោងតាមអង្កេតបានរកឃើញថាភាគច្រើនជាង ៧៥% បានធ្វើការងារក្នុងវិស័យក្រៅប្រព័ន្ធ។ ប្រាក់ឈ្នួលក្នុងវិស័យក្រៅប្រព័ន្ធច្រើនតែមិនបានចុះបញ្ជី គ្មានច្បាប់ និងប្រាក់ឈ្នួលទាប។ ភាគច្រើននៃអ្នកក្នុងអាយុធ្វើការគ្មានពេលវេលាគ្រប់គ្រាន់ ដើម្បីស្វែងរកការងារត្រូវឡើយ ដូច្នេះពួកគេច្រើនតែបង្កើតអាជីវកម្មគ្រួសារតូចមួយដើម្បីផ្គត់ផ្គង់ជីវភាព។ ម្យ៉ាងទៀត បើពួកគេអត់មានការងារ ពួកគេច្រើនតែរងសម្ពាធឲ្យទទួលយកការងារអ្វីក៏ដោយដែលមាន សម្រាប់ជាប្រយោជន៍ដល់ការរស់នៅ ទាំងនេះត្រូវបានបញ្ជាក់ដោយការពិត ដោយភាគច្រើនស្ថិតក្នុងការងារក្រៅប្រព័ន្ធដែលបច្ចុប្បន្នមានអត្រា (៨៨,៣%) ក្នុងចំណោមអត្រាខ្ពស់ជាងគេនៅអាស៊ី និងប៉ាស៊ីហ្វិក និងនៅលើពិភពលោក។ រូបភាពកាន់តែច្បាស់នៃការប្រើមិនគ្រប់គ្រាន់នូវសក្តានុពលផលិតភាពរបស់ប្រជាជននៅកម្ពុជា ដែលអាចដឹងបានតាមរយៈការពិនិត្យមើលលើចំណែកនៃការប្រើមិនគ្រប់គ្រាន់ជាទូទៅនូវប្រជាជនក្នុងអាយុធ្វើការ បន្ថែមលើកម្លាំងពលកម្ម។

## ១០.៦ ការប្រើមិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម

សន្និសីទអន្តរជាតិនៃអ្នកស្ថិតិកម្លាំងពលកម្មលើកទី១៩ បានអនុម័តលើសេចក្តីសម្រេចពាក់ព័ន្ធនឹងស្ថិតិស្តីពីការងារ ភាពមានការងារធ្វើ និងការប្រើមិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម នៅឆ្នាំ២០១៣។ សេចក្តីសម្រេចបានកំណត់អត្រាគ្មានការងារធ្វើ ជារង្វាស់មួយនៃការប្រើមិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម។ ក្នុងសេចក្តីសម្រេចនេះ ការប្រើមិនគ្រប់គ្រាន់នូវកម្លាំងពលកម្មត្រូវបានកំណត់ជាភាពមិនស៊ីសង្វាក់គ្នារវាងការផ្គត់ផ្គង់ និងសេចក្តីត្រូវការកម្លាំងពលកម្ម ដែលបកស្រាយអំពីតម្រូវការនៅមិនគ្រប់គ្រាន់សម្រាប់ការងារក្នុងចំណោមប្រជាជន។[៤]

ការទទួលស្គាល់នូវដែនកំណត់នៃអត្រាគ្មានការងារធ្វើ ជារង្វាស់មួយនៃការប្រើមិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម ដែលសន្និសីទអន្តរជាតិនៃអ្នកស្ថិតិកម្លាំងពលកម្មលើកទី១៩ បានណែនាំនិយមន័យស្ថិតិនៃការប្រើមិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម ដោយផ្អែកលើសូចនាករចំនួនបួនដែលត្រូវគណនា ដោយប្រើសមាសធាតុសំខាន់បីគឺ៖

(i) ភាពមានការងារធ្វើមិនគ្រប់គ្រាន់ទាក់ទងនឹងពេលវេលា កាលណាពេលវេលាធ្វើការរបស់អ្នកនៅក្នុងការងារមិនគ្រប់គ្រាន់ ប្រៀបធៀបទៅនឹងស្ថានភាពការងារដែលពួកគេចង់បាន និងអាចចូលរួមបាន។

(ii) ភាពគ្មានការងារធ្វើ ឆ្លុះបញ្ចាំងអំពីការស្វែងរកការងារយ៉ាងសកម្មដោយអ្នកមិននៅក្នុងការងារ ដែលអាចធ្វើការងារបាន និង

(iii) កម្លាំងពលកម្មសក្តានុពល សំដៅលើអ្នកមិននៅក្នុងការងារដែលបង្ហាញចំណាប់អារម្មណ៍លើការងារ ប៉ុន្តែស្ថានភាពពួកគេនៅមានកម្រិតក្នុងការស្វែងរកការងារយ៉ាងសកម្ម និង/ឬ អាចធ្វើការងារបានរបស់ពួកគេ។

ចំណុចស្នូលនៃការប្រើមិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម គឺភាពគ្មានការងារធ្វើ។ អ្នកគ្មានការងារធ្វើគឺជាអ្នកដែលមានតម្រូវការច្បាស់លាស់សម្រាប់ការងារ ហើយទោះបីនៅមានកម្រិតកំណត់ក៏ដោយ អត្រាគ្មានការងារធ្វើតែងត្រូវបានប្រើជារង្វាស់តែមួយគត់នៃការប្រើមិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម។ ទោះជាយ៉ាងណាក៏ដោយ វាផ្តល់តែទស្សនៈមួយផ្នែក

[៤] អង្គការអន្តរជាតិខាងការងារ (ILO) ការិយាល័យការងារអន្តរជាតិ។ ឆ្នាំ២០១៩។ *សេចក្តីណែនាំបែបសង្ខេបពីការបកស្រាយអត្រាគ្មានការងារធ្វើ*។ ហ្សឺណែវ។ https://ilo.org/wcmsp5/groups/public/---dgreports/---stat/documents/publication/wcms_675155.pdf.

នៃការប្រើមិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម ដែលពិតជាអាចទទួលយកបាន (និងនៅក្នុងបរិបទជាច្រើនដែលជាលក្ខណៈទូទៅ) ដើម្បីមានការផ្គត់ផ្គង់កម្លាំងពលកម្មដែលមិនបានប្រើក្នុងចំណោមអ្នកធ្វើការ (ចង់ធ្វើការច្រើនម៉ោងជាងពួកគេធ្វើ) ឬក្នុងចំណោមអ្នកនៅក្រៅកម្លាំងពលកម្ម (ឈប់ស្វែងរកការងារធ្វើ ឬមិនមានការងារធ្វើភ្លាមៗ ប៉ុន្តែចង់បានការងារនៅទីបំផុត)។ វាក៏អាចមានការប្រើមិនគ្រប់គ្រាន់នូវកម្លាំងពលកម្មផងដែរ ក្នុងលក្ខខណ្ឌគុណភាព ពោលគឺភាពមិនត្រូវគ្នាខាងជំនាញរបស់អ្នកធ្វើការ ដែលមានសមត្ថភាពលើសសម្រាប់ការងារដែលពួកគេកំពុងធ្វើ។

រូប ១០.២ បង្ហាញសមាសធាតុនៃប្រជាជនក្នុងអាយុធ្វើការ តាមស្ថានភាពកម្លាំងពលកម្ម និងតំបន់ពណ៌ប្រផេះបង្ហាញកន្លែងសម្រាប់ការប្រើមិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម ដែលកើតមានក្នុងក្របខ័ណ្ឌនេះ៖

រូប ១០.២. សមាសធាតុនៃការប្រើមិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម




ប្រភព៖ ការិយាល័យការងារអន្តរជាតិ អង្គការអន្តរជាតិខាងការងារ (ILO)។ *សេចក្តីណែនាំហ័សស្តីពីការបកស្រាយអត្រាគ្មានការងារធ្វើ*។ ហ្សឺណែវ។ https://ilo.org/wcmsp5/groups/public/---dgreports/---stat/documents/publication/wcms_675155.pdf.

សូចនាករការប្រើមិនគ្រប់គ្រាន់នូវកម្លាំងពលកម្មចំនួនបួន ដែលបានណែនាំក្នុងសេចក្តីសម្រេចត្រូវបានគណនាដូចខាងក្រោម៖

LU1 - អត្រាគ្មានការងារធ្វើ

$$= \frac{\text{គ្មានការងារធ្វើ}}{\text{កម្លាំងពលកម្ម}} \times \text{១០០}$$

LU2 - អត្រារួមមានការងារធ្វើមិនគ្រប់គ្រាន់ទាក់ទងនឹងពេលវេលា និងគ្មានការងារធ្វើ

$$= \frac{\text{មានការងារធ្វើមិនគ្រប់គ្រាន់ទាក់ទងនឹងពេលវេលា} + \text{គ្មានការងារធ្វើ}}{\text{កម្លាំងពលកម្ម}} \times \text{១០០}$$

LU3 - អត្រារួមគ្មានការងារធ្វើ និងកម្លាំងពលកម្មសក្តានុពល

$$= \frac{\text{គ្មានការងារធ្វើ} + \text{កម្លាំងពលកម្មសក្តានុពល}}{\text{កម្លាំងពលកម្ម} + \text{កម្លាំងពលកម្មសក្តានុពល}} \times \text{១០០}$$

LU4 - រង្វាស់សមាសធាតុនៃការប្រើមិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម

$$= \frac{\text{មានការងារធ្វើមិនគ្រប់គ្រាន់ទាក់ទងនឹងពេលវេលា} + \text{គ្មានការងារធ្វើ} + \text{កម្លាំងពលកម្មសក្តានុពល}}{\text{កម្លាំងពលកម្ម} + \text{កម្លាំងពលកម្មសក្តានុពល}} \times \text{១០០}$$

តារាង ១០.៦ បង្ហាញអត្រាប្រើមិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម។ នៅឆ្នាំ២០១៩ ប្រមាណ ៩៧.៦៨៧ នាក់ ដែលកំពុងសកម្មស្វែងរកការងារធ្វើ និងអាចធ្វើការងារបាន ហើយពួកគេមានអត្រាគ្មានការងារធ្វើ ១,២%។ ប៉ុន្តែក៏មានមនុស្សមួយក្រុមដែលចាប់អារម្មណ៍លើការងារផងដែរ ប៉ុន្តែស្ថានភាពពួកគេនៅមានកម្រិតក្នុងការស្វែងរកការងារ ឬអាចធ្វើការងារបាន រួមមាន ១២.៧២៩ នាក់គ្មានការងារ ដែលកំពុងសកម្មស្វែងរកការងារធ្វើ ប៉ុន្តែមិនអាចធ្វើការបាន (អ្នកស្វែងរកការងារតែមិនអាចធ្វើបាន) និង ១១៣.៨៨២ នាក់ ដែលបច្ចុប្បន្នមិនស្វែងរកការងារធ្វើប៉ុន្តែពួកគេចង់ធ្វើការ និងអាចចាប់ផ្តើមការងារបាន (អ្នកស្វែងរកការងារមានសក្តានុពលអាចធ្វើបាន)។ នេះបង្ហាញថាមនុស្សសរុប ១២៦.៦១១ នាក់ ដែលត្រូវបានចាត់ទុកជាអ្នកនៅក្រៅកម្លាំងពលកម្មដែលជាក់ស្តែងកំពុងដាក់សម្ពាធលើទីផ្សារការងារ ហើយពួកគេបង្កើតបានជា "កម្លាំងពលកម្មសក្តានុពល"។ កាលណាក្រុមកម្លាំងពលកម្មសក្តានុពលនេះ បូកបន្ថែមកម្លាំងពលកម្ម ពួកគេបង្កើតបានជា "កម្លាំងពលកម្មបន្ថែម"។

កម្លាំងពលកម្មសក្តានុពលក៏ជាសូចនាករមួយនៃការប្រើមិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម បន្ថែមលើអត្រាគ្មានការងារធ្វើ។ កាលណាអ្នកគ្មានការងារធ្វើ បូកនឹងកម្លាំងពលកម្មសក្តានុពល ហើយផលបូកត្រូវបានគណនាជាចំណែកមួយនៃកម្លាំងពលកម្មបន្ថែម បានផ្តល់នូវសូចនាករ LU3 ស្មើនឹង ២,៨% សំដៅលើការផ្គត់ផ្គង់ទីផ្សារការងារដែលមិនត្រូវបានប្រើប្រាស់។ ក្នុងចំណោមអ្នកមានការងារធ្វើ ៨៤.០០៤ នាក់ បានរាយការណ៍ថាពួកគេចង់ធ្វើការច្រើនម៉ោងទៀត ដែលបង្ហាញថាពួកគេមិនត្រូវបានប្រើប្រាស់ពេញលេញឡើយ។ សូចនាករសមាសធាតុនៃការប្រើមិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម (LU4) គឺជាលទ្ធផលនៃផលបូកអ្នកមានការងារធ្វើមិនគ្រប់គ្រាន់ អ្នកគ្មានការងារធ្វើ និងកម្លាំងពលកម្មសក្តានុពល ជាសមាមាត្រនៃកម្លាំងពលកម្មបន្ថែម ស្មើនឹង ៣,៨% នៃអ្នកដែលមានទំនាក់ទំនងនឹងទីផ្សារការងារត្រូវបានប្រើមិនគ្រប់គ្រាន់។

### តារាង ១០.៦. សូចនាករទីផ្សារការងារ

| សូចនាករកម្លាំងពលកម្ម | | | ទាំងពីរភេទ | ប្រុស | ស្រី |
|---|---|---|---|---|---|
| កម្លាំងពលកម្ម (ចំនួន) | W (a+b+c+d+e+f) | ប្រជាជនក្នុងអាយុធ្វើការ | ១១.៥១៤.៦៨៣ | ៥.៤០៣.១០២ | ៦.១១១.៥៨០ |
| | X (L+P) | កម្លាំងពលកម្មបន្ថែម | ៨.១០៧.៤០៤ | ៤.២២៦.៨០៦ | ៣.៨៨០.៥៩៦ |
| | L (E+c) | កម្លាំងពលកម្ម | ៧.៩៨០.៧៩៣ | ៤.១៦៨.៩២៣ | ៣.៨១១.៨៧០ |
| មានការងារធ្វើ (ចំនួន) | E (a+b) | មានការងារធ្វើ | ៧.៨៨៣.១០៦ | ៤.១១៧.៤៦៤ | ៣.៧៦៥.៦៤១ |
| | a | មានការងារធ្វើពេញលេញ | ៧.៧៩៩.១០២ | ៤.០៦៥.៨៨២ | ៣.៧៣៣.២១៩ |
| | b | មានការងារធ្វើមិនគ្រប់គ្រាន់ទាក់ទងនឹងពេលវេលា | ៨៤.០០៤ | ៥១.៥៨២ | ៣២.៤២២ |
| គ្មានការងារធ្វើ (ចំនួន) | c | គ្មានការងារធ្វើ | ៩៧.៦៨៧ | ៥១.៤៥៨ | ៤៦.២២៩ |
| នៅក្រៅកម្លាំងពលកម្ម (ចំនួន) | P (d+e) | កម្លាំងពលកម្មសក្តានុពល | ១២៦.៦១១ | ៥៧.៨៨៤ | ៦៨.៧២៦ |
| | d | អ្នកស្វែងរកការងារមិនអាចធ្វើបាន | ១២.៧២៩ | ៥.២៣៤ | ៧.៤៩៥ |
| | e | អ្នកស្វែងរកការងារសក្តានុពល | ១១៣.៨៨២ | ៥២.៦៥១ | ៦១.២៣១ |
| | f | នៅក្រៅកម្លាំងពលកម្មបន្ថែម | ៣.៤០៧.២៨០ | ១.១៧៦.២៩៥ | ២.២៣០.៩៨៥ |
| សូចនាករនៃការប្រើមិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម (%) | c/L*១០០ | LU1 (អត្រាគ្មានការងារធ្វើ) | ១,២ | ១,២ | ១,២ |
| | (b+c)/L*១០០ | LU2 | ២,៣ | ២,៥ | ២,១ |
| | (c+P)/X*១០០ | LU3 | ២,៨ | ២,៦ | ៣,០ |
| | (b+c+P)/X*១០០ | LU4 | ៣,៨ | ៣,៨ | ៣,៨ |

LU = ការប្រើមិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម
សម្គាល់៖ សរុបអាចមិនស្មើផលបូក ដោយសារការបង្គត់លេខ។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

ដូចបានសង្កេតក្នុងតារាង ១០.៦ ការប៉ាន់ស្មានចំនួន ៣,៤ លាននាក់ ឬប្រមាណ ២៩,៦% នៃប្រជាជនក្នុងអាយុធ្វើការ គឺនៅក្រៅកម្លាំងពលកម្មបន្ថែម។ អ្នកនៅក្រៅកម្លាំងពលកម្មបន្ថែម រួមមានប្រជាជនក្នុងអាយុធ្វើការដែលមិនស្វែងរកការងារធ្វើ និងមិនអាចធ្វើការបាន ឬមិនចង់ធ្វើការ។

តារាង ១០.៧ បង្ហាញការបែងចែកអ្នកនៅក្នុងអាយុធ្វើការនៅក្រៅកម្លាំងពលកម្មបន្ថែម តាមសកម្មភាពចម្បងរបស់ពួកគេក្នុងរយៈពេលយោងអង្កេត។ ចំណែកធំជាងគេ (៣៩,០%) បានចូលរួមក្នុងការទទួលខុសត្រូវក្រុមគ្រួសារ ឬគ្រួសារ ដូចជាការរៀបចំអាហារ ថែទាំផ្ទះ និងថែទាំកុមារ សកម្មភាពទាំងនេះមិនចាត់ទុកជាការងារឡើយ។ ស្ទើរតែពាក់កណ្តាលនៃស្រីនៅក្រៅកម្លាំងពលកម្មបន្ថែម (៤៧,៨%) បានចូលរួមក្នុងការទទួលខុសត្រូវក្រុមគ្រួសារ ឬគ្រួសារ។ ប្រមាណ ២៣,៦% នៃអ្នកនៅក្រៅកម្លាំងពលកម្មបន្ថែមទាំងអស់ បានរាយការណ៍ថាពួកគេកំពុងសិក្សា ឬបណ្តុះបណ្តាល ខណៈ ១៥,៤% នៃពួកគេបានធ្វើកសិកម្ម ឬនេសាទ ដើម្បីផលិតអាហារសម្រាប់ក្រុមគ្រួសារ ឬគ្រួសារពួកគេ។ តារាង ១០.៧ ក៏បង្ហាញថាប្រមាណ ១២,៥% នៃអ្នកនៅក្រៅកម្លាំងពលកម្មបន្ថែម មានជំងឺ របួសរយៈពេលវែង ឬពិការ បន្ទាប់មកចាស់ជរា (៤,៨%) និងបានចូលនិវត្តន៍ ឬអ្នកចូលនិវត្តន៍ (៣,៤%)។

តារាង ១០.៧. ការបែងចែកប្រជាជនក្នុងអាយុធ្វើការ នៅក្រៅកម្លាំងពលកម្មបន្ថែម តាមសកម្មភាពចម្បងបច្ចុប្បន្ន

| សកម្មភាពចម្បងបច្ចុប្បន្ន | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
|---|---|---|---|---|---|---|
| | | (ចំនួន) | | | (%) | |
| កំពុងរៀន ឬបណ្តុះបណ្តាល | ៨០៥.៧៣៤ | ៣៨៤.៣៤៧ | ៤២១.៣៨៧ | ២៣,៦ | ៣២,៧ | ១៨,៩ |
| ចូលរួមការទទួលខុសត្រូវគ្រួសារ | ១.៣២៧.៧០៤ | ២៦២.១៦៥ | ១.០៦៥.៥៣៩ | ៣៩,០ | ២២,៣ | ៤៧,៨ |
| ធ្វើកសិកម្ម ឬនេសាទ ដើម្បីផលិតអាហារសម្រាប់គ្រួសារ | ៥២៣.១៦១ | ២១២.៤០០ | ៣១០.៧៦១ | ១៥,៤ | ១៨,១ | ១៣,៩ |
| បានចូលនិវត្តន៍ ឬអ្នកចូលនិវត្តន៍ | ១១៧.៤៨៥ | ៧២.២៦៩ | ៤៥.២១៧ | ៣,៤ | ៦,១ | ២,០ |
| មានជំងឺ របួសរយៈពេលវែង ឬពិការ | ៤២៧.៤៨៧ | ១៧៦.៨១២ | ២៥០.៦៧៥ | ១២,៥ | ១៥,០ | ១១,២ |
| ធ្វើអ្នកស្ម័គ្រចិត្តសហគមន៍ ឬការងារសប្បុរសធម៌ | ២.២៦៨ | ១.៣៧១ | ៨៩៧ | ០,១ | ០,១ | ០,០ |
| ចូលរួមក្នុងសកម្មភាពវប្បធម៌ ឬកម្សាន្ត | ២១.៥៦៣ | ១១.៧៧៤ | ៩.៧៨៩ | ០,៦ | ១,០ | ០,៤ |
| ចាស់ជរា | ១៦៥.០០៦ | ៤៧.៣០២ | ១១៧.៧០៣ | ៤,៨ | ៤,០ | ៥,៣ |
| មិនចាប់អារម្មណ៍នឹងការងារ | ១៦.៨៧២ | ៧.៨៥៥ | ៩.០១៧ | ០,៥ | ០,៧ | ០,៤ |
| **សរុប** | **៣.៤០៧.២៨០** | **១.១៧៦.២៩៥** | **២.២៣០.៩៨៥** | **១០០,០** | **១០០,០** | **១០០,០** |

សម្គាល់៖ សរុបអាចមិនស្មើផលបូក ដោយសារការបង្គត់លេខ។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

# ជំពូក ១១
# ចំណាយជ្រើសរើសរបស់ពលករចំណាកស្រុកនិវត្តន៍

## ១១.១ សេចក្តីផ្តើម

ជំពូកនេះបង្ហាញទិន្នន័យអំពីការចំណាយលើការជ្រើសរើសរបស់ពលករចំណាកស្រុកវិលត្រឡប់មកវិញដែលជាសមាជិកគ្រួសារ និងមានអាយុ ១៥ ឆ្នាំឡើង។ ទិន្នន័យនេះរួមមានពលករចំណាកស្រុកនិវត្តន៍តាមប្រទេសក្រៅចុងក្រោយដែលពួកគេបានធ្វើការ វិធីសាស្ត្រស្វែងរកការងាររបស់ពួកគេ ការចំណាយដើម្បីទទួលបានការងារដំបូងនៅបរទេស ចំណូលក្នុងការងារដំបូង និងចំនួនខែនៃបៀវត្សរ៍សម្រាប់សងចំណាយទទួលបានការងារ។

ដោយមានផលប៉ះពាល់នៃការធ្វើចំណាកស្រុកដើម្បីការងារ ទាំងប្រទេសបញ្ជូន និងប្រទេសទទួល បញ្ហាចំណាកស្រុកត្រូវបានដាក់បញ្ចូលទៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs)។ គោលដៅទី ១០ មានគោលបំណង "កាត់បន្ថយវិសមភាពនៅក្នុងប្រទេស និងក្នុងចំណោមបណ្តាប្រទេសនានា" ចំណុចដៅ ១០.៧ បានប្រគល់សិទ្ធិឲ្យរដ្ឋាភិបាល "សម្រួលដល់សណ្តាប់ធ្នាប់ សុវត្ថិភាព ការធ្វើចំណាកស្រុកជាទៀងទាត់ និងប្រកបដោយការទទួលខុសត្រូវ និងការចល័តប្រជាជន រួមទាំងតាមរយៈការអនុវត្តផែនការ និងគោលនយោបាយចំណាកស្រុកដែលគ្រប់គ្រងបានល្អ"។ សូចនាករ ១០.៧.១ នៅក្នុងចំណុចដៅ ១០.៧ គឺ "ចំណាយជ្រើសរើសរបស់និយោជិត ជាសមាមាត្រនៃប្រាក់ចំណូលប្រចាំឆ្នាំដែលរកបាននៅក្នុងប្រទេសគោលដៅ"។[៥] ពាក្យ "ជ្រើសរើសពលករ" រួមមានការផ្សាយពាណិជ្ជកម្ម ការផ្សព្វផ្សាយព័ត៌មាន ការជ្រើសរើស ការដឹកជញ្ជូន ការដាក់ការងារធ្វើ និង-សម្រាប់ពលករចំណាកស្រុក-ត្រឡប់មកប្រទេសដើមវិញ ដែលបានអនុវត្ត។ នេះអនុវត្តទាំងអ្នកស្វែងរកការងារ និងអ្នកបានធ្វើការបច្ចុប្បន្ន។

និយមន័យ "ការជ្រើសរើស" របស់អង្គការអន្តរជាតិខាងការងារ (ILO) បង្ហាញថា ប្រជាជនគោលដៅសម្រាប់ការចំណាយជ្រើសរើស រួមមានពលករចំណាកស្រុកអន្តរជាតិ និងពលករចំណាកស្រុកអន្តរជាតិត្រឡប់មកវិញ ដែលកំពុងឬបានធ្វើការនៅក្នុងប្រទេសមួយដែលមិនមែនសញ្ជាតិពួកគេ។ ដើម្បីចៀសវាងបញ្ហារំលឹកឡើងវិញ ការដាក់បញ្ចូលសំណួរត្រូវបានកំណត់ចំពោះបុគ្គលដែលបានធ្វើចំណាកស្រុកទៅធ្វើការនៅប្រទេសគោលដៅមួយ នាពេលកន្លងមកថ្មីៗ (ឧទាហរណ៍ មិនច្រើនជាង ៣ ឆ្នាំ មុនកាលបរិច្ឆេទវាស់វែង)។[៦]

សម្រាប់អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩ ប្រជាជនគោលដៅសម្រាប់វាស់វែងការចំណាយជ្រើសរើស រួមមានពលករចំណាកស្រុកអន្តរជាតិត្រឡប់មកវិញ ដែលត្រូវបានកំណត់ជាអ្នកដែលបានផ្លាស់ប្តូរលំនៅឋានទៅរស់នៅក្រៅប្រទេស និងធ្វើការដើម្បីទទួលបានបៀវត្សរ៍ ប៉ុន្តែតាំងពីពេលនោះពួកគេបានវិលត្រឡប់មកប្រទេសកម្ពុជាវិញ។

ការជ្រើសសំណាកគំរូសម្រាប់អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩ មិនត្រូវបានកែប្រែដើម្បីចាប់យកពលករចំណាកស្រុកអន្តរជាតិវិលត្រឡប់មកវិញឲ្យបានល្អឡើយ។ ដូច្នេះគំហើញក្នុងអង្កេតនេះទំនងប៉ាន់ស្មានខ្វះនូវចំនួនសរុប

---

[៥] នាយកដ្ឋានកិច្ចការសេដ្ឋកិច្ច និងសង្គម របស់អង្គការសហប្រជាជាតិ។ ការអភិវឌ្ឍប្រកបដោយចីរភាព។ https://sdgs.un.org/goals/goal10.

[៦] អង្គការអន្តរជាតិខាងការងារ (ILO)។ ឆ្នាំ២០១៩។ *សៀវភៅណែនាំប្រតិបត្តិការស្តីពីការចំណាយជ្រើសរើសបុគ្គលិក*។ ហ្សឺណែវ៖ អង្គការអន្តរជាតិខាងការងារ (ILO)។ https://www.ilo.org/wcmsp5/groups/public/---ed_protect/---protrav/---migrant/documents/publication/wcms_745663.pdf.

ជាក់ស្តែងនៃពលករចំណាកស្រុកដែលវិលត្រឡប់មកវិញ។ ក៏បញ្ជាក់ផងដែរ អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩ បានគ្របដណ្តប់តែពលករដែលបានវិលត្រឡប់មកលំនៅឋានគ្រួសាររបស់គាត់វិញ នៅពេលអង្កេតប៉ុណ្ណោះ។ ដោយសារទំហំសំណាកគំរូតូចនៃពលករចំណាកស្រុកវិលត្រឡប់វិញ (សរុប ៤៦០ ករណី) ដូច្នេះការសន្និដ្ឋានមួយចំនួននៅក្នុងជំពូកនេះ ដូចជាសូចនាករទាក់ទងនឹងការបែងចែក គួរតែប្រើដោយប្រុងប្រយ័ត្ន។

## ១១.២ ធ្វើការក្រៅប្រទេស

អង្កេតបានប៉ាន់ស្មានប្រមាណ ១៨២.៩៩៤ នាក់ មានអាយុ ១៥ ឆ្នាំឡើង បានធ្វើការនៅក្រៅប្រទេស ហើយបានវិលត្រឡប់មកផ្ទះវិញក្នុងរយៈពេល ៣ ឆ្នាំមុន (តារាង ១១.១)។ ក្នុងចំណោមនោះ ប្រុសមាន ១០៧.២២៩ នាក់ (៥៨,៦%) និងស្រី ៧៥.៧៦៥ នាក់ (៤១,៤%)។ ភាគច្រើននៃពលករចំណាកស្រុកនិវត្តន៍មកពីតំបន់ជនបទ។ ពលករចំណាកស្រុកនិវត្តន៍ជាច្រើនស្ថិតក្នុងក្រុមអាយុក្មេង ភាគច្រើនក្រុមអាយុ ២៥-៣៤ ឆ្នាំ។ ដូចបានកត់សម្គាល់ខាងលើ ចំនួននេះអាចប៉ាន់ស្មានខ្វះ ព្រោះវាគ្របដណ្តប់តែពលករបានត្រឡប់មកគ្រួសារផ្តល់ចម្លើយនៅពេលអង្កេត និងការជ្រើសសំណាកគំរូសម្រាប់អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩ មិនត្រូវបានកែប្រែដើម្បីចាប់យកពលករចំណាកស្រុកឡើយ។

តារាង ១១.១. ប្រជាជនក្នុងអាយុធ្វើការដែលបានទៅបរទេសរស់នៅ និងធ្វើការយកបៀវត្សរ៍តាមក្រុមអាយុ និងភេទ

(%)

| ក្រុមអាយុ | កម្ពុជា | | | ទីប្រជុំជន | | | ជនបទ | | |
|---|---|---|---|---|---|---|---|---|---|
| | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
| ១៥-២៤ | ២៧,៥ | ២៥,៥ | ៣០,៣ | ១៤,៥ | ១៥,២ | ១៣,៤ | ៣១,១ | ២៨,៧ | ៣៤,៤ |
| ២៥-៣៤ | ៤០,៥ | ៤៤,៤ | ៣៥,០ | ៤៨,២ | ៤៨,៤ | ៤៧,៩ | ៣៨,៤ | ៤៣,១ | ៣១,៩ |
| ៣៥-៤៤ | ២០,១ | ១៨,៦ | ២២,២ | ២២,៣ | ២០,៩ | ២៤,៧ | ១៩,៤ | ១៧,៨ | ២១,៦ |
| ៤៥-៥៤ | ៩,៦ | ១០,១ | ៨,៨ | ១៤,១ | ១៥,៥ | ១១,៧ | ៨,៣ | ៨,៥ | ៨,១ |
| ៥៥-៦៤ | ២,១ | ១,៤ | ២,៩ | ០,៩ | ០,០ | ២,៤ | ២,៤ | ១,៩ | ៣,១ |
| ៦៥+ | ០,៣ | ០,០ | ០,៧ | ០,០ | ០,០ | ០,០ | ០,៤ | ០,០ | ០,៩ |
| **សរុប (%)** | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ |
| **សរុប (ចំនួន)** | ១៨២.៩៩៤ | ១០៧.២២៩ | ៧៥.៧៦៥ | ៣៩.៩៩១ | ២៥.២៨៦ | ១៤.៧០៥ | ១៤៣.០០៣ | ៨១.៩៤៣ | ៦១.០៦០ |

សម្គាល់៖
១. ប្រជាជនក្នុងអាយុធ្វើការ សំដៅលើពលរដ្ឋកម្ពុជាមានអាយុ ១៥ ឆ្នាំឡើង។
២. តួលេខទាំងនេះគ្របដណ្តប់តែពលករចំណាកស្រុកបានវិលត្រឡប់មកវិញ ដែលបានរកឃើញក្នុងគ្រួសារនៅពេលអង្កេត ដូច្នេះគំហើញនេះទំនងប៉ាន់ស្មានខ្វះនូវចំនួនសរុបជាក់ស្តែងនៃពលករចំណាកស្រុកនិវត្តន៍។ ទំហំសំណាកគំរូតូចមានតែ ៤៦០ ករណីប៉ុណ្ណោះ។
៣. សរុបអាចមិនស្មើផលបូក ដោយសារការបង្គត់លេខ។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

អ្នកឆ្លើយត្រូវបានសួរសំណួរអំពីប្រទេសក្រៅដែលពួកគេបានធ្វើការក្នុងពេលថ្មីៗនេះ ឬបច្ចុប្បន្នកំពុងធ្វើការ។ តារាង ១១.២ បង្ហាញថាជាង ៩ នាក់ ក្នុងចំណោម ១០ នាក់ បានវិលត្រឡប់មកពីប្រទេសថៃ (៩៥,៣%) ខណៈពួកគេមួយចំនួនតូចបានវិលត្រឡប់មកពីប្រទេសកូរ៉េខាងត្បូង (១,៧%) ម៉ាឡេស៊ី (១,៥%) វៀតណាម (១,២%) និងហ្វីលីពីន (០,២%)។

តារាង ១១.២. ប្រជាជនក្នុងអាយុធ្វើការបានធ្វើការនៅបរទេស តាមប្រទេសក្រោចុងក្រោយ និងភេទ

| ប្រទេសក្រោចុងក្រោយ | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
|---|---|---|---|---|---|---|
| | (ចំនួន) | | | (%) | | |
| ម៉ាឡេស៊ី | ២.៧៩៣ | ២.១២៦ | ៦៦៧ | ១,៥ | ២,០ | ០,៩ |
| ហ្វីលីពីន | ៣៤៨ | ០ | ៣៤៨ | ០,២ | ០,០ | ០,៥ |
| កូរ៉េខាងត្បូង | ៣.១៩១ | ២.៥៣៤ | ៦៥៧ | ១,៧ | ២,៤ | ០,៩ |
| ថៃ | ១៧៤.៤៣១ | ១០១.៧៨៦ | ៧២.៦៤៤ | ៩៥,៣ | ៩៤,៩ | ៩៥,៩ |
| វៀតណាម | ២.២៣១ | ៧៨៣ | ១.៤៤៨ | ១,២ | ០,៧ | ១,៩ |
| **សរុប** | **១៨២.៩៩៤** | **១០៧.២២៩** | **៧៥.៧៦៥** | **១០០,០** | **១០០,០** | **១០០,០** |

សម្គាល់៖
១. ប្រជាជនក្នុងអាយុធ្វើការ សំដៅលើពលរដ្ឋកម្ពុជាមានអាយុ ១៥ ឆ្នាំឡើង។
២. តួលេខទាំងនេះគ្រាន់តែបង្ហាញតែពលករចំណាកស្រុកបានវិលត្រឡប់មកវិញដែលបានរកឃើញក្នុងគ្រួសារនៅពេលអង្កេត ដូច្នេះគំហើញនេះទំនងជាប៉ាន់ស្មានខ្វះនូវចំនួនសរុបជាក់ស្តែងនៃពលករចំណាកស្រុកនិវត្តន៍។ ទំហំសំណាកគំរូតូចមានតែ ៤៦០ ករណីប៉ុណ្ណោះ។
៣. សរុបអាចមិនស្មើផលបូក ដោយសារការបង្គត់លេខ។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

## ១១.៣ វិធីសាស្ត្រស្វែងរកការងារដំបូង

ផ្នែកនេះពិភាក្សាអំពីវិធីសាស្ត្រដែលបានប្រើដោយពលករចំណាកស្រុកអន្តរជាតិ ដើម្បីស្វែងរកការងារដំបូងរបស់ពួកគេនៅប្រទេសក្រោចុងក្រោយដែលពួកគេបានធ្វើការនៅទីនោះ។ នៅពេលដែលពលករចំណាកស្រុកដែលត្រឡប់មកវិញត្រូវបានសួរសំណួរនេះសម្រាប់អង្កេត ជាងមួយភាគបីបានឆ្លើយថាពួកគេបានទទួលការងារដំបូងតាមរយៈសមាជិកគ្រួសារ ឬសាច់ញាតិ (៣៦,២%) ប្រមាណមួយភាគបីបានឆ្លើយថាតាមរយៈមិត្តភក្តិ (៣២,៤%) ខណៈមួយភាគដប់បានឆ្លើយថាតាមរយៈអ្នកជ្រើសរើស ឬឈ្មួញកណ្តាល (១៣,០%) (តារាង ១១.៣)។

តារាង ១១.៣. វិធីសាស្ត្រស្វែងរកការងាររបស់ពលករចំណាកស្រុកអន្តរជាតិ តាមភេទ

| វិធីសាស្ត្រស្វែងរកការងារ | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
|---|---|---|---|---|---|---|
| | (ចំនួន) | | | (%) | | |
| តាមរយៈផ្ទេរការងារ | ៥៥៩ | ៥៥៩ | ០ | ០,៣ | ០,៥ | ០,០ |
| ពីភ្នាក់ងាររដ្ឋាភិបាលនៅកម្ពុជា | ៥.៥៧០ | ៤.៥២៨ | ១.០៤១ | ៣,០ | ៤,២ | ១,៤ |
| ពីភ្នាក់ងាររដ្ឋាភិបាលនៅក្រៅប្រទេស | ២.១៧៣ | ៩១៧ | ១.២៥៦ | ១,២ | ០,៩ | ១,៧ |
| ពីភ្នាក់ងារជ្រើសរើសឯកជននៅកម្ពុជា | ១១.៤០៥ | ៦.៤៤៧ | ៤.៩៥៧ | ៦,២ | ៦,០ | ៦,៥ |
| ពីភ្នាក់ងារជ្រើសរើសឯកជននៅក្រៅប្រទេស | ៣.៣៥៣ | ១.៨១៩ | ១.៥៣៤ | ១,៨ | ១,៧ | ២,០ |
| ដោយផ្ទាល់ពីនិយោជកក្រៅប្រទេស | ៩.៥៤១ | ៤.៦៥៥ | ៤.៨៨៥ | ៥,២ | ៤,៣ | ៦,៤ |
| តាមរយៈបុគ្គលជ្រើសរើស ឬឈ្មួញកណ្តាល (នៅកម្ពុជា ឬនៅក្រៅប្រទេស) | ២៣.៧៦០ | ១១.៧០៥ | ១២.០៥៥ | ១៣,០ | ១០,៩ | ១៥,៩ |
| តាមរយៈសមាជិកគ្រួសារ ឬសាច់ញាតិ | ៦៦.៣៣០ | ៣៧.០១៨ | ២៩.៣១២ | ៣៦,២ | ៣៤,៥ | ៣៨,៧ |
| តាមរយៈមិត្តភក្តិ | ៥៩.២១០ | ៣៩.០៣៤ | ២០.១៧៦ | ៣២,៤ | ៣៦,៤ | ២៦,៦ |
| តាមរយៈសារព័ត៌មាន ឬវេបសាយ | ១.០៩៥ | ៥៤៧ | ៥៤៧ | ០,៦ | ០,៥ | ០,៧ |
| **សរុប** | **១៨២.៩៩៤** | **១០៧.២២៩** | **៧៥.៧៦៥** | **១០០,០** | **១០០,០** | **១០០,០** |

សម្គាល់៖
១. ប្រជាជនក្នុងអាយុធ្វើការ សំដៅលើពលរដ្ឋកម្ពុជាមានអាយុ ១៥ ឆ្នាំឡើង។
២. តារាងនេះបង្ហាញវិធីសាស្ត្រដែលប្រើដោយពលករចំណាកស្រុក ដើម្បីស្វែងរកការងារដំបូងរបស់ពួកគេនៅប្រទេសក្រោចុងក្រោយដែលពួកគេបានធ្វើការមុនពេលត្រឡប់មកប្រទេសកម្ពុជាវិញ។
៣. តួលេខទាំងនេះគ្រាន់តែបង្ហាញតែពលករចំណាកស្រុកបានវិលត្រឡប់មកវិញ ដែលបានរកឃើញក្នុងគ្រួសារនៅពេលអង្កេត ដូច្នេះគំហើញនេះទំនងជាប៉ាន់ស្មានខ្វះនូវចំនួនសរុបជាក់ស្តែងនៃពលករចំណាកស្រុកនិវត្តន៍។ ទំហំសំណាកគំរូតូចមានតែ ៤៦០ ករណីប៉ុណ្ណោះ។
៤. សរុបអាចមិនស្មើផលបូក ដោយសារការបង្គត់លេខ។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

តារាង ១១.៤ បង្ហាញចម្លើយរបស់ពលករចំណាកស្រុកនិវត្តន៍ នៅពេលពួកគេត្រូវបានសួរអំពីរបៀបដែលពួកគេយល់ដឹងអំពីឱកាសការងារដំបូងរបស់ពួកគេនៅបរទេស។ តារាងបង្ហាញថាពួកគេភាគច្រើនបានឆ្លើយថាពួកគេបានឮពីមិត្តភក្តិដែលធ្លាប់បានធ្វើការពីមុន ឬបច្ចុប្បន្នកំពុងធ្វើការនៅបរទេស (៤៣,៩%) ឬពីសមាជិកគ្រួសារ ឬសាច់ញាតិដែលធ្លាប់បានធ្វើការពីមុន ឬបច្ចុប្បន្នកំពុងធ្វើការនៅបរទេស (៣២,១%)។

តារាង ១១.៤. ប្រភពព័ត៌មានអំពីការងារដំបូងនៅបរទេសសម្រាប់ពលករចំណាកស្រុកនិវត្តន៍ តាមភេទ

| ប្រភពព័ត៌មានការងារ | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
|---|---|---|---|---|---|---|
| | (ចំនួន) | | | (%) | | |
| តាមរយៈមិត្តភក្តិ ដែលមិនធ្វើការនៅក្រៅប្រទេស | ១០.០៤៣ | ៦.១៨៩ | ៣.៨៥៥ | ៥,៥ | ៥,៨ | ៥,១ |
| តាមរយៈមិត្តភក្តិ បានធ្វើការពីមុន ឬកំពុងធ្វើការនៅក្រៅប្រទេស | ៨០.២៤៨ | ៤៩.៧២៦ | ៣០.៥២២ | ៤៣,៩ | ៤៦,៤ | ៤០,៣ |
| តាមរយៈសមាជិកគ្រួសារ/សាច់ញាតិ ដែលមិនធ្វើការនៅក្រៅប្រទេស | ១៤.៩៣២ | ៨.៦៥៦ | ៦.២៧៦ | ៨,២ | ៨,១ | ៨,៣ |
| តាមរយៈសមាជិកគ្រួសារ/សាច់ញាតិ បានធ្វើការពីមុន ឬកំពុងធ្វើការនៅក្រៅប្រទេស | ៥៨.៧៨៥ | ៣២.៧៩៣ | ២៥.៩៩២ | ៣២,១ | ៣០,៦ | ៣៤,៣ |
| តាមរយៈអ្នកនាំមិនមែនសាច់ញាតិ | ៩.៤៩៩ | ៤.៧៤២ | ៤.៧៥៨ | ៥,២ | ៤,៤ | ៦,៣ |
| តាមរយៈសារព័ត៌មាន | ២.២០០ | ១.២៨០ | ៩២០ | ១,២ | ១,២ | ១,២ |
| តាមរយៈវេបសាយ | ១.០០២ | ៣៦៨ | ៦៣៤ | ០,៥ | ០,៣ | ០,៨ |
| តាមរយៈបណ្តាញសង្គម (ហ្វេសប៊ុក ។ល។) | ៦.២៨៥ | ៣.៤៧៦ | ២.៨០៨ | ៣,៤ | ៣,២ | ៣,៧ |
| **សរុប** | **១៨២.៩៩៤** | **១០៧.២២៩** | **៧៥.៧៦៥** | **១០០,០** | **១០០,០** | **១០០,០** |

សម្គាល់៖

១. តារាងនេះបង្ហាញប្រភពព័ត៌មានដែលប្រើដោយពលករចំណាកស្រុក ដើម្បីស្វែងរកការងារដំបូងរបស់ពួកគេនៅប្រទេសក្រៅចុងក្រោយដែលពួកគេបានធ្វើការមុនពេលត្រឡប់មកប្រទេសកម្ពុជាវិញ។

២. តួលេខទាំងនេះគ្របដណ្តប់តែពលករចំណាកស្រុកបានវិលត្រឡប់មកវិញ ដែលបានរកឃើញក្នុងគ្រួសារនៅពេលអង្កេត ដូច្នេះតំហើញនេះទំនងប៉ាន់ស្មានខ្វះនូវចំនួនសរុបជាក់ស្តែងនៃពលករចំណាកស្រុកនិវត្តន៍។ ទំហំសំណាកគំរូតូចមានតែ ៤៦០ ករណីប៉ុណ្ណោះ។

៣. សរុបអាចមិនស្មើផលបូក ដោយសារការបង្គត់លេខ។

ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

ពលករចំណាកស្រុកនិវត្តន៍ត្រូវបានសួរអំពីវិធីដែលពួកគេបានចូលទៅប្រទេសក្រៅចុងក្រោយ ដែលពួកគេបានធ្វើការនៅទីនោះ។ ភាគច្រើនបានទៅតាមច្បាប់អន្តោប្រវេសន៍មានទិដ្ឋាការការងារ (៦៥,៦%) ច្រើនជាងមួយភាគបួនមិនបានទៅតាមច្រកផ្លូវការ ឬតាមច្បាប់ទម្លាប់ (២៥,៩%) និងតិចជាងមួយភាគដប់ (៨,៤%) បានទៅតាមច្បាប់អន្តោប្រវេសន៍គ្មានទិដ្ឋាការការងារ ជំនួសដោយធ្វើដំណើរតាមទិដ្ឋាការទេសចរណ៍ (តារាង ១១.៥)។

តារាង ១១.៥. វិធីប្រើដោយពលករចំណាកស្រុកនិវត្តន៍ចូលទៅប្រទេសក្រៅចុងក្រោយដើម្បីធ្វើការ តាមភេទ

| វិធីចូលប្រទេសក្រៅចុងក្រោយ | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
|---|---|---|---|---|---|---|
| | (ចំនួន) | | | (%) | | |
| តាមរយៈច្បាប់អន្តោប្រវេសន៍មានទិដ្ឋាការការងារ | ១១៩.៩៦៤ | ៧២.៣៧៧ | ៤៧.៥៨៧ | ៦៥,៦ | ៦៧,៥ | ៦២,៨ |
| តាមរយៈច្បាប់អន្តោប្រវេសន៍គ្មានទិដ្ឋាការការងារ (ឧទាហរណ៍ ធ្វើដំណើរ ឬអ្នកទេសចរ) | ១៥.៣០៤ | ៧.៩៣១ | ៧.៣៧៣ | ៨,៤ | ៧,៤ | ៩,៧ |
| មិនតាមច្រកផ្លូវការ ឬតាមច្បាប់ទម្លាប់ | ៤៧.៤៥៨ | ២៦.៦៥៣ | ២០.៨០៥ | ២៥,៩ | ២៤,៩ | ២៧,៥ |
| គ្មានចម្លើយ | ២៦៩ | ២៦៩ | ០ | ០,១ | ០,៣ | ០,០ |
| **សរុប** | **១៨២.៩៩៤** | **១០៧.២២៩** | **៧៥.៧៦៥** | **១០០,០** | **១០០,០** | **១០០,០** |

សម្គាល់៖

១. តួលេខទាំងនេះគ្របដណ្តប់តែពលករចំណាកស្រុកបានវិលត្រឡប់មកវិញ ដែលបានរកឃើញក្នុងគ្រួសារនៅពេលអង្កេត ដូច្នេះតំហើញនេះទំនងប៉ាន់ស្មានខ្វះនូវចំនួនសរុបជាក់ស្តែងនៃពលករចំណាកស្រុកនិវត្តន៍។ ទំហំសំណាកគំរូតូចមានតែ ៤៦០ ករណីប៉ុណ្ណោះ។

២. សរុបអាចមិនស្មើផលបូក ដោយសារការបង្គត់លេខ។

ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

## ១១.៤ ចំណាយជ្រើសរើស

ផ្នែកនេះបង្ហាញចម្លើយអង្កេតទាក់ទងនឹងការចំណាយជ្រើសរើស ដែលជាចំនួនទឹកប្រាក់ដែលត្រូវចំណាយសម្រាប់ទទួលបានការងារក្រៅប្រទេស។ ចំណាយទាំងនោះរួមមាន៖ (i) ឯកសារដូចជា លិខិតឆ្លងដែន ទិដ្ឋាការ ពិនិត្យសុខភាព បណ្តុះបណ្តាលមុនចេញដំណើរ វាយតម្លៃជំនាញ ថ្លៃធានារ៉ាប់រង ថ្លៃសេវាយល់ព្រមលើកិច្ចសន្យា ថ្លៃដំណើរ ឬពិនិត្យសុវត្ថិភាពដំណើរ (ii) ថ្លៃបង់ឲ្យអ្នកជ្រើសរើស ឬឈ្មួញកណ្តាល ឬឲ្យភ្នាក់ងារជ្រើសរើស ឬភ្នាក់ងារការងារ (iii) ចំណាយធ្វើដំណើរ ដូចជាការស្នាក់នៅ និង (iv) ចំណាយផ្លូវការ ឬក្រៅផ្លូវការផ្សេងទៀត រួមទាំងចំណាយឲ្យមិត្តភក្តិ ឬសាច់ញាតិ ដែលបានជួយរកការងារឲ្យធ្វើ ក៏ដូចជាចំណាយក្រៅផ្លូវការដទៃទៀត ឬថ្លៃឈ្នួល និងការប្រាក់លើប្រាក់កម្ចី។

តារាង ១១.៦ បង្ហាញការបែងចែកចំនួនពលករចំណាកស្រុកនិវត្តន៍ តាមចំណាយសរុបរបស់ពួកគេ ដើម្បីទទួលបានការងារដំបូងនៅក្នុងប្រទេសក្រៅចុងក្រោយដែលពួកគេបានធ្វើការ រួមទាំងការកាត់ចេញទាំងអស់ពីបៀវត្សរ៍របស់ពួកគេផងដែរ។ ដូចបានបង្ហាញក្នុងតារាង ប្រមាណ ៣៩,៩% បានចំណាយតិចជាង ៤០០.០០០ រៀល (១០០ ដុល្លារអាមេរិក) ខណៈ ២៩,៦% បានចំណាយពី ៤០០.០០០ រៀល ទៅ ១.៦០០.០០០ រៀល (៤០០ ដុល្លារអាមេរិក)។ ការចំណាយជ្រើសរើសជាមធ្យមមាន ១.៤១៧.៥៣៧ រៀល (៣៥៤,៤០ ដុល្លារអាមេរិក)។

តារាង ១១.៦. ចំណាយទទួលបានការងារដំបូងនៅបរទេសរបស់ពលករចំណាកស្រុកនិវត្តន៍ តាមភេទ

| ចំណាយ | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
|---|---|---|---|---|---|---|
| | (ចំនួន) | | | (%) | | |
| តិចជាង ៤០០.០០០ រៀល | ៧២.៩៥៣ | ៤១.៨៩៦ | ៣១.០៥៧ | ៣៩,៩ | ៣៩,១ | ៤១,០ |
| ៤០០.០០០ ទៅតិចជាង ១.៦០០.០០០ រៀល | ៥៤.១៩៨ | ៣២.២១៨ | ២១.៩៧៦ | ២៩,៦ | ៣០,០ | ២៩,០ |
| ១.៦០០.០០០ ទៅតិចជាង ២.៤០០.០០០ រៀល | ១៣.៦៨៨ | ៧.៩៦៤ | ៥.៧២៥ | ៧,៥ | ៧,៤ | ៧,៦ |
| ២.៤០០.០០០ ទៅតិចជាង ៣.២០០.០០០ រៀល | ១៤.៥៣៣ | ៨.៥០៨ | ៦.០២៥ | ៧,៩ | ៧,៩ | ៨,០ |
| ៣.២០០.០០០ ទៅតិចជាង ៤.០០០.០០០ រៀល | ២០.៤៧២ | ១១.៧៨៩ | ៨.៦៨០ | ១១,២ | ១១,០ | ១១,៥ |
| ៤.០០០.០០០ រៀល ឡើងទៅ | ៧.១៥១ | ៤.៨៥៣ | ២.២៩៦ | ៣,៩ | ៤,៥ | ៣,០ |
| **សរុប** | **១៨២.៩៩៤** | **១០៧.២២៩** | **៧៥.៧៦៥** | **១០០,០** | **១០០,០** | **១០០,០** |
| ចំណាយជាមធ្យម (គិតជារៀល) | ១.៤១៧.៥៣៧ | ១.៤៨៥.០៩៥ | ១.៣២១.៩២២ | | | |

សម្គាល់៖
១. អត្រាប្តូរប្រាក់ ៤.០០០ រៀល ក្នុង ១ ដុល្លារអាមេរិក។
២. តួលេខទាំងនេះគ្របដណ្តប់តែពលករចំណាកស្រុកបានវិលត្រឡប់មកវិញ ដែលបានរកឃើញក្នុងគ្រួសារនៅពេលអង្កេត និងមានលទ្ធផលតាមទំហំសំណាកគំរូតូចដែលមានតែ ៤៦០ ករណីប៉ុណ្ណោះ។
៣. ក្រឡាទទេបង្ហាញថាឈ្មោះជួរដេកមិនអនុវត្ត។
៤. សរុបអាចមិនស្មើផលបូក ដោយសារការបង្គត់លេខ។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

## ១១.៥ ចំណូល

ពលករចំណាកស្រុកនិវត្តន៍ត្រូវបានសួរឲ្យរាយការណ៍ប្រាក់ចំណូលសរុបប្រចាំខែដំបូងរបស់ពួកគេ ពីការងារដំបូងរបស់ពួកគេនៅប្រទេសក្រៅចុងក្រោយ រួមមានបៀវត្សរ៍ ប្រាក់ទូទាត់ជារបស់និងប្រាក់បន្ថែមប្រចាំខែ និងប្រាក់សងប្រចាំខែសម្រាប់ការទទួលបានការងារដំបូងរបស់ពួកគេ បើមាន។

តារាង ១១.៧ បង្ហាញចំណូលប្រចាំខែសរុបរបស់ពលករចំណាកស្រុកនិវត្តន៍ពីការងារដំបូងរបស់ពួកគេនៅក្នុងប្រទេសក្រៅចុងក្រោយ។ ជាសរុប ចំណូលប្រចាំខែជាមធ្យមរបស់ពលករចំណាកស្រុកនិវត្តន៍មាន ២,២ លានរៀល

(៥៥០ ដុល្លារអាមេរិក)។ ប្រមាណ ៨ ក្នុងចំណោម ១០ (៨០,៤%) រកចំណូលចន្លោះ ៤០០,០០០ រៀល (១០០ ដុល្លារអាមេរិក) និង ១,៦ លានរៀល (៤០០ ដុល្លារអាមេរិក)។ អ្នករកប្រាក់ចំណូលខ្ពស់ជាងគេ ជាមួយចំណូលប្រចាំខែយ៉ាងតិច ៤ លានរៀល (១,០០០ ដុល្លារអាមេរិក) មានតែ ៥,៩% នៃពលករចំណាកស្រុកនិវត្តន៍សរុប។

តារាង ១១.៧. ចំណូលប្រចាំខែរបស់ពលករចំណាកស្រុកនិវត្តន៍ពីការងារដំបូងនៅបរទេស តាមភេទ

| ចំណូលប្រចាំខែ | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
|---|---|---|---|---|---|---|
| | (ចំនួន) | | | (%) | | |
| តិចជាង ៤០០.០០០ រៀល | ១២.៧៧៣ | ៧.៣៦៥ | ៥.៤១១ | ៧,០ | ៦,៩ | ៧,១ |
| ៤០០.០០០ ទៅតិចជាង ១.៦០០.០០០ រៀល | ១៤៧.១២១ | ៨៦.៤៣៣ | ៦០.៦៨៦ | ៨០,៤ | ៨០,៦ | ៨០,១ |
| ១.៦០០.០០០ ទៅតិចជាង ២.៤០០.០០០ រៀល | ៨.៧៣៥ | ៤.៤១៨ | ៤.៣១៧ | ៤,៨ | ៤,១ | ៥,៧ |
| ២.៤០០.០០០ ទៅតិចជាង ៣.២០០.០០០ រៀល | ១.៨២៣ | ៩៥០ | ៨៧២ | ១,០ | ០,៩ | ១,២ |
| ៣.២០០.០០០ ទៅតិចជាង ៤.០០០.០០០ រៀល | ១.៧៤៨ | ១.៧៤៨ | ០ | ១,០ | ១,៦ | ០,០ |
| ៤.០០០.០០០ រៀល ឡើងទៅ | ១០.៧៩១ | ៦.៣១៤ | ៤.៤៧៥ | ៥,៩ | ៥,៩ | ៥,៩ |
| **សរុប** | **១៨២.៩៩៤** | **១០៧.២២៩** | **៧៥.៧៦៥** | **១០០,០** | **១០០,០** | **១០០,០** |
| ចំណូលជាមធ្យម (គិតជារៀល) | ២.១៧៦.០៣៥ | ២.៣៦០.៦០៨ | ១.៩១៤.៨១១ | | | |

សម្គាល់៖
១. តារាងនេះបង្ហាញចំណូលរបស់ពលករចំណាកស្រុកនិវត្តន៍ពីការងារដំបូងរបស់ពួកគេនៅប្រទេសក្រៅចុងក្រោយដែលពួកគេបានធ្វើការ។
២. អត្រាប្តូរប្រាក់ ៤.០០០ រៀល ក្នុង ១ ដុល្លារអាមេរិក។
៣. តួលេខទាំងនេះគ្របដណ្តប់តែពលករចំណាកស្រុកបានវិលត្រឡប់មកវិញ ដែលបានរកឃើញក្នុងគ្រួសារនៅពេលអង្កេត ដូច្នេះគំហើញនេះទំនងប៉ាន់ស្មានខ្វះនូវចំនួនសរុបជាក់ស្តែងនៃពលករចំណាកស្រុកនិវត្តន៍។ ទំហំសំណាកគំរូតូចមានតែ ៤៦០ ករណីប៉ុណ្ណោះ។
៤. ក្រឡាទទេបង្ហាញថាឈ្មោះជួរដេកមិនអនុវត្ត។
៥. សរុបអាចមិនស្មើផលបូក ដោយសារការបង្គត់លេខ។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

## ១១.៦ សូចនាករចំណាយជ្រើសរើស

សូចនាករចំណាយជ្រើសរើស (RCI) គឺជាស្ថិតិសំខាន់ដែលត្រូវផលិតសម្រាប់សូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ១០.៧.១ ហើយគួរត្រូវបានគណនាសម្រាប់ពលករចំណាកស្រុក ជាសមាមាត្រនៃចំណាយជ្រើសរើសធៀបនឹងចំណូលប្រចាំខែ។ ចំណាយជ្រើសរើសកើតឡើងដោយពលករចំណាកស្រុកនិវត្តន៍នៅកម្ពុជា ដែលអាចបង្ហាញតាមប្រាក់ចំណូលប្រចាំខែរបស់ពួកគេនៅប្រទេសក្រៅ។

សម្រាប់អង្កេតនេះ សូចនាករចំណាយជ្រើសរើសសម្រាប់ពលករចំណាកស្រុកនិវត្តន៍ត្រូវបានគណនាដោយចំណាយជ្រើសរើសជាមធ្យម ចែកនឹងចំណូលជាមធ្យមក្នុងខែដំបូង។ រូបមន្តនេះផ្អែកតាមកថាខណ្ឌ ១១ និង ៥២ នៃសេចក្តីព្រាងណែនាំរបស់អង្គការអន្តរជាតិខាងការងារ (ILO) ស្តីពីការប្រមូលស្ថិតិសម្រាប់សូចនាករ ១០.៧.១។[៧]

តារាង ១១.៨ បង្ហាញសូចនាករចំណាយជ្រើសរើស តាមភេទ តំបន់ ក្រុមអាយុ វិស័យសេដ្ឋកិច្ច និងប្រទេសក្រៅចុងក្រោយរបស់ការងារ។ តារាងបង្ហាញថាអត្រាសរុបនៃចំណាយជ្រើសរើសជាមធ្យមធៀបនឹងបៀវត្សរ៍ប្រចាំខែស្មើប្រមាណ ០,៧ ខែនៃចំណូល។ អត្រាសម្រាប់ទាំងពីរភេទមានប្រហាក់ប្រហែលគ្នា គឺប្រុសមាន ០,៦ ខែ និងស្រីមាន ០,៧ ខែ។ អត្រាចំណាយជ្រើសរើសជាមធ្យមធៀបនឹងចំណូលប្រចាំខែរបស់ពលករចំណាកស្រុកនិវត្តន៍អាយុ ១៥-២៤ ឆ្នាំ មាន ១,០ ខ្ពស់ជាងពលករចំណាកស្រុកនិវត្តន៍អាយុ ២៥ ឆ្នាំឡើង ដែលមានតែ ០,៦។ តាមវិស័យសេដ្ឋកិច្ច

---

[៧] អង្គការអន្តរជាតិខាងការងារ (ILO) និងធនាគារពិភពលោក ឆ្នាំ២០១៩។ *សេចក្តីព្រាងស្តីពីស្ថិតិសម្រាប់សូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ១០.៧.១ សម្រាប់ការប្រមូលទិន្នន័យ*។ ហ្សឺណែវ។
https://www.ilo.org/wcmsp5/groups/public/---ed_protect/---protrav/---migrant/documents/publication/wcms_670175.pdf.

អត្រាខ្ពស់ជាងគេសម្រាប់ពលករចំណាកស្រុកនិវត្តន៍គឺធ្វើការក្នុងសេវាកម្ម (១,១) បន្ទាប់មកក្នុងកសិកម្ម (០,៩) និងឧស្សាហកម្ម (០,៥)។ ចំពោះប្រទេសក្រៅនៃការងារចុងក្រោយ អត្រាខ្ពស់ជាងគេសម្រាប់ពលករចំណាកស្រុកគឺមកពីប្រទេសថៃ (០,៧) បើធៀបនឹងអ្នកមកពីប្រទេសដទៃទៀត។

តារាង ១១.៨. សូចនាករចំណាយជ្រើសរើស តាមភេទ តំបន់ភូមិសាស្ត្រ ក្រុមអាយុ វិស័យសេដ្ឋកិច្ច និងប្រទេសក្រៅចុងក្រោយរបស់ការងារ

(ខែនៃបៀវត្សរ៍)

| សូចនាករចំណាយជ្រើសរើស | ទាំងពីរភេទ | ប្រុស | ស្រី |
|---|---|---|---|
| **តាមតំបន់ភូមិសាស្ត្រ** | | | |
| ទីប្រជុំជន | ០,៩ | ១,១ | ០,៦ |
| ជនបទ | ០,៦ | ០,៥ | ០,៧ |
| **តាមក្រុមអាយុ** | | | |
| ១៥–២៤ | ១,០ | ១,០ | ១,០ |
| ២៥+ | ០,៦ | ០,៥ | ០,៦ |
| **តាមវិស័យសេដ្ឋកិច្ច** | | | |
| កសិកម្ម | ០,៩ | ១,០ | ០,៧ |
| ឧស្សាហកម្ម | ០,៥ | ០,៥ | ០,៦ |
| សេវាកម្ម | ១,១ | ០,៩ | ១,៣ |
| **តាមប្រទេសក្រៅចុងក្រោយនៃការងារ** | | | |
| ថៃ | ០,៧ | ០,៧ | ០,៧ |
| ប្រទេសដទៃទៀត | ០,៥ | ០,៤ | ១,៤ |
| **សរុប** | **០,៧** | **០,៦** | **០,៧** |

សម្គាល់៖

១. សូចនាករចំណាយជ្រើសរើសសម្រាប់ពលករចំណាកស្រុកនិវត្តន៍ត្រូវបានគណនាជាចំណាយជ្រើសរើសជាមធ្យមសម្រាប់ប្រភេទនីមួយៗ ចែកនឹងចំណូលជាមធ្យមនៅខែដំបូង។

២. តម្លៃក្នុងតារាងនេះគ្របដណ្តប់តែពលករចំណាកស្រុកបានវិលត្រឡប់មកវិញ ដែលបានរកឃើញក្នុងគ្រួសារនៅពេលអង្កេតប៉ុណ្ណោះ។ ទំហំសំណាកគំរូតូចនៃពលករចំណាកស្រុកនិវត្តន៍មានតែ ៤៦០ ករណីជាសរុប។

ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

## ១១.៧ ចំនួនខែត្រូវសងចំណាយជ្រើសរើស

តារាង ១១.៩ បង្ហាញចំនួនខែដែលត្រូវសង ដោយគ្របដណ្តប់ចំណាយដែលកើតមានក្នុងការទទួលបានការងារធ្វើនៅបរទេស ដែលបានរាយការណ៍ដោយពលករចំណាកស្រុកនិវត្តន៍ខ្លួនឯង។ ពលករមួយចំនួនបានខ្ចីប្រាក់ពីអ្នកឲ្យខ្ចីលុយ ឬពីភ្នាក់ងារការងាររបស់ពួកគេ ដើម្បីសងប្រាក់កម្ចីរបស់ពួកគេសម្រាប់ចំណាយជ្រើសរើសពលករ ហើយបន្ទាប់មកពួកគេបានសងប្រាក់កម្ចីទាំងនេះពីចំណូលរបស់ពួកគេក្រោយពីពួកគេបានចាប់ផ្តើមធ្វើការងារ។ តារាង ១១.៩ បង្ហាញថា ចំនួនខែបានរាយការណ៍ជាមធ្យមដែលពួកគេត្រូវសងចំណាយជ្រើសរើសគឺ ១,៤ ខែ។ នៅពេលអង្កេត ប្រមាណ ៧២,៦% នៃពលករចំណាកស្រុកនិវត្តន៍បានសងចំណាយជ្រើសរើសរបស់ពួកគេរួចរាល់ហើយ។ ប្រមាណ ២៣,៧% នៃពួកគេត្រូវធ្វើការពី ១ ខែ ទៅក្រោម ១២ ខែ ដើម្បីសងប្រាក់កម្ចីរបស់ពួកគេ។ មានតែពលករចំណាកស្រុកនិវត្តន៍មួយចំនួនតូចប៉ុណ្ណោះ ដែលត្រូវធ្វើការពីមួយឆ្នាំឡើងទៅដើម្បីសងប្រាក់កម្ចីរបស់ពួកគេ។ ភាពខុសគ្នារវាងការគណនាជាក់ស្តែងនៃសូចនាករចំណាយជ្រើសរើស (០,៧ ខែ) និងការប៉ាន់ស្មានខ្លួនឯង (១,៤ ខែ) គឺមានសារៈសំខាន់ណាស់។ ទោះជាយ៉ាងណាក៏ដោយ គួរពិចារណាលើចំនួនករណីដែលមានចំនួនតិចក្នុងសំណាកគំរូ ដែលគួរតែបកស្រាយភាពខុសគ្នានេះដោយប្រុងប្រយ័ត្ន។

## តារាង ១១.៩. ចំនួនខែរបស់ពលករចំណាកស្រុកនិវត្តន៍ត្រូវទូទាត់សងចំណាយជ្រើសរើស តាមភេទ

| ចំនួនខែ | ទាំងពីរភេទ | ប្រុស | ស្រី | ទាំងពីរភេទ | ប្រុស | ស្រី |
|---|---|---|---|---|---|---|
| | (ចំនួន) | | | (%) | | |
| សងរួចរាល់ហើយ | ១៣២.៨៣៨ | ៧៧.៩៣៧ | ៥៤.៩០១ | ៧២,៦ | ៧២,៧ | ៧២,៥ |
| ១ ខែ ទៅតិចជាង ៣ ខែ | ១៦.៩១៧ | ៩.៥០៦ | ៧.៤១០ | ៩,២ | ៨,៩ | ៩,៨ |
| ៣ ខែ ទៅតិចជាង ៦ ខែ | ១៧.៥១២ | ១១.០៦២ | ៦.៤៥០ | ៩,៦ | ១០,៣ | ៨,៥ |
| ៦ ខែ ទៅតិចជាង ១២ ខែ | ៨.៩២៧ | ៤.៩៥៧ | ៣.៩៦៩ | ៤,៩ | ៤,៦ | ៥,២ |
| ១២ ខែ ទៅតិចជាង ២៤ ខែ | ៦.៥៣៦ | ៣.៧៦៨ | ២.៧៦៨ | ៣,៦ | ៣,៥ | ៣,៧ |
| ២៤ ខែ ឡើងទៅ | ២៦៦ | ០ | ២៦៦ | ០,១ | ០,០ | ០,៤ |
| **សរុប** | **១៨២.៩៩៤** | **១០៧.២២៩** | **៧៥.៧៦៥** | **១០០,០** | **១០០,០** | **១០០,០** |
| ចំនួនខែជាមធ្យម | ១,៤ | ១,៣ | ១,៤ | | | |

សម្គាល់៖
១. តារាងនេះបង្ហាញចំណូលរបស់ពលករចំណាកស្រុកនិវត្តន៍ពីការងារដំបូងរបស់ពួកគេនៅប្រទេសក្រៅចុងក្រោយដែលពួកគេបានធ្វើការ។
២. តួលេខទាំងនេះគ្របដណ្តប់តែពលករចំណាកស្រុកបានវិលត្រឡប់មកវិញ ដែលបានរកឃើញក្នុងគ្រួសារនៅពេលអង្កេត ដូច្នេះគំហើញនេះទំនងប៉ាន់ស្មានខ្វះនូវចំនួនសរុបជាក់ស្តែងនៃពលករចំណាកស្រុកនិវត្តន៍។ ទំហំសំណាកគំរូតូចមានតែ ៤៦០ ករណីប៉ុណ្ណោះ។
៣. អត្រាប្តូរប្រាក់ ៤.០០០ រៀល ក្នុង ១ ដុល្លារអាមេរិក។
៤. ក្រឡាទទេបង្ហាញថាឈ្មោះជួរដេកមិនអនុវត្ត។
៥. សរុបអាចមិនស្មើផលបូក ដោយសារការបង្គត់លេខ។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

# ជំពូក ១២
# សូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការងារសមរម្យជ្រើសរើស

ដើម្បីតាមដានវឌ្ឍនភាពឆ្ពោះទៅការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពសកល និងគោលដៅរួម កំណត់តំបន់ទាក់ទង និងជូនដំណឹងអំពីការបង្កើតគោលនយោបាយ វាចាំបាច់ត្រូវមានសំណុំសូចនាករមួយត្រឹមត្រូវ និងអាចជឿបាន។ នៅថ្នាក់ជាតិ ដើម្បីវាយតម្លៃលើរបៀបវារៈរបស់អង្គការសហប្រជាជាតិ ឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពដែលបានអនុវត្តនៅក្នុងបណ្ដាប្រទេសនានា រដ្ឋាភិបាលអាចផ្ដល់អាទិភាពដល់សូចនាករទាំងឡាយដែលបម្រើបានល្អប្រសើរដល់សេចក្ដីត្រូវការជាតិ ដោយពិចារណាលើបរិបទជាតិ និងការអភិវឌ្ឍស្ថិតិ។

រាជរដ្ឋាភិបាលកម្ពុជាបានទទួលយករបៀបវារៈ ឆ្នាំ២០៣០ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពចំនួន ១៧ ជាមួយការប្ដេជ្ញាចិត្តខ្ពស់ចំពោះសមិទ្ធផលនេះ។ ក្រសួងផែនការត្រូវបានអនុញ្ញាតឲ្យដឹកនាំ និងសម្របសម្រួលគោលនយោបាយគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពជាតិ។ ក្របខ័ណ្ឌនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ឆ្នាំ២០១៦-២០៣០ បានជ្រើសរើសយកទាំង ១៧ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងថែមគោលដៅមួយទៀតទាក់ទងនឹងការបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម[៨] ដែលឆ្លុះបញ្ចាំងពីអាទិភាពជាតិនៃការបញ្ចប់គ្រាប់មីនឲ្យអស់ពីទឹកដីកម្ពុជា។

## ១២.១ សេចក្ដីផ្ដើម

ជំពូកនេះផ្ដោតលើសូចនាករមួយចំនួនទាក់ទងនឹងគោលដៅ ១ គោលដៅ ៥ និងគោលដៅ ៨ ។ ជំពូកនេះក៏រួមបញ្ចូលសូចនាករការងារសមរម្យដទៃទៀត ដែលអាចយកពីអង្កេតនេះផងដែរ។ គោលដៅ ១ ស្វែងរកការបញ្ចប់ភាពក្រីក្រ និងមួយនៃសូចនាករនានាសម្រាប់គោលដៅនេះគឺកិច្ចគាំពារសង្គម ហើយគោលដៅ ៥ ស្វែងរកដំណោះស្រាយសមភាពយេនឌ័រ និងគោលដៅ ៨ ផ្ដោតលើការលើកកម្ពស់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាប័ន្ន ការងារពេញលេញ និងមានផលិតភាព និងការងារសមរម្យសម្រាប់ទាំងអស់គ្នា។ សូចនាករទាំងនេះត្រូវបានបង្ហាញក្នុងតារាង ១២.១។

## ១២.២ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការងារសមរម្យ

តារាង ១២.១ រួមមានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពជ្រើសរើស ក៏ដូចជាសូចនាករការងារសមរម្យផ្សេងៗ ដែលអាចទាញយកពីអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

គោលដៅ ១ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពបានអំពាវនាវឲ្យបញ្ចប់ភាពក្រីក្រតាមគ្រប់ទម្រង់ និងមួយនៃសូចនាករទាំងនោះគឺកិច្ចគាំពារសង្គម។ សមាមាត្រនៃនិយោជិតដែលនិយោជករបស់ពួកគេបានចូលរួមចំណែក

---

[៨] សំណល់ជាតិផ្ទុះពីសង្គ្រាមមិនរាប់បញ្ចូលគ្រាប់មីន ប៉ុន្តែសំដៅលើគ្រាប់កាំភ្លើងធំ គ្រាប់បែកដៃ គ្រាប់កាំភ្លើង គ្រាប់រ៉ុក្កែត គ្រាប់បែកទម្លាក់ពីលើអាកាស និងគ្រាប់បែកចង្កោមមិនទាន់ផ្ទុះ។ http://www.the-monitor.org/en-gb/the-issues/erw.aspx
https://www.unmas.org/sites/default/files/handbook_english.pdf ( ទំព័រ ១១៨ )
https://www.icrc.org/en/document/explosive-remnants-of-war
https://www.ipb.org/explosive-remnants-of-war-cluster-munitions/

ដល់សន្តិសុខសង្គម គឺសូចនាករគាំពារសង្គម។ សូចនាករនេះអាចត្រូវបានបំពេញបន្ថែមដោយសមាមាត្រនៃនិយោជិតដែលមានសិទ្ធិទទួលបានប្រាក់ឈ្នួលនៅពេលឈប់សម្រាកឈឺ។ តារាង ១២.១ បង្ហាញថា ១៩,១% នៃនិយោជិតដែលនិយោជករបស់ពួកគេបានចូលរួមចំណែកដល់សន្តិសុខសង្គម និង ២២,៤% មានសិទ្ធិទទួលបានប្រាក់ឈ្នួលនៅពេលឈប់សម្រាកឈឺ។

គោលដៅ ៥ មានគោលបំណងសម្រាប់សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី និងក្មេងស្រីទាំងអស់។ សូចនាករមួយចំនួន រួមមានសមាមាត្រនៃស្ត្រីមានមុខងារជាអ្នកគ្រប់គ្រង និងប្រាក់ចំណូលជាមធ្យម តាមភេទ។ នៅឆ្នាំ២០១៩ មានតែជាង ៣០% នៃមុខងារជាអ្នកគ្រប់គ្រងត្រូវបានកាន់កាប់ដោយស្ត្រី (តារាង ១២.១)។

សូចនាករសម្រាប់គោលដៅ ៨ ពាក់ព័ន្ធច្រើនជាងគេទៅនឹងសូចនាករការងារសមរម្យរបស់អង្គការអន្តរជាតិខាងការងារ (ILO)។ តារាង ១២.១ បង្ហាញសូចនាករការងារសមរម្យមួយចំនួន តាមភេទ និងតំបន់។ ឧទាហរណ៍ ប្រមាណ ៩ នាក់ ក្នុងចំណោម ១០ នាក់ បានធ្វើការងារក្រៅប្រព័ន្ធ (៨៨,៣%) នៅឆ្នាំ២០១៩។ នេះមានន័យថាពួកគេមិនមានអត្ថប្រយោជន៍ណាមួយ ដូចជាសោធននិវត្តន៍ មានប្រាក់ឈ្នួលពេលឈប់សម្រាក និងឈប់សម្រាកឈឺ។ អត្រាគ្មានការងារធ្វើរបស់យុវជន (២,៥%) ខ្ពស់ជាងមធ្យមថ្នាក់ជាតិ (១,២%) និង ១២,៧% នៃយុវជនមិនធ្វើការងារ មិនសិក្សា ឬបណ្តុះបណ្តាល។

សូចនាករដទៃទៀតទាក់ទងនឹងការងារសមរម្យ គឺជាសមាមាត្រនៃនិយោជិតមានចំណូលប្រចាំខែទាបជាង ២ ភាគ ៣ នៃចំណូលប្រចាំខែជាមេដ្យានរបស់ប្រទេស ដែលត្រូវបានចាត់ទុកជាអត្រាប្រាក់ឈ្នួលទាប។ តារាង ១២.១ បង្ហាញថា ១៧,៩% នៃនិយោជិតនៅកម្ពុជាមានការងារមានប្រាក់ឈ្នួលទាប ក្នុងនោះប្រុសមាន ២១,៥% និងស្រីមាន ១៥,៣%។ មាននិយោជិតច្រើននៅតំបន់ទីប្រជុំជន (១៥,៨%) ជាងនៅតំបន់ជនបទ (១៥,២%) មានការងារបែបនេះ។

ជាចុងក្រោយ តារាងបង្ហាញថាច្រើនជាងមួយភាគបី (៣៦,០%) នៃនិយោជិតបានធ្វើការច្រើនម៉ោង (ពោលគឺធ្វើការម៉ោងធម្មតាច្រើនជាង ៤៨ ម៉ោង ក្នុងមួយសប្តាហ៍)។ សមាមាត្រខ្ពស់ជាងគេធ្វើការច្រើនម៉ោង គឺនៅតំបន់ទីប្រជុំជន (៤៣,០%)។

តារាង ១២.១. សូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការងារសមរម្យជ្រើសរើស នៅកម្ពុជា ឆ្នាំ២០១៩

| សមាមាត្រនៃនិយោជិតដែលនិយោជករបស់ពួកគេបានចូលរួមចំណែកដល់សន្តិសុខសង្គម [a] | |
|---|---|
| ប្រុស | ១៦,៤ |
| ស្រី | ២២,៦ |
| សរុប | ១៩,១ |

| ចំណែកមុខងារអ្នកគ្រប់គ្រង [a] | |
|---|---|
| ប្រុស | ៦៩,០ |
| ស្រី | ៣១,០ |
| សរុប | ១០០,០ |

| សមាមាត្រនៃនិយោជិតទទួលប្រាក់ឈ្នួលពេលឈប់សម្រាក [b] | |
|---|---|
| ប្រុស | ១៧,៨ |
| ស្រី | ២៩,២ |
| ទីប្រជុំជន | ២៤,៦ |
| ជនបទ | ២១,៥ |
| សរុប | ២២,៧ |

| សមាមាត្រនៃនិយោជិតទទួលប្រាក់ឈ្នួលពេលឈប់សម្រាកឈឺ [b] | |
|---|---|
| ប្រុស | ១៨,៤ |
| ស្រី | ២៧,៧ |
| ទីប្រជុំជន | ២៤,៦ |
| ជនបទ | ២១,០ |
| សរុប | ២២,៤ |

| អ្នកធ្វើការងារក្រៅប្រព័ន្ធ ជាសមាមាត្រនៃអ្នកធ្វើការទាំងអស់ [b] | |
|---|---|
| ប្រុស | ៨៩,០ |
| ស្រី | ៨៧,៦ |
| ទីប្រជុំជន | ៨៥,០ |
| ជនបទ | ៩០,០ |
| សរុប | ៨៨,៣ |

| យុវជនមិនធ្វើការងារ មិនសិក្សា ឬបណ្តុះបណ្តាល (NEET) (អាយុ ១៥-២៤ ឆ្នាំ) [a] | |
|---|---|
| ប្រុស | ១១,៤ |
| ស្រី | ១៣,៨ |
| ទីប្រជុំជន | ១២,២ |
| ជនបទ | ១២,៩ |
| សរុប | ១២,៧ |

| អ្នកមានការងារធ្វើធៀបនឹងប្រជាជន (អាយុ ១៥ ឆ្នាំឡើង) [b] | |
|---|---|
| ប្រុស | ៧៦,២ |
| ស្រី | ៦១,៦ |
| ទីប្រជុំជន | ៦៧,០ |
| ជនបទ | ៦៩,២ |
| សរុប | ៦៨,៥ |

| អត្រាយុវជនគ្មានការងារធ្វើ (១៥-២៤ ឆ្នាំ) [a] | |
|---|---|
| ប្រុស | ២,៧ |
| ស្រី | ២,៣ |
| ទីប្រជុំជន | ៣,៣ |
| ជនបទ | ២,២ |
| សរុប | ២,៥ |

| អត្រាគ្មានការងារធ្វើ [a] | |
|---|---|
| ប្រុស | ១,២ |
| ស្រី | ១,២ |
| ទីប្រជុំជន | ១,០ |
| ជនបទ | ១,៤ |
| សរុប | ១,២ |

| សមាមាត្រនៃអ្នកធ្វើការដោយទុនផ្ទាល់ខ្លួន និងអ្នកធ្វើការឲ្យគ្រួសារ មិនយកប្រាក់ឈ្នួល ក្នុងអ្នកធ្វើការទាំងអស់ [b] | |
|---|---|
| ប្រុស | ៤៣,៧ |
| ស្រី | ៥៤,១ |
| ទីប្រជុំជន | ៤៣,២ |
| ជនបទ | ៥១,៥ |
| សរុប | ៤៨,៧ |

| អ្នកធ្វើការលើសម៉ោង (អ្នកធ្វើការម៉ោងធម្មតាច្រើនជាង ៤៨ ម៉ោង ក្នុងមួយសប្តាហ៍) ជាសមាមាត្រនៃអ្នកធ្វើការទាំងអស់ [b] | |
|---|---|
| ប្រុស | ៣៦,៨ |
| ស្រី | ៣៥,១ |
| ទីប្រជុំជន | ៤៣,០ |
| ជនបទ | ៣២,៤ |
| សរុប | ៣៦,០ |

| អ្នកមានការងារធ្វើ តាមស្ថានភាពការងារ [b] | |
|---|---|
| និយោជិត | ៤៧,៨ |
| និយោជក | ៣,៤ |
| អ្នកធ្វើការដោយខ្លួនឯង | ៣៦,៩ |
| អ្នកធ្វើការឲ្យគ្រួសារមិនយកប្រាក់ឈ្នួល | ១១,៩ |
| សរុប | ១០០,០ |

| អត្រាប្រាក់ឈ្នួលទាប (សមាមាត្រនៃអ្នកធ្វើការមានចំណូលប្រចាំខែ ក្រោម ២/៣ នៃប្រាក់ចំណូលប្រចាំខែជាមេដ្យាន) [b, c] | |
|---|---|
| ប្រុស | ២១,៥ |
| ស្រី | ១៥,៣ |
| ទីប្រជុំជន | ១៥,៨ |
| ជនបទ | ១៥,២ |
| សរុប | ១៧,៩ |

[a] ជាសូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ឬផ្អែកលើទិន្នន័យផ្នែកខ្លះរួមចំណែកដល់សូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។
ប្រភព៖ អង្គការអន្តរជាតិខាងការងារ (ILO) ការិយាល័យការងារអន្តរជាតិ។ ឆ្នាំ២០១៨។ *ការងារសមរម្យ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព៖ សៀវភៅណែនាំស្តីពីសូចនាករទីផ្សារការងារគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព* ។ ហ្សឺណែវ។
https://www.ilo.org/ilostat-files/Documents/Guidebook-SDG-En.pdf.

[b] ជាសូចនាករការងារសមរម្យ។
ប្រភព៖ អង្គការអន្តរជាតិខាងការងារ (ILO) ការិយាល័យការងារអន្តរជាតិ។ *សូចនាករការងារសមរម្យ៖ ការណែនាំសម្រាប់អ្នកផលិត និងអ្នកប្រើប្រាស់សូចនាករក្របខ័ណ្ឌស្ថិតិ និងច្បាប់* ។ ហ្សឺណែវ។
https://www.ilo.org/wcmsp5/groups/public/---dgreports/---integration/documents/publication/wcms_229374.pdf.

[c] តម្លៃនេះសំដៅលើតែនិយោជិតដែលបានទទួលប្រាក់ឈ្នួលតាមអត្រាពេលវេលា មិនរាប់បញ្ចូលតាមអត្រាឯកតាឡើយ។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

ចំណូលក៏បានបង្ហាញដោយសូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការងារសមរម្យផងដែរ។ សូចនាករការងារសមរម្យ រួមមានចំណូលប្រចាំខែជាមធ្យមរបស់និយោជិតស្រី និងប្រុស តាមមុខរបរ (តារាង ១២.២)។ ជាទូទៅ ចំណូលប្រចាំខែជាមធ្យមរបស់ប្រុសមានច្រើនជាងស្រី ដោយស្រីរកចំណូលបាន ៨៧% នៃប្រាក់ចំណូលរបស់ប្រុស។ ទោះបីប្រុស និងស្រីមានមុខរបរដូចគ្នាក៏ដោយ ក៏ប្រាក់ចំណូលជាមធ្យមរបស់ប្រុសមានច្រើនជាងស្រីនៅក្នុងគ្រប់មុខរបរទាំងអស់ លើកលែងតែអ្នកបច្ចេកទេសនិងវិជ្ជាជីវៈរង ជំនួយការស្មៀន និងអ្នកធ្វើសិប្បកម្ម និងអាជីវកម្មពាក់ព័ន្ធ ដែលចំណូលរបស់ស្រី និងប្រុសមានស្មើគ្នា។ ចំណូលស្ទើរតែស្មើគ្នាចំពោះអ្នកមានវិជ្ជាជីវៈ និងជំនាញកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប៉ុន្តែដូចបានកត់សម្គាល់ ប្រាក់ចំណូលរបស់ប្រុសនៅតែខ្ពស់។

តារាង ១២.២. ចំណូលប្រចាំខែជាមធ្យមរបស់និយោជិតស្រី និងប្រុស តាមមុខរបរ

| មុខរបរ [a] | ប្រុស (គិតជារៀល) | ស្រី (គិតជារៀល) | អត្រាស្រីធៀបនឹងប្រុស |
|---|---|---|---|
| អ្នកគ្រប់គ្រង | ១.២០០.០០០ | ១.០០០.០០០ | ០,៨៣ |
| អ្នកមានវិជ្ជាជីវៈ | ១.៣០០.០០០ | ១.២០០.០០០ | ០,៩២ |
| អ្នកបច្ចេកទេស និងវិជ្ជាជីវៈរង | ១.២០០.០០០ | ១.២០០.០០០ | ១,០០ |
| អ្នកជំនួយការស្មៀន | ១.២០០.០០០ | ១.២០០.០០០ | ១,០០ |
| អ្នកផ្តល់សេវាកម្ម និងលក់ | ១.០០០.០០០ | ៦៨០.០០០ | ០,៦៨ |
| អ្នកជំនាញកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៦៥០.០០០ | ៦០០.០០០ | ០,៩២ |
| អ្នកធ្វើសិប្បកម្ម និងអាជីវកម្មពាក់ព័ន្ធ | ៩១០.០០០ | ៩១០.០០០ | ១,០០ |
| ការីម៉ាស៊ីន និងរោងចក្រ និងអ្នកផ្គុំតម្លើង | ១.០០០.០០០ | ៨០០.០០០ | ០,៨០ |
| អ្នកធ្វើមុខរបរងាយៗ | ៧៥៨.៣៣៣ | ៦៥០.០០០ | ០,៨៦ |
| កងកម្លាំងប្រដាប់អាវុធ | ១.៣០០.០០០ | ១.៤០០.០០០ | ១,០៨ |
| **សរុប** | **១.០០០.០០០** | **៨៦៦.៦៦៧** | **០,៨៧** |

[a] ប្រភេទសមុខរបរមានក្នុងបង្គោលនេះ បានមកពីចំណាត់ថ្នាក់មុខរបរតាមស្តង់ដារអន្តរជាតិ ឆ្នាំ២០០៨ (ISCO-08)។
ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

ក្នុងចំណោមប្រជាជន ២,៧ លាននាក់ មានអាយុ ១៥-២៤ ឆ្នាំ នៅកម្ពុជា ក្នុងនោះមានប្រមាណ ១២,៧% (៣៤១.២៧២ នាក់) ជាយុវជនមិនធ្វើការងារ មិនសិក្សា ឬបណ្តុះបណ្តាល នៅឆ្នាំ២០១៩។ សមាមាត្រនៃយុវជនមិនធ្វើការងារ មិនសិក្សា ឬបណ្តុះបណ្តាល មានខ្ពស់នៅតំបន់ជនបទ (១២,៩%) ជាងនៅតំបន់ទីប្រជុំជន ១២,២%។

តារាង ១២.៣. ភាគរយនៃយុវជនមិនធ្វើការងារ មិនសិក្សា ឬបណ្តុះបណ្តាល

| តំបន់ | ប្រជាជន អាយុ ១៥-២៤ ឆ្នាំ (ចំនួន) | យុវជនមិនធ្វើការងារ មិនសិក្សា ឬបណ្តុះបណ្តាល (ចំនួន) | សមាមាត្រនៃយុវជនមិនធ្វើការងារ មិនសិក្សា ឬបណ្តុះបណ្តាល % |
|---|---|---|---|
| កម្ពុជា | ២.៦៩២.៧៤៦ | ៣៤១.២៧២ | ១២,៧ |
| ទីប្រជុំជន | ៨៧០.៣០៤ | ១០៥.៨១២ | ១២,២ |
| ជនបទ | ១.៨២២.៤៤២ | ២៣៥.៤៦០ | ១២,៩ |

ប្រភព៖ ទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០១៩។

# ឯកសារយោង


ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។ ឆ្នាំ២០១១។ *សៀវភៅណែនាំស្តីពីការប្រើប្រាស់អង្កេតចម្រុះសម្រាប់វាស់វែងការងារក្រៅប្រព័ន្ធ និងវិស័យក្រៅប្រព័ន្ធ*។ ម៉ានីល៖ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។ https://www.adb.org/sites/default/files/publication/28294/measuring-informal-sector.pdf.

រាជរដ្ឋាភិបាលកម្ពុជា។ ឆ្នាំ២០១៩។ *របាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្តឆ្នាំ២០១៩ របស់កម្ពុជា ស្តីពីការអនុវត្តរបៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព*។ ភ្នំពេញ៖ រាជរដ្ឋាភិបាលកម្ពុជា។ https://sustainabledevelopment.un.org/content/documents/23603Cambodia_VNR_SDPM_Approved.pdf.

រាជរដ្ឋាភិបាលកម្ពុជា ក្រសួងផែនការ។ ឆ្នាំ២០១៩។ *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣*។ ភ្នំពេញ៖ រាជរដ្ឋាភិបាលកម្ពុជា។

អង្គការអន្តរជាតិខាងការងារ (ILO)។ ឆ្នាំ២០១៣។ *សូចនាករការងារសមរម្យ៖ ការណែនាំសម្រាប់អ្នកផលិត និងអ្នកប្រើប្រាស់សូចនាករក្របខ័ណ្ឌស្ថិតិ និងច្បាប់ អង្គការអន្តរជាតិខាងការងារ (ILO) សៀវភៅណែនាំ*។ បោះពុម្ពលើកទី២។ ហ្សឺណែវ៖ អង្គការអន្តរជាតិខាងការងារ (ILO)។ https://www.ilo.org/wcmsp5/groups/public/---dgreports/---stat/documents/publication/wcms_223121.pdf.

———។ ឆ្នាំ២០១៣។ *ការវាស់វែងភាពក្រៅប្រព័ន្ធ៖ ការណែនាំស្ថិតិស្តីពីវិស័យក្រៅប្រព័ន្ធ និងការងារក្រៅប្រព័ន្ធ*។ ហ្សឺណែវ៖ អង្គការអន្តរជាតិខាងការងារ (ILO)។ https://www.ilo.org/wcmsp5/groups/public/---dgreports/---dcomm/---publ/documents/publication/wcms_222979.pdf.

———។ ឆ្នាំ២០១៣។ *របាយការណ៍សន្និសីទ៖ សន្និសីទអន្តរជាតិលើកទី១៩ របស់អ្នកស្ថិតិកម្លាំងពលកម្ម ហ្សឺណែវ ថ្ងៃទី២-១១ ខែតុលា ឆ្នាំ២០១៣*។ ហ្សឺណែវ។ https://www.ilo.org/wcmsp5/groups/public/---dgreports/---stat/documents/publication/wcms_234124.pdf.

———។ ឆ្នាំ២០១៤។ "សេចក្តីសម្រេច I. សេចក្តីសម្រេចទាក់ទងនឹងស្ថិតិការងារ ភាពមានការងារធ្វើ និងការប្រើកម្លាំងពលកម្មមិនគ្រប់គ្រាន់។" សន្និសីទអន្តរជាតិលើកទី១៩ របស់អ្នកស្ថិតិកម្លាំងពលកម្ម ហ្សឺណែវ ថ្ងៃទី២-១១ ខែតុលា ឆ្នាំ២០១៣។ https://www.ilo.org/wcmsp5/groups/public/---dgreports/---stat/documents/normativeinstrument/wcms_230304.pdf.

———។ ឆ្នាំ២០១៥។ *និន្នាការការងារសកលសម្រាប់យុវជន ឆ្នាំ២០១៥៖ ពង្រីកការវិនិយោគសម្រាប់ការងារសមរម្យសម្រាប់យុវជន*។ ហ្សឺណែវ៖ ការិយាល័យការងារអន្តរជាតិ នាយកដ្ឋានគោលនយោបាយការងារ។ https://www.ilo.org/wcmsp5/groups/public/---dgreports/---dcomm/---publ/documents/publication/wcms_412015.pdf.

———។ ឆ្នាំ២០១៨។ "ការចៀសវាងភាពគ្មានការងារធ្វើគឺមិនគ្រប់គ្រាន់ឡើយ៖ ការវិភាគលើទម្រង់ផ្សេងៗនៃការប្រើកម្លាំងពលកម្មមិនគ្រប់គ្រាន់។" ILOSTAT ផ្តោតលើស្ថិតិការងារ។ លេខ៤។ ហ្សឺណែវ៖ អង្គការអន្តរជាតិខាងការងារ (ILO)។ https://www.ilo.org/wcmsp5/groups/public/---dgreports/---stat/documents/publication/wcms_644467.pdf.

